រឿង

# ទំណាញ់លឺតៈឡ៉

និពន្ធដោយ

អ្នកស្រី អ៊ុំ សុផានី

ជ័យលាភី ពានរង្វាន់ ព្រះរាជ សម្រិត

ចំណាត់ថ្នាក់លេខ ៣ ឆ្នាំ ២០០០

5
S

បោះពុម្ពដោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
លើកទី ១ ចំនួន ៥០០ ក្បាល

www.elibraryofcambodia.org

រឿង

# សំណាញ់ជីវិត

និពន្ធដោយអ្នកស្រី :

## ទ្រី សុផានី

គណៈកម្មការកែសម្រួល និងកែអក្ខរាវិរុទ្ធ :

| | | | |
|---|---|---|---|
| លោក | : | យួន | ចំរើន |
| អ្នកស្រី | : | ហេង | សុគី |
| លោក | : | សោម | សុធា |
| លោក | : | ម៉ម | គិណ្ណារ៉ា |
| លោក | : | ញ៉ឹ | សេន |
| លោក | : | ឃុល | សារណា |

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
នាយកដ្ឋានសៀវភៅ និងការអាន

National Library of Cambodia
www.elibraryofcambodia.org

# វាចាអ្នកនិពន្ធ

បើយើងទាំងអស់គ្នាយល់ច្បាស់ថា : យើងឃ្លាន គេក៏ឃ្លាន ។ យើងចង់សុខ គេក៏ចង់សុខ ។ យើងចង់បាន គេក៏ចង់បាន ។ គ្មាននរណាម្នាក់នៅក្នុងលោកយើងនេះ ចង់ទុក្ខនោះទេ ។

កាលណាយើងយល់ច្បាស់នូវអត្ថន័យនៃពាក្យខាងលើនេះហើយ តើយើងត្រូវធ្វើយ៉ាងណា?

តើអ្នកទាំងអស់ដឹងទេថា : យើងទាំងអស់គ្នាសុទ្ធតែត្រូវជាប់ក្នុងសំណាញ់ជីវិត ដោយស្វ័យប្រវត្តិ ។ ដូច្នេះយើងត្រូវតែចៀសវាងនូវអំពើណាដែលនាំឱ្យរងទុក្ខដល់អ្នកដទៃ ។

ដើម្បីជាភស្តុតាងច្បាស់លាស់ ខ្ញុំសូមបង្ហាញជូន " រឿងសំណាញ់ជីវិត " ទុកគ្រាន់ពិចារណា បំភ្លឺផ្លូវ ឱ្យដើរឆ្ពោះទៅរកទីថ្នាក្រចះនៃសុភមង្គល ។

សូមវត្ថុសក្តិសិទ្ធទាំងអស់នៅក្នុងលោក សូមជួយជម្រុញកូនខ្មែរឱ្យចូលចិត្តការរៀនសូត្រស្វាធ្យាយន៍ ដើម្បីស្វែងយល់នូវពាក្យដែលយើងបានសរសេរក្នុងឃ្លាដំបូងបង្អស់ និងសូមឱ្យសង្គមខ្មែរទាំងមូលបានទទួលសេចក្តីសុខ និងអភិវឌ្ឍរីកចម្រើនតរៀងរហូតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០០

អ្នកស្រី អ៊ុំ សុផានី

www.elibraryofcambodia.org

# អារម្ភកថា

រឿង " សំណាញ់ជីវិត " ជាស្នាដៃនិពន្ធរបស់អ្នកស្រី អ៊ុំ សុផានី ។ រឿងប្រលោមលោកនេះ បានលើកឡើងពីដំណើរជីវិតរបស់យុវវ័យ ពីរបបគ្រប់គ្រងមួយទៅរបបគ្រប់គ្រងមួយទៀត ។

រឿង " សំណាញ់ជីវិត " បានជាប់ជ័យលាភីលេខ ៣ ក្នុងការប្រលងប្រណាំងតែងនិពន្ធអក្សរសិល្ប៍ផ្នែកប្រលោមលោកពានរង្វាន់ ព្រះបាទ សុរាម្រឹត នៅឆ្នាំ ២០០០ កន្លងមក ។

ដោយមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដោយមានការយល់ព្រមពីសាមីស្នាដៃ ទើបនាយកដ្ឋានសៀវភៅ និងការអាន បានយករឿងនេះមកបោះពុម្ពដើម្បីរួមចំណែកលើកតម្កើងឧត្តមភាព គថភាព និង កិត្យានុភាពអក្សរសិល្ប៍ជាតិ រួមចំណែកកាត់បន្ថយភាពក្រីក្រ ខាងឯកសារអក្សរសិល្ប៍ និងរួមចំណែកកសាងធនធានមនុស្ស ពិសេសក្នុងចំណោមយុវវ័យ ។

គណៈកម្មការកែសម្រួលឃ្លោងឃ្លា និងអក្ខរាវិរុទ្ធ នៃនាយកដ្ឋានសៀវភៅ និងការអានពុំបានរៀបរៀងស្នាដៃនេះ ឱ្យបានគ្រប់ជ្រុងជ្រោយទេ ដោយសាររឿងនេះ បានជាប់ចំណាត់ថ្នាក់ល្អប្រសើររួចមកហើយ គណៈកម្មការយើងខ្ញុំ គ្រាន់តែសម្រួលឃ្លោងឃ្លាដែលខុសឆ្គងខ្លះៗ និងកែអក្ខរាវិរុទ្ធយកតាមវចនានុក្រមរបស់សម្តេចសង្ឃ ជួន ណាត តែប៉ុណ្ណោះ ។

នាយកដ្ឋានសៀវភៅ និងការអានយើងខ្ញុំ សូមអធ្យាស្រ័យពីសំណាក់ប្រិយមិត្តអ្នកអាន ។

នាយកដ្ឋានសៀវភៅ និងការអាន

www.elibraryofcambodia.org

# មាតិការឿង


| | | |
|---|---|---|
| ១- ចៃដន្យ | ទំព័រ ១ ..... | ១៦ |
| ២- កូននៅឯណា ? | ១៧ ..... | ៤០ |
| ៣- ព្យុះភ្លៀងសំណាង | ៤១ ..... | ៥៧ |
| ៤- រាត្រីសមោសរ | ៥៨ ..... | ៦៦ |
| ៥- ជោគជ័យ | ៦៧ ..... | ៧៣ |
| ៦- ជីវិតថ្មីនៃក្តីសង្ឃឹម | ៧៤ ..... | ៨១ |
| ៧- ភ្លៀងវាសនា | ៨២ ..... | ១០៤ |
| ៨- ទិព្យជីសារី | ១០៥ ..... | ១១៨ |
| ៩- មាតាជាប្រភពនៃសេចក្តីស្នេហា និងជា សភាវៈធន់ធ្ងន់ | ១១៩ ..... | ១៣៥ |
| ១០-សុភមង្គល | ១៣៦ ..... | ១៥០ |


www.elibraryofcambodia.org

# ១

# ចែដន្យ

ស្បៃរាត្រីគ្របដណ្ដប់លើភពផែនដី បណ្ដាលឱ្យងងឹតបន្តិចម្ដងៗ ។ នៅតាមដងវិថីទាំងឡាយ ចង្កៀងអគ្គិសនីក៏ចាប់ផ្ដើមបើកបំភ្លឺជាហូរហែដើម្បីបំបាត់ភាពអន្ធការ ។ ព្រះចន្ទ្រាដែលជារាជនីនៃរាត្រី ទ្រង់ឡើងគង់លើរាជរថដើម្បីបំភ្លឺទ្វីបលោកដែលពោរពេញ ទៅដោយភាពគ្រោតគ្រាតផង និង ភាពផ្អែមល្ហែមផង ព្រមទាំងមានដួងតារារះហែហមជាបរិវារ ។

សំឡេងនាឡិកាភ្លេងមួយបន្លឺសូរស័ព្ទរណ្ដំណែងណង ព្រមទាំងគោះ ប្រាំមួយម៉ឺងយ៉ាងល្វើយចេញពីគេហដ្ឋានមួយខ្នងនៅតំបន់បឹងទំពុន ។

យុវជនម្នាក់ទាញត្រីចក្រយានយកមក រួចធាក់ចេញពីបរិវេណគេហដ្ឋានដោយទឹកមុខស្រស់ថ្លា ។ គេហួចបទ " ឆេពធីតាក្នុងសុបិន " បន្តិចៗល្មមតែកំដរអារម្មណ៍ខ្លួនឯងតែប៉ុណ្ណោះ ។ អ្នកកំលោះពាក់មួកកាតិប ពណ៌ស ស្លៀកខោជើងវែងពាក់អាវដៃវែង តែមូរដៃឡើងមកលើបន្តិច ។ ទោះបីជាអ្នកកំលោះស្លៀកពាក់ខោអាវចាស់ៗក៏ដោយ ក៏ភាពជាយុវវ័យរបស់គេមានកាយវិការស្វាហាប់ រហ័សរហួនដែរ ។ នាយធាក់យានរបស់ខ្លួនឡើងមកតាមវត្តសន្សំកុសល រួចកាត់តាមសាលាភូមិប្រាំមួយ ហើយចេញមករកផ្សារទួលទំពូង ក្នុងគោលបំណងតម្រង់មកទិសខាងកើតដើម្បីមកកាន់សណ្ឋាគារកាំបូឌីយ៉ាណា ។ មិនទាន់ទាំងដល់គោលដៅផង នាយបានឮសំឡេងហៅត្រីចក្រយានរបស់ខ្លួន បន្លឺពីចិញ្ចើមផ្លូវម្ខាង ÷



www.elibraryofcambodia.org

- ស៊ីក្លូ !... ស៊ីក្លូ !.... ស៊ីក្លូ[១] !....

អ្នកកំលោះក៏បត់ឃានរ សំខ្លួនឆ្ពោះទៅរកម្ចាស់សំឡេង ទើបស្គាល់ពាក្យហៅស៊ីក្លូនោះ ។ គ្រាន់តែត្រឹចក្រយានឈប់មិនទាន់ស្រួលបួលផង យុវនារីជាម្ចាស់សំឡេងក៏ប្រញាប់ប្រញាល់ឡើងលើស៊ីក្លូ ហើយរអ៊ូរទាំទាំងចិត្តមួហ្មង :

- យីស ! ពូកអីក៏គ្មានទទំបន្តិចណាសោះអីចេះ... ទៅ !.... (នាងថាដោយលើកដៃត្រង់ទៅមុខ) ។

មាណវី ស្លៀកសំពត់រឹបខើចត្រឹមជង្គង់ ពាក់អាវវៀលក វៀលក្លៀក រំលេចទៅដោយប៉ាក់ឱនចាំងរស្មីផ្លេក១នឹងចង្កៀងគោមតាមផងវិថី ព្រមទាំងមានពាក់អាវដៃវែងស្តើងគ្របពីលើ ។ ជិះបានមួយសន្ទុះ សំឡេងទូរស័ព្ទរោរ៍ពីក្នុងកាបូបស្ពាយលាន់ឮដូចសំឡេងរៃយំ នាងក៏លូកដៃយកទូរស័ព្ទមកចុច ហើយសន្ទនា ÷

- ចាំស !...ចាំស !....បន្តិចទៀតខ្ញុំទៅដល់ហើយ (រួចនាងបញ្ជាទៅអ្នកធាក់ស៊ីក្លូ) មើលពូស៊ីក្លូបន្ថែមល្បឿនឱ្យលឿនជាងហ្នឹងបានទេ !... ខ្ញុំប្រញាប់ណាស់ !

អ្នកកំលោះឆ្លើយដាច់១ ÷

- បាទ... បាន !...

គេពុំបាននិយាយសួរនាំពីភ្ញៀវទេ គេធ្វើតែតាមបញ្ជារបស់ភ្ញៀវដែលលើកដៃខ្វាត់ខ្វែងសំដៅទៅគោលដៅ ។ ទៅដល់សណ្ឋាគារសាន់វៃ *"Sun Way"* ដែលឋិតនៅខាងលិចវត្តភ្នំ ភ្ញៀវក៏បន្លឺសូរស័ព្ទញាប់រន្ថើន ÷

- ឈប់ !... ឈប់ !... ឈប់ត្រង់នេះហើយ !

អ្នកធាក់ស៊ីក្លូឈប់ហើយក៏ចុះពីលើកែប ហើយដើរចូលទៅជិតអ្នកជិះ ដើម្បីទទួលប្រាក់ឈ្នួល ។

- យកប៉ុន្មានទៅពូ ?...

១ - ស៊ីក្លូជាពាក្យបារាំង ប៉ុន្តែប្រជាជនយើងនិយមហៅរបៀបនេះជាយូរមកហើយ ។



www.elibraryofcambodia.org

ភ្ញៀវបានឃើញអ្នកធាក់ស៊ីក្លូច្បាស់ ដោយសារតែសណ្ឋាគារនេះមានចង្កៀងបំភ្លឺចិញ្ចាចចិញ្ចែងលប់បាត់រស្មីព្រះចន្ទ្រា ។

- ...ឱ ! នៅក្មេងសោះ ខំតែហៅពូ...

- មិនជាអ្វីទេនាង... ខ្ញុំចាស់ហើយដែរ... នៅតែប៉ុន្មានឆ្នាំទៀតប៉ុណ្ណោះ លេខ៣ រត់មុខទៅហើយ ។

- អីចឹងពូយកប៉ុន្មាន ?

- ស្រេចតែនាងឱ្យ ។

- បើស្រេចតែខ្ញុំ ១ឱ្យពូតិចហើយ ព្រមទេ ?

- ព្រម !

ថាហើយអ្នកកំលោះបញ្ចេញទឹកមុខស្រស់បំប្រែ ធ្វើឱ្យនាងខំសម្លឹងមុខគេយ៉ាងយកចិត្តទុកដាក់ រួចលូកដៃទៅក្នុងកាបូបហើយយកប្រាក់ចំនួន ប្រាំដុល្លារអាមេរិក មួយសន្លឹក ហុចទៅឱ្យអ្នកធាក់ស៊ីក្លូ ដោយនិយាយថា ÷

- ម៉េច ប៉ុណ្ណឹងពូព្រមទេ ?

- ត្រេកអរណាស់... អរគុណនាងច្រើន !

បានប្រាក់ហើយ អ្នកធាក់ត្រីចក្រយានក៏ឡើងលើយាន រៀបធាក់តម្រង់មកសណ្ឋាគារកាំបូឌីយ៉ាណា ស្រាប់តែមានជនបរទេសម្នាក់ចេញពីក្នុងសណ្ឋាគារ សាន់វេ រួចធ្វើសញ្ញាឱ្យអ្នកធាក់ស៊ីក្លូឈប់ហើយគេក៏ឡើងជិះ ព្រមទាំងលើកដៃចង្អុលទៅទិសខាងកើត ។ មកដល់ត្រង់ភោជនីយដ្ឋាននៅមាត់ទន្លេ ភ្ញៀវជាជនបរទេសលើកដៃបញ្ជាឱ្យអ្នកធាក់ស៊ីក្លូឈប់ ហើយក៏ហុចប្រាក់ ដប់ដុល្លារ មកម្ចាស់ស៊ីក្លូ ។ យុវបុរសលើកដៃទទួលប្រាក់ហើយក៏និយាយពាក្យ “ អរគុណ ” មួយម៉ាត់ ។ ជនបរទេសឆ្លើយតបមកវិញ ÷

- មិនជាអ្វីទេ !

រាត្រីចេះតែរំកិលខិតទៅមុខជានិច្ច ។ ប្រមាណជាម៉ោង ម្ភៃ អ្នកកំលោះធាក់


www.elibraryofcambodia.org

យានឆ្ពោះមកសណ្ឋាគារកាំបូឌីយ៉ាណា ។ លុះមកដល់ព្រះអង្គដងកើ ស្ត្រីម្នាក់មានសាច់ទ្រលុកទ្រលន់ ដឹកដៃក្មេងស្រីតូចដែលធ្វើអាកប្បកិរិយារបៀបកិកកុកផងនោះ គាត់ក៏និយាយលុងលោមថា ÷

- មិនអីទេ !... មិនអីទេ !... ចាំម៉ែយាយហៅស៊ីក្លូណាំចៅណាំ !... នុះស៊ីក្លូមកហើយ !... ស៊ីក្លូ !...ស៊ីក្លូ !... មកនេះ !...

អ្នកកំលោះបរយានអែបជិតភ្លៀវ ហើយក៏ពោលពាក្យគួរសមថា ÷

- លោកស្រីចាំស៊ីក្លូក្រោយទៀតទៅ... ខ្ញុំបាទប្រញាប់ទៅសណ្ឋាគារកាំបូឌីយ៉ាណាផង ។

លោកស្រីនោះក៏បន្តសំដីដោយទទូចថា ÷

- ទោះអ្នកប្រញាប់យ៉ាងណា ... ក៏គង់អ្នកត្រូវទៅតាមផ្លូវមាត់ទន្លេនេះដែរមែនទេ ?

- បាទ !... មែនហើយ !

- ដូច្នេះ អ្នកព្រមដាក់មីងទៅ ! ពីព្រោះកូននេះវាកិកកុកចង់ជិះស៊ីក្លូ ម៉្យាងទៀតផ្ទះមីងនៅតាមបណ្ដោយផ្លូវនេះដែរ ត្រង់ម្ដុំខាងត្បូងរដ្ឋសភា ... ក្មួយគ្រាន់តែបត់ចូលតែបន្តិចទេ... វាមានទៅឆ្ងាយប៉ុន្មាន ?

- អ៊ីចឹងលោកស្រីឡើងមក ... ខ្ញុំបាទជូនទៅ ។

ពេលលោកស្រីនិងចៅឡើងជិះស៊ីក្លូស្រួលបួលហើយ អ្នកកំលោះរុញស៊ីក្លូ ហើយឡើងផែលលើរថរបស់ខ្លួន បរតាមបញ្ជាលោកស្រីនោះទៅ ។ អ្នកជិះសួរទៅអ្នកធាក់ដោយសំដីរួសរាយរបៀបជាមនុស្សនិយាយច្រើន ÷

- និយាយអ៊ីចឹង !... មួយថ្ងៃក្មួយរកបានប៉ុន្មានរៀលដែរ ?

- ខ្ញុំបាទមិនរកទេពេលថ្ងៃ គឺរកតែពេលយប់ ។

- អ៊ីចឹងមានតែពេលថ្ងៃ ក្មួយជាប់ធ្វើការងារអ្វីទៅ ?


www.elibraryofcambodia.org

- ខ្ញុំបាទជាប់រៀន...តែពេលនេះជាពេលវិស្សមកាល ខ្ញុំបាទក៏ឆ្លៀតរកលុយខ្លះគ្រាន់បានឧបត្ថម្ភជីវភាពខ្លួន ។

អូ៎ ! ក្មួយចេះគិត...មីងសូមសរសើរឯង...អ្នកដែលរកស៊ីតាមកម្លាំងខ្លួនដូច្នេះប្រសើរណាស់ !...តើប្រាក់កាសដែលរកបាននោះគ្រប់គ្រាន់ទេ ?

- បាទ លោកស្រី...

និយាយហើយ អ្នកកំលោះអស់សំណើចបន្តិច ទើបចាប់បន្តសំដីទៅទៀត ÷

- មានថ្ងៃហេង... មានថ្ងៃស៊យ.... មិនអាចកំណត់ដូចជាអ្នកមានការងារច្បាស់លាស់នោះទេ...ជីវិតខ្ញុំបាទដូចជាចកមិនទាន់រកកោះត្រើយឃើញនៅឡើយ ។

- អ៎ុះ ! ឈប់ !...ឈប់ !...រវល់តែជាប់មាត់និយាយ...មើល៍ ! ហួសផ្ទះបន្តិចហើយ ។

ស៊ីក្លូឈប់ អ្នកស្រីចុះ ហើយលូកហៅប៉ៅយកប្រាក់មករាប់ឃើញមានចំនួនប្រាំពាន់រៀល ក៏ហុចឱ្យទៅអ្នកធាក់ស៊ីក្លូ រួចឆ្លៀតនិយាយបន្តថា ÷

- សូមឱ្យថ្ងៃនេះជាថ្ងៃហេងរបស់ក្មួយទៅចុះណា៎ !

អ្នកធាក់ស៊ីក្លូលើកដៃទទួលដោយញញឹមញញែមត្រេកអរ ព្រមទាំងតបវាចាទៅអ្នកមានធម៌សប្បុរស ÷

- អរគុណលោកស្រីណាស់ ... សូមឱ្យលោកស្រីចម្រុងចម្រើនរហូត ។

- អូ ! សាធុ !...សាធុ !...អ្នករៀនអ្នកសូត្រមានឫកពាថ្លៃថ្នូរគួរឱ្យរាប់អានណាស់ !...ទៅចុះក្មួយ ទៅឱ្យបានសុខ និងសូមឱ្យជួបប្រទះតែសំណាងល្អណា៎ ក្មួយណា៎ !

- បាទ !...ខ្ញុំបាទសូមលាលោកស្រីហើយ ។

ថាហើយ យុវជននេះក៏ធាក់ស៊ីក្លូមកសណ្ឋាគារកាំបូឌីយ៉ាណាដែលនៅជិតបង្គើយ ។ នៅពីមុខសណ្ឋាគារតាមបណ្ដោយថ្នល់ខាងលិច មានផ្ទះប្រជាជនមានរង្គសាល មានហាងលក់គ្រឿងប្រាក់ គ្រឿងចម្លាក់ ធ្វើអំពីថ្ម កែវ និងធ្វើអំពីឈើដាក់


www.elibraryofcambodia.org

តាំងក្នុងទូកញ្ចក់ ។ នៅតាមជញ្ជាំងសងខាងមានផ្ទាំងគំនូរធំៗព្យួររណោងរណោង ។ ហាងខ្លះបិទទ្វារហើយ ឯហាងខ្លះទៀតនៅមិនទាន់បិទទ្វារនៅឡើយទេ ។ បុរសធាក់ស៊ីក្លូនៅវេរាត្រង់ផ្លូវចូលនោះ ទំនងជារង់ចាំនរណាម្នាក់ដោយការណាត់ជួប ។` អ្នកគិតតែម្នាក់ឯង : "ត្រូវដឹកអ្នកណាទៅឯណា ?...ហេតុដូចម្ដេចក៏មិនឃើញ...ឆ្កួតហើយរូបអញនេះ ...ម៉ោងមិនទាន់ប្រាំបួនផង នៅខ្វះដប់ប្រាំនាទីទៀតឯណោះ...អញប្រញាប់តែភ័យធ្វើអ្វី ! " ។ គិតឃើញដូច្នេះហើយ អ្នកស៊ីក្លូរូបនេះក៏ឡើងទម្រេតលើស៊ីក្លូរបស់ខ្លួនយ៉ាងសុខស្រួល រួចទាញយកកូនសៀវភៅពីក្រោមពូកស៊ីក្លូយកមកមើលក្រោមពន្លឺគោមដែលគេដាក់សម្រាប់បំភ្លឺផ្លូវពេលយប់ ។ ស្រាប់តែអ្នកឮសំឡេងមនុស្សមករំខានដោយស្រែកហៅ ÷

- ពូស៊ីក្លូ !... ពូស៊ីក្លូ !...

អ្នកកំលោះម្ចាស់ស៊ីក្លូមានអាការៈរបៀបភ្ញាក់ ក៏រហ័សដកសៀវភៅចេញពីមុខហើយក៏ជួបវ៉ាក់នឹងក្មេងប្រុសម្នាក់ស្លៀកខោខ្លីឥតពាក់អាវ ។ ក្មេង នោះក៏សួរថា ÷

- ពូស៊ីក្លូ...ឈ្មោះជនមែនទេ ?

បុរសឈ្មោះជន រាងបែបដូចស្រឡាំងកាំងបន្តិចនឹងសំដីក្មេងប្រុសដែលមានឫកពាក្យាហាន ។ ជនតបទៅក្មេងនោះដោយងឿងឆ្ងល់ ÷

- ហេតុអ្វីក៏ប្អូនស្គាល់ពូថាឈ្មោះជន ?

ក្មេងតូចសើចគ្រហាញ រួចឆ្លើយផង ដៃចង្អុលផង ÷

- គឺ រំយោលពណ៌បៃតងនេះដែលមិនមានស៊ីក្លូណាដូចស៊ីក្លូពូ ... ស្រួលចំណាំណាស់ !

- មែនហើយ...ក្មេងឆ្លាត...ឯងមានប្រាជ្ញាណាស់អានាង...ពូឱ្យពរឯង ធំឡើងឱ្យឯងបានធ្វើប្រធានសណ្ឋាគារកាំបូឌីយ៉ាណា...ម៉េចទៅអានាងព្រមទេ ?

ក្មេងនោះឮជនឱ្យពរអស្ចារ្យដូច្នេះ ក៏ត្រេកអរលោតកញ្ឆេង ហើយនិយាយឮៗថា÷



www.elibraryofcambodia.org

- ផ្ទះខ្ញុំធំណាស់...ផ្ទះខ្ញុំធំណាស់...ខ្ញុំនឹងឱ្យពូជនមួយបន្ទប់ ។

- អ៊ី ! ពូអរគុណឯងទុកជាមុន...ប៉ុន្តែអានាង ឯណាសំបុត្រសម្រាប់ពូនោះ ?

ក្មេងប្រុសនោះហុចសំបុត្រដែលមានសរសេរកាខ្នងថា " ចំពោះក្មួយជន " ។ ជនហែកសំបុត្រ រួចអានដោយស្ងាត់ស្ងៀម ។ ខ្លឹមសារសំបុត្រមានដូចតទៅ : " សូមក្មួយជួយជូនភ្ញៀវរបស់មីងទៅតាមសេចក្តីស្នើសុំរបស់គេផង ។ ភ្ញៀវមីងស្នាក់នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ នាថ្ងៃនេះវេលាម៉ោង ប្រាំបួន យប់ គេនឹងចេញពីសណ្ឋាគារតាមការណាត់របស់មីង ដើម្បីឱ្យក្មួយឯងជូនគាត់ ។ ក្មួយចេះភាសាអាចទំនាក់ទំនងជាមួយភ្ញៀវមីងបាន ។ ភ្ញៀវមីងឈ្មោះ " ហ្សង់ហ្វេដេរ៉ូ ហៅ រ៉ូ *Jean Fédéro* " ។

អរគុណ !

ពីមីងចម្ប៉ា "

ជនក្រឡេកមើលនាឡិកាដៃ ឃើញនៅខ្វះប្រាំនាទីទៀតដល់ម៉ោង ម្ភៃមួយហើយ អ្នកប្រញាប់ប្រញាល់ឡើងស៊ីក្លូធាក់ទៅត្រង់ក្លោងទ្វាររបងសណ្ឋាគារ ។ ម៉ោងម្ភៃមួយគត់ ជនបរទេសម្នាក់ដើរចេញមកឈរវេរា មើលឆ្វេង មើលស្តាំ ។ ជនសង្ស័យក៏ធាក់ស៊ីក្លូរបស់ខ្លួនទៅជិតជនបរទេស រួចសួរជាភាសាអង់គ្លេស ÷

- លោកឈ្មោះ ហ្សង់ ហ្វេដេរ៉ូ មែនទេ ?

ជនបរទេសតបមកវិញដោយទឹកមុខញញឹមញញែម ÷

- គឺខ្ញុំហ្នឹងហើយ !... អ្នកអាចជូនខ្ញុំទៅវង្គសាលមួយនៅតាមបណ្តោយផ្លូវព្រះមុនីវង្សបានទេ ?

ថាហើយជនបរទេសនោះក៏បង្ហាញផែនទីឱ្យជនមើល...ជនឆ្លើយភ្លាមឥតបង្អង់ ÷

- ខ្ញុំអាចជូនអ្នកទៅបាន ខ្ញុំស្គាល់ហើយ !

ជនបរទេសឈ្មោះ ហ្វេដេរ៉ូ ឡើងជិះស៊ីក្លូ ហើយជនក៏បរជូនទៅវង្គសាលនោះ ។


www.elibraryofcambodia.org

ហ្វេដេរ៉ូ សួរ ជន ÷

- អ្នករៀនបានប៉ុន្មានឆ្នាំទើបនិយាយបានដូចជនបរទេសអ៊ីចឹង ?

- ខ្ញុំរៀនបានប្រាំឆ្នាំហើយ !...ខ្ញុំឧស្សាហ៍និយាយឆ្លងឆ្លើយជាមួយបរទេស ទើបលោកស្តាប់ទៅគិតថា ខ្ញុំនិយាយបានល្អ ។

- អរគុណនឹងអ្នកហើយដែលបានផ្តល់ពត៌មានដល់ខ្ញុំ !

ប្រហែលជារយៈពេលម្ភៃនាទី ស៊ីក្លូជនក៏បានមកដល់វង្គសាល ហ្គោល ឌិនបូស *" Golden Boss "* ។ ជនផ្តើមសួរ ÷

- នេះហើយវង្គសាលដែលលោកត្រូវការ...ជាវង្គសាលនៅជិតបង្កើយ នឹងផ្ទះម្ចាស់ស៊ីក្លូដែលខ្ញុំជួល ។ តើលោកត្រូវការយ៉ាងណាដែរ !... ខ្ញុំត្រូវចាំលោកនៅទីនេះ... មែនទេ ?

ហ្វេដេរ៉ូ ឆ្លើយគាត់ ÷

- ជន... អ៊ីចឹងស្រួលហើយ !...អ្នកយកស៊ីក្លូទៅផ្ទះថៅកែរបស់អ្នកទៅ ! ហើយខ្លួនអ្នកចូលទៅជាមួយខ្ញុំ...យល់ព្រម ?

ជនដូចជាស្រឡាំងកាំង...ហ្វេដេរ៉ូឃើញដូច្នេះក៏ប្រញាប់និយាយតឿន ÷

- យ៉ាងដូចម្តេចដែរ ? ខ្ញុំចង់មានគ្នា...ខ្ញុំមិនចង់ដើរម្នាក់ឯងទេ...ទៅ ! ខ្ញុំរង់ចាំឯងនៅទីនេះ ។

ជនរកប្រកែកតទៅទៀតពុំបាន ក៏ធ្វើតាមបង្គាប់ហ្វេដេរ៉ូ ។ ទៅដល់ផ្ទះថៅកែ ប្រពន្ធថៅកែស្រែកសួរ ÷

- ថ្ងៃនេះ ហេតុអីបានជាឯងប្រញាប់យកស៊ីក្លូមកម្ល៉េះ ?

- ខ្ញុំយកមកផ្ញើមីងទេ !...ពីរ...បីម៉ោងទៀតខ្ញុំមកយកវិញហើយ ។

- អ៊ីចឹងឯងទៅណាមកណាដែរ ?

- ខ្ញុំនាំភ្ញៀវមកវង្គសាលហ្គោលឌិនបូស ។


www.elibraryofcambodia.org

# ២

# ក្មួននៅឯណា ?

ស្ត្រីចំណាស់ម្នាក់អាយុប្រហែលជាជាង ហាសិប ឆ្នាំ អង្គុយលក់ត្រកួន និង ស្លឹកអំពិលនៅផ្សារបឹងកេងកង ។ គាត់រកបានប្រាក់សម្រាប់តែឧបត្ថម្ភខ្លួនពីមួយថ្ងៃ ទៅមួយថ្ងៃតែប៉ុណ្ណោះ ។ការរស់នៅរបស់មនុស្សដែលរង់ចាំតែសេចក្តីស្លាប់ សេចក្តីវិនាសទៅវិញនោះ មិនមានភាពស្មើគ្នាសោះយ៉ាងនេះ ? ហើយចាំបាច់មានអ្នកមាន មានអ្នកក្រធ្វើអ្វី ? ព្រោះមនុស្សយើងកើតមកខ្លួនទទេសោះនុំះ ! មិនត្រឹមតែប៉ុណ្ណោះគេបំពាក់បំពោកបញ្ចើចបញ្ចើឱ្យមនុស្សចេះច្រណែន និន្ទា បន្តុះបង្អាប់ រហូតដល់កាប់សម្លាប់គ្នា ដើម្បីបានបំពេញនូវទឹកចិត្តលោភលន់ឥតស្កប់ស្កល់...នេះហើយឬទើបបានគ្រប់លក្ខណៈ ដែលហៅថាជីវិតនោះ ?

ទិដ្ឋភាពរស់រវើកអ៊ូអរខ្សៀវខ្សារ រវាងអ្នកលក់ និងអ្នកទិញជជែកតថ្លៃទំនិញគ្នា ឮទ្រហឹងអឹងអាប់ ។ ជួនពេលខ្លះអ្នកលក់ និងអ្នកទិញឈ្លោះប្រកែកគ្នា និងពេលខ្លះទៀតអ្នកលក់ និងអ្នកលក់ដណ្តើមអតិថិជន (ភ្ញៀវ) គ្នា ។ ផ្សារនេះនៅមិនទាន់មានអនាម័យនៅឡើយទេ កាលណាមានភ្លៀងធ្លាក់មកម្តងៗ គេឃើញភក់ជ្រាំប៉ប៉ិចប៉ប៉ាច់គួរឱ្យខ្ពើមរអើមណាស់ ។ អ្នកមានតូប គេរៀបចំទំនិញរបស់គេឱ្យខ្ពស់ផុតពីភក់ជ្រាំ ចំពោះអ្នកគ្មានតូបវិញ គេលក់នៅផ្ទាល់ដីតាមផ្លូវដែលគេទុកសម្រាប់ដើរ ។ ប៉ុន្តែអ្នកលក់ដែលគ្មានតូបទាំងនេះ បង់ត្រឹមតែជាស៊ីប៉ុណ្ណោះ ។

អ្នកលក់មានវ័យនៅក្មេងជាងស្ត្រីចំណាស់ម្នាក់ឈ្មោះ សាមិត្ត ដែលជាអ្នកលក់ដូរតូចតាចម្នាក់ដែរ បានយកដៃកេះស្ត្រីចំណាស់ រួចនិយាយខ្សឹបៗថា ÷



www.elibraryofcambodia.org

កម្ទេចកាំរស្មីព្រះអាទិត្យពេលជិតអស្តង្គត នៅតែបាចសាចចាំងលើស្មឹករុក្ខជាតិទាំងឡាយដែលកំពុងតែធ្វើចលនាបក់រវិច១តាមកម្លាំងជំនោរពេលសាយ័ណ្ហ ប្រៀបហាក់បីដូចជាជួយបីបម លួងលោម បបោសអង្អែលរូបកាយដ៏អភ័ព្វនៃយុទ្ធជនកំព្រាបិតាតាំងពីក្មេងវ័យនេះ ដោយក្តីសន្តោសមេត្តា ។ នាយខំសម្លឹងមើលលំហអាកាសដ៏សែនឆ្ងាយដែលឋិតនៅចំពីមុខ ។ ដុំពពកសស្គុះប្រឡាក់ដោយកម្ទេចកាំរស្មីព្រះសុរិយា កំពុងអណ្តែតត្រសែតឃឹត១ ជាកញ្ចុំ១ ផ្តុំគ្នាយ៉ាងព្រងើយ ហាក់ដូចជាគ្មានអើពើនឹងជីវិតជិតអស្តង្គតរបស់ខេមរាឡើយ ។

ស្មារតីរបស់ខេមរា ហាក់បីដូចជាលិចអណ្តែត១ ស្រមើស្រមៃទៅរកភពមួយនៃទីបញ្ចប់ ។ នៅពេលដែលអារម្មណ៍អ្នកលិចទៅ អ្នកហាក់ដូចជាគិតថា " អ្នកនឹងស្វែងរកព្រលឹងឪពុករបស់អ្នកហើយ ដែលលោកបានចែកឋានទៅក្នុងយុទ្ធនាការកាប់ព្រៃដែលមានឈ្មោះថា " ក៥ " ក្នុងខេត្តឧត្តរមានជ័យ ។ អ្នកសង្ឃឹមថា ព្រលឹងរបស់អ្នកនឹងបានជួបឪពុកជាមិនខាន ពីព្រោះតំបន់ដែលឪពុករបស់អ្នកទៅកាប់ព្រៃនោះ និងសមរភូមិដែលអ្នកកំពុងត្រូវរបួសនេះ គឺឋិតនៅជិតគ្នាបង្គើយ ។ បើបានជួបឪពុក អ្នកនឹងពាំនាំយករបាយការណ៍ដ៏ច្រើនសន្ធឹកសន្ធាប់ទៅជម្រាបជូនលោកឱ្យបានជ្រាបមិនខាន អំពីអ្វី១ដែលកំពុងកើតឡើងនៅក្នុងសង្គមសព្វថ្ងៃនេះ ។ ប៉ុន្តែអ្នកគិតថាមុននឹងអ្នកជម្រាបលោកពីអ្វី១ទាំងឡាយនោះ អ្នកនឹងជម្រាបពីការកាប់ព្រៃរបស់ឪពុកអ្នកថា : ពលិកម្មកាប់ព្រៃដើម្បីកំចាត់ជម្រកខ្មាំងសត្រូវ រហូតដល់លោកមានជំងឺគ្រុនសន្នំ ហើយស្លាប់បាត់បង់ជីវិតនោះ គឺគេពុំបានចារឈ្មោះលោកឪពុកទុកក្នុងបញ្ជីប្រវត្តិសាស្ត្រថាជាវីរជនស្នេហាជាតិឡើយ ។ ផ្ទុយទៅវិញ គឺជាសកម្មភាពបំផ្លាញសម្បត្តិជាតិឯងដោយដៃខ្លួនឯងផ្ទាល់ ព្រមទាំងបន្សល់ទុកឱ្យកូនក្លាយទៅជាក្មេងកំព្រា ចំណែកឯម៉ែ ក្លាយទៅជាស្រីមេម៉ាយ ។ ម៉ែខំប្រឹងរកស៊ីចិញ្ចឹមកូនទាំងត្រដាបត្រដួស គ្មានប្រាក់គ្រប់គ្រាន់ដើម្បីជំរុញកូនឱ្យបានរៀនសូត្រវែងឆ្ងាយ គ្រាន់នឹងបានរស់នៅតាមគន្លងធម៌នឹងគេទេ ហេតុដូច្នេះ


www.elibraryofcambodia.org

ហើយបានជាកូនក្លាយទៅជាមនុស្សអវិជ្ជា ជឿតែតាមពាក្យញុះញង់ចាក់ដោត សេពគប់តែជាមួយជនពាលខ្នៅ ចំណែកឯសតិបញ្ញារបស់ខ្លួនពិតប្រាកដគឺគ្មានសោះ ។ តើឱ្យកូនស្គាល់អ្វីទៅត្រូវ អ្វីទៅខុស ដូចម្ដេចនឹងកើត ?

ចំណែកឯយុទ្ធនាការកាប់ព្រៃដែលលោកឪពុកបានចូលរួមនោះ មិនត្រឹមតែបន្សល់ទុកផលវិបាកឱ្យគ្រួសារយើងតែម្នាក់ប៉ុណ្ណោះទេ តែវាបង្កផលវិបាកដល់សង្គមទាំងមូលឱ្យជួបប្រទះគ្រោះទឹកជំនន់ជាញឹកញាប់ ដែលបណ្ដាលឱ្យមានវិបត្តិសង្គម និងសេដ្ឋកិច្ចយ៉ាង ធ្ងន់ធ្ងរថែមទៀតផង ។

សម្រែកវិប្បដិសារីរបស់ខេមរា លាន់ឮរំពងពេញអារម្មណ៍បន្តទៀត ÷

- លោកឪពុកអើយ ! កូនមានកំហុសធ្ងន់ណាស់ ពុំអាចអត់ឱនបានឡើយ... សូមលោកឪពុកដាក់ទណ្ឌកម្មមកលើកូនចុះ កូនយល់ព្រមទទួលទាំងអស់ ដើម្បីកុំឱ្យកូនមានវិប្បដិសារីតទៅទៀត ។ ប៉ុន្តែមុនលោកឪពុកដាក់ទណ្ឌកម្មកូន កូនសូមជម្រាបថា ហេតុអ្វីបានជាកូនក្លាយទៅជាមនុស្សអាក្រក់ ? គឺកូននឹកឃើញកាលកូនប្រឡង កូនគ្មានលុយសូកលោកគ្រូ ។ពុំអនុញ្ញាតឱ្យកូនលួចបើកសៀវភៅចម្លង ។ លក្ខណៈនេះជាការចាប់ផ្ដើមបង្រៀនសិស្ស ឱ្យចេះប្រព្រឹត្តអំពើពុករលួយតាំងពីវ័យកុមាររួចស្រេចទៅហើយ ។ ឯណាទៅគុណភាពសិស្ស ឯណាទៅការអប់រំឱ្យសង្គមបានល្អ ?

លោកឪពុក ! នឹកដល់រឿងហ្នឹងកាលណា កូនខឹងណាស់ ! ហើយដើម្បីរំងាប់កំហឹងផ្ទាល់ខ្លួន កូនបែរជាធ្វើអំពើពុំគប្បីដល់សង្គមរបស់ខ្លួនទៅវិញ គឺកូនបែរជាបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជាតិឯង ដូចជាបំផ្លាញស្ពាន កាត់ផ្ដាច់ផ្លូវ បំផ្លាញទ្រព្យសម្បត្តិប្រជាជនបង្កឱ្យមានអសន្តិសុខក្នុងសង្គម ។

ស្ដាយណាស់ ! ស្ដាយពុំអាចថ្លែងបានថា ហេតុអ្វីក៏ខ្ញុំឆ្កួតដល់ថ្នាក់ហ្នឹង ! តើរបស់ឥតវិញ្ញាណទាំងនោះ គ្មានកំហុសអី បានជាខ្ញុំបំផ្លាញវា ? ចុះហេតុអ្វីបានជាខ្ញុំពុំបានមើលឃើញគុណប្រយោជន៍របស់ឥតវិញ្ញាណទាំងនោះផង ។ លុះដល់ពេលយើង



www.elibraryofcambodia.org

ត្រូវការធ្វើដំណើរ ត្រូវការជ្រកដើម្បីការពារកម្ដៅថ្ងៃ និងភ្លៀង គឺមានតែរបស់ទាំងអស់នោះហើយ ដែលអាចជួយសម្រួលឱ្យយើងបាន ។ របស់ទាំងនោះគ្រាន់តែជាអ្នកបម្រើដ៏ស្មោះត្រង់ជាទីបំផុត គ្មានទោសកំហុសអ្វីឡើយ ។ ឯអ្នកដែលត្រូវមានទោសគឺរូបខ្ញុំឯណោះវិញទេ ! ។

ពន្លឺសច្ចៈធម៌មកបំភ្លឺផ្លូវគេមួយរយៈតូច ដើម្បីជម្រុះនូវក្ដីមន្ទិលសៅហ្មងទាំងឡាយដែលមាននៅសេសសល់ក្នុងអារម្មណ៍ទាំងប៉ុន្មានឱ្យជ្រះស្រឡះអស់ មុនពេលគេស្លាប់ទៅ ។ សំឡេងឪពុករន្ធឺពេញឱរារបស់ខេមរា ទាំងកណ្ដាលទ្រូងព្រៃដ៏ស្ងាត់ជ្រងំតែម្នាក់ឯង ÷

- កូនមាសឪពុក... ប្រការដែលកូនប្រព្រឹត្តអំពើបំផ្លិចបំផ្លាញសម្បត្តិជាតិឯងផ្ទាល់នេះជាអំពើខុសធ្ងន់ណាស់ ១១១

ខេមរា ហាក់ដឹងថាខ្លួនកំពុងនិយាយឆ្លងឆ្លើយជាមួយសំឡេងវិញ្ញាណក្ខន្ធ ដែលខ្លួនគេសន្មតថាជាសំឡេងរបស់ឪពុកគេ ។ សំឡេងដដែលនោះសង្កត់ធ្ងន់ៗ សាចុះសាឡើងច្រំដែលៗ មកពញ្ញាក់ស្មារតីគេឥតឈប់ឈរ ។ គេឆ្លើយតបទៅសំឡេងនោះថា ÷

- បើអ៊ីចឹងខ្ញុំខុសរបៀបណាទៅ ? បើខ្ញុំខឹងនឹងគ្រូគ្មានសីលធម៌ ទទួលសំណូកពីសិស្ស ហើយធ្វើអំពើអយុត្តិធម៌... ខឹងនឹងពេទ្យគ្មានសីលធម៌ ឱ្យថ្នាំអ្នកជំងឺមិនត្រូវតាមជំងឺ ដែលគេនិយាយថា មើលសន្សំជំងឺ ដើម្បីឱ្យអ្នកជំងឺនៅរ៉ុំរ៉ៃ... ខឹងនឹងកងទ័ពយកអាវុធទៅគំរាមកំហែងប្រជាជនឯងដើម្បីប្លន់យកទ្រព្យសម្បត្តិ... ខឹងនឹងចោររូចខ្លួនឯងជនស្លូតត្រង់បែរជាមានទោសយ៉ាងអយុត្តិធម៌ទៅវិញ... រីឯឧបាសកខ្លះ ពុំបានគោរពវិន័យសាសនា ហ៊ានលួចដើររៃអង្គាសដោយថាយកថវិកាទៅកសាងព្រះវិហារ ប៉ុន្តែផ្ទុយទៅវិញ គឺយកប្រាក់ទៅប្រព្រឹត្តអំពើពាលា ។ ចំណែកឯម៉ែវិញ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួននោះ គាត់ធ្វើតែបុណ្យសាងអំពើល្អជាប្រចាំ ប៉ុន្តែពុំបានទទួលសេចក្ដីសុខមកវិញសោះ គឺជួបប្រទះតែការព្រាត់ប្ដី-កូនបន្តបន្ទាប់ រស់នៅទាំងវេទនា


www.elibraryofcambodia.org

លំបាកលំបិន ព្រមទាំងត្រូវគេប្រមាថមើលងាយ ។ កត្តាទាំងនេះហើយដែលបណ្តាលឱ្យកូនខឹងម្ចមៅ ហើយស្អប់សង្គមជាតិខ្លួនឯង ទើបបណ្តាលឱ្យកូនប្រកាន់ចិត្តសងសឹកដោយធ្វើអំពើពាលរហូតមក ព្រមទាំងមិនចង់រស់នៅក្នុងសង្គមនោះ ។ មូលហេតុដូច្នេះហើយបានជាកូនតស៊ូចង់ទៅរស់នៅប្រទេសផ្សេងទៀត ប៉ុន្តែទៅមិនរួច ក៏រស់នៅវិលវល់ត្រឹមទល់ដែន ។ លុះឃើញមានក្រុមចលនាតស៊ូ កូនក៏ចូលនឹងគេទៅក្រែងលោក្រុមនោះមានចិត្តស្នេហាជាតិ អាចជួយស្រោចស្រង់ជាតិបាន ដោយបំបាត់អំពើពុករលួយ និងអំពើអយុត្តិធម៌បាន ។ ប៉ុន្តែក្រុមចលនានេះខ្ញុំសង្កេតឃើញថា គេបញ្ជាឱ្យខ្ញុំសងសឹកតែជាមួយជាតិសាសន៍ឯង ដោយចោទម្ខាងនោះថាជាខ្មាំង... លោកឪពុកអើយ ! ខ្ញុំវិលវល់វង្វេងស្មារតីអស់ហើយ កាលខ្ញុំនៅក្នុងស្រុក គេថាអ្នកនៅព្រៃក្បត់ជាតិ ដល់ខ្ញុំរត់ចូលព្រៃ គេថាអ្នកនៅក្នុងស្រុកជាជនក្បត់ជាតិ... តើការពិតត្រឹមត្រូវនៅឯណាទៅលោកឪពុក ?

- កូនអើយ ! នៅលើលោកយើងនេះ ពិបាកណាស់ ទាល់តែយើងចេះសម្របសម្រួលខ្លះទៅតាមសង្គម បើមិនដូច្នេះទេ កូនមុខជាមិនបានសេចក្តីស្ងប់ជាដាច់ខាត ។ ម៉្យាងទៀត កូនទៅបំផ្លាញរបស់ឥតវិញ្ញាណ ដែលគ្នាគ្រាន់តែជាអ្នកបម្រើដល់យើងប៉ុណ្ណោះ ទោះអ្នកនោះជាមិត្ត ឬជាសត្រូវយ៉ាងណា ក៏គ្នាមិនដែលប្រកែកតវ៉ាដល់ម្តងណាឡើយ ។

- ខ្ញុំភ្លឺច្បាស់ក្នុងអារម្មណ៍ហើយ សំដីលោកឪពុកមានប្រសាសន៍មិនខុសមែន... ដូច្នេះតើខ្ញុំត្រូវធ្វើយ៉ាងណាទៅវិញ ដើម្បីរំងាប់កំហឹងឈឺចាប់នោះ ?

- គឺកូនត្រូវចេះកែប្រែកំហឹងឈឺចាប់ឱ្យទៅជាអំពើល្អ ផ្តល់ផលប្រយោជន៍ដល់ខ្លួន និង ដល់សង្គម ។ អំពើល្អគឺមានការខំប្រឹងសិក្សារៀនសូត្រ ស្តាប់ដំបូន្មានចាស់ទុំស្រឡាញ់ការងារ ។ បើកូនប្រកាន់នូវប្រការដូចឪពុករៀបរាប់នោះ កូនមិនសូវម្ចមៅ នាំឱ្យក្តៅក្រហាយចិត្តប៉ុន្មានទេ ។ ចំណែកឯការសងសឹកគ្នាចុះឡើងនេះ ធម៌ព្រះពុទ្ធលោកហាមខ្លាំងណាស់ លោកប្រដៅយើងមិនឱ្យចងពៀរគ្នាទេ ។ បើយើងវល់តែដោះស្រាយ


www.elibraryofcambodia.org

ដោយការកាប់សម្លាប់គ្នាទៅវិញទៅមក រឿងនេះនឹងគ្មានទីបញ្ចប់ ហើយនៅទីបំផុត លទ្ធផលមានតែសូន្យទាំងសងខាង ។ កូនពិចារណាទៅ ដូចសព្វថ្ងៃ បើខ្មែរច្បាំងតែជាមួយខ្មែរ បើខ្មែរគិតតែសងសឹកខ្មែរ ខ្មែរនឹងសូន្យផុតពូជ ឯផលចំណេញត្រូវបានទៅប្រទេសជិតខាងជាមិនខាន... មែនទេកូន ?

ខេមរា តវ៉ា ÷

- ហួសពេលហើយលោកឪពុកអើយ ! តើធ្វើដូចម្តេចទៅ ដើម្បីឱ្យកូនអាចងើបឡើងកែខ្លួនបានម្តងទៀត បើរូបកូនកំពុងតែឈានទៅរកពេលអស្តង្គតរលត់ជីវិតទៅហើយនោះ ? ដូច្នេះមានតែកូនស្រែកផ្តាំតាម " ទំព័រអក្សរនេះ " ផ្ញើជូនដល់ជនរួមជាតិទាំងមូល...

ខេមរាស្រែកច្រៀងចម្រៀង " ឆន្ទៈខេមរា " រងំនៅក្នុងពោះតែម្នាក់ឯង ÷

I. សុភមង្គលត្រសុំត្រសាយ ដូចជាផ្កាសាយភាយ រាយកណ្តាលរាត្រី
ស្រឡាញ់មាតុភូមិពេញដួងហឫទ័យ ដោយសារតែទឹកដី នៃបុព្វជនតា ។

II. សម្បូណ៌សម្បត្តិធម្មជាតិឥតខ្វះ សព្វសត្វមីរដេរដាស គ្រាស់គ្រែក្នុងអរញ្ញវា
ក្នុងទីមានត្រីជីវិតថ្វីដា សមុទ្រទន្លេបុព្វតា សាវតារចារលុះឥឡូវ ។

R. - ប្រជាកសិករខិតខំបង្ក បង្កើនផលស្រូវ
- យុវតី យុវជនមិនស្លឹកស្រពន់ មិនដើរខុសផ្លូវ
- យើងជាកងទ័ពត្រូវប្រកាន់ភ្ជាប់វិន័យទិសដៅ
- មន្ត្រីរាជការស្មោះស្ម័គ្រសច្ចាតាំងចិត្តត្រឹមត្រូវ
- មិនស៊ីសំណូក លួកលាន់ទ្រព្យជាតិនាំឱ្យអាស្រូវ
- ទៅពួកយើងទៅ ទិសដៅតែមួយ ស្ទួយជាតិថ្កើងថ្កាន

III. មើលហ្ន៎អង្គរឈរមិនរង្គាត ឈរក្នុងទង់ជ័យជាតិ សូមញាតិថែទាំឱ្យបាន
បើសន្តិសុខឈានក្បោះក្បាន្ត វប្បធម៌គង់វង្សថ្កើនថ្កាន រស់បានទាំងជាតិខេមរា ។


www.elibraryofcambodia.org

ខេមរាច្រៀងចប់ ស្រាប់តែយុវយុទ្ធមិត្តម្នាក់ទៀតដែលត្រូវរបួសដែរនោះ ខំលូនទាំងត្រដាបត្រដូសមកជិតខេមរា ។ គេទះដៃយ៉ាងសោះកក្រោះ ភ្ជាប់នឹងសំឡេងខ្សាវៗ ជាមួយផង ÷

- ខេមរា ឯងច្រៀងពីរោះណាស់... គ្នាសុំកោតសរសើរអត្ថន័យនៃចម្រៀងរបស់ឯង ។

ខេមរាបន្ទឹតិចៗ ÷

- អាវ៉ាន់... គឺឯងទេឬ ?... គ្នាប្រហែលជាមិនអាចរស់ទេ... ចូរឯងមេត្តានាំសំបុត្រនេះទៅជូនម៉ែគ្នាផងថា គ្នានឹកម៉ែ នឹកប្អូនស្រីណាស់ !

នាយនិយាយឃ្លានេះចប់ទាំងពុំមានសង្ឃឹមថាបានជួបគ្នាទៀតទេ... នាយធ្វើមាត់ម្ជុបៗហាក់ដូចជាមានន័យថា " ម៉ែ និងប្អូនស្រី កូន និងបង សូមលាអ្នកជារៀងរហូតហើយ " ។ ខេមរា ងាកមើលទៅលើដើមឈើមួយដើមដែលជ្រុះស្លឹកអស់ នៅសល់តែមែកច្រងេងច្រងាងត្រដោលតោល នៅគល់មានស្នាមភ្លើងឆេះ ដែលគេដុតយកជ័រ ។ ដើមឈើនេះត្រូវងាប់ដោយបង្ខំដូចជាខេមរាដែរ គ្រាន់តែដើមឈើនេះ ងាប់ដោយសារគេយកជ័រទៅបម្រើផលប្រយោជន៍ដល់សង្គមមនុស្ស ចំណែកឯខេមរាវិញ គឺស្លាប់ដោយសារសង្គ្រាមរវាងជាតិសាសន៍ឯង ពុំបានផ្តល់ផលប្រយោជន៍ដល់សង្គមជាតិឡើយ ។ ខេមរា កំពុងតែនឹកគិតដូច្នេះ ស្រាប់តែឃើញសត្វត្មាតហើរមកទម្លាក់ខ្លួន ទំលើមែកឈើត្រដោលនោះ ធ្វើឱ្យមែកឈើរលាស់ចុះរលាស់ឡើង ដូចដៃកីស័រ ហាក់ដូចជាវាសំដែងកាយវិការសប្បាយរីករាយនឹងរូបខេមរាដែលបន្តិចទៀតខាងមុខនេះ នឹងក្លាយជាចំណីវាយ៉ាងឆ្ងាញ់ពិសា ។

ស្បៃអន្ធការគ្របដណ្តប់លើភពផែនដី ហើយក្រសោបយកវិញ្ញាណក្ខន្ធយុទ្ធជនដ៏អភ័ព្វទៅជាមួយផង ដោយទុកឱ្យរាងកាយឥតខ្លឹមសាររបស់ខេមរានៅកណ្តោចកណ្តែងនាមាត់ព្រៃស្ងាត់ជ្រងំ ក្រោមសំឡេងថ្ងូចថ្ងូរនៃតន្ត្រីធម្មជាតិយ៉ាងអាណោចអាធម្ម


www.elibraryofcambodia.org

ក្រែលែង ។

---

មីងប្រាជ្ញជាអ្នកជិតខាងនៅក្នុងស្រុកភូមិបោះពៃនេះដែរ គាត់រាប់អានមីងបុល ណាស់ ប្ដីគាត់ឈ្មោះ លុយ ជំនាញខាងបរបាញ់សត្វ ។ ពូលុយ ឧស្សាហ៍ចេញចូលព្រៃ ដូច្នេះហើយបានជាពូលុយត្រូវខ្មែរម្ខាងទៀតនៅក្នុងព្រៃដែលគេតាំងខ្លួនថា " ជាខ្មែរ ស្នេហាជាតិ ឬជាខ្មែររំដោះជាតិនោះ " ស្គាល់ច្បាស់ គេក៏មិនធ្វើបាបពូលុយទេ ។ ម្យ៉ាង ទៀតកាលណាបាញ់បានសត្វព្រៃ ពូលុយតែងតែចែករំលែកសាច់សត្វឱ្យទៅពួកព្រៃខ្លះ ទើបគាត់បានសុខ បើមិនដូច្នេះទេ មុខជាគ្មានស្រមោលនៅលើផែនដីនេះឡើយ ។

មីងប្រាជ្ញប្រពន្ធពូលុយស្រែកហៅ ឧប្បល ÷

- អ្នកបុលអើយ... អ្នកបុល... នៅឯណាហ្នឹង ?

ឮដូច្នេះ ឧប្បលដែលកំពុងប៉ះខោអាវប្រកបដោយវង់ភក្រ្តស្លូតស្លប់ផងនោះ ក៏ ដាក់ខោអាវចុះ ហើយប្រញាប់ប្រញាល់ចេញមករានហាលខាងក្រៅ រួចលាន់មាត់ ÷

- ឱ ! បងប្រាជ្ញទេតើ !...អញ្ជើញឡើងមកមានការអីទៅបង ?

មីងប្រាជ្ញបន្តសំដី ÷

- ប្ដីខ្ញុំបានប្រគល់សំបុត្រនេះមកអ្នកបុលឯង !

- សំបុត្រស្អីអីចេះ ?

- គាត់ថាបានពី...

ដល់ពាក្យបន្តទៀត គាត់ឱនខ្សឹបខ្សៀវដាក់ត្រចៀកមីងបុល :

- ... ពួកព្រៃ

រ៉ាវិន ឃើញចាស់ទុំនិយាយខ្សឹបខ្សៀវស្ងាត់ៗ ក៏សសៀរមកអង្គុយជិត ។ ទន្ទឹម នឹងពាក្យសំដី មីងប្រាជ្ញក៏លូកដៃទៅក្នុងហោប៉ៅអាវ គាត់មានអាកប្បកិរិយារាងកន្ទេង រាងកស្ដាំ រួចក៏ប្រគល់ក្រដាសដែលបត់ជាច្រើនផ្នត់យ៉ាងតូច ឱ្យទៅមីងបុលដោយប្រុង


www.elibraryofcambodia.org

ប្រយ័ត្ន ព្រោះគ្រួសារ ឧប្បល ចាប់តាំងពីប្តីស្លាប់ទៅ ហើយកូនប្រុសក៏រត់ចូលព្រៃទៀត គ្រួសារនេះហាក់ដូចជាត្រូវគេខ្ពាចរអា មិនសូវមានគេរាប់រក ។ ប៉ុន្តែផ្ទុយស្រឡះទាំងស្រុង នាងឧប្បលជានារីមានអាកប្បកិរិយា សុភាពរាបសា សីលធមិរស់នៅប្រពៃតាំងពីដើមរហូតមក ប្រការខាងលើនេះដោយសារកូនប្រុសរត់ចូលព្រៃ ទើបគេក៏គិតថាគាត់ជាខ្មាំងបង្កប់ ។ នេះហើយសង្គមខ្មែរ ដោយសារតែការចោទប្រកាន់ឥតសមហេតុសមផលនេះហើយ ដែលធ្វើឱ្យប្រជាជនខ្មែររកសេចក្តីសុខមិនឃើញសោះ ។

ឧប្បល លាផ្ទត់ក្រដាសនោះយឺត១ ដូចជាពិភាល់អ្វីចម្លែកនៅក្នុងចិត្ត ។ ឧប្បលក៏អានអក្សរនោះទាំងពិបាក ដោយសារលោហិតប្រឡាក់ ប្រតេកប្រតាក ។

ពីសមរភូមិឧត្តរមានជ័យ, ថ្ងៃទី ១៨ - ០៩ - ១៩៩០

ជូនចំពោះអ្នកម្តាយ និង អាទិន ប្អូនស្រីសំឡាញ់

ខ្ញុំមិនបានមកក្រាបលាអ្នកម្តាយដោយផ្ទាល់ទេ គឺកូនសូមលាពីចម្ងាយដោយគ្មានថ្ងៃណាសង្ឃឹមថាបានជួបលោកជាទីគោរពទៀតទេ ។ អ្នកម្តាយ ការពិតកូនគ្មានបំណងក្បត់ជាតិមាតុភូមិរបស់ឯងឡើយ ការដែលកូនរត់ចេញពីផ្ទះនេះ ក្នុងគោលបំណងទៅប្រទេសទីបីឯណោះទេ ដើម្បីស្វែងរកលុយកាក់មកដោះបំណុលម៉ែ មកឧបត្ថម្ភប្អូនឱ្យរៀនសូត្រតែប៉ុណ្ណឹងឯង ។ ប៉ុន្តែកូនទៅមិនដល់គោលដៅ ក៏នៅត្រឹមទល់ដែន ជាប់អន្ទាក់អ្នកដែលគេប្រឆាំងនឹងរដ្ឋាភិបាល ដោយគេអះអាងថាគេជាជនស្នេហាជាតិ ។ ចំណែករូបកូនរកឱកាសរំដោះចេញពីទីនោះជាច្រើនដងដែរ ប៉ុន្តែមិនសម្រេច បានត្រឹមតែពួកវាវាយធ្វើបាបយ៉ាងដំណំគ្រាំគ្រាវេទនាជាទីបំផុត ម្ល៉ោះហើយក៏សុខចិត្តស៊ូទ្រាំរស់នៅទីនោះទៅដោយបន្សល់ទុកឱ្យអ្នកម្តាយមានកេរ្តិ៍ឈ្មោះថាមានកូនរត់ចូលដៃខ្មាំង ហើយគេផាត់គ្រួសារយើងឱ្យនៅក្រៅសង្គមរបស់គេ ។ កូនសូមសារភាពថា កូនខុសធ្ងន់ណាស់ចំពោះ



www.elibraryofcambodia.org

គ្រួសារយើង ។

អារិន ! បងក៏សូមលាប្អូនស្រីជារៀងរហូតដែរ ។ បើអត់ពីបងទៅ ប្អូនត្រូវមើលថែម្ដាយយើង កុំឱ្យលោកពិបាកចិត្តណា ! ប្អូនណា ! និង... កុំភ្លេច...ប្រពៃណីជាតិយើង !... បងមានតែប៉ុណ្ណឹងទេ !...បងលាហើយប្អូនស្រីសំឡាញ់ ...

ពីកូនប្រុស ពីបងប្រុស

កែវ ខេមរា

មីងបុលអានសំបុត្រទាំងទឹកភ្នែកធ្លាក់មកតក់ៗដូចតំណក់ទឹកភ្លៀង ចំណែកឯរ៉ារិនក៏រត់ទៅពួនយំនៅក្នុងបន្ទប់ ។ មីងប្រាជ្ញឃើញបរិយាកាសអួរអាប់ គាត់ក៏និយាយលួងលោមមីងបុល ÷

- អ្នកបុលអើយ ! កាត់ចិត្តខ្លះទៅ ការព្រាត់ប្រាសគឺជាការធម្មតាមើលមិនឃើញទេ ។

មិនឮមានចម្លើយឆ្លើយតបតនឹងពាក្យលួងលោមរបស់មីងប្រាជ្ញវិញសោះ ប៉ុន្តែបែរជាឮសំឡេងខ្សឹកខ្សួលនៅបន្តទៀតទៅវិញ ។ ឧប្បល នឹកដល់អតីតកាលដែលធ្លាប់រុងរឿងថា : " បើកុំតែមានសង្គ្រាមផ្លាស់របបចុះឡើង ម្ល៉េះសមខ្លួនគេបានរស់នៅជួបជុំសុខដុមរមនា ប្ដី កូន ហើយតទៅអនាគតនឹងមានចៅស្រី ចៅប្រុស ឯកូន ប្រុសក៏គ្មានគំនិតរត់គេចពីគ្រួសារទៅរស់នៅប្រទេសទីបី ទីបួន នោះទេ " ។ នឹកដល់ត្រង់នេះស្រាប់តែមីងបុលនិយាយចេញមក ÷

- កុំអីគ្រួសារខ្ញុំរស់នៅជុំគ្នាយ៉ាងសុខសាន្ត... គ្មានបែកបាក់ព្រាត់ប្រាសដូច្នេះទេ ។

នាង រ៉ារិនស្ដាប់ម្ដាយនិយាយទាំងទឹកភ្នែកហូរមិនដាច់ឡើយ ។ នាងនៅតែនឹកឃើញដល់សេចក្ដីក្នុងសំបុត្ររបស់ខេមរា ដែលបងប្រុសបាត់បង់ជីវិតដោយសារចង់ទៅប្រទេសទីពីរ ទីបី ដើម្បីរកលុយឱ្យម្ដាយដោះបំណុលគេ ឧបត្ថម្ភឱ្យនាងរៀនសូត្រ ។ តែទី


www.elibraryofcambodia.org

បំផុត បងប្រុសក៏ស្លាប់ ឪពុកក៏ស្លាប់ បំណុលក៏កាន់តែកើនឡើង ដូចពាក្យចាស់លោកពោលថា : “ ប្រាក់ក៏បង់ ផង់ក៏ដាច ” ។ នាងរ៉ាវិនយកក្រមាមកផ្តិតទឹកភ្នែក ហើយរអ៊ូថា ÷

- តើខ្ញុំត្រូវជួយម្តាយខ្ញុំដោយវិធីណាទៅព្រះអើយ ! បើខ្លួនជាស្រី តម្រិះតិច... ដូចជារំពឹងតែទៅលើការអស់សង្ឃឹមតែមួយប៉ុណ្ណោះ ។

នៅថ្ងៃដែលបានទទួលដំណឹងអាក្រក់នោះ ទាំងមីងបុល ទាំងរ៉ាវិន គ្មានបាយមួយគ្រាប់ចូលពោះសោះ ព្រោះតែសេចក្តីទុក្ខមកញាំញីយ៉ាងធ្ងន់ធ្ងរ ។

នៅពេលរសៀល ប្អូនស្រីជីដូនមួយមីងប្រាជ្ញឈ្មោះ សាមិត្ត ក៏មកលាមីង បុល ដើម្បីទៅនៅជាមួយបងស្រីឈ្មោះសាមួនឯទីក្រុងភ្នំពេញ ។

ឮពាក្យភ្នំពេញ ដូចជាកន្ត្រាក់អារម្មណ៍ចិត្ត រ៉ាវិនភ្លាម ។ នាងគិតថាទីនោះ អាចរកលុយបានច្រើន មិនចាំបាច់ទៅប្រទេសទីបី-ទីបួន ដូចបងខេមរារបស់ខ្លួនឡើយ ប៉ុន្តែបើរស់នៅស្រែចម្ការដូចសព្វថ្ងៃនេះ ពីរ-បីជីវិតទៀត ក៏ម្តាយនាងពុំអាចដោះបំណុលគេរួចដែរ ។ រ៉ាវិនលួចស្រមៃជាសម្ងាត់តែម្នាក់ឯង ហើយមិននិយាយពីគោលបំណងនេះប្រាប់ដល់អ្នកណាម្នាក់ឡើយ ។

នៅឆ្នាំ ១៩៩៣ ពួកអ៊ុនតាក់ *UNTAC* ចុះទៅរៀបចំការបោះឆ្នោតរើសតំណាងរាស្ត្រដែលជាឱកាសល្អ ធ្វើឱ្យនាងរ៉ាវិន រៀនភាសាអង់គ្លេសពីពួកនេះបានខ្លះៗ ។ រ៉ាវិន ព្យាយាមរៀនឆាប់ចេះណាស់ ដោយសារមានគោលបំណងចង់ទៅរកស៊ីនៅភ្នំពេញ ។ ម្យ៉ាងទៀតនាងរ៉ាវិន ចងចាំឥតភ្លេចនូវសំឡេងវិទ្យុដែលបានផ្សាយថា បើចង់ដើរឆ្ងាយ ទាល់តែរៀនភាសាបរទេស ។

លុះបោះឆ្នោតឆ្នាំ ១៩៩៣ រួចហើយ ពួកអ៊ុនតាក់ *UNTAC* ក៏ចេញពីប្រទេសកម្ពុជា ។ អង្គការក្រៅរដ្ឋាភិបាលនានា ចុះទៅពង្រឹងពីអនាម័យ ពីអំពើហិង្សានៅក្នុងគ្រួសារ ពីជំងឺអេដស៍ ។ល។ ជាបន្តបន្ទាប់នៅតាមមូលដ្ឋាន ធ្វើឱ្យរ៉ាវិនមានទំនាក់ទំនងជាមួយពួកបរទេសបានជាហូរហែ ហើយការចេះដឹងក៏កាន់តែប្រសើរឡើង


www.elibraryofcambodia.org

- បងបុល ! អង្គុយឱ្យផ្ចឹងមើលតែជុំថ្មអីចឹង...ហេតុអីក៏បងមិនអញ្ជើញភ្ញៀវឱ្យទិញបន្ទែរបស់បងទៅ?

ស្ត្រីឈ្មោះ បុល អង្គុយទទូរក្រមាអំបោះ ប្រកបដោយទឹកមុខស្មើ អារម្មណ៍របស់គាត់ហាក់ដូចជាកំពុងគិតពីបញ្ហាលក់ដូរផង ពីបញ្ហាផ្ទាល់ខ្លួនផង ។ ភ្លាក់បន្តិច ស្ត្រីឈ្មោះ បុល ក៏ឆ្លើយតបទៅសាមិត្ត ÷

- បើគេពេញចិត្តនឹងទំនិញរបស់យើង គឺគេទិញហើយ ! បើគេមិនពេញចិត្តទេ បង្ខំគេក៏មិនកើតដែរ !

សាមិត្តលាន់មាត់ អ៊ឹស ! រួចដកដង្ហើមធំ ÷

- ផ្អែកផ្អូលរំពឹងព្រេងវាសនាសោះតែម្តងហើយ បងបុលនេះ !

- ចុះឯងមិនរំពឹងព្រេងវាសនា !...តាំងពីព្រឹកមក ប្រឹងនិយាយឡើងខ្សោះអស់ទឹកមាត់ទៅហើយ...ក៏មិនឃើញបានប្រសើរឯណាឱ្យលើសពីបងទៅ?

- ម៉េចក៏បងនិយាយអីចឹង...យ៉ាងណាៗ ! ត្រូវតែប្រឹងតស៊ូដែរណា៎ បង !

- បងខំប្រឹងអង្គុយហាលក្តៅប៉ុណ្ណឹងហើយ ឯងគិតថាបងមិនតស៊ូទេឬយ៉ាងដូចម្តេច?

- តស៊ូ !...តែតស៊ូស្ងាត់ឈឹងអីចឹងឬ ?... ការតស៊ូត្រូវតែមានគ្រប់ជ្រុងជ្រោយណា៎បង !... មើលបងមើល !...គេខំផ្សាយបារី...ផ្សាយស្រាស្ទើរកក្រើកទឹកកក្រើកដី បំពងសំឡេងតាមវិទ្យុផង បញ្ចាំងតាមទូរទស្សន៍ផង...ស្តាប់ទៅ ដូចជាស្រា និង ផ្សែងបារីនោះឆ្ងាញ់ណាស់អីចឹង !... គិតៗទៅក្នុងលោកនេះ ដូចជាវង្វេងវង្វាន់អស់ហើយ...

សាមិត្តកំពុងស្រវឹងទឹកមាត់ ស្រាប់តែស្ត្រីម្នាក់រូបរាងស្អាតបាតបានមកនិយាយម៉ៅក្រសាំង ÷

- បង ! ក្រសាំងមួយកញ្ចើហ្នឹងថ្លៃប៉ុន្មានដែរ?



www.elibraryofcambodia.org

ជាល់ជាប់ ។ នៅឆ្នាំ ១៩៥៨ មេខ្យល់មួយចំនួន បានដើរទៅបំផុសបំផុលនារីស្អាតៗនៅតាមជនបទឱ្យមកធ្វើការនៅទីក្រុង ។ ប៉ុន្តែការងារដែលធ្វើឱ្យវ៉ាវិនខកចិត្តនោះ មិនមែនការងារថ្លៃថ្នូរឡើយ គឺការងារជានារីបម្រើតាមរង្គសាល ។

ព្រហ្មលិខិតបានកំណត់វាសនាឱ្យដល់មនុស្សលោក ដែលធ្វើឱ្យវ៉ាវិនឆ្លាតជាងនារីដទៃ ។ នាងបានបន្លំសំបុត្រពេទ្យរបស់នារីម្នាក់ ដែលកើតអេដស៍យកមកលុបឈ្មោះគេចេញ ហើយកែដាក់ឈ្មោះខ្លួនវិញ ។

ការនិទានរឿងរបស់នាងវ៉ាវិន បានបញ្ចប់ទៅដោយកម្លាំងកាយនាង កាន់តែអន់ថយ ហើយភាពងងុយបានមកសណ្ឋិតមកលើរូបកាយនាងវិញម្តង ធ្វើឱ្យនាងគេងលង់លក់ទៅ ។ ជនទាញភួយដណ្តប់ឱ្យវ៉ាវិន ចំណែកឯខ្លួនវិញ ទាញកៅអីយកមកផ្តុំ ហើយប្រះខ្លួនលើកៅអីនោះទៅ ។

នៅម៉ោង ប្រាំបួនព្រឹក សំឡេងទូរស័ព្ទរោទិ៍ ជនស្ទុះទៅលើកភ្លាម ពីព្រោះអ្នកមិនចង់រំខានដំណេកវ៉ាវិន អ្នកចង់ទុកឱ្យនាងសម្រាកឱ្យបានស្កប់ស្កល់ ។ សំឡេងពីចុងខ្សែម្ខាងចាប់ផ្តើម ÷

- អាឡូ... ជនភ្ញាក់ហើយឬ ?

- ភ្ញាក់ហើយ !... គឺភ្ញាក់ពេលឮទូរស័ព្ទរោទិ៍

- ឱ ! សុំទោសដែលខ្ញុំរំខានអ្នក... ប៉ុន្តែបើអ្នកចង់ញ៉ាំអាហារពេលព្រឹក អ្នកប្រាប់ទៅអ្នកបម្រើ គេនឹងលើកយកមកឱ្យអ្នកដល់បន្ទប់... ពីព្រោះខ្ញុំបានប្រាប់គេអស់ហើយ... អ្ហា ! យ៉ាងម៉េចទៅជន ?

- អ្វីៗប្រសើរណាស់ នៅទីនេះ (ជនតប) ។

- តែប៉ុណ្ណឹងទេ ! បានហើយជន...បន្តការសប្បាយទៀតចុះ...លាសិនហើយ !

ជនដាក់ទូរស័ព្ទចុះ រួចអង្គុយសម្លឹងវ៉ាវិន ដែលកំពុងតែគេងលក់យ៉ាងសុខស្រួល ហើយនឹកស្មានតែម្នាក់ឯងរកការពិតមិនឃើញ : “ តើហេតុអ្វីដែលបណ្តាលឱ្យនាងឃ្លាត



www.elibraryofcambodia.org

ចាកចេញពីមាតា បិតា មករកស៊ីជានារីរាត្រីដូច្នេះ ! ចាំខ្លួនខ្ញុំចុះបានជាកម្សត់ កំព្រាទៅហើយ ! ចុះអ្នកដែលមានឪពុក ម្តាយហើយ ហេតុអ្វីក៏ក្លាយទៅជាយ៉ាងនេះដែរ ? "។ មិនសុខមិនសាប់ អ្នកកំលោះក៏យកដៃផាត់វាំងននមើលទៅទន្លេមេគង្គ ដែលកាលពីឆ្នាំ ១៨៦៦ ទន្លេមេគង្គ បែកចេញជាបួននៅត្រង់មុខព្រះបរមរាជវាំង ឥឡូវនេះទន្លេមុខបួននោះមកឋិតនៅត្រង់សណ្ឋាគារកាំបូឌីយ៉ាណាវិញ ។ អ្វីៗនៅ លើលោកយើងនេះ តែងតែប្រែប្រួលមិនទៀងទាត់ឡើយ ។ ជនអង្គុយមើលទេសភាពឯត្រើយនាយវិញម្តង នឹកអនិច្ចាដល់ខ្លួនកម្សត់ កំព្រា គ្មានបង គ្មានប្អូន គ្មានម៉ែ គ្មានឪ ស្រាប់តែអួលដើមករកកលចង់ស្រក់ទឹកភ្នែក ។ ដើម្បីកាត់អារម្មណ៍លន្លង់លន្លោចនោះ ជនក៏ងើបចូលទៅបន្ទប់ទឹកបាត់ទៅ ។ មួយសន្ទុះក្រោយមក អ្នកហាក់មានអារម្មណ៍ថ្លាក្នុងចិត្ត ក៏ទាញក្រដាស និងប៊ិចសរសេរអត្ថបទមួយមានចំណងជើងថា : " មាតាជាប្រភពនៃសេចក្តីស្នេហា និងជាសភាវៈទន់ភ្លន់ " ដែលខ្លឹមសារ មានជាអាទិ៍ដូចតទៅ ...

* * * * *



www.elibraryofcambodia.org

# ៦

# មាតាជាប្រភពនៃសេចក្តីស្នេហា និង ជាសភាវៈធន់ធ្ងន់

ពេលដែលខ្ញុំប្រសូត្រចេញមកនៅថ្ងៃដំបូង ភាពប្រែប្រួលនៃសីតុណ្ហភាពរបស់ពិភពលោក បានរសាត់មកប៉ះទង្គិចសារពាង្គកាយរបស់ខ្ញុំ បណ្តាលឱ្យខ្ញុំរងាចំប្រប់ ។ ខ្ញុំស្រែកចំទាលក្តែងៗដោយសភាវគតិ ហាក់ដូចជាទទូចរកជំនួយសង្គ្រោះជាបន្ទាន់ ។ មែនហើយសម្រែកខ្ញុំនោះ ហាក់ដូចជាពុំមានប្រសិទ្ធិភាពអ្វីឡើយ ។ គេទាំងឡាយនោះដែលខ្លះឈរក្បែរខ្ញុំ ពុំបានយកចិត្តទុកដាក់ដល់សម្រែកចំទាលរបស់ខ្ញុំ ដល់តិចតួចឡើយ គឺគេធ្វើព្រងើយ ខិតខំតែបំពេញភារកិច្ចរបស់គេទៅតាមតួនាទីរៀងៗខ្លួន ។ ខ្លួនខ្ញុំប្រឡាក់ទៅដោយលោហិតរបស់ស្ត្រីម្នាក់ ដែលមុននោះបន្តិច លោកស្រែកថ្ងូចថ្ងូរដោយក្តីឈឺចាប់ហួសនិស្ស័យស្ទើរតែផុតរលត់សង្ខារ ព្រោះតែខ្ញុំត្រៀមលក្ខណៈប្រវេប្រវាប្រសូត្រចេញពីឧទររបស់អ្នកម្តាយខ្ញុំមក ។ ខ្ញុំគិតជាស្រេចថា ៖ គឺខ្លួនខ្ញុំនេះហើយជាដើមហេតុដែលធ្វើឱ្យគាត់មានការឈឺចាប់នោះ ។ ហេតុនេះហើយ បានជាខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង រហូតដល់ស្រែកក្តែងៗរកជំនួយផងដែរ គួបផ្សំនឹងសីតុណ្ហភាពខុសគ្នារវាងខាងក្នុងនិងខាងក្រៅគភ៌របស់អ្នកម្តាយ ។

សូរសំឡេងសម្ភារៈដែលគេកំពុងតែអនុវត្តការងារ លាន់ឮក្បែរត្រចៀកខ្ញុំ ប៉ុន្តែខ្ញុំពុំឮសំឡេងគេជជែកគ្នាទេ ។ ខ្ញុំកំពុងតែរងា កំពុងតែភ័យនឹងអ្នកម្តាយ ដែលលោកកំពុងតែសម្រាកស្តូកស្តឹងដោយអស់កម្លាំងល្ហិតល្ហៃ ប្រយុទ្ធទ្រាំទ្រនឹងការឈឺចុកចាប់មុននេះបន្តិច ។ ពេលនេះ ខ្លួនខ្ញុំត្រូវគេលើកពីក្បែរជើងអ្នកម្តាយ យកទៅជម្រះកាយនឹង


www.elibraryofcambodia.org

អង្គធាតុរាវក្តៅឧណ្ហៗ ។ ខ្ញុំហាក់ដូចជាស្ងប់អារម្មណ៍ ព្រមទាំងមានការសុខស្រួលក្នុងអង្គធាតុនោះ ហើយលោហិតដែលរីបរូតស្បែករបស់ខ្ញុំក៏រលាយខ្សាក ធ្វើឱ្យខ្ញុំមានអារម្មណ៍ធូរស្រឡះ ។ ភាពសុខស្រួលមិនបានប៉ុន្មាននាទីផង ស្រាប់តែខ្លួនខ្ញុំត្រូវគេយកចេញពីអង្គធាតុនោះ ហើយផ្តេកខ្ញុំទៅលើអ្វីមួយរឹងៗ ទំនងជាបន្ទះក្តារ ។ ភាពប្លែកៗថ្មីៗដែលតែមួយសន្ទុះសោះ ខ្ញុំបានជួបប្រទះជាច្រើនរឿង គ្មានអ្វីក្រៅតែពីធ្វើឱ្យខ្ញុំភិតភ័យនឹងរឿងថ្មីនោះទេ ។ ខ្ញុំក៏បន្លឺសម្រែកឡើង ប៉ុន្តែភ្លាម នោះគេក៏បានយកក្រណាត់ក្រាស់ធ្ងន់បន្តិច មកគ្របសង្កត់លើខ្លួនខ្ញុំឱ្យបានកក់ក្តៅ រួចហើយគេក៏ចាត់ចែងរៀបរយខ្ញុំដោយរុំនឹងក្រណាត់ត្រង់ពោះ និងត្រង់កេរ្តិ៍ខ្មាសរបស់ខ្ញុំយ៉ាងប្រយ័ត្នប្រយែង ។ គេបានយកប្រេងកូឡាមករីតពោះខ្ញុំមុននិងគេរុំក្រណាត់ ធ្វើឱ្យអាកាសៈក្នុងខ្លួនខ្ញុំប្រែប្រួលរហូតរបូតខ្យល់ពីរ បីភួសចេញមកក្រៅ លាយឡំនឹងសម្រែកខ្ញុំដែរ ។ គេនិយាយតិចៗមកកាន់ខ្ញុំថា : អ្នកកំលោះដ៏ខ្លាំងក្លា អ្វីៗតាមសម្រួលដូចប្រក្រតីហើយ ។ បន្ទាប់មកទៀតគេក៏បំពាក់ឱ្យខ្ញុំតាមលំដាប់លំដោយ គឺគេពាក់អាវ ពាក់ស្រោមជើង ហើយចុងបញ្ចប់គេក៏ពាក់ស្រោមដៃឱ្យខ្ញុំទៀត ។ ខ្ញុំនឹកក្នុងចិត្តថា : ការតុបតែងរបៀបនេះ ខ្ញុំបានកក់ក្តៅមែនទែន ក៏ប៉ុន្តែខ្ញុំកំពុងនឹកសង្ស័យផងដែរថា តើគេពាក់ស្រោមដៃឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំបានកក់ក្តៅតែមួយមុខប៉ុណ្ណោះទេ ឬមួយក៏គេមានគោលបំណងពាក់ឱ្យខ្ញុំ ដើម្បីត្រៀមប្រយុទ្ធនឹងអ្នកណាម្នាក់ ។ ច្បាស់ហើយ គឺសម្រាប់ប្រយុទ្ធជាមួយអ្នកម្តាយខ្ញុំ ពីព្រោះខ្ញុំគិតថា លោកពិតជាខឹងនឹងខ្ញុំ ហើយបើលោកប្រព្រឹត្តអំពើមិនគប្បីមកលើខ្ញុំ ពេលនេះខ្ញុំមានឱកាសទប់ទល់ ការពារខ្លួននឹងលោកបានវិញខ្លះមិនខាន ។ ខ្ញុំកំពុងតែគិតដូច្នេះ ស្រាប់តែគេលើកខ្ញុំយកទៅ ខ្ញុំមិនទាន់មើលអ្វីឃើញនៅឡើយ ប៉ុន្តែខ្ញុំឮសស្រើបជើងជាច្រើនគូដើររសើបរសាវ ហែហមទៅតាមខ្ញុំ ។ ខ្ញុំដឹងថា ខ្ញុំឋិតនៅក្នុងរង្វង់ដៃបីត្រកងរបស់គេ។ ឥឡូវគេឈប់ទ្រើង ខ្ញុំឮគេនិយាយឆ្លងឆ្លើយ : ម៉េចទៅកូនខ្ញុំ អ្នកគ្រូពេទ្យ ? ។ អ្នកបីខ្ញុំឆ្លើយ : ពេញលក្ខណៈជាតួអង្គបុរសទ្រូងប្រាំហត្ថ... ទាំងសុខភាពក៏ល្អមាំទាំ... ទាំង


www.elibraryofcambodia.org

រូបសម្បត្តិ ក៏ស្រស់ប្រិមប្រិយ... ស្អាតដូចម្ដាយអ៊ីចឹង ។ ពេលទម្ងន់កូននេះ នឹងធ្វើទុក្ខបុក
ម្នេញ នាំឱ្យអ្នកស្រីចាញ់ឬទេ ?

អ្នកម្ដាយឆ្លើយ : ចាស ! ធ្វើទុក្ខដែរ !

គ្រាន់តែឮចម្លើយរបស់អ្នកម្ដាយ ខ្ញុំភ័យប្រហោងពោះរបូតខ្យល់លាន់ភូស១ទៀតលើដៃអ្នកគ្រូពេទ្យ បណ្ដាលឱ្យអ្នកគ្រូពេទ្យលាន់មាត់សរសើរ : កូននេះដើរខ្យល់ល្អណាស់ ។ ចប់វាចា អ្នកគ្រូពេទ្យក៏ដាក់ខ្ញុំប្របខ្លួនអ្នកម្ដាយ ជើងដៃខ្ញុំកម្រើកដោយស្វ័យប្រវត្តិញាក់ញ័រទទ្រើត ហាក់ដូចជាខឹងសម្បាចង់ប្រឈមនឹងគូសត្រូវរបស់ខ្លួន ប៉ុន្តែខ្ញុំហាក់ដូចជាបានកក់ក្ដៅឡើងវិញ ដោយសារអ្នកម្ដាយបានកាន់ដៃខ្ញុំថ្នម១ រួចលោកបន្លឺសំឡេងស្រាល១ ហាក់ដូចជាខ្លាចរំខានខ្ញុំ : " កូនប្រុសមាសម្ដាយ " ។ ព្រះអើយ ! ខ្ញុំរំភើបពេករកថាមិនត្រូវ តើមានអ្វីឱ្យគេដឹងថាខ្ញុំនេះត្រេកអរ គឺមានតែស្រែកចំទាលលាន់កងរំពងឡើងដែលខ្ញុំទើបតែចេះតែប៉ុណ្ណឹង ។ ខ្ញុំគិតថា ទាំងអ្នកគ្រូពេទ្យដែលឈរនៅក្បែរនោះ ទាំងអ្នកម្ដាយ ប្រហែលជាស្មានខុសថា ខ្ញុំនេះខឹងហើយ ប៉ុន្តែផ្ទុយទៅវិញគឺខ្ញុំត្រេកអរនឹងទឹកចិត្តល្អបរិសុទ្ធមិនយកទោសពៃរ៍របស់លោក ។ ខ្ញុំឮលោកមានប្រសាសន៍ថា : កូនប្រុសមាសម្ដាយ កូនឃ្លានហើយ ។ គ្រាន់ផុតវាចា លោកក៏លាត់អាវបញ្ចេញសុដនទាំងគូ រួចរីតច្របាច់បញ្ចេញទឹកដោះហូរឆ្ពោចមកលើមុខខ្ញុំ បំណងបញ្ចុកមាត់ខ្ញុំ ប៉ុន្តែត្រូវបានអ្នកគ្រូពេទ្យឃាត់សិន ព្រោះខ្លួនខ្ញុំមិនទាន់ដល់ពេលបៅនៅឡើយ ។ ពុទ្ធោអើយ ! គឺខ្លួនខ្ញុំនេះស្មានខុសទាំងស្រុង ថាលោកខឹង ថាលោកចង់សងសឹកខ្ញុំ ប៉ុន្តែផ្ទុយស្រឡះទៅវិញ លោកគ្មានគំនិតដូចខ្ញុំស្មានសោះ ។

ពីមួយថ្ងៃទៅមួយថ្ងៃ វ័យវឌ្ឍនាការរបស់ខ្ញុំក៏រីកចម្រើនធំធាត់ដោយសារតែអ្នកម្ដាយបំបៅ ថែបំប៉ន បញ្ចុកចំណីជាប្រចាំ ។ ខ្ញុំចាំឥតភ្លេចទេ នៅថ្ងៃដែលខ្ញុំស្គាល់ពិភពលោកជាលើកដំបូង គឺពេលនោះហើយ ដែលខ្ញុំបានឃើញពន្លឺព្រះអាទិត្យចាំងចូលមក ហើយនិងរូបភាពមួយដែលកាលពីមុនគ្រាន់តែជាស្រមោលខ្មៅស្លុង១ ឋិតនៅនែបនិត្យ


www.elibraryofcambodia.org

ជិតខ្ញុំគ្រប់ពេលវេលា ។ ឥឡូវខ្ញុំមើលឃើញច្បាស់ហើយវង់ភក្ត្រដ៏ល្អសោភា ដែលបង្កប់ទៅដោយស្នាមញញឹមពព្រាយស្រស់ស្រាយ ដូចស្រទាប់ផ្កា កុលាបនៃនារីម្នាក់គឺអ្នកម្ដាយរបស់ខ្ញុំ ។ ពេលលោកបំបៅខ្ញុំឆ្អែតហើយ លោកផ្ដេកខ្ញុំក្នុងអង្រឹង រួចលោកច្រៀងបំពេ វាយទំនុកយ៉ាងពីរោះជូនរណ្ដំ ដែលខ្ញុំមិនទាន់យល់ថាមានន័យយ៉ាងដូចម្ដេចនៅឡើយ ។ ខ្ញុំហាត់បញ្ចេញសំឡេងតាមលោក ជួនកាលទៀតខ្ញុំខំលើកដៃរលាស់ទៅតាមបទចម្រៀងនោះ ។ ខ្ញុំហាត់រៀនឥតឈប់ឈររៀងរាល់ថ្ងៃនូវមុខវិជ្ជាដដែលៗ ត្បិតមានពេលខ្លះ ខ្ញុំត្រូវធ្វើច្រើនសាទម្រាំតែចេះ ។ ប្រហែលដោយក្ដីស្រឡាញ់ក៏មិនដឹងបានជាពាក្យពេចន៍ដែលលោកមានប្រសាសន៍មកកាន់ខ្ញុំ គឺសុទ្ធតែជាពាក្យពីរោះៗ ថ្លៃថ្នូរប្រកបដោយសីលធម៌ លើកកម្ពស់កម្លាំងចិត្ត ផ្ដល់នូវសេចក្ដីសង្ឃឹមជានិច្ច ព្រមទាំងបណ្ដុះចិត្តក្លាហាន ដល់ខ្ញុំគ្រប់ពេលវេលា ។

ខ្ញុំគិតថាប្រហែលជាមានតែអ្នកម្ដាយទេ ដែលលោកយកចិត្តទុកដាក់ជាពិសេសដល់រូបខ្ញុំ ពីព្រោះនៅពេលណាដែលខ្ញុំស្រែកយំ លោករហ័សស្ទុះភ្នែកមកមើលខ្ញុំដូចផ្លេកបន្ទោរ ក្រែងលោមានអ្វីមកយាយីលើរាងកាយខ្ញុំ ដែលសូម្បីតែសត្វស្រមោច សង្ការដ៏តូចល្អិតក៏លោកពុំអនុញ្ញាតឱ្យមកបំពះសាច់ខ្ញុំដែរ ។ ពេលខ្ញុំចេះដើរតេះតះ លោករឹងរឹតតែយ៉ាប់យ៉ឺនក្នុងការថែទាំ និងការពីសនៃខ្ញុំ ។ ពេលនោះអ្នកម្ដាយប្រហែលជាគ្មានបានសម្រាកសុខស្រួលទេ ពីព្រោះតែក្ដីបារម្ភមានដល់រូបខ្ញុំស្ទើរតែគ្រប់នាទី ។ ខ្ញុំឃើញអ្នកម្ដាយស្រកសាច់ ភ្នែកខូងបន្តិច ប៉ុន្តែអ្វីដែលនៅតែដដែលឥតប្រែប្រួល គឺដួងចិត្តថ្លាបរិសុទ្ធដែលស្ដែងចេញតាមភក្ត្រញញឹមប្រិមប្រិយមកកាន់ខ្ញុំជានិច្ច ព្រមទាំងនៅមានសំដីពីរោះថ្នាក់ថ្នមថែមទៀត ។

ពាក្យដែលខ្ញុំចេះមុនគេបង្អស់គឺពាក្យ " ម៉ែ " ហើយខ្ញុំស្រឡាញ់មនុស្សដែលមានឈ្មោះនេះស្មើនឹងកែវភ្នែករបស់ខ្ញុំ ។ ខ្ញុំនឹកលោកគ្រប់វេលា ជាពិសេសនៅគ្រាលំបាកជួបគ្រោះអាសន្នម្ដងៗ ខ្ញុំតែងតែស្រែកដង្ហោយរក " ម៉ែអើយជួយខ្ញុំផង ! " ។


www.elibraryofcambodia.org

ខ្ញុំមិនដែលឃើញលោកគេចវេះដល់ម្តងណាសោះ នៅចំពោះមុខការស្រេកឃ្លានរបស់ខ្ញុំ លោកតែងតែប្រឈមមុខជានិច្ច ។ ជូនកាលទៀត ក្រោយពីការបរិភោគឆ្អែតស្កប់ស្កល់ ដែលមានម្ហូបអាហារដ៏សម្បូណ៌បែបរួចហើយ ខ្ញុំនឹកស្មានតែអ្នកម្តាយមានអ្វីៗដូចខ្ញុំដែរ ផ្ទុយទៅវិញគឺរាល់ចំណែករបស់លោកៗតែងតែយកមកផ្គត់ផ្គង់ឱ្យខ្ញុំ រីឯខ្លួនលោក ៗ សុខចិត្តទ្រាំអត់ឃ្លាន ដោយសោមនស្សរីករាយពុំមានត្អូញត្អែរអ្វីឡើយ ។ លោកលាក់នូវរឿងរ៉ាវស្មុគស្មាញទាំងឡាយ ដែលនាំឱ្យចិត្តសៅហ្មង ។ ដូច្នេះប្រហែលជាលោករែកពុនតែម្នាក់ឯង ដោយលោកចង់តែឱ្យខ្ញុំសុខស្រួលរហូត ។ ជូនកាលខ្ញុំ លួចនឹកតែក្នុងចិត្តថា : ស្ត្រីដែលខ្ញុំចង់រៀបការជាមួយ គឺស្ត្រីដែលមានលក្ខណៈដូចជាអ្នកម្តាយនេះហើយ បានសេចក្តីថា ខ្ញុំស្រលាញ់លោកពេញបេះដូង លើសខ្ញុំស្រឡាញ់គូស្នេហ៍ទៅទៀត ។ អ្នកម្តាយជាស៊ីម៉ងត៍ដ៏រឹងមាំ ជួយផ្សាររទំនាក់ទំនងសមាជិកក្នុងគ្រួសារឱ្យមានអធ្យាស្រ័យល្អ ចេះយោគយល់គ្នា ចេះស្រឡាញ់រាប់អានគ្នា ។ ពេលខ្ញុំធំដឹងក្តីឡើងកាលណា លោកបញ្ជូនខ្ញុំឱ្យទៅសាលារៀន ដើម្បីផ្សារទំនាក់ទំនងជាមួយសង្គមខាងក្រៅទៀត ព្រមទាំងពន្យល់ណែនាំនូវមាគ៌ាណាដែលនាំឱ្យរីកចម្រើនថ្លៃថ្នូរជានិច្ច ហើយទីបំផុត ខ្ញុំក្លាយទៅជាថ្នាក់ដឹកនាំដ៏កំពូលម្នាក់ ប្រកបដោយគុណធម៌ និងសមត្ថភាព ។ ខ្ញុំមានសិល្បវិធីក្នុងការធ្វើឱ្យប្រជារាស្ត្រ មានសុខសន្តិភាព ព្រមទាំងបានបង្កើតទុកនូវស្នាដៃជាច្រើន ដែលធ្វើឱ្យប្រជារាស្ត្រកោតសរសើរ ពេញចិត្តយ៉ាងខ្លាំងនូវទង្វើរបស់ខ្ញុំ ។ ខ្ញុំក៏លួចត្រេកអរផងដែរ ក៏ប៉ុន្តែរាល់សកម្មភាពអស់ទាំងនេះ បើកុំតែមានអ្នកម្តាយជាទីគោរពស្នេហាដ៏ជ្រាលជ្រៅ ណែនាំជាប្រចាំតាំងពីកើតចេញម៉ាមករហូតដល់ខ្ញុំក្លាយជាមនុស្សម្នាក់ដ៏សំខាន់នៅក្នុងសង្គមទេនោះ ម្ល៉េះសមខ្ញុំក្លាយជាមនុស្សអាវ៉ាសែ ដែលសង្គមស្អប់ខ្ពើមជាទីបំផុត ជាមនុស្សឥតប្រយោជន៍គ្មានខ្លឹមសារ ដែលគេតែងតែប្រៀបប្រដូចទៅនឹងផ្កាយទោះបីជាមានចំនួនច្រើនលានដួងយ៉ាងណា ក៏ពុំអាចប្រៀបប្រដូចទៅនឹងព្រះចន្ទដែលមានតែមួយដួងគត់ ប៉ុន្តែមានពន្លឺអាចកំចាត់អន្ធការបាន ។


www.elibraryofcambodia.org

ខ្លួនខ្ញុំនេះមានកំណើតក៏ដោយសារតែការខំប្រឹងប្រែងឥតឈប់ឈរ គ្រប់ពេលវេលារបស់អ្នកម្ដាយ តើមានអ្វីដែលថាខ្ញុំមើលពុំឃើញឧបការគុណរបស់លោកនោះ ? ហើយក្នុងនាមជាកូនល្អ តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីឆ្លើយតបចំពោះអ្នកម្ដាយវិញ ?

សេចក្ដីដែលខ្ញុំបានរៀបរាប់ត្រួស១យ៉ាងសង្ខេបខាងលើ គឺខ្ញុំគ្រាន់តែចង់បញ្ជាក់ថា បើអ្នកម្ដាយមានសមានចិត្តចំពោះខ្ញុំ ដូច្នេះហើយកាតព្វកិច្ចរបស់ខ្ញុំ គឺត្រូវតែខិតខំកសាងខ្លួនឱ្យក្លាយទៅជាមនុស្សមានប្រយោជន៍ដល់សង្គមជាតិទាំងមូល ។ ខ្ញុំមិនត្រូវធ្វើអំពើណាដែលនាំឱ្យគេប្រមាថដល់អ្នកម្ដាយឡើយ ។ ត្បិតនៅក្នុងសង្គមខ្មែរ កាលណាកូនប្រព្រឹត្តមិនគប្បី គឺគេវាយតម្លៃជៀលត្មះដល់ម្ដាយភ្លាមមួយរំពេច ប៉ុន្តែបើកូននោះប្រព្រឹត្តអំពើល្អ មានស្នាដៃល្បីល្បាញ គេក៏លើកសរសើរម្ដាយផងដែរ ។ ហើយខ្ញុំគិតថាកូនទាំងឡាយ បើចង់ឱ្យមាតាសប្បាយចិត្ត គឺត្រូវដើរតាមគន្លងធម៌របស់លោកជានិច្ច ។ នេះហើយជាកិច្ចតបស្នងសងគុណដ៏ប្រសើរបំផុត ។

សរសេរចប់ ជនអង្គុយពិនិត្យផ្ទៀងផ្ទាត់ ដោយមិនបានដឹងខ្លួនជាមុនសោះថា រ៉ាវិនមកឈរមើលអត្ថបទនោះពីក្រោយខ្នងអ្នកដែរ ។ នាងអានខ្សឹប១នូវខ្លឹមសាររបស់អត្ថបទនោះដែលធ្វើឱ្យប៉ះទង្គិចអារម្មណ៍នាងយ៉ាងខ្លាំង បណ្ដាលឱ្យនាងស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ដោយការនឹករឭកដល់ម្ដាយជាទីស្រឡាញ់ ។ ជនឮសំឡេងខ្សឹកខ្សួលតិច១ ក៏ងាកមកក្រោយ អ្នកមានអាការៈភ្ញាក់ ÷

- អា ! គឺរ៉ាវិនទេឬ !... ភ្ញាក់ពីថ្មើរម៉ាន !

រ៉ាវិន ជូតទឹកភ្នែក រួចឆ្លើយទាំងរអាក់រអួល ÷

- អត្ថបទរបស់បង ធ្វើឱ្យខ្ញុំរំភើបចិត្តណាស់... ហេតុអ្វីបានជាបងនឹកសរសេរអត្ថបទរបៀបនេះ ?

- ព្រោះបងគ្មានម៉ែនឹងគេ !

ចប់សំដីជន នាងរ៉ាវិនសម្លក់... រួចរអ៊ូ ÷



www.elibraryofcambodia.org

- និយាយមើលតែចៅចិត្រ នៅក្នុងរឿងកុលាបប៉ៃលិន ... បើគ្មានម៉ែទេ បងកើតមកពីណា?

- បងចង់និយាយថា គឺម្ដាយ ឪពុកបងស្លាប់តាំងពីបងនៅពីតូច ។

- អីចឹង ! រាល់ថ្ងៃបងនៅជាមួយអ្នកណា?

ជនដកដង្ហើមធំ រួចឆ្លើយដោយអស់សង្ឃឹម ÷

- សព្វថ្ងៃនេះបងរស់ដូចមនុស្សអនាថា មិនដឹងពូជពង្ស វង្សត្រកូលរបស់ខ្លួននៅឯណា... ប៉ុន្តែដែលខិតខំតស៊ូត្រដររស់រហូតមកដល់សព្វថ្ងៃនេះ មកពីបងឮព្រះសង្ឃទេសនាថា មនុស្សណាធ្វើអត្តឃាតខ្លួនឯង មានទោសធ្ងន់ណាស់ ព្រះប្រោស មិនរួចទេ... លុះបងគិតសព្វៗទៅឃើញថា ចាំបាច់ប្រញាប់សម្លាប់ខ្លួនធ្វើអ្វី បើគង់តែដល់ថ្ងៃស្លាប់ចៀសមិនផុតដដែល... ទុកឱ្យស្លាប់ទៅតាមកាលវេលានៃព្រះព្រហ្មលិខិតលោកកំណត់ទៅចុះ !

កំពុងជជែកគ្នា ស្រាប់តែឮសំឡេងទូរស័ព្ទរោទ៍ឡើង រ៉ាវិនស្ទុះភ្លែតទៅលើកប្រកបដោយទឹកមុខញញឹម រួចឆ្លើយចាស !... ចាស !...ហើយងក់ក្បាលតែម្នាក់ឯង ។ នាងដាក់ទូរស័ព្ទចុះ ហើយបែរមកនិយាយជាមួយជន ÷

- កន្លះម៉ោងទៀត យើងត្រូវចេញក្រៅ ទៅដើរលេងជាមួយលោកហ្វេដេរ៉ូ... លោកថាចាំជួបជុំសិន សឹមសម្រេចចិត្ត ។ ឥឡូវមិនទាន់ដឹងទេ... ខ្ញុំសុំចូលទៅបន្ទប់សិនហើយ ។

កំលោះ ជន ងក់ក្បាលរៀបចំគ្រែឱ្យមានរបៀប ហើយក៏អង្គុយរង់ចាំរ៉ាវិន ។ ពេលរ៉ាវិនចេញពីបន្ទប់ទឹក ឃើញគ្រែរៀបចំមានរបៀបរៀបរយ នាងក៏និយាយ ÷

- បើបងប្រុសខ្ញុំនៅរស់... មិនដឹងជាខ្ញុំសប្បាយចិត្តយ៉ាងណាទេ !... តែនេះ អស់ទាំងឪពុក អស់ទាំងបងប្រុសសំឡាញ់ ... នៅតែលគោលពីរនាក់ម្ដាយ ម៉ង់ៗ ។ ដល់ខ្ញុំចេញចោលទៀត អ្នកម្ដាយអើយ ! តើអ្នកម្ដាយកណ្ដោចកណ្ដែងតែម្នាក់ឯងយ៉ាង


www.elibraryofcambodia.org

ដូចម្ដេចទៅ ?

រៀបចំខ្លួនប្រាណហើយ នាងរ៉ាវិន និង ជន ក៏បណ្ដើរគ្នាត្រសងទៅបន្ទប់ហ្វេដេរ៉ូ ។ គេគួរសមដាក់គ្នា រួចក៏ចុះមករថយន្តដែលចតនៅវាលខាងក្រោម ។ ជន ផ្ដើមសំនួរ ÷

- លោក ហ្វេដេរ៉ូ គិតអញ្ជើញទៅណាហ្នឹង ?

- ខ្ញុំចង់ទៅឧត្ដុង្គ ប៉ុន្តែទៅតាមផ្លូវដីក្រហម ហើយចូលភ្នំរាបសិន... ជន ឯង ស្គាល់ទេ ?

ជនងក់ក្បាល រួចឆ្លើយយ៉ាងរហ័ស ÷

- ស្គាល់ច្បាស់ណាស់ !

- បើអីចឹង ទៅ ! យើងទៅ !

រថយន្តបរតាមផ្លូវជាតិលេខបួន ឆ្លងកាត់កំបូល លុះដល់បែកចាន ក៏មានក្លោងទ្វារវត្ត សរសេរដាក់ថា វត្តភូមិថ្មី ជនកាច់ចង្កូតរថយន្តចូលតាមក្លោងទ្វារវត្តនោះទៅ ។ ទេសភាពវាលស្រែយ៉ាងគួរឱ្យស្រណោះ លាតសន្ធឹងក្រោមចក្ខុទេសចរបរទេស ។ ហ្វេដេរ៉ូស្រឡាញ់ទឹកដីរបស់ប្រទេសកម្ពុជាណាស់ ។ អ្នកមិនត្រឹមតែចាប់អារម្មណ៍លើប្រាសាទអង្គរតែមួយប៉ុណ្ណោះទេ ប៉ុន្តែវាលស្រែ និងដើមត្នោតដែលជាមរតករបស់ជាតិ ក៏ជនបរទេសរូបនេះចាប់អារម្មណ៍ខ្លាំងណាស់ដែរ ។ ផ្លូវក្រាលគ្រួសក្រហមនេះ ជាជំនួយរបស់អង្គការក្រៅរដ្ឋាភិបាល មានលក្ខណៈល្អក្នុងការធ្វើចរាចរទៅមក ។ ផ្លូវនេះគេបានដាក់បណ្ដាញឱ្យនៅចាំថែរក្សារជាអចិន្ត្រៃយ៍ ដោយមានផ្ដល់ប្រាក់ឧបត្ថម្ភដែរ ។ ការគ្រប់គ្រងរបៀបនេះ ជាការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពល្អណាស់ ។

នៅអមសងខាងផ្លូវ គេហដ្ឋានកាលពីជំនាន់ដើម ក្នុងអំឡុងទស្សវត្សរ៍ទី ៦០-៧០ នៅសេសសល់មិនច្រើនប៉ុន្មានទេ ។ គេសម្គាល់ថាជាផ្ទះសល់ពីបុរាណដោយសារការតុបតែងលំអដោយបន្ទុបមកុដ[១] នៅចុងមេដំបូល និងមានក្បាលនាគសន្ធឹកនៅ

១ - មានរាងក្រឡុម មានកំពូលរំលេចដោយក្បាច់រចនាវិចិត្រធ្វើអំពីស៊ីម៉ង់ត៍ ប៉ុន្តែមកុដសម្រាប់ក្សត្រិយ៍ទ្រង់ពាក់ព្រះសិរ ធ្វើដោយមាសសុទ្ធ និងដាំត្បូង ។


www.elibraryofcambodia.org

- ចាស ! ប្រាំពាន់រៀល លោកស្រីទិញអ្វីច្រើនម្ល៉េះ ? (សាមិត្តសួរទាំងជ្រួញចិញ្ចើម ) ។

មីងបុលអង្គុយក្បែរនោះ លាន់មាត់ ÷

- បានលោកស្រីទិញហើយ នៅសួររកហេតុផលអីទៀត ?

អ្នកទិញញញឹមញញែម ឆ្លើយយ៉ាងរាក់ទាក់ ÷

- មានទៅទាស់អីប្អូន ! គាត់គ្រាន់តែសួរប៉ុណ្ណឹង ! គឺខ្ញុំទិញធ្វើក្រសាំងបុកផ្ញើទៅបងស្រីខ្ញុំនៅបរទេស.....ស្អែកបើមាន មីងយកមកចុះ ! ខ្ញុំទិញទាំងអស់ទៀតណា !

សាមិត្តអរកខិបកខុប រួចឆ្លើយ ចាស !...ចាស !...យ៉ាងញាប់មាត់ ។

ពេលអ្នកទិញដើរចេញផុតទៅ សាមិត្តរាប់ប្រាក់ដាក់ហោប៉ៅ រួចងាកទៅនិយាយខ្សឹបដាក់មីងបុល ÷

- បងបុលឃើញទេ...ការនិយាយរបស់ខ្ញុំមានឥតប្រយោជន៍ឯណា ?

- អឺ ! បងជួយអរឯង...ឯងគិតទៅផ្ទះឥឡូវឬ ?

- ខ្ញុំនៅជួយលក់បងសិន...ចាំបងលក់អស់ សឹមយើងទៅទាំងអស់គ្នា ។

ថ្ងៃជិតត្រង់ ម៉ោងប្រហែលជា ៩ប់ ទើបមីងបុលលក់ត្រកួន និង ស្លឹកអំពិលអស់ ។ អ្នកទាំងពីរបានប្រាក់ ឆ្មៀតទិញអង្ករពីរគីឡូ ត្រសក់ត្រាំទឹកផ្អក ពីររយរៀល និងកំពិសពីររយរៀល យកទៅបុកជាមួយក្តិបអំពិល ។ បន្ទាប់មកអ្នកទាំងពីរក៏ជិះម៉ូតូឌុបត្រឡប់មកលំនៅដ្ឋានវិញដែលឋិតនៅទំនប់បឹងទំពុន ក្បែរម៉ាស៊ីនបូមទឹកស្អុយ ជិតក្បាលថ្នល់ ។ ម៉ូតូឌុបបានដឹកស្ត្រីទាំងពីរ មកដល់ខ្ទមតូចមួយ ដែលទ្រដោយសសរតូចៗ ប៉ុនកំភួនជើង លើកខ្ពស់ស្មើនឹងថ្នល់ទំនប់ ។ នៅខាងក្នុងទំនប់នេះ ត្រកួនឈ្នក់ទឹកថ្នោសៗជាច្រើនដាំជារងជាជួរ ។ ម្ចាស់កម្មសិទ្ធិនិមួយៗដោតឈើតម្រុយជាសញ្ញាសម្គាល់រៀងៗខ្លួន ។ កូនទូកតូចៗខ្លះចតនៅក្រោមផ្ទះ ទុកសម្រាប់បេះត្រកួន ។

មីងបុល និង សាមិត្តមកដល់ផ្ទះហើយ អ្នកទាំងពីរដើរសួតាមស្ពានឈើ តម្រង់


www.elibraryofcambodia.org

ចុងចែង ព្រមទាំងមានរចនាបថនាសម័យនោះ ។ ផ្ទះខ្លះគ្មានរានហាលទេ ដែលគេហៅថា ផ្ទះប៉ិត របៀបខ្លះទៀតជារបៀបផ្ទះកន្តាំង ។ គេអាចសន្និដ្ឋានថាជាផ្ទះពីដើមដែរ គឺ ម៉្យាងដោយសារសាច់ក្តារក៏មានភាពចំណាស់ដោយកាលវេលា ។

ជនកាច់ចង្កូតរថយន្ត សង្កេតឃើញម្នាក់ៗស្ងាត់មាត់ អ្នកក៏បើកវិទ្យុស្តាប់ឮនារី អ្នកប្រកាសកម្មវិធីនិយាយថា ÷

- បន្ទាប់ពីការផ្សាយតន្ត្រីសម័យ សូមអស់លោក-លោកស្រី-នាងកញ្ញា -មេត្តា ស្តាប់ការផ្សាយពីប្រវត្តិសាស្ត្រកម្ពុជា...

គ្រាន់តែផ្សាយត្រឹមពាក្យកម្ពុជា នាងដារីឃាត់ឱ្យជនបិទវិទ្យុភ្លាម ប៉ុន្តែត្រូវ ហ្វេដេរ៉ូ ឃាត់ ។ ការផ្សាយពីប្រវត្តិសាស្ត្របានបន្តទៅទៀត ។ ដារី ឆ្លើយបញ្ជាក់ ÷

- ខ្ញុំចូលចិត្តស្តាប់ណាស់ ពីប្រវត្តិសាស្ត្រនេះ តែខ្ញុំខ្លាចក្រែងលោក (សំដៅ ហ្វេដេរ៉ូ) មិនចូលចិត្ត ។

- ខ្ញុំចូលចិត្តណាស់ ! (ហ្វេដេរ៉ូឆ្លើយ) ពីព្រោះខ្ញុំរៀនខាងប្រវត្តិសាស្ត្រនេះ ជាពិសេសខ្ញុំរៀនខាងប្រវត្តិសាស្ត្រនៅអាស៊ីអគ្នេយ៍នេះឯង ។ នាងដឹងទេថាប្រទេស កម្ពុជា នៅ ស.ត ទី ១៣ ក្នុងរាជ្យស្តេចជ័យវរ្ម័នទី ៧ មានទំហំធំណាស់ គឺខាងកើត ទល់ចម្ប៉ា ខាងលិចទល់ភូមា ខាងជើងទល់ចិន ខាងត្បូងទល់សមុទ្រ ។ កាលណោះគេ ហៅប្រទេសកម្ពុជាថា : អាណាចក្រខ្មែរ ។ ខ្មែរមានឥទ្ធិពលខ្លាំងពូកែរបៀបនេះ ទើប អាចកសាងប្រាសាទអង្គរដ៏ធំសម្បើមនេះបាន ។

ហ្វេដេរ៉ូ នៅស្ងៀមឈឹងមួយសន្ទុះ ហាក់ដូចមានហេតុការណ៍អ្វីកើតឡើង រួច ទើបហ្វេដេរ៉ូបន្តទៀត...

- យី !...គេសង់ពីអង្កាល់ហ្ន៎ ! ផុសពីចុងព្រឹក្សារបៀបនេះ ដូចប្រាសាទអង្គរ បេះបិទតែម្តង...

ទាំងអស់គ្នាសម្លឹងតាមសំដីហ្វេដេរ៉ូ ក៏ឃើញកំពូលប្រាសាទភ្នំរាប លេចត្រដែត


www.elibraryofcambodia.org

ឡើង ដែលដូចបេះបិទនឹងកំពូលប្រាសាទអង្គរវត្ត គ្រាន់តែតម្លៃស្នាដៃខុសគ្នាត្រង់ មួយសាងនៅ ស.ត ទី ១២ ធ្វើអំពីថ្មភក់ ឯមួយទៀតសាងនៅឆ្នាំ ១៩៥៨ ធ្វើអំពីស៊ីម៉ង់ត៍ ។ ប្រាសាទក្រោយនេះ ប្រជាជនសាមញ្ញជាអ្នកផ្ដើមសាងសង់សម្រាប់ទុកតម្កល់ព្រះពុទ្ធរូប ។ ចម្លាក់នៅតាមជញ្ជាំង សុទ្ធតែរូបអប្សរាជាក្បាច់ក្រឡោតទាប ។ នៅតាមបោជាងមានចម្លាក់សូនរូបរឿង រាមកេរ្តិ៍ យ៉ាងរស់រវើក ។

ខ្យល់បក់រំភើយ នាំឱ្យអ្នកកំសាន្តទីនេះទាំងប៉ុន្មាន ធូរស្រាលអារម្មណ៍ ។ ទេសចរទាំងបួនប្រាណ នាំគ្នាឈរគយគន់ពុំឆ្អែតឆ្អន់សោះ នូវទឹកដីនៃរាជធានីកាលពីអតីតកាល ។ បន្ទាប់មកទៀតគេនាំគ្នាឡើងភ្នំប្រសិទ្ធិ៍ ទៅទស្សនាព្រះចូលនិព្វាន ដែលមានបណ្ដោយប្រវែងប្រហែល ដប់ម៉ែត្រ ។ នាង រ៉ាវិន និងនាង ដារី នាំគ្នាអង្គុយបត់ជើង ដៃផ្គុំប្រណម្យ ហើយឧទ្ទិសខ្សឹបៗបន់ស្រន់ពីសេចក្ដីបំណងប្រាថ្នារៀងៗខ្លួន ។ ដារី ងាកមកនិយាយខ្សឹបៗសួររ៉ាវិន ÷

- ឯងប្រាថ្នាយ៉ាងណាដែរ រ៉ាវិន ?

រ៉ាវិន មិនឆ្លើយនឹងសំនួរ ដារី តែនាងបែរជាសួរ ដារី វិញម្ដង ÷

- ចុះដារី ឯងបន់សុំអ្វីដែរ ?

- គឺសុំលុយណា៎ !

រ៉ាវិន ឮចម្លើយរបៀបនេះ ធ្វើឱ្យគេអស់សំណើច រួចនិយាយបន្តរតាមក្រោយចម្លើយ ដារី :

- ព្រះមានលុយឯណាឱ្យឯង... មានតែក្នុងកែសពុទ្ធបូជា... បើចង់បានលុយអីចឹង ម៉េចមិនសុំបងហ្វេដេរ៉ូឯងទៅ ក្រែងសង្ឃឹមខ្លះ !

ដារី ឮ រ៉ាវិន និយាយដូច្នេះ ក៏អត់ទ្រាំសើចមិនបាន រួចនាងយកដៃគក់ រ៉ាវិន ហើយឆ្លើយរបៀបទាល់ច្រក :

- មិនដឹងជាស្អីទេ រ៉ាវិន ! ប្រញាប់តែដេញទាន់ជាន់កែងគ្នា ! គ្នាដូចជាអៀន



www.elibraryofcambodia.org

នឹងឯងណាស់ !

- អៀននឹងគ្នាធ្វើអី ! បើគ្នាក៏បន់ឱ្យមានទ្រព្យដូចឯងអីចឹងដែរ !

អ្នកទាំងពីរសើចសប្បាយនឹងចិត្តគំនិតដូចគ្នា ។ ឃើញដូច្នេះជន ដែលទើបដើរមកពីមើលទឹកន្លែងផ្សេងៗ ក៏សួរទៅនារីទាំងពីរ ÷

- រ៉ាវិន និង ដារី មានរឿងអ្វីហ្នឹង បានជាសប្បាយម្ល៉េះ ?

រ៉ាវិន និយាយទាំងនៅសើច ÷

- ដារី សុំលុយព្រះ... ហើយខ្ញុំថាយកទៅ នៅក្នុងកែសនោះ !

រ៉ាវិននិយាយផង ចង្អុលទៅកែសពុទ្ធបូជាផង ធ្វើឱ្យជនអស់សំណើចដែរ រួចជននិយាយរង៉ូវៗតែម្នាក់ឯង ÷

- ព្រះអើយ ! ហេតុអ្វីក៏មិនព្រមយល់ហ្ន៎ !... ថាលុយបានមកពីណា ?

ដារីឮដូច្នោះ ក៏រហ័សឆ្លើយ ÷

- ខ្ញុំដឹងហើយ ថាបានមកពីរក... ហើយខ្ញុំខំរករហូតលក់ទាំង...

ដារីឈប់និយាយ ហាក់ដូចជាពាក្យបន្តទៅទៀតពិបាកនិយាយ ក៏ឈប់ទ្រឹងនាងបន្តប្រយោគ ÷

-...ក៏នៅតែមិនគ្រប់សម្រាប់សេចក្តីត្រូវការដ៏ធំធេងទៀត ។ ឱ ! ជីវិតអើយ ! ខ្ញុំមើលទៅដូចជាស្មុគស្មាញខ្លាំងណាស់... ព្រះអង្គអើយ ! សូមលោកជួយដោះស្រាយខ្ញុំម្ចាស់ផង !... ខ្ញុំម្ចាស់កើតមកក្នុងជាតិនេះ ហាក់ដូចជាទាល់តម្រិះហើយ ដូច្នេះមានតែខ្ញុំម្ចាស់សង្ឃឹមលើការបន់ស្រន់ទៅចុះ !

- អីចឹង ដារី បន់ស្រន់ទៅ ! ចាំខ្ញុំ (ជន) ពាំនាំពាក្យទៅថ្វាយព្រះ សូមឱ្យលោកជួយដារី ផង !...

ដារីបន្តសំដី ÷

- លោកជន ! តើខ្ញុំជាមនុស្សលោភលន់ទេ ...បើនៅក្រោយខ្នងខ្ញុំ (បានសេចក្តី


www.elibraryofcambodia.org

ថានៅក្នុងបន្ទុករបស់ដារី ) ខ្ញុំមានប្អូនប្រុស ប្អូនស្រីចំនួនប្រាំនាក់ទៀត នៅកំពុងពេញរៀនសូត្រ...

ដារីអួលដើមក រកនិយាយទៀតមិនរួច ក៏ផ្អាកបន្តិចសិន... លុះបែបរសាយធូរក្នុងចិត្តបន្តិច នាងក៏បន្តសំដី ÷

- កុំអីខ្ញុំត្រូវបានរៀនសូត្រវែងឆ្ងាយតទៅទៀតហើយ... កុំដោយសារតែ ឪពុកម្ដាយខ្ញុំមានគ្រោះថ្នាក់ចរាចរ លោកទាំងពីរជិះម៉ូតូពេលលោកគេចជង្ហុក ស្រាប់តែមានឡានតូចមួយគ្រឿងបរយ៉ាងលឿនមកបុកលោកឱ្យដួល ហើយស្លាប់ភ្លាមមួយរំពេចនៅនឹងកន្លែងតែម្ដង ។ ខ្ញុំនៅចាំច្បាស់ណាស់ថា ពេលឪពុក ម្ដាយខ្ញុំមានគ្រោះថ្នាក់ គឺពេលយប់ គេដាក់សពលោកទាំងពីរសម្រាន្តទន្ទឹមគ្នានៅកន្លែងកើតហេតុ ។ គេអុជចង្កៀងតូចមួយនៅចុងជើងសពយ៉ាងគួរឱ្យអាណោចអាធម្ម ព្រោះយប់ហើយ គេក៏មិនដឹងជាទៅរកសាច់ញាតិសពនៅឯណា...

ដារី ងាកមករកជន រួចពោលបន្ត ÷

- លោកសាកល្បងគិតលមើល ! ថាតើពេលខ្ញុំបានទទួលដំណឹងថា ឪពុក ម្ដាយខ្ញុំស្លាប់យ៉ាងតក់ក្រហល់ដោយឥតព្រាងទុក តើកូនៗនោះវាតក់ស្លុតរន្ធត់ប៉ុណ្ណាទៅ ? ខ្ញុំដែលជាកូនច្បង ស្រែកទ្រហោយំតែមួយរំពេច ស្រាប់តែបាត់ព្រលឹងមិនដឹងជារលត់ពីកាលណាពេលដឹងស្មារតីឡើងវិញ ឮអាចារ្យសូត្រអភិធម្មយ៉ាងលន្លង់លន្លោច ។ ខ្ញុំឮសំឡេងអ្នកជិតខាងបន្ទឺក្បែរត្រចៀកខ្ញុំ តែសំឡេងនោះហាក់ដូចអ្នកម្ដាយខ្ញុំបាននិយាយថា : ដារី ! ឯងពង្រឹងស្មារតីឱ្យមែនទែន !...អត់ពីពុក ម៉ែហើយ ប្អូនៗរំពឹងលើឯងម្នាក់ !... រឹងប៉ឹងឡើងដារី !...រឹងប៉ឹងឡើងដារី !

ពេលនោះអាចារ្យស្មូតដល់ពាក្យថា មានរូបមានទុក្ខ... មនុស្សលោកគ្រប់រូបគ្មានអ្នកណាម្នាក់ចៀសផុតពីការស្លាប់ទេ ដូច្នេះមនុស្សគ្រប់រូបត្រូវតែទទួលដឹងឮជាបណ្ដើៗ ... កុំគប្បីធ្វើពុតជាមិនឮពាក្យទូន្មានទាំងនេះ គ្រាន់តែគ្មានអ្នកណាដឹងមុនន្ធូវ


www.elibraryofcambodia.org

ថ្ងៃស្លាប់របស់ខ្លួនឡើយ ។

ដារី បន្តសំដីដោយក្តីក្តាហាន ÷

- ខ្ញុំត្រវែងសៀវភៅទៅរៀនជញ្ជាំងទាំងក្តីសោកស្តាយហួសនិស្ស័យ ប៉ុន្តែធ្វើម្តេចពេលនេះ សភាពការណ៍វាបង្ខំខ្ញុំឱ្យធ្វើដូច្នេះ ខ្ញុំគ្មានមីង មា ឯណាច្រើន បើគាត់ស្លាប់នៅសម័យប៉ុល ពត អស់ហើយ គឺនៅសល់តែមីងខាងម្តាយម្នាក់តែប៉ុណ្ណោះ ។ គាត់មិនមាំទាំទេ ប៉ុន្តែគាត់ធ្លាប់រស់នៅជាមួយខ្ញុំយូរហើយ ខ្ញុំក៏មិនអាចបោះបង់គាត់ចោលឡើយ គាត់ក៏បន្តរស់នៅជាមួយខ្ញុំតទៅទៀត ។ ពេលនោះខ្ញុំកណ្តៀតកញ្ច្រែងបន្តវេនលក់ដូរជំនួសម្តាយខ្ញុំម្តង ដើម្បីចិញ្ចឹមប្អូន១ និងម្តាយមីងម្នាក់នេះទៀត ។ ប៉ុន្តែ... ប៉ុន្តែ...

ដារីនិយាយត្រឹមតែប៉ុណ្ណោះ ក៏នៅស្ងៀមឈឹង ហាក់ដូចជានឹកស្តាយពាក្យរបស់ខ្លួនដែលរៀបរាប់កន្លងមក នាំឱ្យរំខានចិត្តអ្នកដទៃទៀតសោះ ។ ដារីពង្វេះពង្វាងពាក្យរបស់ខ្លួន ÷

- ទៅ !...យើង !...ទៅ !...ល្មមទៅថ្វាយបង្គំព្រះអង្គនៅប្រាង្គខាងលើហើយ ។

ថាហើយ ដារី ក៏ងើបឡើងដើរទៅមុន ។ ចំណែកឯរ៉ាវិន និង ជន ងាកមើលមុខគ្នា ធ្វើភ្នែកឡឹនឡង់ រកគិតមិនយល់ពីជម្រៅចិត្តដារី ដែលមុននោះបន្តិច ហាក់បីដូចជាមានទុក្ខធ្ងន់ធ្ងរ រួចប្រែក្រឡាស់ធ្វើបែបវាហីទៅវិញ ។

ជន ងាកមកមើលមុខ រ៉ាវិន ជាថ្មី រួចនាយសួរស្ទាបស្ទង់ចិត្ត ÷

- រ៉ាវិន អាណិតដារីទេ ?

រ៉ាវិនមិនឆ្លើយ គ្រាន់តែសំដែងទឹកមុខស្រងូតស្រងាត់ ហើយងក់ក្បាលក្នុងន័យថា : អាណិត ។ នាងនឹកទៀតថា : " ឱ ! ដារីអើយ ! រឿងឯងកម្សត់ប្រាកដមែនហើយ !...ប៉ុន្តែរឿងខ្ញុំក៏មិនខុសប្លែកឆ្ងាយពីឯងប៉ុន្មានឡើយ... តែធ្វើដូចម្តេចទៅហ្ន៎ !... ខ្ញុំគ្មានលទ្ធភាពឯណាជួយឯងបាន បើជួយខ្លួនឯងជួយមិនទាំងរួចផង " ។ កំពុងតែស្ទុងអារម្មណ៍គិតរវើរវាយដល់អនាគតដ៏ខ្មៅងងឹតរបស់ខ្លួនដែលឋិតនៅវែងឆ្ងាយ ធ្វើឱ្យរ៉ាវិន


www.elibraryofcambodia.org

ជាន់កាំជណ្ដើរខុស បណ្ដាលឱ្យដួលទាំងជំហរបោកក្បាលនឹងកាំជណ្ដើរ រួចរមៀលខ្លួនពីរ-បីកាំបន្តទៀត ទម្រាំជនងាកមកទប់ទាន់ ។ វ៉ារិនសន្លប់ឥតដឹងខ្លួន ឈាមហូររហាច ទទឹកសក់ជោក ។ ជន លើកវ៉ារិន បីយកមកដាក់ផ្ដេកនៅលើរានអ្នកលក់ដូរ រួចក៏ជូតឈាម ។ ចំណែកឯ ដារី ដែលកំពុងតែឡើងទៅកំពូលភ្នំ ពេលងាកមកក្រោមឃើញវ៉ារិន ដួលរមៀលខ្លួនដូច្នេះ ក៏រហ័សចុះត្រឡប់មករកវ៉ារិន រួចស្ទុះឡើងទៅលើវិញដើម្បីប្រាប់ហ្វេដេរ៉ូ ÷

- វ៉ារិន... ដួល... មានរបួស... នៅឯក្រោមឯណោះ !

ថាហើយ ដារី លើកដៃចង្អុលតម្រង់មកកន្លែងវ៉ារិនសម្រាក ។ ទេសចរណ៍ណាដែលបានឃើញព្រឹត្តិការណ៍នេះ ក៏នាំគ្នាចោមរោមមើលវ៉ារិនដែរ ។ អ្នកខ្លះឃើញវ៉ារិន មិនថែមទាំងនិយាយថាគួរឱ្យអាណិតប៉ុណ្ណោះទេ គេថែមទាំងនិយាយថា នាងនេះស្អាតណាស់ ព្រមទាំងជញ្ជក់មាត់សរសើរហើយសរសើរទៀតផង ។ ជន ឮដូច្នេះ បែរជានឹកហួសចិត្តទៅវិញ ។ ជន បានសុំក្រូចឆ្មារអ្នកលក់ពងទាស្ងោរ យកមកច្របាច់សម្រក់ទឹកលើថ្ងាដក់ចំនួនប៉ុនមេដៃ រួចយកមកញីនៅចំមុខរបួសដែលមើលឃើញស្នាមរយះប្រហែលជាពីរសង់ទីម៉ែត្រ ។ អ្នកកំលោះសួរទៅអ្នកលក់ដូរ ÷

- មីងមានថ្នាំបិទដំបៅទេ ?

- គ្មានទេលោកក្មួយអើយ !

ពេលនោះ វ៉ារិន ប្រែដឹងស្មារតីឡើងវិញ ។ នាងបើកភ្នែកឡើង បាក់ដូចជាឆ្ងល់នឹងមនុស្សដែលចោមរោមច្រើន ក៏ធ្វើភ្នែកឡឹនឡង់ ហើយនិយាយរអ៊ូតិចៗថា :

- មានរឿងអីកើតឡើងហ្នឹង !

ដារីដែលនៅក្បែរនេះដែរ ក៏ឆ្លើយតប ÷

- អូ ! ឯងអត់ដឹងថាឯងដួលទេឬ ?

ហ្វេដេរ៉ូនិយាយ ÷


www.elibraryofcambodia.org

- ទៅ ! យើងត្រឡប់ទៅវិញ !

ជនតប ÷

- ឈប់សិន ! ខ្ញុំលាបថ្នាំឱ្យរ៉ាវិនសិន !

ថាហើយជនក៏ទទួលយកថ្នាំក្រហមពីដៃដារី ដែលនាងបានរត់ទៅរកសុំព្រះសង្ឃមុននេះបន្តិច ។ លាបបណ្ដើរ ជនសួររ៉ាវិនបណ្ដើរ ÷

- រ៉ាវិន អាចដើរខ្លួនឯងបានទេ?

- បាន !

ជនងាកទៅរកហ្វេដេរ៉ូ ÷

- លោកចាំបន្តិចសិនទៅ ! ឱ្យរ៉ាវិនស្រួលខ្លួនសិន សឹមត្រឡប់ទៅវិញ ។

ដារីនិយាយតម្អូញ ÷

- ឱ ! ព្រះជាម្ចាស់អើយ ! ហេតុអ្វីក៏ធ្វើបាបតែអ្នកកម្សត់ដូច្នេះទៅវិញ !

ឮដារីពោលដល់ពាក្យកម្សត់ ស្រាប់តែរ៉ាវិននឹកឃើញបងប្រុសដែលបានស្លាប់បាត់ទៅហើយ ក៏យំបង្ហូរទឹកភ្នែកសស្រាក់ដោយមិនដឹងខ្លួន ។ ជនដែលនៅក្បែរនោះឃើញដូច្នេះ ក៏និយាយលួងលោម ÷

- រ៉ាវិន ឈឺខ្លាំងឬ?

រ៉ាវិនឆ្លើយរបៀបអណ្ដឹតអណ្ដក អួលដើមក ស្ទើរតែរកនិយាយមិនរួច ÷

- ឈឺខ្លួនយ៉ាងណា !... យ៉ាងណា... ក៏អាចទ្រាំបាន !... ប៉ុន្តែបើឈឺខាងផ្លូវចិត្តវិញនោះ... វាពិបាកទ្រាំណាស់... មែនទេបង?

ជននិយាយ ÷

- តើអ្នកណាទៅធ្វើបាបរ៉ាវិន ហ្ន៎ !

- ព្រហ្មលិខិត !...

រ៉ាវិន មិនដាក់ទោសទៅលើអ្នកណាម្នាក់ច្បាស់លាស់ទេ តែនាងបែរជាដាក់


www.elibraryofcambodia.org

ទោសទៅលើព្រហ្មលិខិតទៅវិញ ។ នាងនិយាយបន្តទៀត ÷

-...ខ្ញុំអាចទៅរួចហើយ... កុំឱ្យលោកហ្វេដេរ៉ូចាំយូរ ។

នាងបន្តនិយាយរអ៊ូៗតែម្នាក់ឯងទៀត ÷

- បន្ទាប់ពីស្នាក់នៅសណ្ឋាគារកាំបូឌីយ៉ាណាហើយ ឱ ! ជីវិតខ្ញុំអើយ !... នឹងរសាត់ទៅណាទៀត... រកប្រាកដកំណត់ច្បាស់លាស់មិនឃើញឡើយ !

ពាក្យរអ៊ូរទាំរបស់វ៉ាវិន បានរសាត់អណ្តែតទៅតាមព្រះពាយបក់ផាត់ មិនដឹងជាទៅដល់ទីណាទេ ។ វ៉ាវិនងើយមើលទៅលំហអាកាសដ៏ធំល្វឹងល្វើយ ។ ចំណេះដែលខ្លួនមានស្អុចស្អើងពេកនោះ រកគិតអ្វីមិនឃើញក្រៅពីគិតថា ទាល់តែមានប្រាក់ ទើបសម្រេចអ្វីៗបានទាំងអស់ ។ គំនិតរបស់នាងបាញ់ឆ្ពោះទៅលើប្រាក់មួយមុខប៉ុណ្ណោះ ។

- មកវ៉ាវិន ! បងជួយកាន់ដៃ ខ្លាចដួលម្តងទៀត ។

វ៉ាវិនងើបឈរឡើង ហើយដើរយ៉ាងព្រងើយហាក់ដូចជាគ្មានហេតុការណ៍អ្វីកើតឡើង ។ នាងនឹកនៅក្នុងចិត្តថា មនុស្សកំព្រាត្រូវតាំងចិត្តខិតខំស៊ូស៊ះស្វាដូច្នេះ ហើយយ៉ាងណាឱ្យកំព្រាតែកាយបានហើយ កុំឱ្យកំព្រាចិត្តទៀតនោះ វាវីតតែវីវរធំហើយ !

ចំណែក ហ្វេដេរ៉ូ វិញ ជាមនុស្សមិនសូវបានសំដីទេ គេសំដែងតែទឹកមុខញញឹមៗរួចសួរវ៉ាវិនថា ÷

- យ៉ាងម៉េចដែរ វ៉ាវិន ?

- មិនអីទេ !

នៅវេលារសៀល អ្នកទាំងអស់គ្នាក៏វិលត្រឡប់មកភ្នំពេញវិញ ។ ជន បើកឡានជូន វ៉ាវិន និង ដារី ទៅកាន់គេហដ្ឋានរបស់នាង ។ អ្នកបានដឹងថា វ៉ាវិន មកស្នាក់អាស្រ័យនៅផ្ទះដារី ដែលទីនោះមានម្តាយមីងដារីជាចាស់ទុំម្នាក់ដែរ ។

ពេលនៅក្នុងឡានតែពីរនាក់ហ្វេដេរ៉ូ ជនសួរថា ÷

- លោកពេញចិត្តដារីទេ ?


www.elibraryofcambodia.org

ហ្សេដៅរ៉ូ ងក់ក្បាល រួចញញឹមពព្រាយ ហើយនិយាយប្រាប់ជនថា ÷

- ខ្ញុំនឹងឱ្យលោកស្រីជួយទាក់ទងនាងឱ្យខ្ញុំ ។

- ធ្វើរបៀបណាទៅ?

- គឺធ្វើតាមប្រពៃណីជាតិខ្មែរណា៎!

ជនបន្ទឺដោយត្រេកអរ ÷

- តែប៉ុណ្ណេះជារីមានអនាគតហើយ... យប់នេះលោកទៅរង្គសាលនោះទៀតទេ?

ហ្សេដៅរ៉ូឆ្លើយយ៉ាងញាប់មាត់ ÷

- ទៅ !.. ទៅ !...ទៅជាមួយឯង ហើយឯងក៏បានជួបស្រីតូច រ៉ាវិនរបស់ឯងដែរ មែនទេ?

អ្នកទាំងពីរសើចមើលមុខគ្នា ហាក់ដូចជាយល់ជម្រៅចិត្តគ្នាទៅវិញទៅមក ។

* * * * *



www.elibraryofcambodia.org

# ១០

# សុភមង្គល

ថ្ងៃនេះនៅផ្ទះសាមិត្តឯទំនប់បឹងទំពុននាពេលថ្ងៃត្រង់ មានការរៀបចំម្ហូបអាហារដើម្បីបរិភោគដូចសព្វដង ។ មីងបុលលើករឿងមកនិយាយមុនគេ ÷

- សាមិត្ត ស្អែកបងគិតត្រឡប់ទៅវវៀងវិញហើយ !

សាមិត្តដែលហៀបតែនឹងហួបបាយទៅហើយនោះ ក៏កាន់ស្លាបព្រាផ្អឹងនៅនឹងដៃ រួចលាន់មាត់ : អឺស ! ហើយចាប់ផ្ដើមសំណួរ ÷

- បងប្រញាប់ទៅម្ល៉េះ ! បើរកកូនមិនទាន់ឃើញផង ?

- បើរង់ចាំរកកូនឃើញមិនដឹងថ្ងៃណាទៅ !... នៅដេកស៊ីផ្ទះប្អូនដូច្នេះមិនកើតទេ !... ណាមួយប្អូនត្រូវចិញ្ចឹមបងស្រីមួយទាំងមូលទៀត... ការចិញ្ចឹមមនុស្សនេះណា៎ ...វាមិនងាយស្រួលទេ !

សាមិត្តលើកឡើង ÷

- បងបុលគិតមើល៍ !... បងមួនបងស្រីខ្ញុំនេះ កើតមកល្អជាដូចគេដូចឯង មានគ្រួសារ មានប្ដី មានកូនដូចគេដូចឯង... អាចោរជង្ហុកសំបុកមាន់នោះណា៎ ! វាធ្វើឱ្យបងមួនក្លាយជាមនុស្សគ ឯប្ដីនិងកូនក៏ស្លាប់អស់គ្មានសល់ម្នាក់ ។ ផ្ទះដែលគាត់នៅជាមួយបងថ្លៃគាត់ ក៏គេរំលោភយកថាជារបស់គេ... ពីព្រោះតែគាត់បាត់បង់សំដីហ្នឹងណា៎ ! មានមាត់ឯណានិយាយតវ៉ា... សមឥឡូវគេស៊ីលុយស៊ីកាក់ទៀត មានផ្លូវឯណាឈ្នះនោះ !... ល្ហើយឱ្យវាយកទៅចុះ.... ងាប់ទៅក៏មិនទូលយកទៅផងដែរ មិនអ៊ីចឹងឬបងបុល ?



www.elibraryofcambodia.org

ទៅខ្ទមរបស់ខ្លួន ។ ខ្ទមនេះមានរានហាលប្រហែលជាមួយម៉ែត្រទទឹង លំអរដោយរុក្ខជាតិដែលម្ចាស់ផ្ទះនេះបានអារចុងធ្វើពីប្លាស្ទិកដាក់ដី ហើយដាំផ្កា ។ ឯផ្កាខ្លះទៀតដាំក្នុងក្រឡកំបែក ព្រមទាំងមានជីរ ស្លឹកគ្រៃ ដាំក្នុងចានក្បាំដែកដែលបាក់បែកធ្លុះធ្លាយប្រើការលែងកើត ។ សាមិត្តឆ្លៃប្រឌិតរបស់អស់ទាំងនេះ ឱ្យទៅជាមានប្រយោជន៍សម្រាប់ការដាំដុះទៅវិញ ។

សាមិត្តលូកដៃបើកគន្លឹះទ្វារ ហើយចូលទៅឃើញសាមួននៅក្នុងផ្ទះ ÷

- បងមួនដាំបាយហើយឬនៅ ?

រអ៊ូបណ្ដើរ សាមិត្តធ្វើដៃធ្វើជើងបណ្ដើរ ។ ស្ត្រីឈ្មោះសាមួនមិនឆ្លើយតប គ្រាន់តែងក់ក្បាលប៉ផ្ងក់ដូចសត្វបង្កួយ បញ្ជាក់ថាអ្វីដែលសាមិត្តធ្វើសញ្ញាអំបាញ់មិញនោះ គាត់យល់អស់ហើយ ។ សាមិត្តបន្លឺសំឡេងបន្ត ÷

- បងបុលអើយ ! ថ្ងៃនេះខ្ញុំដូចជាឃ្លានបាយណាស់ !

មីងបុលបុកកំពិស និងក្ដិបអំពិលបន្ថែមលើសម្លម្ជូរត្រកួនដែលសាមួនបានរៀបចំរួចស្រេចហើយ ។ ខ្ទមនេះបែរមុខទៅទិសខាងជើងទៅរកថ្នល់ ដូច្នេះសាមិត្តចូលចិត្តបិទទ្វារចូលណាស់ កាលណាតែចេញចូលហើយ គាត់តែងតែបិទទ្វារនេះជាប់ ពីព្រោះថ្នល់ទំនប់មិនទាន់ចាក់កៅស៊ូ ម៉្លោះហើយកាលណាមានឡាន ម៉ូតូ ធ្វើចរាចរម្ដងៗ ធូលីនឹងហុយសំពោងឡើងជាប់មិនដាច់ លុះត្រាតែមានភ្លៀងទើបមិនមានធូលីហុយ ប៉ុន្តែផ្លូវបែរទៅជាភក់ប៉ប៉ិចប៉ប៉ាច់ ដោយទឹកភ្លៀងទៅវិញ ។

សមាជិកនៅក្នុងផ្ទះនេះ មានគ្នាបីនាក់ជាស្ត្រីភេទទាំងអស់ ។ ប៉ុន្តែសាមួនមិនចេះនិយាយទេ ។

ខ្យល់ទិសទក្សិណបក់ចូលមកបណ្ដាលឱ្យល្ហើយត្រសៀកៗធូរអារម្មណ៍ បាត់អស់ការហួងសៅទាំងឡាយ ។ សាមួនរៀបចំដួសដោះបាយសម្ល ព្រមទាំងម្ហូបបន្ថែមមានល្ហុងត្រាំផ្អក និងបុកអំពិលខ្ចីដាក់ម្ទេសហឹរៗ ដែលមីងបុលរៀបចំមុននេះបន្តិច ។ ស្ត្រី


www.elibraryofcambodia.org

- ហ្នឹងហើយ !...ប្អូនថាអាចោរជង្ហុកសំបុកមាន់ អ្នកណាគេហ្នឹង ! បងមិនយល់ទេ?

- ឱ ! បងមិនយល់ឬ ? គឺផ្លូវជង្ហុកធំៗដូចសំបុកមាន់នោះ ពេលឡានគាត់ធ្លាក់ជង្ហុក ស្រាប់តែមានឡានធំបរពីក្រោយមកបុកឡានគាត់ ឱ្យស្លាប់ទាំងគ្រួសារ នៅសល់តែបងមួនម្នាក់ខ្ទាតចេញពីឡាន ដល់គាត់បានជា ស្រាប់តែលែងនិយាយរួចតែម្តង ។ មិនបណ្តាលមកពីអាជង្ហុកសំបុកមាន់ហ្នឹងឬ?

មីងបុល មិននិយាយអ្វីតទៅទៀត គ្រាន់តែរអ៊ូ ÷

- ហ៊ឺ ! គិតទៅជីវិតគ្រួសារសាមួន នៅត្រឹមជង្ហុកសំបុកមាន់ជាអ្នកសម្រេចសោះ!

មីងបុល និងសាមិត្ត និយាយពីបងមួន ដែលគិតតែពីបរិភោគបាយ ។ យូរៗគាត់ងើបមើលអ្នកទាំងពីរម្តង ឃើញគេនៅតែនិយាយគ្នា គាត់ក៏ធ្វើកាយវិការយកដៃចង្អុលមាត់ ថាឱ្យញ៉ាំបាយទៅ ។

មីងបុលបន្តសំដី ÷

- រសៀលថ្ងៃនេះបងគិតទៅមើលផ្ទះចាស់បងមួយភ្លែត ។

បន្ទាប់មកគេទាំងអស់គ្នា ក៏បរិភោគបាយដោយស្ងៀមស្ងាត់ ។

---

មីងបុលធ្វើដំណើរដោយថ្មើរជើងតាមបណ្តោយមហាវិថីព្រះមុនីវង្ស ពីជើងមកត្បូង ។ ភ្នែកគាត់គយគន់មើលទិដ្ឋភាពទូទៅនៃមហាវិថីនេះយ៉ាងយកចិត្តទុកដាក់ ។ គាត់ក៏ធ្វើការប្រៀបធៀបតែម្នាក់ឯង រវាងមុនឆ្នាំ ១៩៧៥ ហើយនិងក្រោយ ឆ្នាំ ១៩៧៥ ។

មុនឆ្នាំ ១៩៧៥ ជំនាន់របបសង្គមរាស្ត្រនិយម គេហៅប្រទេសកម្ពុជាថាជាគ្រាប់គុជនៃអាស៊ីអគ្នេយ៍ ។ លុះដល់ក្រោយៗមក ស្រាប់តែបាត់រហស្សនាមគ្រាប់គុជនោះទៅ ។ រឿងនេះគួរបន្ទោសអ្នកមិនហៅគ្រាប់គុជ ឬក៏បន្ទោសកម្ពុជាខ្លួនឯងដែលមិន


www.elibraryofcambodia.org

ព្រមធ្វើឱ្យល្អ ដើម្បីនៅរក្សាឈ្មោះនោះ សម្រាប់គេហៅតទៅទៀត !

សំឡេងកញ្ចែ " ច្រេក១ " ផ្ទុំរន្ថើនឡើង ដូចជាធ្វើមជង្គក់នៃមនុស្សដែលហៀបតែនឹងដាច់ខ្យល់ស្លាប់ ។ មីងបុល ភ្ញាក់ពីការត្រិះរិះពិចារណាមុននេះបន្តិច រួចរេកែរភ្នែកតាមសម្លឹងទៅឃើញបុរសចំណាស់ម្នាក់ បើកទោចក្រយានយន្តមកឈប់នៅចំកណ្ដាលទ្រូងផ្លូវ ចំណែកយានយន្តឯទៀតបានឈប់នៅពីក្រោយគំនូសឆ្នូត១ ដែលទុកសម្រាប់ឱ្យអ្នកដើរឆ្លងកាត់ ។ ម្ចាស់យានយន្តនោះងាកមើលទៅតម្រួតចរាចរ ដែលកំពុងផ្លុំកញ្ចែឯដៃលើកឡើងបក់រវិច១ជាសញ្ញាហៅទៅបុរសចំណាស់ដែល ឈប់នៅកណ្ដាលផ្លូវនោះឱ្យងាកមើលភ្លើងសញ្ញាចរាចរដែលមានពណ៌ក្រហម ហាក់ដូចជាមានន័យថា : គឺអ្នកឯងហ្នឹងហើយដែលយើងផ្លុំកញ្ចែឱ្យឈប់ ហេតុអ្វីក៏នៅរេរា អល់អែកដល់ណាទៀត ? បើដឹងខ្លួនខុសហើយ ម៉េចក៏មិនចូលមកជិតយើងដើម្បីទទួលការពិន័យ ។

បុរសនោះចុះពីលើយានយន្ត ពន្លត់ម៉ាស៊ីន ហើយដោះលេខ រួចដឹកចូលទៅជិតតម្រួត ។ តម្រួតយកកញ្ចែចេញពីមាត់ ហើយនិយាយទៅកាន់ម្ចាស់យានយន្ត ឯដៃដែលកាន់កញ្ចែយកមកជុះខាត់ឱ្យរលោង ។ បុរសម្ចាស់ទោចក្រយានរាងចំណាស់ ដូចជាគ្មានឃើញនិយាយស្ដីអ្វីទេ ក្រៅពីងក់ក្បាលបំផ្ទក់ទទួលយល់ព្រមគ្រប់យ៉ាងទាំងអស់ ។ បន្ទាប់មកក្បាលគាត់ឈប់ងក់ តែដៃគាត់លូកហោប៉ៅយកអ្វីចេញមកហើយហុចទៅនាយតម្រួតដោយដៃទាំងពីរ ព្រមទាំងធ្វើកាយវិការឱនលំទោនដូចអ្នកសុំទាន ។

នាយតម្រួតដែលមានឯកសណ្ឋានខោពណ៌ខៀវចាស់ អាវពណ៌ផ្ទៃមេឃ និងពាក់ស្បែកជើងឃ្មុបពណ៌ខ្មៅ បានប្រាក់ដាក់ហោប៉ៅភ្លែតគ្មានបង្អែបង្អង់ ហើយបន្តគ្រួតពិនិត្យទៅទៀតក្បែរកាច់ជ្រុងភ្លើងស្តុប ។

មីងបុលគិតតែម្នាក់ឯង ការដាក់ពិន័យនេះត្រឹមត្រូវហើយនូវអ្នកដែលបំពានច្បាប់ ប៉ុន្តែគាត់ឆ្ងល់ត្រង់នាយតម្រួតយកប្រាក់ដាក់ហោប៉ៅដោយមិនបានចេញប័ណ្ណពិន័យឱ្យទៅបុរសមានកំហុស ដូច្នេះប្រាក់នោះចូលហោប៉ៅនាយតម្រួត ឬក៏ចូលហិបរដ្ឋ?


www.elibraryofcambodia.org

មីងបុលដើរមកជិតនាយតម្រួត ភ្លើងក្រហមនេះភ្លែតឡើង គាត់ក៏ឈប់រង់ចាំភ្លើងខៀវ ។ ពេលនោះមីងបុលងាកមកទិសខាងកើត ផ្លូវនោះត្រង់មកចំខាងក្រោយព្រះបរមរាជវាំង ហើយគាត់ងាកទៅទិសខាងលិច ចំពហុកីឡាដ្ឋានជាតិអូឡាំពិក ។ ប៉ុន្តែគាត់ធ្វើដំណើរទៅទិសខាងត្បូងតាមបណ្ដោយផ្លូវព្រះមុនីវង្សនេះទៅវិញទេ ។

មីងបុល មើលទៅផ្លូវឃើញផ្សែងដូចចុះអ័ព្ទ ចេញពីកន្ទុយរថយន្ត និងយានយន្តគ្រប់ប្រភេទ លាយឡំនឹងសំឡេងស៊ីផ្លេលាន់ឮទ្រហឹងអឺងអាប់កងរំពង បន្លឺជ្រែងគ្នាយ៉ាងប្រញាប់ប្រញាល់ បំប៉ើងធូលីឱ្យហុយសំពោង ។ ម្ចាស់រថយន្តចុចកញ្ចក់ឱ្យចុះក្រោមដោយស្វ័យប្រវត្តិ រួចលេចមុខបុរសម្នាក់មូលក្រឡង់ ប៉ុន្តែគេធ្វើមុខក្រញេក្រញូវដោយកំហឹង ស្រែកចំទាលទៅកាន់អ្នកជាក់ត្រីចក្រយានដែលកំពុងតែបត់យានរបស់ខ្លួនទៅត្រើយម្ខាង ÷

- អាងាប់ ! ភ្នែភ្លើមិនដឹងងាប់អីចេះ...ចង់បត់ក៏លើកដៃភ្នាមបត់ភ្លែតអីចឹងមិន *ដឹងងាប់ទេឬអី !*

អ្នកជេរបានត្រឹមជេរឱ្យធូរកំហឹងនៅក្នុងចិត្ត ចំណែកឯអ្នកធ្វើអំពើខុស នៅតែប្រព្រឹត្តខុសបន្តទៅទៀតដដែល រកតែរង្វាស់មកវាស់កម្រិតក្រឹត្យក្រមមួយឱ្យបានពិតប្រាកដ ក៏នៅតែរកមិនបានដដែល ហើយខែណា ឆ្នាំណា ទៅហ្ន៎ ! ទើបឈប់មានទង្វើដូចរបៀបនេះទៀត ?

មីងបុលយកកន្សែងដៃខ្ទប់ច្រមុះដើម្បីកុំឱ្យទទួលខ្យល់អុអាប់នេះខ្លាំងពេក ឯភ្នែកចេះតែរេរំពៃរកមើលរោងចក្រទឹកក្រូច សេវ៉ែនអាប់ *(7up)* ។

- តើគេរុះរើអស់ហើយទេដឹង ? (មីងបុលគិត) ។

ពេលនេះឆ្នាំ ១៩៩៨ បើគិតពីឆ្នាំ ១៩៧៥ មកទល់ពេលនេះមានរយៈពេល ២៣ឆ្នាំហើយ អ្វីៗនាពេលនេះ មីងបុលចង់ភ្លេចអស់ទៅហើយ ។ នៅតែមួយឆ្នាំទៀត មីងបុលអាយុ ហាសិបឆ្នាំ ហើយ... គាត់មិនទាន់ទាំងបានសប្បាយឱ្យអស់ចិត្តផង ស្រាប់


www.elibraryofcambodia.org

តែធ្មេចបើក១ កន្ទះសតវត្សរ៍កន្លងផុតទៅយ៉ាងឆាប់រហ័ស ។ កំពុងតែដើរគិត ស្រីម្នាក់ស្រែកឡើង ៖

- យីស ! ឆ្កួតទេឬអី ! បានជាដើរមកបុកមនុស្សទាំងរស់អ៊ីចឹង !

មីងបុល ងាកយ៉ាងរហ័សហើយប្រញាប់និយាយ ៖

- សុំទោស ! នាង ! ខ្ញុំរវល់តែរកមើលរោងចក្រទឹកក្រូច សេវិនអាប់ *(7up)* កាលពីដើម បានជាមិនបានឃើញនាង ។

ស្រីម្នាក់ដែលមីងបុលដើរបុកអម្បាញ់មិញ មានអាយុប្រហែលជា ម្ភៃប្រាំបួន ឬ សាមសិបឆ្នាំ ។ ស្រីនោះក៏កំពុងតែឈររមើលអ្វីភាំងដែរ បានជាមិនឃើញមីងបុល ។

មីងបុល បន្តដំណើរទៅមុខដោយរអ៊ូម្នាក់ឯងដូចមនុស្សឆ្កួត ដូចស្រីនោះថាមិនខុស ៖ “ នៅជិតរោងចក្រទឹកក្រូចមានផ្ទះឈើមួយ... ឥឡូវបាត់ស្រមោលផ្ទះឈើនោះទៅហើយ...” ។ ផ្ទះឈើដែលមីងបុលត្រូវរកនោះ ជាផ្ទះថ្មនៅត្រើយខាងលិចផ្លូវ ឋិតនៅទល់មុខតែឆៀងខាងជើងរោងចក្រទឹកក្រូចនោះ ពីព្រោះជាផ្ទះរបស់គាត់កាលពីដើម ។

មីងបុល វង្វេងវង្វាន់មើលមិនចង់ស្គាល់ផ្ទះរបស់គាត់ទេ ព្រោះគេសង់បន្ថែមពីមុខ ពីក្រោយ បាត់បង់រចនាបថដើមអស់ ។ គាត់ដើររេរានៅមុខទ្វារចូល ស្របពេលដែលក្មេងប្រុសម្នាក់បើកទ្វារចេញមក ក៏វ៉ាក់នឹងគាត់ រួចសួរថា ៖

- អ៊ំរកអ្នកណាហ្នឹង ?

មីងបុលភ្ញាក់ព្រើតនឹងសំឡេងក្មេងប្រុសម្នាក់នេះ ដែលជិះកង់ចេញមក ។ គាត់ឆ្មៀតមើលតាមទ្វារនោះ ឃើញកូនក្មេងម្នាក់អាយុប្រហែលជាពីរឆ្នាំ វត់ត្រេចុះ ត្រេឡើង បង្អើនសូរក្រឹង១ ។ នៅក្បែរនោះមានស្រីជំទង់ម្នាក់ចាំឃ្លាំមើលកុមារតូច ។ ក្មេងប្រុសដែលសួរមីងបុលអម្បាញ់មិញ រង់ចាំចម្លើយមីងដោយកិរិយាសុភាពរាបសា ។ ភ្នែកគេសម្លឹងមីងជាប់ដោយទឹកមុខស្រស់ស្រាយ ។ មីងបុលឆ្លើយទាំងស្ទាក់ស្ទើរ ៖

- អ៊ំមករកមិត្តភក្តិម្នាក់ គេរស់នៅទីនេះកាលពីដើម ។



www.elibraryofcambodia.org

ក្មេងប្រុសសួរទៀត ៖

- អ៊ីចឹងអ៊ំស្គាល់ឈ្មោះគេទេ ?

មីងបុលរកចំនុកឆ្លើយមិនទាន់ ក៏និយាយស្ទាក់ៗដោះកុន ៖

- អ៊ីចឹងម្ចាស់ផ្ទះឥឡូវនេះ មិនមែនជាម្ចាស់ពីដើមទេឬ ?

ក្មេងប្រុសគ្រវីក្បាល ហាក់បញ្ជាក់ថាខ្លួនឯងនេះក៏មិនដឹងច្បាស់លាស់ដែរ ក៏ស្រែកហៅទៅក្មេងស្រីជំទង់ដែលកំពុងមើលក្មេងតូច ៖

- ភីន ! ឯងនាំលោកអ៊ំស្រីទៅជួបចាស់ៗឯក្នុងទៅ !... នែប្រញាប់បិទទ្វាររបងផងណា៎ !...(រួចក្មេងនោះរអ៊ូបន្ត) មនុស្សឥឡូវយ៉ាប់ណាស់... ពិបាកទុកចិត្ត.... មិនដឹងជាស្អីទេម៉ាក់ ក្មេងមិនទាន់ទាំងដឹងអីផង !... ប្រញាប់តែបំពោកមាសឱ្យស្រោចខ្លួន... ហើយតាំងនាំគ្នាភ័យ... តាំងនាំគ្នាប្រយ័ត្នតែនឹងទ្រព្យឯង... យីះ !

ក្មេងប្រុសបង្ហើយពាក្យយីះមួយម៉ាត់ចុងក្រោយ ក៏ឡើងកង់ជិះទៅ ។ មីងនឹកអៀនខ្លួនបន្តិច នឹកចង់សើចបន្តិចដោយសំដីក្មេងប្រុសនិយាយមួយគ្រួសអម្បាញ់មិញនេះ ហើយនឹកថា " ហេតុតែក្មេងមានគំនិតត្រង់ច្រើនហើយ បានជានិយាយប្រយ័ត្ននៅចំពោះមុខភ្ញៀវដូច្នេះ... ប៉ុន្តែប្រហែលជាគេមិនខ្លាចទេ... គេទុកចិត្ត បានជាមិនទាន់ស្គាល់អ្នកណាផង គេប្រញាប់តែអនុញ្ញាតឱ្យចូលក្នុងផ្ទះ ...។ មួយគេយល់ថា ខ្លួនចាស់ និងមានមុខមាត់ស្លូតបូតជាមនុស្សសុចរិត បានជាគេ ឆាប់ទុកចិត្តដូច្នេះ ?" ។

ស្រីជំទង់អញ្ជើញមីងបុលចូល ហើយក៏ទាញទ្វាររបងបិទតាមក្រោយ រួចលើកកុមារតូចពឡើង បង្អើនស្នូរចង្រ្កង់លាន់ក្រឹងៗដើរនាំមុខគាត់ទៅ ។ មីងវង្វេងវង្វាន់អស់ហើយ ទីនេះកាលពីមុនមានសួនច្បារយ៉ាងធំ ហើយមានទ្វារចូលធំៗពីរផង ឥឡូវផ្ទះនោះគេមកនៅច្រើនគ្រួសារ ព្រមទាំងខណ្ឌជញ្ជាំងទៀត ។ កន្លែងណាដែលពីមុនគ្មានផ្ទះ គេក៏បន្ថែមដំបូលពីមុខពីក្រោយ ។ នាងភីននាំមីងបុលដើរបត់ ហើយសសៀរតាមបណ្ដោយជញ្ជាំងរបងទៅដល់ក្រោយ ។ ទីនេះមានទីធ្លាទូលាយ ព្រមទាំងមានដើមខ្នុរ


www.elibraryofcambodia.org

មួយយ៉ាងធំ បែកមែកបោះទៅសងខាង និងមានផ្លែរណោងរណោង តូចធំតាមមែក ខ្លះៗ ។ ពេលនេះមីងបុលឈរទុចង៉ក់ ហាក់ដូចជានឹកហួសចិត្តដល់ដើមខ្នុរដែលធាប់ស្លុះ ធំយ៉ាងនេះ ។ នៅខាងក្រោមដើម មានគ្រែឫស្សីធំមួយ ។ នាង ភីន ដាក់កុមារីនៅលើ គ្រែឫស្សី រួចអញ្ជើញមីងបុលឱ្យអង្គុយរង់ចាំចាស់ទុំនៅទីនេះ ÷

- អ៊ំ... ចាំខ្ញុំទៅអញ្ជើញអ៊ំស្រីខ្ញុំមកជួបអ៊ំនៅទីនេះណា !

មួយសន្ទុះធំទើបលេចស្ត្រីម្នាក់ សក់ស្កូវសសំព្រោង កាត់សក់ផ្កាថ្កូវ (ជារបៀប សក់ប្រុស) ពាក់អាវពណិ កកំពត ស្លៀកសារុងពុម្ពផ្កា ដើរចេញមកដោយ សម្លឹងមក មីងបុលឥតដាក់ភ្នែក ។ មីងបុលដែលកំពុងប្រឡែងលេងជាមួយក្មេងតូច ក៏ផ្អាក សកម្មភាព ហើយក្រោកឈរសំដែងអាកប្បកិរិយារង់ចាំទទួលស្វាគមន៍ស្រីនេះ ។ ស្ត្រី នេះរាងសង្ហិត តែរហ័សរហួន ហើយចាស់ជាងមីងបុលច្រើនឆ្នាំ ។ ពេលដើរមកជិត គាត់ លើកដៃសំពះសួរលោក ១ភ្លាក់សំពះតបវិញ ព្រមទាំងបន្លឺវាចា ÷

- លើកដៃថ្វាយព្រះ នាង !

ស្ត្រីនេះមានចរិតឫកពាថ្លៃថ្នូរ និងមានសីលធមិរស់នៅល្អប្រពៃសមដូចជា មនុស្សមានចំណេះចេះដឹងក្នុងខ្លួន ។ មីងបុលនៅតែឈររង់ចាំការអនុញ្ញាតពីម្ចាស់ផ្ទះ ទើបដាក់ខ្លួនអង្គុយសាជាថ្មីឡើងវិញ ។

- នាងភីនអើយ នាងភីន !

- ចាស លោកម៉ែ ។

- អើ !... មកយកស្រីតូចមុជទឹក... បញ្ចុកបបរ... ឱ្យគេងទៅ...ដល់ម៉ោងហើយ ។

លោកម៉ែមានប្រសាសន៍ ហើយងាកមកសួរមីងបុល :

- នាងក្មួយ ចង់ជួបអ្នកណាគេ ?

- ចាសទេ !... ដើរៗមកដល់ទីនេះ ក៏កើតការនឹករឭកដល់មិត្តភក្តិដែលធ្លាប់ រស់នៅក្នុងភូមិគ្រឹះនេះ ខ្ញុំក៏សួរក្មេងថា ... ម្ចាស់ផ្ទះនេះជាម្ចាស់ផ្ទះពីដើម ឬក៏ម្ចាស់ផ្ទះ


www.elibraryofcambodia.org

សម័យឥឡូវទេ ?... តែក្មេងៗមិនដឹងក៏បញ្ជូនខ្ញុំឱ្យមកជួបលោកម៉ែតែម្ដង ។

ស្ដាប់សំដីមីងមួយគ្រួសអម្បាញ់មិញ លោកម៉ែគ្រវីក្បាលមួយៗ យឺតៗ រួចមានប្រសាសន៍ថា ÷

- ត្រូវហើយនាង ! ខ្ញុំផ្ដាំកូនចៅខ្ញុំមែន ! ថាបើមានអ្នកណាគេមកសួររក... ឬក៏មានពាក់ព័ន្ធអ្វីនឹងផ្ទះនេះ ឱ្យគេចូលមកជួបនឹងខ្ញុំចុះ... ខ្ញុំមិនកំណាញ់ទេ... តែខ្ញុំ... ខ្ញុំជាមនុស្សថ្មីមកនៅទីនេះក្រោយឆ្នាំ ១៩៧៩...មួយភ្លែតម្ភៃឆ្នាំទៅហើយនាង !

- លោកម៉ែ គិតដូចខ្ញុំដែរហ្ន !

- នាងមានដឹងរឿងអ្វីនិយាយទៅមើល៍ !... ខ្ញុំចូលចិត្តស្ដាប់ណាស់ !

- ចាំសទេ !... ខ្ញុំមិនដឹងរឿងអ្វីច្រើនប៉ុន្មានទេ... គ្រាន់តែកូនស្រីម្ចាស់ផ្ទះនេះកាលពីដើមជាមិត្តភក្ដិខ្ញុំ... ខ្ញុំបានសរសេររឿងនេះទុក... តែឥឡូវគេនោះរលត់រលាយអស់ទៅហើយ... វានៅសេសសល់តែក្នុងក្បាលខ្ញុំនេះ !

និយាយហើយមីងបុលទះក្បាលខ្លួនតិចៗ ពីព្រោះរឿងនេះជារឿងរបស់គាត់ ប៉ុន្តែគាត់ក្លែងថាជារឿងមិត្តភក្ដិគាត់ទៅវិញ ។ ប្រការដែលគាត់មិននិយាយត្រង់ ពីព្រោះគាត់មិនចង់ឱ្យអ្នកនៅផ្ទះគាត់រង្កៀសចិត្តឡើយ ។

លោកម៉ែសួររន្ថើន ÷

- និយាយទៅ !...និយាយទៅនាង !...វាយ៉ាងម៉េចដែរ !... ខ្ញុំជួយចងចាំនាង... ហើយបើមានអ្នកណាគេមកសួររកទៀត ខ្ញុំនឹងប្រាប់គេថា : នាងជាមិត្តភក្ដិម្ចាស់ផ្ទះនេះ... នៅរស់ដែរ !... និយាយអីចឹងនាងឈ្មោះអីទៅ ?

- ខ្ញុំឈ្មោះ ឧប្បល ។

- ហើយផ្ទះសម្បែងនៅឯណាដែរសព្វថ្ងៃនេះ !

- ចាំស ! ខ្ញុំស្នាក់នៅផ្ទះជាមួយមិត្តភក្ដិឈ្មោះសាមិត្ត ! នៅទំនប់បឹងទំពុនជិតកន្លែងបូមទឹកស្អុយ ។


www.elibraryofcambodia.org

នាងភីនដើរចូលមកឱន១ ក៏ត្រូវបានលោកម៉ែសួរភ្លាម ÷

- ស្រីតូចគេងលក់ហើយឬនៅនាងភីន ?

- ចាស នាងគេងលក់ហើយលោកម៉ែ !

- ឱ ! នាងភីនអើយ !...ម៉ែភ្លេចទៅ ... លើកទឹកមកជូននាងពិសាផងណា !

នាងភីនស្ទុះរឹងទៅយកទឹកមកជូនភ្ញៀវតាមបញ្ជារបស់លោកម៉ែ... រួចងាកមកអង្គុយយ៉ាងសមរម្យក្បែរខាងលោកម៉ែ ក្រែងលោលោកត្រូវការហៅប្រើហុចនេះ ហុចនោះបន្តទៀត ។ មីងបុល លើកកែវក្រេបទឹកត្រជាក់ពីរ-បីក្អឹក ដើម្បីបន្ធូរបំពង់ក ។ គាត់និទានរឿងកាលពីអតីតកាលដែលបានកន្លងផុតទៅយ៉ាងយូរ ប្រាប់ទៅស្ត្រីចំណាស់នោះ ។ គាត់និយាយព្រមទាំងសំដែងអាកាស:ស្រពាប់ស្រពោន នឹករឭកដល់លោកឪពុកអ្នកម្ដាយ ព្រមទាំងអ្នកបម្រើទាំងឡាយដែលធ្លាប់តែរស់នៅយ៉ាងសុខដុមជាមួយគ្នា តែឥឡូវព្រាត់ប្រាសអស់ហើយ មិនដឹងជារស់ ឬស្លាប់ នៅក្នុងស្រុក ឬនៅឯបរទេសទេ ។

មីងបុលនិទានរឿងផ្ទាល់ខ្លួនចប់ហើយ ស្ត្រីចំណាស់ចាប់ផ្ដើមមានប្រសាសន៍បន្ត÷

- ខ្ញុំអរគុណហើយ ដែលនាងបាននិទានរឿងដ៏ពីរោះនៃជីវិតម្ចាស់ផ្ទះនេះឱ្យខ្ញុំស្ដាប់ ។ ហ៊ឺ ! ផ្ទះនិមួយ១សុទ្ធតែបង្កប់រឿងរ៉ាវយ៉ាងនេះ យ៉ាងនោះផ្សេង១គ្នា ។ ប្ដូរឈ្មោះ ឬក៏ប្ដូរម្ចាស់ថ្មី មិនខុសអីពីគេចង់បំបាត់ភស្តុតាងទេ... មែនទេនាងក្មួយ ?

- ចាស !

មីងបុលឆ្លើយយ៉ាងល្ហើយ រួចគាត់ក៏លើកដៃសំពះ ព្រមទាំងនិយាយថា ÷

- ខ្ញុំសូមជម្រាបលាលោកម៉ែហើយ !

- អ៊ឺ អញ្ជើញចុះ !... អូ ! ឈប់សិននាង ១...

ស្ត្រីម្ចាស់ផ្ទះនិយាយឃាត់ រួចដើរចូលទៅក្នុងបាត់ទៅ... បន្ទាប់មកលោកដើរចេញមកវិញដោយមានកាន់រូបថតដែលដាក់កញ្ចក់យ៉ាងស្អាត រួចសួរមីងបុល ÷

- នាងស្គាល់រូបនេះទេ ? គេជាម្ចាស់ផ្ទះហ្នឹងឬ ?



www.elibraryofcambodia.org

គ្រាន់តែឃើញរូបថតឪពុកម្ដាយរបស់គាត់ភ្លាម ទឹកភ្នែកហូរមកស្រក់តក់ៗឥត ដាច់ចេញពីកែវភ្នែកទាំងគូរបស់គាត់ ។ លោកឪពុក អ្នកម្ដាយគាត់ញញឹមយ៉ាងស្រស់ ហាក់ដូចជាគ្មានរឿងអ្វីកើតមានឡើយ ធ្វើឱ្យរឿងរ៉ាវដែលមីងបុលទើបតែនិទាន រឹងរឹត តែច្បាស់ក្នុងអារម្មណ៍របស់គាត់ថែមទៀត ។ ស្ត្រីចំណាស់សួរមីងបុល ÷

- បើនាងចង់បាន ខ្ញុំជូននាងចុះ !

មីងបុល មិននិយាយអ្វីតទៀតច្រើនទេ គ្រាន់តែលើកដៃសំពះ រួចថ្លែង អំណរគុណដល់ម្ចាស់ផ្ទះថ្មី ហើយគាត់កាន់រូបថតដើរចេញមកក្រៅ ។ គាត់ដើរបានបន្តិច ក៏វិលមុខដួលមិនដឹងខ្លួនទាំងដៃកាន់រូបថតឪពុក ម្ដាយ ។

---

ពេលគាត់ដឹងស្មារតីឡើងវិញ វង់ភក្ត្រនាងរ៉ាវិន បុត្រីតែមួយ ជាត្រួយដួងចិត្ត របស់គាត់ ដែលគាត់ស្វះស្វែងរកជាយូរថ្ងៃមកហើយនេះ បានមកប្រត្យក្សចំពោះមុខគាត់ តែម្ដង ។ អ្នកទាំងពីរខ្សឹកខ្សួល ដោយម្ដាយអាណិតកូន ចំណែកឯកូនវិញអាណិតម្ដាយ ។ សេចក្ដីអាណិតផ្ដោតលើដួងចិត្តរៀងៗខ្លួន ក៏បណ្ដាលឱ្យទឹកភ្នែកហូរដោយក្ដីរំភើបផង ត្រេកអរផង លាយឡំច្របូកច្របល់គ្នា ។ រ៉ាវិន សួរម្ដាយ ÷

- ម៉ែដឹងខ្លួនហើយឬ ?

មីងបុលមិនឆ្លើយនឹងសំនួរកូន បែរជាសួរទៅវិញថា ÷

- ហេតុអ្វីក៏កូនដឹងថាម៉ែនៅទីនេះ ?

រ៉ាវិននិយាយមិនរួចតទៅទៀត តែនាងចង្អុលទៅជន ។ មីងបុលងាកទៅជន ដោយបញ្ចេញវាចា ÷

- ហេតុអ្វីក៏ក្មួយដឹងថាមីងនៅទីនេះ ?

- ខ្ញុំទៅផ្ទះមីងសាមិត្តឯទំនប់បឹងទំពុន ដើម្បីយកដំណឹងពីរ៉ាវិនថានាងពិតជាកូន មីងប្រាកដហើយ ពុំមែនរ៉ាវិនឯណាផ្សេងទៀតទេ ... ពេលខ្ញុំទៅដល់មិនជួបមីង ជួបតែ


www.elibraryofcambodia.org

មីងសាមិត្ត គាត់ប្រាប់ថា មីងអញ្ជើញមករកមើលផ្ទះចាស់នៅម្តុំខាងជើងវិទ្យាល័យព្រះយុគន្ធរ តាមបណ្តោយផ្លូវព្រះមុនីវង្ស រំលងតែបី-បួនផ្លូវប៉ុណ្ណោះ ។ ខ្ញុំផាក់ស៊ីក្លូតាមមីងម្តុំនេះបី-បួនសារ ទើបតែពេលនេះឃើញមីងដួល ក៏ដឹកមកមន្ទីរពេទ្យកាល់ម៉ែតតែម្តង រួចក៏ទៅហៅវ៉ាវិនមក ។

មីងបុល និយាយកាត់ ÷

- មីងអរគុណក្មួយហើយ ! ដែលជួយឃើញ្ញាលមីងពីដើមដល់ចប់... សូមឱ្យសេចក្តីប្រាថ្នារបស់ក្មួយសម្រេចដូចចិត្តណា !

ជនមិននិយាយគ្រាន់តែលើកដៃសំពះ ទទួលពរជ័យ ។ មីងបុលនិយាយបន្ថែមទៀត ÷

- នេះរូបថតលោក វង្ស សម្បត្តិ និងលោកស្រី សិរិទ្ធ សោភា ដែលត្រូវជាលោកតា លោកយាយរបស់កូន... លោកមកនៅជាមួយយើងវិញហើយ គឺនៅតាមរយៈរូបថតនេះ !

វ៉ាវិនឃើញទឹកមុខម្តាយស្រស់បស់ឡើងវិញ ក៏សួរបញ្ជាក់ ÷

- ម៉ែ ! យ៉ាងដូចម្តេចដែរក្នុងខ្លួន ?

- ពេលបានជួបមុខកូន ដូចជាមានកម្លាំងកំហែងធម្មតា...

គាត់ងាកមកនិយាយជាមួយជន ÷

- ...ក្មួយអាចជូនមីងទៅផ្ទះវិញបានទេ ?

- បាទ ! បាន !

វ៉ាវិនបើកកាបូប រួចយកប្រាក់ចេញមកប្រគល់ជូនម្តាយ ហើយនិយាយយ៉ាងសប្បាយរីករាយថា ÷

- ប្រាក់នេះ... ជាប្រាក់ដែលកូនបានពីអស់លោក១... លោកមានចិត្តសប្បុរសឱ្យកូនច្រើន១ សម្រាប់កូនរស់បន្ត ពីព្រោះលោកជ្រាបថាកូនកើតអេដស៍...


www.elibraryofcambodia.org

ទាំងបីអង្គុយបរិភោគបាយជុំគ្នា ។ ដោយសារគម្លានខ្លាំងពេក សាមិត្តហាក់ដូចជាហូបបាយយ៉ាងឆ្ងាញ់ពិសា ។ គាត់ហូបបណ្តើរ ផ្លុតញើសដែលហៀរដោយសារបាយក្តៅ សម្លក្តៅ បូកនឹងជាតិហឹរផ្សំផង ធ្វើឱ្យសាមិត្តលាន់មាត់ ÷

- បុកអំពិលរបស់បងត្រូវមាត់ខ្ញុំណាស់...ចុះបងឆ្ងាញ់ដែរទេ ?

សាមិត្តងើបមើលមុខមីងបុល ហាក់ដូចជាទឹកមុខរបស់គាត់ហូបបណ្តើរ គិតបណ្តើរ ។ មីងបុលឮសាមិត្តសួរ ក៏ឆ្លើយដូចភ្ញាក់ ÷

- អូ ! ឆ្ងាញ់ដូចសាមិត្តដែរ ។

- រួចចុះបង ទំនងដូចជាគិតអីទៀតហើយហ្នឹង ?

មីងបុល បញ្ចេញខ្យល់លាន់ហ៊ឹស ! ទើបទំពាបាយដែលនៅក្នុងមាត់ឱ្យអស់ហើយបញ្ចេញមតិ ÷

- ភ្នំពេញធំណាស់...មិនដឹងជាទៅរកកូននៅឯណាទេ...ម្តង១ ដូចជាអស់សង្ឃឹមចង់តែត្រឡប់ទៅស្រុកភូមិវិញ...ចង់តែបណ្តោយទៅតាមយថាកម្មទៅចុះ...អ្វីដែលវាប្រុងកើតទៅហើយប្រឹងគិតក៏មិនបានផលអ្វីដែរ...គឺឱ្យវាកើតចុះ...

មីងបុលដូចជាអស់យោបល់ត្រឹមនេះទាំងឃ្លាមិនទាន់ចប់ស្រួលបួលផង ក៏ឮសាមិត្តនិយាយកាត់ឡើង ÷

- តស៊ូបន្តិចទៀតទៅបង... ទីនេះមិនស្អុកស្កម្មមែន តែគ្រួសារខ្ញុំញញឹមទទួលបងជានិច្ច...ក្រែងបងមិនពេញចិត្តដូចម្តេចខ្ញុំមិនដឹងទេ ... តែចាចិត្តខ្ញុំ ... ចិត្តបងស្រីខ្ញុំ... គឺបងមូននោះ ... ដូចជាសប្បាយទៅវិញទេបានបងមកនៅជាគ្នា ។

ពេលនិយាយនោះ សាមូនសម្លឹងមុខសាមិត្តភាំង ទាំងកាន់ស្លាបព្រា នៅនឹងដៃហាក់ចង់ដឹងពីអ្វីដែលគេជជែកគ្នាអំបាញ់មិញនោះ ។ សាមូនងក់ក្បាល រួចងាកទៅរកមីងបុល ព្រមទាំងធ្វើកាយវិការថា គាត់ពេញចិត្តមីងបុលណាស់ ។ មីងបុលបន្តសំដី ÷

- អរគុណ អ្នកទាំងពីរហើយ ! ដែលស្រឡាញ់រាប់អានបង...ប៉ុន្តែខ្លាចតែបង


www.elibraryofcambodia.org

រ៉ាវិនមិនទាន់បញ្ចប់ ស្រាប់តែមីងបុលភ្ញាត់មាត់ស្រែក ÷

- កូនកើតអេដស៍ ! ពុទ្ធោ ! រ៉ាវិនកូនម្ដាយ ! ម្ដេចក៏ទៅជាយ៉ាងដូច្នេះទៅវិញ!

រ៉ាវិននិយាយកាត់ម្ដាយ ÷

- ទេ !...ទេ !... ម៉ែស្ដាប់កូនសិន !...អត់ទេ !...អត់ទេ !...កូនកុហកគេ... ដោយសារតែសំបុត្រក្លែងក្លាយនេះ ។

និយាយហើយ រ៉ាវិនក៏យកសំបុត្របញ្ជាក់របស់នាងមកបង្ហាញម្ដាយ ដោយចង្អុលចំឈ្មោះ ហើយនិយាយបណ្ដើរ ÷

- ម៉ែ ! ឈ្មោះកន្លែងនេះ ខ្ញុំលុបឈ្មោះគេចេញ ហើយខ្ញុំដាក់ឈ្មោះខ្ញុំ ដើម្បីបំភ័ន្តគេវិញ អាចមានឱកាសថែទាំខ្លួនប្រាណបានយ៉ាងល្អផងណា !

ម្ដាយឮដូច្នេះ ក៏ធូរចិត្តខ្សាក រួចនិយាយដោយការខកចិត្ត ÷

- ម៉េចក៏កូនដើរកុហកគេអ៊ីចឹង ?

- កូនគ្មានផ្លូវណាផ្សេងទេម៉ែ ! ក្រៅពីធ្វើល្បិចដូច្នេះ !

- អស់លោកទាំងនោះ ចេះតែជឿកូនដែរឬ ?

- មិនដឹងដែរម៉ែ ប៉ុន្តែចេះតែបានរួចខ្លួនរហូតមក ។

មីងបុលអស់ពីយំបែរជាសើច ហើយគាត់រាប់លុយឃើញមានចំនួនច្រើនហួសពីការស្មានដែលរ៉ាវិនប្រគល់ឱ្យគាត់មុននេះបន្ដិច ។ គាត់ក៏លាន់មាត់ឡើង ÷

- កូនមកភ្នំពេញមិនដល់មួយឆ្នាំផង បានលុយជាងមួយពាន់ដុល្លារ មិនគួរឱ្យជឿសោះ !

- មនុស្សខុសៗគ្នា វាសនាក៏ខុសៗគ្នា ដល់ខ្ញុំមកនៅឆ្ងាយពីម៉ែ ទើបខ្ញុំដឹងថាជីវិតគឺយ៉ាងដូច្នេះ... ខ្ញុំខំបម្រើអស់លោកយ៉ាងស្មោះត្រង់... លើកលែងតែខ្លួនប្រាណដែលខ្ញុំមិនប្រគល់ជូនគេ... អ្នកណាក៏អាណិតខ្ញុំ... ខ្ញុំមិនដឹងចិត្តគេយ៉ាងណាទេ... មានលោកម្នាក់ឱ្យខ្ញុំបីរយដុល្លារ ហើយនិយាយថា : " ប្រាក់នេះទុកសម្រាប់នាងឈឺក្រោកដើរមិន


www.elibraryofcambodia.org

រួច " ។ ខ្ញុំនិយាយជម្រាបម៉ែពេលនេះ ដូចជាគ្មានវិប្បដិសារីទេ ពីព្រោះថវិកាទាំងនេះ ខ្ញុំទុកសម្រាប់ជូនម៉ែដោះបំណុលគេ ។ ខ្ញុំសូមបួងសួងដល់អស់លោកអ្នកសប្បុរសទាំងអស់ដែលលោកជួយឧបត្ថម្ភខ្ញុំ សូមលោកបានចម្រុងចម្រើនតរៀងទៅ !

មីងបុលឃើញអាកប្បកិរិយាកូនដូចនេះ ធ្វើឱ្យគាត់ហួសចិត្តនឹកអាណិតកូនខ្លោចចិត្ត ។ រ៉ាវិន និយាយមិនអស់សេចក្ដី ក៏ប្រញាប់បន្ថែមគំនិតរបស់ខ្លួន ÷

- ស្រីរកស៊ីដូចខ្ញុំខ្លះ គេហ៊ឺហាណាស់ម៉ែ ! ចំណែកខ្ញុំមានគំនិតសន្សំសំចៃតែមួយមុខប៉ុណ្ណោះ ហើយខិតខំរៀនបន្ថែមខាងភាសាបរទេសឱ្យបានចេះច្រើនថែមទៀត តែប៉ុណ្ណឹងឯង !

មីងបុលគ្មានយោបល់អ្វីបន្ថែម គ្រាន់តែដកដង្ហើមធំ បន្ទូរភាពតានតឹងដែលសង្គមចាប់បង្ខំឱ្យមនុស្សប្រព្រឹត្តអំពើប្រាសចាកសីលធម៌ ។ មីងយើងសម្លឹងមុខកូនស្រីជាថ្មីទៀត រួចសួរថា ÷

- ឥឡូវកូនគិតយ៉ាងណា ?

- ខ្ញុំមិនដឹងថា លុយរបស់ខ្ញុំគ្រប់ចំនួនម៉ែសងបំណុលគេដែរឬអត់ ?

- ហៀរហូរហើយកូន !

- បើដូច្នេះ ខ្ញុំសម្រេចចិត្តទៅស្រុកភូមិយើងវិញជាមួយម៉ែ... ឈប់ដើរកុហកគេទៀត ពីព្រោះបំណងខ្ញុំបានសម្រេចហើយ ។

មីងបុលរំភើបពេក គាត់ស្រវាឱបកូនស្រីពេញក្នុងរង្វង់ដៃ ហើយក៏និយាយតឿន:

- ទៅកូន !... យើងទៅផ្ទះយើងវិញ !

ជនបញ្ជិះមីងបុល និងរ៉ាវិន ទៅផ្ទះមីងសាមិត្ត ។ មីងបុលឆ្លៀតនិយាយគួរសមជាមួយជន :

- មីងអរគុណក្មួយហើយណា៎ ! ហើយក្មួយនៅឯណាដែរ !

- ខ្ញុំបាទនៅជាមួយប្រពន្ធអ្នកភ្នក (អ្នកដុតសព) នៅបឹងទំពុន ។ ពីមុនខ្ញុំនៅ


www.elibraryofcambodia.org

កំពង់ចាមទេ ខ្ញុំគ្មានម៉ែគ្មានឪ ខ្ញុំជាកូនកំព្រាដើរនៅតែជាមួយគេ តែបានគេឱ្យខ្ញុំរៀនរហូតដល់ប្រឡងមធ្យមសិក្សាប័ត្រភាគ២ជាប់ ក៏មកភ្នំពេញប្រឡងចូលមហាវិទ្យាល័យខាងភាសាបារាំង លុះដល់ខ្ញុំបាទប្រឡងជាប់ទៀត ខ្ញុំក៏បានមកស្នាក់នៅវត្តឧណ្ណាលោម ក្បែរបាំឆាជាមួយអ្នកភ្នុក រហូតដល់រៀនចប់ ។ នៅពេលរង់ចាំស្តាប់ការប្រកាសលទ្ធផលប្រឡង ខ្ញុំក៏មកនៅបឹងទំពុនជាមួយប្រពន្ធអ្នកភ្នុកវិញ ។ តែព្រឹកមិញនេះខ្ញុំបានទៅមើលលទ្ធផលពីការប្រឡងនោះ ស្រាប់តែ... មីងទាយទៅថាខ្ញុំយ៉ាងណាដែរ ?

ទាំងអស់គ្នាទៅជាស្រឡាំងកាំង មិននឹកស្មានថា អ្នកធាក់ត្រីចក្រយានរូបនេះមានចំណេះវិជ្ជាខ្ពស់គួរសរសើរសោះ ។ មីងបុលរបូតមាត់ ÷

- មីងថាក្មួយជាប់ចុះ មែនទេ ?

- បាទត្រូវហើយ ! ខ្ញុំបាទជាប់បានអាហារូបករណ៍ទៅប្រទេសបារាំង ។

នៅលើត្រីចក្រយាន ទាំងអ្នកធាក់ និងទាំងអ្នកជិះសុទ្ធតែបានទទួលលទ្ធផលល្អគួរជាទីគាប់ចិត្តដូចគ្នា ។ ចម្ងាយផ្លូវពីមន្ទីរពេទ្យកាល់ម៉ែត មកបឹងទំពុនដូចជាឋិតនៅជិតបង្កើយ ។ អ្នកកំលោះជន ធាក់មិនចេះហត់ គេត្រេកអរនឹងបានប្រឡងជាប់ផង និងត្រេកអរនឹងលំអងកេសរ នាងវ៉ាវិនមិនរុះរោយដូចការស្មានរបស់គេផង ។ ដល់ផ្ទះមីងសាមិត្តហើយ អ្នកកំលោះប្រញាប់លាសមាជិកទាំងអស់ត្រឡប់មកផ្ទះវិញ ដើម្បីរត់ការរឿងបែបបទទៅស្រុកគេ ។ វ៉ាវិនជូនដំណើរជនដល់ច្រកផ្លូវចូល ។ ជនសម្លឹងមុខវ៉ាវិនហើយបន្លឺសួរសៀងខ្សឹបៗថា ÷

- វ៉ាវិន អាចរង់ចាំបងបួនឆ្នាំបានទេ ?

វ៉ាវិនមិននិយាយ នាងគ្រាន់តែញញឹម ។ ជនលើកជាសំនួរទៀត ÷

- តើជាញញឹមបោកប្រាស់ដូចសព្វមួយផង ឬក៏ស្មោះត្រង់ ?

ថាហើយអ្នកកំលោះក៏ផៃលលើត្រីចក្រយាន ដោយហួចបន្លឺសូរជាបទ " ទេពធីតាក្នុងសុបិន " យ៉ាងពីរោះគ្រលួច គេនឹកសប្បាយរីករាយក្នុងអារម្មណ៍តែម្នាក់


www.elibraryofcambodia.org

ឯង ហើយប្រហែលជាទេពធីតាក្នុងសុបិនពេលនេះ លេចរូបរាងយ៉ាងច្បាស់ក្នុងដួងចិត្តរបស់គេហើយមើលទៅ ។ ចំណែកឯនាងកញ្ញា វ៉ាវិនវិញ នៅឈរជូនដំណើរអ្នកកំលោះជន រហូតទាល់តែផុតកន្ទុយភ្នែក ប្រកបដោយវង់ភក្ត្រាប្រិមប្រិយ បីដូចជាបុប្ផាត្រូវទឹកសន្សើម ។

ឱ ! សត្វលោកអើយ អ្នកនៅតែវិវក់ វិលវល់ក្នុងអន្ទាក់នៃវាលវដ្តសង្សារដែលពុំអាចរំដោះខ្លួនឱ្យផុតពី “ សំណាញ់ជីវិត ” ដ៏សែនសាំញ៉ាំនេះបានឡើយ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០០

អ្នកស្រី អ៊ុំ សុផានី



www.elibraryofcambodia.org

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
លិខិតអនុញ្ញាតលេខ ៤៧ ស.ណ
ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០២
បោះពុម្ពលើកទី ១ ចំនួន ៥០០ ក្បាល

www.elibraryofcambodia.org

គ្មានអំណត់តស៊ូនឹងជីវភាពទីក្រុងពុំបាន ... ប្អូនឱ្យបងតស៊ូ !... ប៉ុន្តែការតស៊ូក៏ត្រូវមានព្រំដែនដែរណា៎ប្អូន ! បងមកឃើញទីក្រុង...ដូចជាកន្លែងសុខស្រួលសម្រាប់តែអ្នកមានទ្រព្យសម្បត្តិ រស់នៅប៉ុណ្ណោះ...បើវិភាគទៅដូចជាកន្លែងគេប្រណាំងប្រជែងគ្នាទៅវិញ...

- ម៉េចក៏បងនិយាយអ៊ីចឹង ! គេរស់នៅដោយគេ យើងរស់នៅដោយយើង... យើងមានមុខរបរដ៏សុចរិតត្រឹមត្រូវ ថ្វីត្បិតតែតិចតួចស្តួចស្តើងមែន ប៉ុន្តែអារម្មណ៍ស្ងប់ល្អណាស់ ! ដូចពេលនេះជាដើម ខ្ញុំហូបបាយឆ្ងាញ់មែនទែន ទោះបីសម្លម្ជូរត្រកួន ជាមួយត្រីឆ្អិតល្មោចក៏ខ្ញុំគិតថាពិសេសទៅហើយ ! ម្យ៉ាងវាប្រសើរជាងសាច់កាប់ដែលទ្រលាន់លេបមិនចូលដែរ !

- ប្អូននិយាយមិនខុសទេ ! គឺវាត្រូវមួយបែបតាមគំនិតរបស់ប្អូន ហើយ...! ចំណែកឯអ្នកដែលចូលចិត្តសាច់កាប់ គេក៏តាំទ្រគំនិតរបស់គេដែរ... ដូច្នេះម្យ៉ាងម្នាក់ទេ !

- បងបុល សម្បូរមតិណាស់...ខ្ញុំសូមខ្លាចបងហើយ ។

និយាយហើយ សាមិត្តសើចសប្បាយនឹងការនិយាយឆ្លងឆ្លើយគ្នានេះ រួចសួរមីងបុល :

- ល្ងាចបងគិតអញ្ជើញទៅណា ?

- បងទៅរកកូនតាមអាសយដ្ឋានដែលគេបានប្រាប់ ។

- អ៊ីចឹង...បងឱ្យខ្ញុំទៅជាមួយទេ ?

មីងបុល ងក់ក្បាល រួចឆ្លើយទាំងញញឹម ÷

- ហ្នឹងហើយ ! ប្អូនទៅជាមួយបង ដើម្បីឱ្យបានជាគ្នា ។

សមាជិកទាំងបីនាក់ ទុកដូចគ្រួសារតែមួយ បានបញ្ចប់ការស្រស់ស្រូបអាហារថ្ងៃត្រង់ប្រកបដោយបរិយាកាសរីករាយ និងឆ្ងាញ់ពិសារៀង១ខ្លួន ។

សាមួនងាកទៅសួរមីងបុល ÷

- បងឆ្អែតហើយឬនៅ ?...យ៉ាងណា១បងកុំលាក់ពោះឱ្យសោះណា៎ !


www.elibraryofcambodia.org

- ឆ្អែតហើយ ឆ្ងាញ់ទៀត...ប្អូនកុំព្រួយ បងមិនលាក់ពោះទេ ។

សាមិត្តងាកទៅធ្វើកាយវិការប្រាប់បងស្រីថា : “ ពេលល្ងាចខ្លួននឹង ទៅជាមួយបងបុលហើយ...ចំណែកបងវិញទៅបេះត្រកួនម្នាក់ឯងចុះ ” ។

សាមួនងក់ក្បាល យល់ច្បាស់ណាស់នូវភាសាកាយវិការនេះ ។

សម្រាកបានតែបន្តិច មីងបុលក៏ភ្ញាក់ឡើងទាំងទឹកមុខស្រពាប់ស្រពោន ។ គាត់យកដៃឈ្ងីក្បាល រួចក្រោកដើរទៅយកសេនមកកោសខ្យល់ ។ សាមិត្តឃើញដូច្នេះហើយសួរទៅមីងបុល ÷

- បងបុលកើតអីហ្នឹង ?

- ភ្ញាក់ឡើងឈឺក្បាលចង់បែកតែម្តង...ហើយដូចជាវិលមុខយ៉ាងដូចម្តេចទេ ! ...កាលណាបងកោសខ្យល់ខាងមុខហើយ បងសុំពឹងប្អូនកោសខ្នងឱ្យបងបន្តិចណា៎ !

- លុះគាត់កោសពីមុខរួចហើយ សាមិត្តទាញសេនពីដៃមីងបុល កោសយ៉ាងញាប់ដៃ ឯមាត់ឡេវ្រតនិយាយ ÷

- យីក្រហមណាស់...បងខ្យល់ខ្លាំងទេតើ ?...បើបងឈឺអ៊ីចឹង !...តើបងទៅរកកួនបានដែរ ?

- ហ៊ឺ ! មិនឡេវងទេ...កាលណាអន់បានទៅ ។

- និយាយអ៊ីចឹង...

សាមិត្តដំអក់បន្តិចក៏បន្តសំនួរ ÷

- ...បើរកកួនឃើញ បងគិតយ៉ាងម៉េច ?

មីងបុល ឮសំនួរនេះដូចជាគិតមិនលេច ក៏នៅទ្រឹង រួចហើយគាត់គ្រវីក្បាលយឺតៗ ហើយឆ្លើយទាំងគិត ÷

- រឿងហ្នឹងមិនទាន់ហ៊ានថាទេ ! ពីព្រោះមិនទាន់ជួបសំដីគ្នានៅឡើយ...

មីងបុល គិតបន្តិចស្រាប់តែផ្ទុះសំដីឡើង ÷


www.elibraryofcambodia.org

- ...ពុទ្ធោ ! កូនស្រមាសម្ដាយ !

ឈប់និយាយត្រឹមនេះ មីងបុលនឹកគិតតែម្នាក់ឯង... " មិនដឹងជាវាសនាកូនទៅជាយ៉ាងណាទេ...ព្រះជាម្ចាស់អើយ ! " ។

- បងបុលបាត់មាត់ឈឺងអឺចឹង បានធូរខ្លះទេ ?

- អ្ហឺ ! បានធូរខ្លះហើយ ។

- បងអើយ កុំគិតច្រើនពេក !

- បងក៏មិនចង់គិតដែរ តែក្បាលបងវាចេះតែគិតដោយស្វ័យប្រវត្តិ... ទោះបងបង្គាប់ដូចម្ដេចក៏វាមិនព្រមស្ដាប់បងសោះ !

- ឥឡូវខ្ញុំកោសខ្យល់ហើយ ខ្ញុំទៅទិញថ្នាំមួយភ្លែតណា !

ថាហើយ សាមិត្តក៏ប្រញាប់ប្រញាប់ទៅទិញថ្នាំនៅផ្ទះអ្នកលក់ចាប់ហួយដែលមានលក់ថ្នាំតែបន្តិចបន្តួច ដូចជាថ្នាំបំបាត់ឈឺក្បាល បំបាត់រាក បំបាត់ខ្យល់ បំបាត់ក្អក តែប៉ុណ្ណោះ ។ បានថ្នាំហើយ មីងបុលលេបភ្លាម រួចសម្ងំបន្តិចដើម្បីឱ្យបានធូរស្រាល ។

ដោយសារតែមីងបុលមិនស្រួលខ្លួន ដូច្នេះហើយបានជាការទៅរកកូន ត្រូវពន្យាពេលមកល្ងាចវិញ ។ គាត់ទៅរកកូនតែម្នាក់ឯង ត្បិតសាមិត្តត្រូវទៅផ្សារច្បារអំពៅ ចាំទទួលយកក្រសាំងទុកលក់នៅថ្ងៃស្អែក ។

មីងបុល ហៅម៉ូតូឌុបហើយជិះសំដៅទៅសណ្ឋាគារកាំបូឌីយ៉ាណា ។ ទៅដល់មុខសណ្ឋាគារ គាត់បញ្ជាឱ្យម៉ូតូឈប់ រួចប្រគល់ប្រាក់ទៅម្ចាស់ម៉ូតូ ។ គាត់ឈររវេរវា ...មើលនាយ មើលអាយមួយសន្ទុះ ក៏ដាច់ចិត្តដើរចូលទៅទាំងញញើតញញើម ស្ទាក់ស្ទើរ ហាក់ដូចជាទីនេះជាកន្លែងថ្មីសន្លាងសម្រាប់គាត់ ។ មីងបុលដើរបណ្ដើរ លួចកោតសរសើរការតុបតែងលំអសួនច្បារបណ្ដើរ ដែលស្ថាបត្យករចេះរៀបរយគួរឱ្យចាប់អារម្មណ៍ក្រៃលែង ។ បន្ទាប់មក មីងបុលងើយមើលសណ្ឋាគារនេះដែលមានរូបរាងធំស្កឹមស្កៃ ឈរបង្ហួតរាងដ៏សង្ហារបស់ខ្លួនតាមបណ្ដោយដងទន្លេ ព្រមទាំងបំពាក់បន្ថែមនូវ


www.elibraryofcambodia.org

រចនាបថខ្មែរ ដែលមានរាងដូចមកុដនៅត្រង់កំពូល ។ ការតុបតែងបន្ថែមកំពូលរបៀបនេះ ទោះសង់នៅក្នុងតំបន់ណា ប្រទេសណា ក៏ខ្មែរមិនច្រឡំអារ្យធម៌របស់ខ្លួនដែរ ។ ប៉ុន្តែក្នុងទសវត្សរ៍ទី ចិតសិប ទីនេះជាកាស៊ីណូលេងល្បែងដ៏ធំមួយ ដែលវាសនាអ្នកចាញ់ល្បែងទាំងឡាយ តែងតែសម្រេចចិត្តបូជាជីវិតនៅក្នុងទន្លេ ដើម្បីជម្រះនូវវិបត្តិទាំងប៉ុន្មានឱ្យរលត់សូន្យសុង ។ កំពុងតែស្លុងអារម្មណ៍ ស្រាប់តែឮសំឡេងហៅ ÷

- អ្នកមីង !... អ្នកមីង !...
- ចុំកណ្ដុំនែប ! ( មីងបុលភ្ញាត់មាត់ ) ។
- សុំទោសដែលធ្វើឱ្យអ្នកមីងភ្ញាក់យ៉ាងនេះ...អ្នកមីងមានការអ្វីដែរ ?
- ចុះក្មួយជាអ្នកណាដែរ ?
- ខ្ញុំជាសន្តិសុខនៅសណ្ឋាគារនេះ ។
- អ៊ីចឹងស្រួលហើយ...សូមក្មួយជួយរកឈ្មោះក្នុងសំបុត្រនេះឱ្យមីងផង !

ថាហើយ មីងបុលក៏លូកយកសំបុត្រមកបង្ហាញសន្តិសុខនោះ១ទទួលសំបុត្រពីមីងបុលហើយឃើញនៅលើខ្នងសំបុត្រសរសេរថា : " សូមបងបុល មកជួបខ្ញុំនៅសណ្ឋាគារកាំបូឌីយ៉ាណា "

ពីដួងចម្ប៉ា

គ្រាន់តែឃើញឈ្មោះ " ដួងចម្ប៉ា " បុរសនោះលាន់មាត់ ÷

- លោកស្រីដួងចម្ប៉ា...ខ្ញុំស្គាល់គាត់...អ៊ីចឹងអ្នកមីងរង់ចាំខ្ញុំមួយភ្លែត ខ្ញុំទៅកន្លែងរដ្ឋបាល ។

មីងបុលឆ្លើយទទួល ÷

- ចាស ! លោកក្មួយអញ្ជើញចុះ ! មីងនៅរង់ចាំទីនេះ ។

សន្តិសុខពីរនាក់យាមប្រចាំការនៅទីនេះ ម្នាក់រត់ទៅទីចាត់ការដើម្បីសួរលោកស្រីចម្ប៉ា ថាតើលោកស្រីអនុញ្ញាតឱ្យភ្ញៀវចូលជួបឬមួយក៏អត់ទេ ។ មួយសន្ទុះអ្នក


www.elibraryofcambodia.org

យាមនោះត្រឡប់មកវិញ រួចនាំមីងបុលចូលទៅជួបលោកស្រី ។

មីងបុលដើរពីក្រោយសន្តិសុខ បត់បែនចុះឡើង ឆ្លងកាត់ពីកន្លែងមួយ ទៅកន្លែងមួយពីបន្ទប់មួយទៅបន្ទប់មួយ ភ្នែកគាត់រំពៃមើលគ្រប់ទីទាំងអស់។ គាត់ក៏រអើលខ្នងហើយនឹកមមៃ : " ឱ !... កន្លែងណាក៏ដូចកន្លែងណាដែរ ! អីក៏ស្អាតម្ល៉េះហ្ន៎ ! ហើយមានផាសុខភាពល្អទៀត ! ខ្លួនឯងមានឋានៈដូច្នេះ មិនសមនឹងមកកន្លែងនេះទេ !...ឱ !... តើចិត្តមនុស្សដែលខ្ញុំនឹងជួបបន្តិចទៀតនេះ គេមានចិត្តល្អដូចកន្លែងនេះដែរឬទេ ? " ។

ចិត្តចេះតែនឹកគិត ជើងចេះតែដើររហូតអ្នកទាំងពីរមកដល់បន្ទប់មួយ ។ គេគោះទ្វារ រួចទ្វារក៏របើកឡើង អ្នកយាមងាកទៅរកមីងបុលហើយប្រាប់គាត់ថា ÷

- មីងអញ្ជើញចូលទៅជួបលោកស្រីចម្ប៉ាចុះ...ខ្ញុំអស់ការហើយ...ខ្ញុំសូមលាសិនហើយ !

- អរគុណ ក្មួយហើយ !

មីងបុល ដើរចូលទៅលប១ថ្នម១លើកម្រាលសណ្ឋាគារ រួចក៏ស្រាប់តែស្រីក្មេងម្នាក់ស្លៀកពាក់តាមលក្ខណៈប្រពៃណី ស្ទុះមកទទួលរាក់ទាក់ញញឹម ញញែម ហើយនាំមីងបុលទៅបន្ទប់ធំមួយ ។ គ្រាន់តែបើកទ្វារចូលភ្លាម ស្រីម្នាក់អាយុប្រហែលជាសាមសិបប្រាំឆ្នាំ ស្លៀកពាក់ស្អាតបាត ឫកពាសមរម្យ ដើរមកទទួលមីងបុល ហើយអញ្ជើញគាត់ឱ្យអង្គុយលើកៅអីពូកដ៏ទន់ល្មើយ ។ លោកស្រីចម្ប៉ាផ្ដើមសំនួរ ÷

- អ្នកបងសុខសប្បាយទេ ?

- សុខ តែមិនសូវសប្បាយទេ...កូនស្រីបងនៅឯណា ?

- ខ្ញុំកំពុងស៊ើប... ប៉ុន្តែការជួបនោះវាចៃដន្យពេក... ហើយកំពុងស្វែងរកអាសយដ្ឋានពិតប្រាកដ...អ្នកបងស្នាក់នៅឯណា ?...ស្រួលមិនស្រួលយ៉ាងណា អ្នកបងមកនៅជាមួយខ្ញុំទៅ...អ្នកបងមិនចាំបាច់ព្រួយផង !

- មិនអីទេប្អូន ! បងរស់នៅជាមួយមនុស្សមកពីស្រុកជាមួយបង ...មិនអីទេ !



www.elibraryofcambodia.org

ថាហើយជនក៏ចូលទៅបន្ទប់ទឹកលប់លាងខ្លួនដើម្បីកុំឱ្យធុំញើស ព្រមទាំងផ្លៀត ផ្លាស់ខោអាវដែលខ្លួនមានផ្ញើទុកនៅផ្ទះចៅកែស៊ីក្លូ ។ ជនរៀបរយយ៉ាងរហ័ស ក៏ដើរចេញទៅឃើញ ហ្សេដេរ៉ូ ឈររង់ចាំអ្នកនៅខាងមុខទ្វារចូល ។ អ្នកដើរទៅជិត រួចនិយាយខ្សឹបៗ ÷

- ខ្ញុំមកដល់ហើយលោក !

ហ្សេដេរ៉ូភ្ញាក់ព្រើត ហើយពោល ÷

- គឺពិតជាឯងប្រាកដឬ ?

- បើមិនមែនខ្ញុំនោះ តើលោកថាជាអ្នកណាវិញ ?

ហ្សេដេរ៉ូ សើចបញ្ចេញសំឡេងលាន់ក្អឹកៗ រួចឆ្លើយថា ÷

- ខ្ញុំថាជាតារាភាពយន្ត !

- ឱ ! ខ្ញុំនេះឬដល់ម្ល៉ឹងផងហ្ន៎ ?

- បើខ្ញុំជាស្រី ខ្ញុំនឹងស្រឡាញ់ឯង !

- ចុះបើលោកជាប្រុស ?

- មានតែការខកចិត្ត ។

ហ្សេដេរ៉ូ និងជន និយាយគ្នាយ៉ាងស្និទ្ធស្នាលអស់រយៈពេលមួយសន្ទុះ ។ ទើបអ្នកទាំងពីរបណ្ដើរគ្នាចូលទៅក្នុងរង្គសាល ។ ទីនោះងងឹតព្រាលៗ មានតែពន្លឺតូចៗនៅតាមពិតាន ចាំងផ្លេកៗដូចគ្រាប់ពេជ្រ ។ ភ្លេងប្រគំរងំបន្ទរដោយចង្វាក់ស្លោមួយៗយឺតៗ ។ ជនអាចមើលទិដ្ឋភាពក្នុងរង្គសាលបានហើយ ។ គេឃើញកៅអីពួកមានបង្អែកដាក់តម្រៀបទល់មុខគ្នា ។ នៅខាងលិចអ្នក មានទីលានមួយសម្រាប់ជាឆាករាំ ដែលនៅជាប់នឹងឆាកនោះ ក្រុមតន្ត្រីករកំពុងប្រគំបទភ្លេងយ៉ាងពីរោះលន្លង់លន្លោចក្រៃលែង ។ ជន អួលណែនក្នុងឱរា រួចនឹកសង្វេគអនិច្ចានឹងខ្លួនឯង ដែលកំពុងតែឈានជើងចូលក្នុងភពមួយ ខុសប្លែកពីជីវិតពិតរបស់ខ្លួនប្រចាំថ្ងៃ ។ ស្រីៗស្អាតៗអង្គុយដង្ហែជិតមាត់ទ្វារចូល ។ ជនភ្ញាក់



www.elibraryofcambodia.org

ទីនេះបងមានមុខរបរបន្តិចបន្តួចដែរ គ្រាន់បានចាយខ្លះ ។

- អ្ហា ! មុខរបរអ្វីទៅ ?

- គឺលក់ដូរបន្តិចបន្តួច...ហើយពេលណាទៅ បងអាចបានជួបកូន ?

លោកស្រីចម្ប៉ាងាកមើលនាឡិកាព្យួរ រួចឆ្លើយ ៖

- ម៉ោងប្រាំសាមសិបនាទីទៅហើយ...បងទ្រាំចាំបន្តិចទៅ ! បងនឹងបានទទួលដំណឹងខ្លះៗហើយ ។ និយាយអីចឹង ! អ្នកបងមានអញ្ជើញទៅមើលផ្ទះទេ ?

- នៅទេ !...បងទើបតែមកភ្នំពេញ ពីរបីថ្ងៃ មិនទាន់បានដើរទៅណាក្រៅពីទៅលក់ត្រកួនជាមួយប្អូនសាមិត្ត នៅផ្សារបឹងកេងកង ។ គិតឱ្យសព្វទៅ មនុស្សយើងអើយខ្វល់ខ្វាយតែពីរឿងស៊ីចុកតែមួយប៉ុណ្ណោះ ។

នៅវេលាម៉ោងប្រាំមួយល្ងាច លោកស្រីចម្ប៉ាបានចុចទូរស័ព្ទហៅអ្នកយាម ឱ្យមកទទួលមីងបុល ទៅជួបជន ដែលលោកស្រីបានណាត់ ។

អ្នកយាមបានហៅជន ឱ្យមកជួបមីងបុលតាមពាក្យលោកស្រីចម្ប៉ា ។ មីងបុលគ្រាន់តែជួបជន ក៏ដូចជាមានចិត្តអន្ទះសា រួចដាក់សំនួរផ្ទួនៗភ្លាមៗមួយរំពេច ៖

- ក្មួយប្រុសជួបកូនស្រីខ្ញុំនៅឯណា ?

- គឺជួបតាមផ្លូវ ។

និយាយហើយ ជន ដកដង្ហើមធំ រួចឆ្លើយទាំងប្រថុយប្រថាន ដូចមនុស្សទៅប្រឡងចេះមេរៀនមិនប្រាកដ ៖

- ខ្ញុំជួបកូនមីងដោយចៃដន្យ នាងឈ្មោះរ៉ាវិនមែនទេ ?

- មែនហើយ !...ធ្វើម្ដេចទៅមីងបានជួបរ៉ាវិន ! សូមក្មួយជួយគិតមីងផង មីងដូចជាភ្លេចភ្លាំង គាំងគំនិតអស់ហើយ !

- អីចឹង បើតាមគំនិតរបស់ខ្ញុំ ! ខ្ញុំចង់ឱ្យមីងអញ្ជើញទៅផ្ទះសិន ដើម្បីឱ្យខ្ញុំបានស្គាល់ផ្ទះមីងផង ! ចំណែកខ្ញុំ ជារៀងរាល់យប់តែងតែទៅទទួលជនបរទេស ហើយជន


www.elibraryofcambodia.org

បរទេសនោះមានសន្តានចិត្តល្អណាស់ គេឱ្យខ្ញុំចូលរួមកំសាន្តក្នុងរង្គសាល និងជាថៃ្ងដែលឱ្យខ្ញុំក៏បានស្គាល់វ៉ាវិន ។ ខ្ញុំកំពុងតែតាមដានថាតើផ្ទះនាងនៅឯណាឱ្យពិតប្រាកដ !

ជនឈប់បន្តិចដូចជាខំរកនឹករឿងរ៉ាវអ្វីមួយដែលខ្លួនបានជួបវ៉ាវិននៅគ្រាដំបូង ។ អ្នកកំលោះបន្តទៀត ÷

- ខ្ញុំបានយកនាងទៅដាក់នៅសណ្ឋាគារ សាន់វេ ហើយខ្លួនខ្ញុំរៀប នឹងបានរាំជាមួយនាងផង ! ប៉ុន្តែអាក់ខានទៅវិញ ។

- ម៉េចអីចឹង ? (មីងបុលងាកទៅសួរជន)

- មកពីខ្ញុំមិនចេះរាំនេះម៉្យាង ឯម៉្យាងទៀតនាងវ៉ាវិនមានការចាំបាច់ដែលខ្ញុំមិនអាចដឹងដល់ ។

ជនបញ្ជិះមីងបុលត្រឡប់មកផ្ទះវិញដោយសន្យាថា កាលណាគេជួបវ៉ាវិន គេនឹងឆ្លៀតយកដំណឹងនេះមកប្រាប់មីងបុល ។ មីងបុលសួរទៅជនដែលកំពុងតែធាក់ស៊ីក្លូ ÷

- ក្មួយត្រូវជាអ្វីនឹងលោកស្រីចម្ប៉ា ?

- ខ្ញុំគ្មានត្រូវជាអ្វីនឹងលោកស្រីទេ ប៉ុន្តែពេលលោកស្រីត្រូវការមនុស្សចេះ ភាសាអង់គ្លេសដើម្បីជូនភ្ញៀវទៅតាមសេចក្តីត្រូវការរបស់គេនោះ អ្នកធ្វើការនៅសណ្ឋាគារនេះមួយចំនួនដែលធ្លាប់ស្គាល់ខ្ញុំ កាលនៅជាសិស្សបឋមជាមួយគ្នា គេក៏មកហៅខ្ញុំ .. ប៉ុន្តែមិនមករហូតទេ គឺតែមួយរយៈប៉ុណ្ណោះ ។

- អ្ហុះ ! ...សណ្ឋាគារត្រូវការអ្នករត់ស៊ីក្លូអីចឹងឬ ?

មីងបុលគាត់នឹកហួសចិត្ត ក៏របូតមាត់និយាយនូវឃ្លាខាងលើនេះ ។ ជនអស់សំណើចលាន់ក្អឹកៗ រួចឆ្លើយថា ÷

- សណ្ឋាគារមិនរកអ្នករត់ស៊ីក្លូទេ ...តែលោកស្រីចម្ប៉ា លោកត្រូវការអ្នកជូនភ្ញៀវគាត់ដែលជាជនជាតិបរទេស ។ ហើយខ្ញុំមានស៊ីក្លូធាក់ក៏ធាក់ជូនភ្ញៀវនោះតែម្តងទៅ ! ឃើញថាមិនត្រឹមតែត្រូវជូនភ្ញៀវចាប់តាំងពីម៉ោង ប្រាំបួនយប់ទៅទេ តែមាន


www.elibraryofcambodia.org

មនុស្សជិះហួរហែបន្ថែមទៀតតាំងពីព្រលប់ម្ល៉េះ ហើយបើខ្ញុំមិនច្រឡំទេ គឺខ្ញុំបានជួប រ៉ាវិនទៅតាមផងផ្លូវ ម៉ៅសេទុង នោះនាគ្រាដំបូងនៅពេលយប់មួយ... បន្តមកទៀតខ្ញុំក៏បានជួបនាងនៅក្នុងវត្តសាល រួចបានរួមតុជាមួយគ្នាទៀតផង ! បើខ្ញុំដឹងមុនថាមីងចង់ជួបកូនឈ្មោះរ៉ាវិននេះ ម្ល៉េះសមខ្ញុំសួរនាំនាងតាំងពីជួបគ្នាដំបូងម្ល៉េះ ! ខ្ញុំរៀបរាប់យ៉ាងនេះ មីងយល់ ច្បាស់ណាស់មែនទេ ?

- អឺ ! យល់ហើយក្មួយ !

- ចុះមីងត្រូវជាអ្វីនឹងលោកស្រីចម្បា ?

- លោកស្រីត្រូវជាញាតិសន្តាន បើរៀបរាប់ទៅវែងឆ្ងាយណាស់ ! គេទៅរៀននៅឯបរទេសតាំងពីសម័យ លន់ នល់ ម្ល៉េះ ! គេមកធ្វើការនៅស្រុកខ្មែរយើងនេះតែមួយរយៈពេលប៉ុណ្ណោះទេ តែកាលណាចប់កិច្ចសន្យាហើយ គេត្រូវធ្វើបន្តទៀត ឬត្រូវឈប់ទៅតាមសេចក្ដីត្រូវការរបស់ម្ចាស់សណ្ឋាគារ ។

- ចុះផ្ទះមីងនៅឯណាដែរ ?

- ផ្ទះមីងពិតប្រាកដនៅខេត្តព្រះវិហារឯណោះ...តែមីងមកភ្នំពេញនេះស្នាក់នៅតាមទំនប់បឹងទំពុន...

ឮតែពាក្យបឹងទំពុន ជនភ្ញាក់ ព្រមទាំងរលាស់សម្ដី ÷

- អឺស !... មីងនឹងខ្ញុំនៅជិតគ្នាសោះ !

- ក្មួយនៅត្រង់ណា ?

- ខាងត្បូងវត្តសន្សំកុសល ។

- និយាយចុះនិយាយឡើង យើងនៅក្បែរគ្នា... អីចឹងស្រួលហើយ ! បើបានដំណឹងពីរ៉ាវិនកាលណា កុំភ្លេចឆ្មៀតប្រាប់មីងផងណា !

- បាទ !

ត្រីចក្រយានប្រើដោយកម្លាំងរបស់កំលោះជន បាននាំមីងបុលមកដល់ផ្ទះនៅ


www.elibraryofcambodia.org

វេលាម៉ោង ប្រាំពីរ យប់ ។ គាត់បង្គាប់ឱ្យជនឈប់ រួចនិយាយគួរសមថា ÷

- ក្មួយចូលផ្ទះមីងបន្តិចសិនទៅ! ដើម្បីឱ្យអ្នកផ្ទះនេះបានស្គាល់ក្មួយផង ពីព្រោះក្រែងលោមីងត្រូវការទៅព្រះវិហារវិញ... មិនជួបមីងយ៉ាងណា អ្នកផ្ទះនេះអាចជួយសម្រួលឱ្យមីងបាន !

ថាហើយមីងបុលក៏ចុះពីស៊ីក្លូ ហើយនាំជនចូលទៅបង្ហាញមុខអ្នកផ្ទះទាំងពីរនាក់បងប្អូន ។

មីងបុលនិយាយណែនាំប្រាប់អ្នកទាំងពីរ ÷

- នេះជាអ្នកធ្លាប់បានជួបកូនរ៉ាវិន !

ជនលើកដៃប្រណម ព្រមទាំងវាចា :

- ជម្រាបសួរមីង !

សាមិត្ត និង សាមួន ភ្នឹកបន្តិចក៏លើកដៃសំពះតបវិញព្រមទាំងនឹកថា : " អ្នកធាក់ស៊ីក្លូរូបនេះស្អាតបាតណាស់ មុខមាត់ស្រស់បស់ទំនងដូចជាមិនសមជាអ្នកទីទ័លសោះ ! " ។ រួចសាមិត្តក៏តបទៅវិញ ÷

- អើ ! លើកដៃថ្វាយព្រះក្មួយ មកហូបបាយជាមួយមីង !

មិនទាន់បានចម្លើយពីយុវបុរសផង សាមិត្តក៏និយាយតែម្នាក់ឯង ÷

-...ញាតិមិត្ត ឪពុកម្ដាយយ៉ាងណាទេ ! បានជាបណ្ដោយឱ្យអ្នកកំលោះមកធាក់ស៊ីក្លូយ៉ាងនេះ ?

មីងបុលប្រញាប់កេះសាមិត្ត ព្រមទាំងនិយាយខ្សឹបៗ ÷

- ឯង រអិលមាត់អាក្រក់ម្ល៉េះ !...ប្រញាប់តែស្មាន បើមិនទាន់ដឹងការពិតផង !

ផ្ទះខ្ទមនេះមានតែអំពូលម៉ែត្រប្រវែងប្រាំមួយតឹកមួយគត់ ។ គេទុកសម្រាប់បំភ្លឺនៅពេលយប់តែប៉ុណ្ណោះ ដែលវាប្រសើរជាងប្រើប្រាស់ចង្កៀងប្រេងកាតហុយផ្សែងខ្មៅ រំខានដល់ការដកដង្ហើម និងយូរៗទៅអាចឱ្យកខ្វក់ដល់សម្ភារៈទៀត ។


www.elibraryofcambodia.org

មីងបុលងាកទៅរកជន ហើយពោលបន្ត ÷

- មកក្មួយហូបបាយជាមួយមីង... ដល់ពេលហូបបាយហើយ... កុំខ្មាសអៀន អី !...ទុកមីងដូចសាច់ញាតិក្មួយទៅចុះ ! ហូបរួចហើយ សឹមត្រឡប់ទៅវិញ !

ជនធ្វើអាកប្បកិរិយាអេះអុញ រួចឆ្លើយបដិសេធ ÷

- អរគុណមីងហើយ ! មិនអីទេ ! ខ្ញុំប្រញាប់ទៅទទួលភ្ញៀវ...ខ្លាចមិនទាន់ម៉ោង ។

សាមិត្តទទូច ÷

- ហូបបន្តិចទៅក្មួយ គ្រាន់បានបង្អន់កុំឱ្យឃ្លានពេក ! មកក្មួយមក !

ជនខ្ជិលប្រកែកនឹងស្ត្រីចំណាស់ច្រើនដង ក៏យល់ព្រមចូលហូបនៅទីនោះ ។ អ្នកទាំងបីរីករាយណាស់ រៀបចំម្ហូបគ្រឿមគ្រោះដែលមានទាំងប៉ុន្មាន មកដាក់ទាំងអស់ហាក់ដូចជាបង្ហាញចិត្តថ្លើមដ៏ស្មោះរបស់ខ្លួនទៅកាន់ភ្ញៀវ ។

វ៉ាយោបក់មករំភើយៗ នាំឱ្យអាហារមានរសជាតិឆ្ងាញ់ពិសា ។ ជនហូបមួយចាន ហើយក៏ថែមមួយចានទៀតរហូតទាល់តែឆ្អែត ។ ម្ចាស់ផ្ទះមិនសួរនាំអ្វីច្រើនទេ ខ្លាចជនរវល់តែនិយាយដែលនាំឱ្យរំខានក្នុងពេលបរិភោគ ។ ក្រោយពេលឆ្អែតហើយ ជនជម្រាបលាម្ចាស់ផ្ទះដើម្បីទៅទទួល ហ្សេដេរ៉ូ តាមការណាត់ជួប ។

ជនត្រឡប់មកផ្ទះវិញ រៀបចំស្លៀកពាក់ស្អាតបាតខុសពីសព្វមួយដង ព្បិតអ្នកមានគោលបំណងចង់ទាក់ទាញវ៉ារិន បើសិនជាបានជួបដើម្បីឱ្យនាងព្រមនិយាយការពិតប្រាប់អ្នក និងព្រមទាំងចង់ធ្វើជាអ្នកសម្រុះសម្រួលរវាងម្តាយ និងកូនដែលបែកគ្នាឱ្យត្រឡប់មករួមរស់នឹងគ្នាវិញ។ កិច្ចការនេះហាក់ដូចជាស្មុគស្មាញបន្តិចចំពោះកំលោះជនដែលត្រូវសម្រេចចិត្តយ៉ាងណានោះ ពីពេលនេះទៅមុខទៀត ។

ថ្ងៃនេះ ហ្សេដេរ៉ូ និង ជន រសាប់រសល់ប្រញាប់ប្រញាល់មករង្គសាលឱ្យសមតាមបំណងរបស់ខ្លួន ។ ម៉ោង ម្ភៃ និងសាមសិបនាទី ទើបរង្គសាលចាប់ដំណើរការ ភ្ញៀវមក


www.elibraryofcambodia.org

កាន់ទីនេះជាបណ្តើរៗ អ្នកខ្លះមកជាគូប្តីប្រពន្ធ អ្នកខ្លះបណ្តើរសង្សារមកជាមួយ ឯអ្នកខ្លះទៀតមកតែឯកឯងរំពឹងលើនារីរង្គសាល ។ ចំណែកឯជន និង ហ្វេដេរ៉ូ ហាក់ដូចជាក្លាយទៅជាមិត្តជិតស្និទ្ធនឹងគ្នាទៅហើយ ។ ជនមានតែកម្លាំងកាយបម្រើ ហ្វេដេរ៉ូ រីឯ ហ្វេដេរ៉ូមានប្រាក់ ដូច្នេះទាំងពីរមុខ កម្លាំង និង មាសប្រាក់នេះអាចគួបផ្សំគ្នាបាន ។

មុននឹងទៅដល់រង្គសាល ហ្វេដេរ៉ូបាននាំជនចូលហាងបរិភោគអាហារពេលល្ងាចសិន ។ កំលោះជនញ៉ាំតែបន្តិចបន្តួច ធ្វើឱ្យហ្វេដេរ៉ូឆ្ងល់ ក៏សួរ ÷

- ហេតុអ្វីបានជាឯងញ៉ាំតិចម្ល៉េះ ?

- ខ្ញុំញ៉ាំពីផ្ទះរួចខ្លះហើយ !

ជនបែរសំនួរ សួរទៅ ហ្វេដេរ៉ូ ÷

- ថ្ងៃណាអ្នកត្រឡប់ទៅប្រទេសអ្នកវិញ ?

- មួយអាទិត្យទៀត !

- អ្នកមានគម្រោងការយ៉ាងណាខ្លះ នៅទីនេះ ? (ជនសួរបន្ត) ។

- ខ្ញុំមានផែនការទៅទស្សនកិច្ចប្រាសាទព្រះវិហារ នៅខេត្តព្រះវិហារ រួចទៅភ្នំគូលែន នៅខេត្តសៀមរាប ។

- តែមួយអាទិត្យប៉ុណ្ណោះ អ្នកទៅច្រើនកន្លែងយ៉ាងនេះ ខ្ញុំគិតថាមិនអាចទៅរួចទេ ។ តែបើទៅខេត្តព្រះវិហារហើយទៅទស្សនាប្រាសាទព្រះវិហារ ហើយត្រឡប់មកខេត្តសៀមរាបទៀត ខ្លាចក្រែងតក់ក្រហល់ពេក ហើយហត់នឿយខ្លាំងណាស់ ។ ម៉្យាងខ្ញុំគិតថាបាន ! ប៉ុន្តែទាល់តែអ្នកជិះយន្តហោះទៅខេត្តសៀមរាប រួចសឹមទៅភ្នំគូលែនហើយចេញពីភ្នំគូលែនតម្រង់ទៅខេត្តព្រះវិហារតែម្តង បើធ្វើដូច្នេះគឺសម្រេចបាន !

កិច្ចសន្ទនាបានបញ្ចប់ទៅយ៉ាងល្អកល្អិន ធ្វើឱ្យហ្វេដេរ៉ូកាន់តែទុកចិត្តលើជន ជនបរទេសមើលនាឡិកាដៃ រួចហៅអ្នកបម្រើឱ្យមកគិតលុយ ។ បន្ទាប់មកទៀតអ្នកទាំងពីរក៏ធ្វើដំណើរមករង្គសាលហ្គោជិនបូស ។ ពេលនេះ ជន និង ហ្វេដេរ៉ូ ក៏ចូលទៅ


www.elibraryofcambodia.org

រង្គសាលដូចភ្ញៀវឯទៀតដែរ ចម្លែកតែជនម្នាក់ប៉ុណ្ណោះ កែវភ្នែករបស់គេរេគ្រប់ទិសទី ហាក់ដូចចង់រកអ្វីមួយ ។ ស្រាប់តែរំពេចនោះ ចក្ខុរបស់កំលោះយើងក្រឡេកឃើញនារី វ៉ាវិន ដែលកំពុងអង្គុយ នៅជួរកៅអីនារីកំដរ ។ ជនភ្ញាក់មាត់ " ហ្អះ ! វ៉ាវិន ! " ។

ជនលួចត្រេកអរព្រួច ប្រៀបដូចជារបស់បាត់ហើយរកឃើញវិញ ។ នៅពេលអង្គុយស្រួលបួលហើយ ជនហៅអ្នកបម្រើមកខ្សិប ÷

- គឺពួកយើងត្រូវការនារីកំដរ ដដែលនោះ ។

ថាហើយជនចង្អុលបន្ថែមទៀត ខ្លាចក្រែងលោអ្នកបម្រើយកមកមិនចំចិត្តខ្លួន ។ បន្តិចក្រោយមក នារីទាំងពីរ វ៉ាវិន និង ដារី ក៏មកប្រស្សក្សចំពោះមុខជន និង ហេងដូ ។ ហេងដូទាញដៃដារីឡើងរាំដោយស្និទ្ធស្នាល ចំណែកឯជនវិញ ក្នុងពេលនោះអ្នកមានគោលបំណងសម្ងាត់ចំពោះវ៉ាវិន ដូច្នេះហើយអ្នកប្រញាប់ប្រញាល់សម្ដែងអាការៈស្និទ្ធស្នាលដើម្បីឱ្យវ៉ាវិនទុកចិត្ត ។ ម្យ៉ាងទៀត ជនបង្ហាញតែទឹកមុខញញឹមៗមួយមុខប៉ុណ្ណោះជាសក្ខីភាពបញ្ជាក់ពីសមានចិត្តដែលខុសពីពេលមុន ។ ជនចាប់ផ្ដើមបបួលវ៉ាវិន ÷

- វ៉ាវិន ! នាងសន្យាថាបង្រៀនខ្ញុំរាំ...ឥឡូវខ្ញុំត្រៀមខ្លួនរួចស្រេចហើយ !

វ៉ាវិនញញឹមបញ្ចេញស្នាមខួចម្ខាងនៅថ្ពាល់ឆ្វេង លើកសម្រស់ឱ្យស្រស់ត្រកាលដូចបុប្ផាត្រូវទឹកសន្សើម ។ ជនសម្លឹងគេរាំងដោយក្នុងចិត្តលួចកោតសរសើរសម្រស់ស្រស់ស្រី ហើយគិតថា : " ហេតុអ្វីបានជានាងដាច់ចិត្តមកធ្វើ ជានារីតាមរង្គសាលដូច្នេះ ? ដោយសារការភ្លើតភ្លើននៃកាមគុណ ឬមួយដោយសារប្រាក់អូសទាញ ? " ។

សម្រស់នាងវ៉ាវិនដែលជនទើបនឹងចាប់ផ្ដើមសម្លឹង គយគន់យ៉ាងយកចិត្តទុកដាក់នៅរាត្រីនេះ បានទាក់ទាញដួងចិត្តអ្នកកំលោះឱ្យរន្ធត់ញាប់ញ័រយ៉ាងចម្លែក ។ ភ្លាមនោះអារម្មណ៍ជនប្រែប្រួលយ៉ាងរហ័ស ដោយចង់ហួងហែងនាងសម្រាប់តែខ្លួនឯងម្នាក់ប៉ុណ្ណោះ ។

វ៉ាវិន ងើបឈរឡើងបង្ហាញរាងស្ដើងល្វតល្វន់ ស័ក្តិសមនឹងសម្លៀកបំពាក់រឹប


www.elibraryofcambodia.org

រាងទៀតនោះ ធ្វើឱ្យនេត្រារបស់ជនភ័ន្តច្រឡំ នឹកស្មានតែនាងជាទេពអប្សរធ្លាក់ពីលើមេឃ ។ អ្នកកំលោះឧទានខ្សឹបៗល្មមឮតែក្នុងដួងចិត្តខ្លួនៈ " រ៉ាវិន !...រ៉ាវិន !.... នាងស្អាតណាស់ !.... ស្អាតគ្មានគូប្រៀបទេ "។ កំពុងតែឈររបៀបភ្លេចភ្លឹក នឹងសម្រស់ស្រី ស្រាប់តែជនត្រូវរ៉ាវិនចាប់ដៃទាញចូលក្នុងទីលានរាំ ។ ជនញញាក់ ញញ៉ើរដូចត្រីត្រូវមួយដំបង ។ ឃើញសភាពដូច្នេះ រ៉ាវិនក៏សួរខ្សឹបៗ ÷

- យ៉ាងម៉េចបង...មិនស្រួលខ្លួនឬ ?

- មិនអីទេ...បង្រៀនបងរាំមក់រ៉ាវិន...តឹបងចង់រាំជាមួយអូន !

រ៉ាវិន បង្ហាញជនឱ្យទ្រដៃនាង ព្រមទាំងបង្គាប់ឱ្យយកដៃម្ខាងទៀតនោះក្រសោបចង្កេះដ៏រាវស្លូចរបស់នាង ។ ជនធ្វើគ្រាប់បានយ៉ាងល្អ ដោយសារមានឥទ្ធិពលចម្លែក បណ្តាលឱ្យអ្នកទាំងពីររាំត្រូវចង្វាក់ភ្លេងបានល្អ ។ ជនបន្តឹងដៃរឹតរ៉ាវិនឱ្យខិតយ៉ាងស្អិទ្ធជាប់នឹងឱរា រួចអ្នកហាក់ដឹងថាទ្រូងរ៉ាវិនដ៏ក្រពុំស្រួច បានចាក់ទម្លុះទ្រូងអ្នកឱ្យធ្លុះធ្លាយ ។ ពីមុន ជន បានតាំងចិត្តយ៉ាងម៉ឺងម៉ាត់ និងសន្យាថា មិនយកភ្នែកមើលជាដាច់ខាត ស្រីដែលរកស៊ីតាមចិញ្ចើមថ្នល់ ឬតាមរង្គសាល ប៉ុន្តែរាត្រីនេះ ជន ហាក់ដូចជាកំពុងក្បត់ពាក្យសន្យារបស់ខ្លួន ហើយការតាំងចិត្តទាំងអម្បាលម៉ាន ក៏ត្រូវរលត់រលាយសូន្យសុង នៅសេសសល់តែការស្រើបស្រាលនៃចំណង់តណ្ហាតែប៉ុណ្ណោះ ។ នេះហើយស្រី ជាឧបករណ៍ដ៏ស័ក្តិសិទ្ធិទាក់ទាញដួងចិត្តបុរសឱ្យលិចលង់ក្នុងតណ្ហាប្រាកដមែន ។

- រ៉ាវិន !...(ជនហៅឈ្មោះរ៉ាវិន ហាក់ដូចខ្លាចភ្លេចឈ្មោះនេះ) ។

នាងបិទនេត្រាកំពុងទទួលភាពសុខស្រួល លុះឮសំឡេងហៅឈ្មោះដូច្នេះ រ៉ាវិនក៏បើកភ្នែកឡើង ហើយសម្លឹងចំមុខជន ។ នាងឆ្លើយ ÷

- ចាស ! (ដ៏ផ្អែមពីរោះ)

- រ៉ាវិន ប្រាប់បងបានទេ ថាអូនជាអ្នកណា នៅឯណា ?

- ហេតុអ្វីក៏រាត្រីនេះ បងចង់ដឹងពីប្រវត្តិរបស់ខ្ញុំម្ល៉េះ ?


www.elibraryofcambodia.org

- ព្រោះបងពេញចិត្តរូបអូន ។

- ពេញចិត្តខ្ញុំ ? (រ៉ាវិនឧទានដោយផ្ទួនពាក្យទៀត) ពេញចិត្តខ្ញុំ !... គឺមានតែបងម្នាក់ទេដែលនិយាយពាក្យនេះចេញមកសម្រាប់រូបខ្ញុំ បងមិនសមនឹងប្រើពាក្យថ្លៃថ្នូរដូច្នេះទេ... បងដឹងទេថាខ្ញុំជានារីវង្គសាល ។

គ្រាន់តែឮពាក្យនេះ ជន ក៏ប្រញាប់យកដៃខ្ទប់មាត់រ៉ាវិន ហាក់ដូចបង្ខំបញ្ឈប់មិនឱ្យនាងនិយាយតទៅទៀត ។ រ៉ាវិនសម្លឹងមុខជនដោយក្រសែភ្នែកស្រទន់គួរឱ្យអាណិត ។ ជនសួរនាងបន្តទៀត ÷

- នាងជាកូនចៅអ្នកណា ?

- ខ្ញុំជាកូន " ទឹក ដី ភ្លើង ខ្យល់ "...

ទន្ទឹមនឹងពាក្យទឹក ដី ភ្លើង ខ្យល់ ទឹកភ្នែកដ៏ថ្លាឆ្វង់រមៀលធ្លាក់កាត់ថ្ពាល់ដូរផង់របស់នាង ដែលជនគិតថាមិនគួរធ្វើឱ្យនាងសៅហ្មងក្នុងចិត្តសោះ ។

រ៉ាវិន បន្លសំដីរអាក់រអួល រួចហើយធ្វើជាអស់សំណើច ដើម្បីលុបស្នាមជីវិតដ៏ជូរចត់សោកសៅ ÷

- ...មិនសំខាន់ទេបង... ទោះប្រាប់ក៏បងមិនស្គាល់ដែរ.... ណ្ហើយកុំខ្វល់ថ្វី... បងកុំហកខ្ញុំថាមិនចេះរាំ...ការពិតទៅបងចេះយ៉ាង ប្រសប់ទៀតផង ។

ជន ខ្វិលប្រកែក ដោយបណ្តោយឱ្យរ៉ាវិនគិតទៅតាមចិត្តនាងយល់ឃើញទៅចុះ ។ តាមការពិតចង្វាក់យឺតនេះមិនពិបាកទេ តែគេចង់ចេះគឺចេះភ្លាម ជាពិសេសអ្នកបង្រៀនស្អាតដូចរ៉ាវិនដូច្នេះ ថែមទាំងមានចរិតក្អិកក្អក់ រីងរឹតតែជម្រុញជនឱ្យចង់រាំក្រសោបរាងកាយដ៏ល្វតល្វន់នេះក្នុងរង្វង់ហត្ថាទាំងទ្វេ ។

ពេលកំពុងរាំ វិញ្ញាណអ្នកទាំងពីររសាត់អណ្តែតដល់ភពមួយដ៏សែនឆ្ងាយ នោះគឺភពស្នេហ៍ដែលមនុស្សលោកទាំងឡាយរមែងវង្វេងវង្វាន់ ប្រកាប់ប្រចាក់គ្នាឥតឈប់ឈរហួងហែងនារី ឬបុរសជាគូស្នេហ៍មកជាកម្មសិទ្ធិផ្តាច់មុខ របស់គេតែម្នាក់ឯង ។


www.elibraryofcambodia.org

តាំងពីតូចរហូតដល់ធំ ជនមិនដែលយកភ្នែកមើលនារីណាម្នាក់សោះ ពីព្រោះអ្នកខ្លាច ខ្លាចខ្លាំងណាស់ ខ្លាចក្រែងហែលឆ្លងសមុទ្រស្នេហ៍មិនផុត ។ ប៉ុន្តែនៅរាត្រីនេះ អ្នកចង់ធ្វើខ្លួនឱ្យជិតស្និទ្ធ ដើម្បីស៊ើបដំណឹងពីរ៉ាវិនឱ្យម្ដាយនាង ប៉ុន្តែបែរជាមកជំពាក់រ៉ាកវិនចិត្តអ្វីនឹងរូបដែលគ្មានខ្លឹមសារនេះទៅវិញ ។ " ណ្ហើយ ! កុំរវល់នឹងស្រើបស្រាលរបៀបនេះ " ជនបង្ក្រាបចិត្តរបស់ខ្លួនដែលកំពុងតែកញ្ជ្រោលនឹងសម្រស់របស់រ៉ាវិនឱ្យមានប្រក្រតីភាពឡើងវិញ ។

ជនគិតចុះគិតឡើងទៀត" បើជជីកសួរនាងខ្លាំងពេកទៅ ក្រែងលោនាងសង្ស័យ ទើបតែស្គាល់គ្នាសោះ ហេតុអ្វីក៏សួររកម៉ែ-ឪ សួរអាសយដ្ឋាន មិនសមទេដឹង ? បើដល់ពេលជួបម្ដាយរ៉ាវិន មានអ្វីយកទៅនិយាយប្រាប់គាត់... យី ! ការនេះពិបាកខ្លាំងណាស់ណាមួយឯងគ្មានចំណេះខាងតាមដាន មិនដឹងជាត្រូវផ្ដើមរបៀបណា " ។ ជនគ្មានការពិសោធន៍របៀបនេះទាល់តែសោះ ពីព្រោះជីវិតអ្នកជាជីវិតទុរគតជន ដឹងតែរកបាយហូប ហើយនិងរៀនតែប៉ុណ្ណោះ ។ កំពុងតែគិតមិនដាច់ស្រេចដូច្នេះ ស្រាប់តែមានតំណក់ទឹកក្ដៅឧណ្ហៗ ស្រក់តក់ៗបន្ថែមទៀតមកលើដៃជន ពេលរ៉ាវិនគេចមុខទាំងខ្សឹកខ្សួល ។ ជនឱនខ្សឹបទៅក្បែរត្រចៀកនាង ÷

- នាងមិនស្រួលខ្លួនឬ ? ទៅយើងត្រឡប់ទៅកន្លែងវិញ !

រ៉ាវិនមិនឆ្លើយ ប៉ុន្តែនាងដោះដៃពីជន បញ្ជាក់ថា នាងយល់ព្រមទៅកន្លែងអង្គុយវិញ ។ បទភ្លេងយឺតៗនៅតែបន្ត ចំណែកឯអ្នករាំក៏នៅតែបន្តការឱបរឹតយ៉ាងភ្លើតភ្លើន ។ ឃើញរឿងរ៉ាវយ៉ាប់យ៉ឺនយ៉ាងនេះ ជនហាក់ដូចជាសោកស្ដាយពីដំបូងថា ហេតុអ្វីបានជាខ្លួនចូលមកធ្វើការកន្លែងជូនភ្ញៀវបរទេសយ៉ាងនេះ ហើយថែមទាំងត្រូវធ្វើការតាមដានកូនឱ្យម្ដាយគេទៀត ។ ការជ្រមុជខ្លួននេះកាន់តែផុងជ្រៅទៅៗ ។ " ណ្ហើយ ! កើតមកជាកូនប្រុស ហើយឃើញការងារពិបាកហើយ រាថយទៅវិញ ដូចជាមិនសមសោះ " ។ គិត ដូច្នេះហើយ ជន ហាក់ដូចមានកម្លាំងកំហែងឡើងវិញ ដើម្បីបន្តការប្រយុទ្ធតស៊ូ ។


www.elibraryofcambodia.org

ព្រើតនឹងនារីម្នាក់ពាក់អាវប៉ាក់ឱន ហើយនឹកក្នុងចិត្តថា : " ពិតជានាងនោះហើយ ដែលជិះស៊ីក្លូរបស់ខ្លួនពីព្រលប់ " ។ ជនឮសំឡេងហ្វេដេរ៉ូ ហៅ ក៏ងាកក្រោយ ÷

- យើងនឹងអង្គុយត្រង់ណា ? ( ហ្វេដេរ៉ូសួរជន ) ។

ជនចង្អុលត្រង់ទៅមុខសំដៅទៅទិសខាងត្បូង ព្រោះទីនោះមានកៅអីនៅសល់ ទំនេរ ។ គ្រាន់តែបុរសទាំងពីរអង្គុយចុះភ្លាម អ្នកបម្រើក៏រៀបចំកែវទឹកកក ហើយគាស់ស្រាបៀរដាក់កែវព្រមទាំងយកគ្រឿងក្លែមមកជាបន្ទាន់ ។ អ្នកបម្រើឱនមកខ្សឹបសួរជន ÷

- លោកត្រូវការស្រីកំដរទេ ?

ជនសួរទៅហ្វេដេរ៉ូបន្ត ។ ជនបរទេសងក់ក្បាលជាសញ្ញាយល់ព្រម ដោយលើកម្រាមដៃពីរ ។ អ្នកបម្រើយល់សេចក្តីបាន ក៏ស្ទុះភ្លែត ប៉ុន្តែត្រូវជនឃាត់ ហើយប្រាប់ថា ÷

- យកពីរនាក់មក...តែនាងម្នាក់ពាក់អាវប៉ាក់ឱន...ឯម្នាក់ទៀតត្រូវចេះនិយាយភាសាអង់គ្លេសផង !

អ្នកបម្រើតបមកវិញដោយសំដីតិចៗ ÷

- សុទ្ធតែចេះអង់គ្លេសតែទាំងអស់ហ្នឹង !

- អីចឹងស្រួលហើយ !...តែពិសេសនាងម្នាក់ពាក់អាវប៉ាក់ឱន ។

អ្នកបម្រើឆ្លើយ " បាទ ! "ហើយក៏ចេញបាត់ទៅ ។ បន្តិចក្រោយមក នារីពីរនាក់ ដើរត្រសងមករកតុហ្វេដេរ៉ូ ។ បុរសទាំងពីរអញ្ជើញភ្ញៀវឱ្យអង្គុយ ។ ស្រីម្នាក់ស្លៀកអៀមរីបចង្កេះវែងដល់កែងជើង វៀលក វៀលក្លៀក ពណ៌ខៀវចាស់ ប៉ាន់ជរពណ៌ស នៅខាងមុខត្រង់ទ្រូង ។ នាងពាក់ស្បែកជើងកែងស្រួច បន្ទើតចង្កើតបង្ហាញឱ្យឃើញរាងល្វតល្វន់ រាវស្តើង ងខ្ចើត ស័ក្តិសមនឹងដើមទ្រូងពើងយ៉ាងព្រហើនអើនទៅមុខ ។ ហ្វេដេរ៉ូចាប់ដៃនាងឱ្យអង្គុយ ឯដៃម្ខាងទៀតក្បៀកចង្កេះដ៏ស្លូចរបស់នាងជាប់ ។ ហ្វេដេរ៉ូ ពេញចិត្តនាងពាក់អាវពណ៌ខៀវចាស់នេះណាស់ ប្រហែលដោយសារនាងចេះនិយាយភាសាអង់គ្លេសរអិលដូចទឹក ហើយប្រហែលជាដោយសារនាងមានរាងស្តើងខ្ពស់


www.elibraryofcambodia.org

ជនកំពុងគិតរកមធ្យោបាយ ស្រាប់តែព្វាំវិនសួរ ÷

- ហេតុអ្វីក៏បងចង់ដឹងពីឫសគល់របស់ខ្ញុំ ?

វ៉ាំវិនងឹងអក់បន្តិច មិនឮជនមានយោបល់អ្វី នាងក៏បញ្ជាក់ហេតុផល ÷

- បើបងស្គាល់ខ្ញុំត្រឹមសំបកក្រៅដូច្នេះ...រូបខ្ញុំនៅមានតម្លៃខ្លះ...ប៉ុន្តែបើបងបានដឹងពីជីវប្រវត្តិរបស់ខ្ញុំ...ខ្ញុំគិតថា បងច្បាស់ជាស្អប់ខ្ញុំ...ហើយមិនយកភ្នែកមកគយគន់រូបខ្ញុំទេ...យកល្អយើងស្គាល់គ្នាត្រឹមសំបកក្រៅទៅបានហើយ ! ដោយខ្ញុំចង់ទុកឱ្យបងឋិតនៅក្នុងការស្មានថាយ៉ាងនេះឬ យ៉ាងនោះទៅតាមតែបងនឹកទៅចុះ !...

រាត្រីកាលវិកិលទៅមុខ ហ្វេដេរិ៍មនិងនាងដារីកាន់តែស្និទ្ធស្នាល ចំណែកឯជននិង វ៉ាំវិននៅអង្គុយជជែកគ្នា ឯតន្ត្រីករក៏ខិតខំយកអស់ស្នាដៃបម្រើភ្ញៀវយ៉ាងយកចិត្តទុកដាក់ ។ ការសប្បាយរីករាយមានរយៈពេលយ៉ាងឆាប់រហ័ស ម៉ោងជប់ពីរអធ្រាត្រហើយ ហ្វេដេរិ៍ឱនខ្សឹបដាក់ត្រចៀកជន រួចជនដើរទៅនិយាយជាមួយអ្នកចាត់ការរង្គសាល ។ មួយសន្ទុះជនត្រឡប់មកវិញ ហើយឮតែសំឡេងជននិយាយពាក្យតែពីរម៉ាត់ប្រាប់ទៅហ្វេដេរិ៍វិញថា : អូខេ(*OK*) ។ ពាក្យពីរម៉ាត់យ៉ាងខ្លី ប៉ុន្តែមានន័យទូលំទូលាយប្រែថា : អ្វីៗដែលអ្នកប៉ុនប៉ងប្រាថ្នាក្នុងពេលនេះបានសម្រេចហើយ ។

ថ្ងៃនេះពិសេសណាស់ ដោយហ្វេដេរិ៍បានយករថយន្តមក ដូច្នេះគេមានឱកាសបានដឹកដារី និង វ៉ាំវិនមកសណ្ឋាគារកាំបូឌីយ៉ាណា ។ រឿងនេះ ហ្វេដេរិ៍បានរៀបចំចាត់ចែងរួចស្រេចហើយ ។ ហ្វេដេរិ៍ងាកមកសួរជន ÷

- ឯងយ៉ាងម៉េចដែរ បើយើងរៀបចំយ៉ាងដូច្នេះ ?

ជនឆ្លើយដោយគ្មានការគិតទុក ÷

- ពិសេសណាស់ សម្រាប់រូបខ្ញុំ ... សូមឱ្យអ្នកមានសុភមង្គលនៅរាត្រីនេះណា៎ !

ហ្វេដេរិ៍ញញឹមងក់ក្បាលដោយក្តីពេញចិត្ត រួចឆ្លើយតបទៅជនវិញថា ÷

- ឯងក៏ឱ្យជួបសុភមង្គលដែរ ។



www.elibraryofcambodia.org

- អរគុណណាស់ !

ដារីមិននិយាយអ្វី ប៉ុន្តែនាងសើចឱ្យកក្អឹកធ្វើឱ្យបរិយាកាសនៅក្នុងរថយន្ត រីករាយទៅតាមសំណើចនោះដែរ ។ រថយន្តហ្វេដេរ៉ូមកឈប់នៅក្នុងបរិវេណសណ្ឋាគារ ។ ជន មិនភ្លេចងាកមើលទៅផ្ទះអ្នកដែលខ្លួនផ្ញើស៊ីក្លូទេ ពេលនេះគេកំពុងសម្រាន្តលក់ទៅហើយ ដោយបិទទ្វារផ្ទះហើយពន្លត់ចង្កៀងទៀត ។

ហ្វេដេរ៉ូ និងជនបណ្តើរគូស្នេហ៍ទៅបន្ទប់រៀងៗខ្លួន ។ ការពិតទៅ ជនមិនមានចេតនាដូច្នេះឡើយ ប៉ុន្តែដោយសារការចង់ដឹងពីនាងរ៉ាវិន អ្នកកំលោះក៏បណ្តោយខ្លួនឱ្យទៅតាមហេតុការណ៍នេះចុះ ។

ជនចូលទៅក្នុងបន្ទប់ដែលមានកៅអីផ្អែក មានតុលំអដោយថូផ្កា មានទូទឹកកកតូចល្មម និង ទូរទស្សន៍ទំហំ ២១អ៊ីង មួយគ្រឿង ហើយមានគ្រែតែមួយគត់ទៀត ក្រាលដោយកម្រាលសស្អាតគួរឱ្យចង់ទម្រេតខ្លួនយកកម្លាំង ។ នាងរ៉ាវិនចូលបន្ទប់ទឹក ពេលចេញមកវិញនាងមានទឹកមុខរីករាយ ញញឹមញញែម ហាក់ដូចកង្វល់របស់នាងជ្រុះបាត់នៅក្នុងបន្ទប់ទឹកនោះអស់ទៅហើយ ។ ដោយសារទីនេះធាតុអាកាសត្រជាក់រហូតដល់ ២១ អង្សា មាណវីប្រទាក់ដៃគ្នាឱបដើម្បីកុំឱ្យរងាពេក ពីព្រោះនាងពាក់អាវវៀលកវៀលដៃ ។ នាងរអ៊ូតិចៗ ÷

- ត្រជាក់ណាស់បង !

ជន ជិនឬកនឹងនារីរាត្រីនេះ ហើយក្លែងធ្វើជាមិនឮអ្វីដែលនាងនិយាយ ។ រ៉ាវិនឃើញកន្សែងពោះគោធំដែលគេដាក់នៅលើចុងជើងគ្រែ ក៏ទាញយកមកដណ្តប់ រួចផ្តួលខ្លួនលើគ្រែទាំងគ្រលំកន្សែងពោះគោនោះទៅ ។ រ៉ាវិនឡៀតនិយាយមកជន ÷

- បង ខ្ញុំសូមអនុញ្ញាតសម្រាកហើយណា !

- បងមិនអនុញ្ញាតទេ ?

- អីចឹងមានតែបងខ្លាច...


www.elibraryofcambodia.org

ជនប្រញាប់ឆ្លើយកាត់ពាក្យនាងរ៉ាវិន ÷

-...ខ្លាចស្អីទៅ...ស្រីតូចច្រមក់ដូច្នេះ មានអ្វីគួរឱ្យខ្លាចទៅ !... បងមិនខ្លាចអ្វីទាំងអស់ ទោះជាស្លាប់ក៏ដោយ...

រ៉ាវិនឃើញជននិយាយដល់ពាក្យ " ទោះជាស្លាប់ក៏ដោយ " ក៏ងើបស្ទុះភ្លែតទំនងដូចជាស្វាងងងុយ ហើយបញ្ចេញសាជាថ្មី ÷

- ហេតុអ្វីក៏បងមិនខ្លាចស្លាប់ ?...បងដឹងទេថាខ្លួនខ្ញុំមួយអាចសម្លាប់ប្រុសមួយនគរបានណា !

- ប្រាកដណាស់ !... បើទោះជានាងសម្លាប់ពីរ-បីនគរទៀត ក៏ខ្ញុំមិនខ្លាចនាងដែរ !

- ហេតុអីទៅបង ! បងឯងនេះមិនដូចគេឯងដទៃទៀត ដែលគ្រាន់តែខ្ញុំប្រាប់ដូច្នេះ គេមិនរវីរវល់នឹងរូបរាងកាយរបស់ខ្ញុំផង !

គ្រាន់តែចប់សំដីរ៉ាវិន ជនស្ទុះទៅជិត ហើយក្រសោបនាងពេញហត្ថា ធ្វើឱ្យរ៉ាវិនស្រឡាំងកាំង រកតែត្រៀមខ្លួនប្រយុទ្ធជាមុនក៏មិនទាន់ ។ នាងប្រញិបប្រញាប់និយាយ ÷

- កុំបង !... កុំបង !...ខ្ញុំកើតអេដស៍ !

ជន រឹតបន្តឹងបន្ថែមទៀត ហាក់ដូចជាពាក្យកើតអេដស៍នេះជាពាក្យយល់ព្រមស្នេហាទៅវិញ ។ រ៉ាវិនក៏ប្រញាប់និយាយអង្វរ ÷

- បង !...ស្តាប់ខ្ញុំសិន !..បងចង់ដឹងអ្វីពីខ្ញុំ ...ខ្ញុំយល់ព្រមទាំងអស់...

ជននឹកគិតថា : " គោលបំណងដែលចង់ដឹងពីប្រវត្តិនាងរ៉ាវិន ខ្លួននឹងបានសម្រេចហើយ " ។ ជននិយាយបែបមាយា ÷

- ខ្ញុំគ្មានរឿងអ្វីចង់ដឹងពីនាងពេកទេ !...ប៉ុន្តែខ្ញុំចង់ស្លាប់ជាមួយនាង ។

រ៉ាវិននឹកស្មានតែប្រាកដ ក៏អង្វរបន្ថែមទៀតធ្វើឱ្យជនរឹងរឹតតែបានចិត្តទ្វេឡើង÷

- ខ្ញុំសូមអង្វរ...សូមបងអាណិតស្តាប់ខ្ញុំសិន !


www.elibraryofcambodia.org

រ៉ាវិនលើកដៃសំពះជនយ៉ាងសុភាពទន់ភ្លន់គួរឱ្យអាណិត ។ ទឹកមុខនាងរ៉ាវិនធ្វើឱ្យជនចាប់អារម្មណ៍តាំងពីថ្ងៃដំបូងម្ល៉េះ ទោះបីជានាងសំដែងអាកប្បកិរិយាគ្រប់បែបយ៉ាងណាក៏ដោយ ក៏ជនមើលឃើញសភាពស្រគត់ស្រគំ លាក់ទុកអាថ៌កំបាំងនៅក្នុងផ្ទៃមុខនិងនៅក្នុងកែវនេត្រានាងជានិច្ច ។ ជនធ្វើជាពោលពាក្យ ÷

- ល្អើយ ! បើអូនអង្វរទៅហើយ បងត្រូវតែស្តាប់ពាក្យអង្វររបស់អូនចុះ ! ទើបមានតម្លៃ ។

ពោលពាក្យចប់កាលណា ជនលួចត្រេកអរនៅក្នុងចិត្ត រួចធ្វើជានិយាយយ៉ាងម៉ឹងម៉ាត់ ÷

- និយាយទៅមើល៍ រ៉ាវិន ! ថាហេតុអ្វីបានជានាងមកចាប់យកអាជីពជានារីរង្គសាលនេះ ?

- សង្គមនេះនៅតែប្រកាន់ឈ្មោះខ្ញុំជានារីរង្គសាលជាប់រហូត ហើយបើខ្ញុំកែប្រែក្តី ក៏គេមិនលើកលែងឱ្យខ្ញុំដែរមែនទេ ?

- អូនរវល់នឹងសង្គមច្រើនពេកធ្វើអ្វី ! ត្រូវអូនរវល់នឹងខ្លួនអូនខ្លាំងជាងគេ បើយើងបែរជាបានកែខ្លួននោះវាប្រសើរហើយ...ឥឡូវអូនឈប់គិតនឹងសង្គមទៅ...ប៉ុន្តែអូនត្រូវគិតថា បងក្តី ម្តាយអូនក្តី ច្បាស់ជាអភ័យទោសឱ្យអូន កាលណាអូនកែខ្លួន ។

- ខ្ញុំព្រមជឿបងម្តងចុះ ហើយទីបំផុតខ្ញុំសូមឱ្យបងវិនិច្ឆ័យរឿងខ្ញុំថា ហេតុអ្វីក៏បណ្តាលឱ្យខ្ញុំធ្វើដូច្នេះ ពីព្រោះខ្ញុំគិតថា គ្រប់រឿងរបស់មនុស្សក្នុងលោកនេះ សុទ្ធតែមានហេតុផលទាំងអស់ ដូចជាកាលណាមានភ្លើង គឺត្រូវមានផ្សែងជានិច្ចអ៊ីចឹង !

ជននឹកគិតថា : " ឱ ! ជីវិតអើយ ហេតុអ្វីក៏ស្មុគស្មាញខ្លាំងម្ល៉េះ ដូចពាក្យព្រះពុទ្ធលោកតែងតែពោលថា : មានរូបមានទុក្ខ មានរូបគឺមានបញ្ហា ពិតជាពុំមានខុសអ្វីបន្តិចសោះ " ។ ជនផ្តួលខ្លួនលើពូកដ៏ទន់ល្មើយ រង់ចាំស្តាប់រឿងរ៉ាវរបស់រ៉ាវិនយ៉ាងស្ងៀមស្ងាត់ ។

* * * * *



www.elibraryofcambodia.org

# ៣

# ព្យុះភ្លៀងសំណាង

ម៉ោងមួយអធ្រាត្រហើយ ចរាចរនៅតាមផ្លូវព្រះមុនីវង្សបានស្ងប់ស្ងាត់យូរបន្តិចហើយដែរ ។ ប៉ុន្តែជួនកាលមានសំឡេងហួចយ៉ាងគ្រលួចរបស់យុវកម្មករដែលកំពុងតែធាក់ត្រីចក្រយានយឺតៗ ឆ្ពោះទៅលំនៅដ្ឋានរបស់ខ្លួនវិញក្រោយពេលដែលខ្លួនឆ្លៀតរកប្រាក់ពេលយប់ ដើម្បីជួយដល់ការចំណាយក្នុងការរៀនសូត្ររបស់ខ្លួនខ្លះៗ ។ យុវកម្មករនេះ ច្រើនតែរស់នៅតាមវត្តអារាម ត្បិតអ្នកខ្លះជាកូនអ្នកនៅស្រែចម្ការដែលមានជីវភាពទីទ័លក្រ ដូច្នេះហើយបានជាពួកគេឆ្លៀតពេលយប់ខ្លះដើម្បីរកកម្រៃឧបត្ថម្ភខ្លួន ម្យ៉ាងទៀត ពេលយប់មិនសូវមានមនុស្សស្គាល់ច្រើន ហើយគេក៏មិនចង់ឱ្យមិត្តភក្តិដែលរៀនជាមួយគ្នាដឹងរឿងសំងាត់របស់ខ្លួនផង ។ ការងារនេះមិនមែនជាអំពើថោកទាបទេ គួរតែមនុស្សយើងមិនត្រូវខ្មាសអៀនឡើយ ។ ក្រៅពីសំឡេងហួចរបស់យុវកម្មករធាក់ត្រីចក្រយាន នៅមានសំឡេងរថយន្តដែលបរយ៉ាងលឿន ធ្វើឱ្យកក្រើករំពើករួចក៏ស្ងប់ស្ងាត់ទៅវិញ ។ សំឡេងប៉ិកប៉ក់ៗដោយកំណាត់ឫស្សីពុះជាពីរ ជួនកាលក៏បន្លឺសូរស័ព្ទញាប់រន្ថើន ជួនកាលក៏បន្លឺរម្ងើលមួយៗ ដែលសបញ្ជាក់ឱ្យដឹងថានៅមិនឆ្ងាយប៉ុន្មានពីអ្នកវាយប៉ិកប៉ក់នេះ ច្បាស់ជាមានអ្នករុញធុងគុយទាវលក់ជាមិនខានឡើយ ។

អ្នកដែលបរិភោគគុយទាវរុញនេះ មានជាហូរហែ ជាពិសេសអ្នកធាក់ស៊ីក្លូ អ្នកបើកបរឡំប្រិតា[១] អ្នកធ្វើការពេលយប់ ឬអ្នកដើរលេងពេលយប់។

ឆ្នាំ ១៩៧០ ពេលនោះខ្មែរកំពុងស្រវឹងនឹងជោគជ័យដែលបានរំដោះខ្លួនពីរបបរាជានិយម...ហើយរបបមូលធននិយមក៏កំពុងតែចូលជ្រៀតជ្រែកតាមសរសៃសរស្លងមែក

---

១ - ឡំប្រិតា មានកង់បី គេហៅថាវេស្ប៉ា ( *Vespa* ) កង់បី សម្រាប់រត់ឈ្នួល



www.elibraryofcambodia.org

ផាងនៃស្រទាប់វណ្ណៈទាំងអស់ ។ បុណ្យជាតិមួយចំនួនត្រូវលុបបំបាត់ចោលជាស្ថាពរ ។ ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជាឋិតនៅក្នុងរបប " សាធារណរដ្ឋខ្មែរ " ដឹកនាំដោយសេនាប្រមុខ លន់ នល់ ។

នៅលើវេហាស៍ ព្រះចន្ទ្រា ដប់បី រោច ខំប្រឹងបញ្ចេញរស្មីកំដរវាត្រីទៅតាមមុខនាទីរបស់ខ្លួននៃក្រឹត្យក្រមរបស់ធម្មជាតិដែរ ។ នៅកន្លែងខ្លះក្នុងទីក្រុងដែលមានចង្កៀងអគ្គិសនីបំភ្លឺគ្រប់គ្រាន់ រស្មីព្រះចន្ទ្រាហាក់មិនសូវមានន័យ មានតម្លៃប៉ុន្មានឡើយ ប៉ុន្តែបើនៅស្រុកស្រែចម្ការវិញ រស្មីនេះផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងណាស់ ដល់ប្រជាកសិករ ។ សន្សើមក៏ចាប់រុះរោយលើរុក្ខជាតិជាបន្តបន្ទាប់ឡើងសើមរលេរ ។ រីឯបក្សីរាត្រីចរ ក៏ខំស្វះស្វែងរកចំណីអាហារបំពេញក្រពះ ដើម្បីបន្តជីវិតរស់កំដរផែនដីដែលពោរពេញទៅដោយភាពគ្រោតគ្រាត និងផ្អែមល្ហែមលាយឡំគ្នាមិនឈប់ឈរនៃវាលវដ្តសង្សារនេះ ។

ទោចក្រយានយន្តមួយគ្រឿងផ្ទុកអ្នកជិះពីរនាក់ ជិះច្រកកៀវពាក់អាវសឺមីមូរដៃ ស៊កចូលក្នុងខោខូវបូយ *(Cow Boy)* ពណ៌ខៀវ ។ អ្នកបើកបរដែលនៅខាងមុខពាក់អាវពណ៌ស មានមាឌមាំ ចំណែកអ្នកជិះខាងក្រោយ ពាក់អាវពណ៌ផ្ទៃមេឃ មានមាឌស្គមស្តើង ។ អ្នកទាំងពីរពាក់មួកសម្រាប់ការពារក្បាលដែលមានសណ្ឋានដូចជាមួកប្រណាំងអឺចឹង ។ ទោចក្រយានយន្តនោះ បរលឿនពីទិសខាងត្បូងមកទិសខាងជើង រួចឡើងមកខាងជើងវិទ្យាល័យ ១៨ មីនា ( ព្រះយុគន្ធរ )[១] ក្រោមសន្សើមរាត្រីធ្វើឱ្យអ្នកជិះដែលនៅខាងក្រោយយកដៃរបស់ខ្លួនមកឱបចង្កេះអ្នកបើកបរ ។ រួចហើយម៉ូតូក៏មកឈប់នៅភូមិគ្រឹះមួយដែលឋិតនៅទល់មុខរោងចក្រទឹកក្រូច សេវ៉េនអាប់ *(7 up)*[២] ។ ពេលនោះមានបុរសម្នាក់រត់មកបើកទ្វាររបង ហើយម៉ូតូក៏ចូលទៅឈប់នៅក្រោមដើមមៀនខាងចំហៀងផ្ទះ ។ ម្នាក់ដែលមានមាឌមាំនៅចាំម៉ូតូ ចំណែកឯម្នាក់ទៀត មាឌស្គម

---

១ - មុនឆ្នាំ ១៩៧០ ជាវិទ្យាល័យព្រះយុគន្ធរ

២ - មុនឆ្នាំ ១៩៧៥ ឋិតនៅខាងកើតឆៀងខាងជើងនគរបាល ខ័ណ្ឌ ៧ មករា



www.elibraryofcambodia.org

ស្ដើងក៏ស្ទុះភ្លែតឡើងជណ្ដើរទៅជាន់ខាងលើ ។ បន្តិចក្រោយមកមនុស្សមាឌស្ដមចេញមកវិញ រួចចុះមកក្រោម ហើយយកមួកការពារមកពាក់ឡើងជិះម៉ូតូបរចេញទៅ ។ ឯអ្នកឆ្មាំទ្វារក៏ទាញទ្វារបិទដូចធម្មតា ។ ភាពកម្រើករំពើកអំបាញ់មិញដោយសកម្មភាពម៉ូតូក៏ប្រែជាស្ងាត់ជ្រងំឡើងវិញ ហើយអ្វីៗក៏លង់លក់បន្តទៀតក្នុងអន្ធង់រាត្រីដ៏សែនស្ងប់ស្ងាត់នោះ ។

---

រស្មីព្រះអាទិត្យជ្រៀតចូលតាមស្នាបព្រិលនៃភូមិគ្រឹះមួយ ដែលមានសកម្មភាពកាលពីយប់កន្លងផុតទៅនោះ ។ នៅលើគ្រែពូក យុវនារីឋិតនៅក្នុងសម្លៀកបំពាក់ដំណេក កំពុងពត់ពេនខ្លួនយ៉ាងខ្ជិលច្រអូស ។

សំឡេងគោះទ្វារបន្ទប់ឡើង ៖

- តុក១...តុក១...

- ចូលមកចុះ ! (តរុណីស្រដីឡើង) ។

គ្រាន់តែពាក្យអនុញ្ញាតបញ្ចប់ភ្លាម ស្ត្រីម្នាក់អាយុប្រហែល ហាសិបឆ្នាំ បង្អើបទ្វារ អើតកចូលមក ហើយនិយាយថា ៖

- នាង ញ៉ាំអីព្រឹកនេះ !... ពីព្រោះបន្តិចទៀតលោកប៉ា លោកម៉ាក់នឹងអញ្ជើញមកដល់ភ្នំពេញហើយ...នាងត្រូវទៅកំពង់ចាមជាមួយលោកទាំងពីរផងណា !

នាងក្រមុំស្ទុះក្រោកយ៉ាងរហ័សរហួន រួចនិយាយមួយត្រួសដោយគ្រវីក្បាល ៖

- មីងយកទឹកដោះគោមកចុះ...តែខ្ញុំមិនទៅកំពង់ចាមជាមួយលោកប៉ា លោកម៉ាក់ទេ...សូមមីងឆ្លៀតជម្រាបលោកទាំងពីរជំនួសខ្ញុំផង ។

- ម៉េចអីចឹងនាង ?

- ពីព្រោះខ្ញុំបានណាត់ពួកម៉ាកខ្ញុំឱ្យមករៀន... ពេលជិតប្រឡងណាស់ហើយ... នៅ មិនដល់ពីរខែទៀតផងហ្នឹង !


www.elibraryofcambodia.org

ស្ត្រីចំណាស់ទាញទ្វារបិទហើយថយទៅ...មួយនាទីក្រោយមកស្ត្រីដដែលនោះ ក៏កាន់ថាសដាក់ទឹកដោះគោ និងនំប៉័ង ចូលមកហើយដាក់ថាសនោះលើតុក្បែរបង្អួច ។ គាត់ងាកមកញញឹមដាក់ចៅហ្វាយតូចដែលអង្គុយសិតសក់នៅមុខកញ្ចក់ ។ ពេលនាងលើកដៃក្របួចសក់ផាត់ចុះឡើង មីងអ្នកបម្រើទុចង៉ក់ រួចខំតាមសម្លឹងកញ្ចឹងកស្រស់ស្រីដែលមានស្នាមពណ៌ប្រផេះ ។ តរុណីក៏ប្រញាប់ទម្លាក់ដៃចុះ បណ្តាលឱ្យសក់វែងរួញទឹករលករំសាយគ្របលើស្នាជាថ្មីឡើងវិញ លាក់បំបាំងស្នាមនោះ ហើយស្ត្រីបម្រើលាចេញទៅ ។

មាណវី ដើរមកឈរជិតតុ រួចបើកបង្អួចឱ្យស្រឡះ ព្រមទាំងយកដៃផាត់វាំងននឱ្យញែកទៅសងខាង ។ ភ្នែកនាងសម្លឹងទៅចរាចរនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស នាងឈរមើលទិដ្ឋភាពចរាចរបណ្តើរ ឯដៃក៏លើកកែវទឹកដោះគោ ក្រេបបណ្តើរ ។ ចំណុចមួយដែលធ្វើឱ្យកែវភ្នែកនាងតាមសម្លឹងភាំងគ្មានព្រិចនោះ គឺរថយន្តម៉ាកតូនូស *(Taunus)* ពណ៌ក្រហម ។ ស្រស់ស្រីទន់ដៃទន់ជើង រួចខំរកទីករឿងស្អុតស្អាញដែលឋិតនៅក្នុងរថយន្តនោះ ។ នាងនាថបន្លឺវាចា ÷

- ព្រះអើយ !... នេះឬចិត្តប្រុស...

ផុះវាចាតែពីរ-បីម៉ាត់ នាងក៏ឋិតនៅស្ងៀមឈឹងព្រមទាំងមានវង់ភក្ត្រក្រហមពោរពេញដោយភ្លើងកំហឹងឆេះឆួល ។ នាងកញ្ញាធីតាអភិជនកើតទុក្ខក្ងាន់ក្នាញ់ដោយក្តីស្នេហាតែម្នាក់ឯង ។ ទុក្ខនេះគឺសម្រាប់តែយុវវ័យដែលនៅមានជីវិតវែងឆ្ងាយ សាកល្បងភ្លក្សរសជាតិជីវិត ថាតើជីវិតមានរសជាតិយ៉ាងណា ? ប៉ុន្តែបើចំពោះត្រកូលកសិករវិញ គេមិនសូវមានពេលមកអណ្តែតអណ្តូងនឹងស្នេហានេះប៉ុន្មានទេ ដោយសារតែជីវភាពពុំបានគ្រប់គ្រាន់ ។ នៅក្នុងរថយន្តឯនោះវិញ កិច្ចសន្ទនារបស់គូស្នេហ៍មួយគូបានចាប់ផ្តើមឡើង ÷

- ហេតុអ្វីបានជាអូនមានទឹកមុខមិនសប្បាយសោះយ៉ាងនេះ ?

- នេះជាលើកទីមួយ ហើយដែលខ្ញុំហ៊ានចេញមកដោយមិនបានជម្រាបលោកប៉ា



www.elibraryofcambodia.org

លោកម៉ាក់...ដោយសារតែ...

មាណពជាអ្នកបញ្ជាយានយន្តងាកមើលគូស្នេហ៍ដែលមានវាចាទាំងក្ដីព្រួយបារម្ភជាប់ជានិច្ច ។ អ្នកកំលោះនិយាយលួងលោម ÷

- យ៉ាងដូចម្ដេចហ្នឹង ! មិនទុកចិត្តបងទេឬ ឧប្បល ?

នាងឧប្បលគ្រវីក្បាល រួចឆ្លើយដោយសំឡេងខ្សឹបៗ ÷

- ខ្ញុំខឹងនឹងខ្លួនឯងដែលហ៊ានក្បត់ចិត្តចាស់ទុំ...ដោយភាពងងឹតងងល់... ដូចមោហ៍បាំងឱ្យភ្លេចភ្លាំងថាអ្វីល្អ អ្វីអាក្រក់...ហើយទម្រាំតែដឹងខ្លួន អំពើបានកសាងរួចស្រេចទៅហើយ ។

ឧប្បលដកដង្ហើមធំ ខំជម្រុះក្ដីកង្វល់ឱ្យអស់ពីទ្រូង...ប៉ុន្តែកង្វល់នោះនៅតែ មិនថយចុះដូចក្ដីប្រាថ្នា ។

នៅក្នុងរថយន្ត គេមិនឮពាក្យឆ្លងឆ្លើយទៀតទេ គេឮតែស្នូរម៉ាស៊ីនដំណើរការឱ្យទៅមុខ ក្រោមការបញ្ជារបស់យុវជន កែវ ខេមរិន្ទ ។ រថយន្តឆ្លងស្ពានព្រះមុនីវង្សហើយឆ្ពោះទៅទិសខាងកើតដោយល្បឿនមធ្យម ត្បិតម្ចាស់រថយន្តមិនប្រញាប់ប្រញាល់ទៅណាឡើយ ។ រថយន្តគេចចេញពីផ្លូវជាតិលេខមួយ រួចចូលតាមផ្លូវលំ បត់ចុះបត់ឡើងក៏មកដល់ផ្លូវប្រឫបមាត់ទន្លេ ។ ខេមរិន្ទបញ្ឈប់រថយន្តក្រោមម្លប់ដើមល្មុត បើកទ្វារចេញមកឈរមើលទៅទន្លេដែលមានទឹកសស្វាច មានរលកតូចៗរត់ប្រជេញចោលកាំរស្មី នឹងព្រះសូរិយាពេលព្រលឹម ។ ជំនោរបក់មករំភើយៗ ធ្វើឱ្យអ្នកមានគូស្នេហ៍មានចិត្តរំភើបឥតឧបមាដែលបានមកនៅនែបនិត្យជិតប្រាណ ។ នេះជាលើកទីមួយនៃវ័យក្រពុំរបស់ឧប្បលហើយដែលជានិច្ចកាល នាងមានអារម្មណ៍រំភើបស្រៀវស្រើបនៅពេលដែលរស្មីនេត្ររបស់ខេមរិន្ទចាំងចំកែវភ្នែកនាងម្ដងៗ ។ កំលោះនេះបានគ្រោងថានឹងសារភាពក្នុងគ្រានេះនូវអ្វីៗទាំងឡាយដែលគេបានលាក់មកជាយូរ...នៅសល់តែប៉ុន្មានម៉ោងទៀតទេ គេនឹងត្រូវវិលត្រឡប់មកក្រុងភ្នំពេញវិញហើយ ។ នាងឧប្បលធ្មេចភ្នែក ផ្ដេកក្បាល


www.elibraryofcambodia.org

លើកៅអីបង្អែកដោយភក្ត្រាស្ងួតស្ងប់ ។ ចំណែកឯខេមរិន្ទវិញ ឈរមិនសុខមិនសាប់ ក៏បើកទ្វារចូលមកអង្គុយថ្នមៗ រួចងាកមកគយគន់ភក្ត្រាឧប្បលដែលនៅជិតបង្អើយ ។ អ្នកកំលោះស្ទើរតែទប់ចិត្តមិនបាន...ចង់តែឱនទៅថើបភក្ត្រផ្ទូរផង់នៃកុលាបព្រហ្មចារីនេះ ។ អ្នកនឹកក្នុងចិត្តថា : " ឧប្បលអូនល្អអ្វីក៏ល្អម្ល៉េះ...សម្រស់ដ៏មានមន្តស្នេហ៍នេះ ខ្ញុំបានកត់ត្រាចងចាំអស់កាលមកជាយូរមកហើយ...ខ្ញុំមិនឆ្កួតទេ ដែលខ្ញុំមានគំនិតប្រតិព័ទ្ធមកលើគូស្នេហ៍ខ្ញុំនេះ...គួរឱ្យចម្លែកណាស់ហ្ន៎ ! ស្នេហាខ្ញុំនេះ... ជាស្នេហាខុសគេ ដោយសារតែនាងឧប្បលមានរូបរាងដូចប្អូនខ្ញុំបង្កើត " ។

ពេលសម្លឹងវង់ភក្ត្រនាងយូរៗទៅ ធ្វើឱ្យខេមរិន្ទអត់ទ្រាំពុំបានតទៅទៀត ក៏ឱនទៅជិត...ជិតរហូតដល់បានស្រង់ស្រូបក្លិនប្រហើរនៃព្រហ្មចារី ដែលអ្នកកំលោះកំពុងតែឈ្លក់វង្វេង វិលវល់ភ្លេចអ្វីៗដែលនៅជុំវិញខ្លួនទាំងអស់ ...ហើយអ្នកបាក់នឹកស្រមៃថារូបអ្នកកំពុងឋិតនៅក្នុងទេវឋាននាពេលនេះ... " ឱ ! ព្រលឹងស្នេហ៍មាសបងអើយ !...រូបអូននេះហើយជាជីវិត...ជាកែវភ្នែកទាំងគូ...សូមឱ្យព្រះអង្គជាម្ចាស់ លោកកុំពង្រាត់នាងពីខ្ញុំឡើយ...បើមិនដូច្នោះទេ រូបរបស់ខ្ញុំព្រះអង្គនឹងគ្មានស្រមោលនៅលើផែនដីនេះឡើយ " ។

ឧប្បលដូចជាដឹងថា មានដង្ហើមក្តៅៗក្បែរប្រាណដ៏ហ្មត់រលោងរបស់នាងៗក៏បើកនេត្រាខ្មៅរលោងដូចត្បូងនិលថ្មៃសន្សើមៗឡើង ក៏បានយល់ភក្ត្រអ្នកកំលោះនៅជិតបង្អើយ ធ្វើឱ្យនាងញ័ររន្ធត់ឥតឧបមា...រកនឹងហាស្រែក ក៏ស្រែកពុំរួច...រកនឹងលើកដៃច្រាន ប៉ុន្តែត្រូវដៃមាណពក្តោបច្របាច់ជាប់ដូចចរន្តអគ្គិសនីកំពុងស្រូបឆក់...គឺឆក់យកទាំងរូបកាយ និងវិញ្ញាណឱ្យភ្លេចភាន់ភាំងគាំងចលនាមួយរយៈ ។ ពេលដឹងខ្លួនឡើងវិញ ឧប្បលរើបម្រះខ្ញើកៗក្នុងរង្វង់ហត្ថា ដែលកំពុងក្រសោបរបស់ខេមរិន្ទ ។ នរៈក៏មានអាការៈភ្ញាក់កន្ត្រាក់ខ្លួនដែរ នៅពេលដែលហត្ថានាងឧប្បលកំពុងប្រយុទ្ធរុញច្រាន ប្រាថ្នាយកជ័យជំនះលើគូសត្រូវឱ្យបានសម្រេច ។


www.elibraryofcambodia.org

ស្រឡះក៏មិនដឹង ។ ចំណែកស្រីម្នាក់ទៀតរាងស្ដើងដែរ ប៉ុន្តែមិនសូវជាខ្ពស់ប៉ុន្មានទេ ។ ជនមិនច្រឡំទេគឺពិតជានាងហើយ ដែលជិះស៊ីក្លូរបស់ខ្លួនកាលពីព្រលប់ ។ ពេលនេះនាងមានអាកប្បកិរិយាសុភាពរាបសា ទន់ភ្លន់គួរឱ្យមេត្រីរាប់អានពន់ពេកក្រៃ ។

មិនបានប៉ុន្មាននាទីផង ហ្វេដេរ៉ូកៀកដៃគូរបស់គេឡើងរាំចង្វាក់យឺតៗ ចោលអ្នកកំលោះជនឱ្យនៅតែពីរនាក់នាងពាក់អាវប៉ាក់ឌិន ។ ជននឹកក្នុងចិត្តថា : " ពូដែលនាងជិះស៊ីក្លូនេះហើយបានឱ្យថ្លៃឈ្នួលដល់ទៅប្រាំដុល្លារ ឥឡូវនាងយកប្រាំដុល្លារ ពីពូវិញនៅរាត្រីនេះឬ !...ពុទ្ធោនាង...ពូមិនសមនឹងមកអង្គុយ ជាមួយនាង នៅទីនេះទេ !... " ។

- លោក !...លោក !...

ជនភ្ញាក់ព្រើតដាច់អារម្មណ៍ដែលរវើរវាយ រួចនឹកអៀនខ្លួននៅពេលដែលឮនាងហៅខ្លួនថាលោក ។ អ្នកកំលោះមានអាការៈរសាប់រសល់ ដូចជាមិនដឹងជាត្រូវផ្ដើមរបៀបណា ពីព្រោះអ្នកពុំមានគោលដៅគ្រោងទុកមុន ... អ្នកមានមុខនៅក្នុងវង្គសាលនេះគឺដោយចៃដន្យទេ ។ គម្រោងការពិតប្រាកដរបស់អ្នក គឺត្រូវអង្គុយចាំភ្ញៀវនៅក្រៅវង្គសាលឯណោះ...ម៉ូរ៉ូសមមូសកំពុងតែខាំបឺតឈាមយ៉ាងគួរឱ្យស្រណោះ ឯអារម្មណ៍ស្រីញី អូនបង ក៏គ្មាននៅក្នុងចិត្តទេ...ឱ្យមានដូចម្ដេចកើត បើក្នុងហោប៉ៅនោះមានប្រាក់ស្ដួចស្ដើងប៉ុណ្ណោះ ។ ជនលើកស្រាបៀរក្រេបពីរបីក្អឹក ជាតិស្រវឹងក្ដៅសាយភាយពេញខ្លួនអ្នកកំលោះពុំមានយោបល់អ្វីក្រៅពីអង្គុយសម្លឹងមុខស្រីស្រស់ប្រិមប្រិយនោះទេ ។ នាងបន្តសំដីរបស់ខ្លួនតទៅទៀត ÷

- លោកមិនអញ្ជើញឡើងរាំដូចជាមិត្តរបស់លោកទេឬ ?

- ខ្ញុំមិនចេះរាំទេ !

- តើធ្វើដូចម្ដេច ខ្ញុំនឹងជឿលោកទៅ ?

- គឺជឿសំដីខ្ញុំកំពុងនិយាយប្រាប់នាងទៅ...ខ្ញុំមិនកុហកនាងទេ !

នាងសើចហាក់ដូចជាកំពុងផ្សារទំនាក់ទំនងមេត្រីភាពរវាងនាង និង ភ្ញៀវ ÷


www.elibraryofcambodia.org

ខេមរិន្ទខ្សឹបតិចៗក្បែរត្រចៀកស្រស់ស្រី ៖

- អត់ទោសឱ្យបងផងណា !...ដែលបងប្រព្រឹត្តមិនគប្បីអំបាញ់មិញនេះ ។

ឧប្បលមិនឆ្លើយ តែទឹកភ្នែកនាងរលីងរលោងខ្សឹកខ្សួល ធ្វើឱ្យខេមរិន្ទចង់តែក្រសោបត្រកងដោយមិនចង់ឱ្យបុប្ផាមួយទងនេះមានក្ដីហ្មងសៅឡើយ ។

- តើនាងចង់ឱ្យបងធ្វើដូចម្ដេច ដើម្បីឱ្យដឹងថានាងព្រមអភ័យទោសឱ្យបងហើយ !... បងធ្វើអំពើមិនគប្បី ក៏ព្រោះតែបងមានចិត្តប្រតិព័ទ្ធលើនួននាងដ៏លើសលប់ស្ទើរទប់ចិត្តមិនបានទៅហើយ !

ឧប្បលអួលដើមករកបាមាត់និយាយពុំរួច ដូចជាមានអ្វីមកខ្ទាស់បំពង់កនោះឱ្យពេញណែន ។ នាងគ្រវីក្បាល ហើយក៏នៅស្ងៀមឈឹង បណ្ដាលឱ្យបរិយាកាសតានតឹងស្ងប់ស្ងាត់ ទោះបីជាជំនោរទន្លេបក់មកយ៉ាងរំភើយឱ្យត្រជាក់ស្រួលយ៉ាងណាក៏ដោយ ។ ខេមរិន្ទឃើញនាងឧប្បលយំ ហើយមិនស្ដីដូច្នេះ អ្នកចេះតែនឹកស្មានថាយ៉ាងនេះ យ៉ាងនោះ តែម្នាក់ឯង : " ឱ ! ប្រហែលជានាងខឹងហើយ ! បានមិននិយាយស្ដីសោះយ៉ាងនេះ !...ឬក៏មកពីខ្លួនហ៊ានបំពារបំពានគ្មានខ្លាច !...គ្មានរអែងចិត្តនាងសោះ !...សមមុខហើយខេមរិន្ទខ្ញុំអើយ ! " ។ ខេមរិន្ទបន្ថែមវាចាបន្ត ៖

- យើងត្រឡប់ទៅវិញ...តើល្អទេ ?

ឧប្បលងក់ក្បាលបាក់ដូចជាពេញចិត្តនឹងសំដីនេះ ។ រថយន្តបញ្ឆេះម៉ាស៊ីនរោទ៍បន្តិច ហើយបើកចេញពីទីនេះទៅ ដោយទុកឱ្យធម្មជាតិបិតនៅស្ងប់ស្ងាត់គ្មានអ្នកកំដរតទៅទៀត ។ ខេមរិន្ទលែងហ៊ាននិយាយស្ដីអ្វី ថែមទាំងមិនហ៊ានងាកមើលនាងឧប្បលអង្គុយទៀតផង ។ ជីវិតយុវវ័យមានលក្ខណៈស្រួយផុយស្រាលដូចពពុះទឹក...ឆាប់កើតហើយក៏ឆាប់រលត់រលាយយ៉ាងងាយ ... គេមិនអាចបន្ទោសគូស្នេហ៍ទាំងពីរនោះបានទេ ព្រោះនេះជាច្បាប់របស់ធម្មជាតិ លោកកំណត់ឱ្យយ៉ាងដូច្នេះ គ្រាន់តែថា យើងជាមនុស្សដែលមានការចេះដឹង ចេះត្រិះរិះពិចារណា បណ្ដោយឱ្យធម្មជាតិដឹកមុខ ឬក៏យើងជាអ្នក


www.elibraryofcambodia.org

អារកាត់ហ៊ានមានះជំនះរឿងខ្លះៗតែប៉ុណ្ណោះ ។ ប៉ុន្តែក្នុងរឿងស្នេហានេះគឺជាប្រធានបទមួយដ៏សំខាន់បំផុតរបស់មនុស្សលោក ដែលស្ទើរតែគ្មាននរណាម្នាក់អាចចៀសវាបានឡើយ ហើយបើមានអ្នកណាមួយចៀសវាបាននោះ ក៏ត្រូវតែហែលឆ្លងវិញ្ញាសាដ៏លំបាកដូចជាការខកចិត្ត !...ការផិតក្បត់រហូតដល់ហ៊ានស្លាប់ !...ឬក៏ត្រូវតាំងចិត្ត សមាធិជំនះផ្ទោះរំលងសមុទ្រស្នេហ៍លោកីយ៍នេះដែរ ។

ខេមរិន្ទបើកឡានម៉ាកតូនូស *Taunus* ទៅសងម្ចាស់គេវិញ ហើយក៏ប្តូរឡានហ្វីយ៉ាត *(Fiat)* ពណ៌សពីរោងជាងដែលទើបនឹងប្តូរប្រេង និងប្តូរកង់រួច ។ ឧប្បលនៅតែរក្សាទឹកមុខក្រៀមក្រំស្រពោនដដែល ហាក់ដូចជាមានមន្ទិលយ៉ាងធំធេងនៅក្នុងទ្រូង ។ វិប្បដិសារីកំពុងតែបន្ទោសនាងយ៉ាងកងរំពង ។

ពេលទៅដល់ផ្ទះ នាងប្រាប់ទៅខេមរិន្ទថា ÷

- ចាំរសៀល ចាំមកទទួលកេសរ ... ឥឡូវខ្ញុំត្រូវរៀនជាមួយកេសរសិន !

និយាយហើយ នាងក៏ចុះពីឡានដោយមិនរង់ចាំចម្លើយអ្វីពីខេមរិន្ទឡើយ ។ អ្នកកំលោះនឹកហួសចិត្តនឹងកិរិយាក្អិកក្អក់របស់ស្រីស្នេហ៍ គួរឱ្យគ្នាន់ក្នាញ់ស្រឡាញ់ពេញចិត្ត ហើយចិត្តប្រតិព័ទ្ធចេះតែផុងជ្រៅទៅៗជារៀងរាល់ថ្ងៃ ។ យុវវ័យទាំងពីរមានសេចក្តីស្នេហាក្នុងខ្លួនមែន ប៉ុន្តែគេមិនភ្លេចភ្លាំងការរៀនសូត្រ សូម្បីមួយវិនាទីណាឡើយ ដូច្នេះស្នេហារបៀបនេះក៏មិនធ្វើឱ្យគេបាត់បង់អនាគតដែរ ។

ឧប្បលឡើងទៅលើផ្ទះ រួចគោះទ្វារបន្ទប់របស់នាងដែលនាងដឹងថាមិត្តនាងនៅរង់ចាំនៅទីនេះ ÷

- តុកៗ...តុកៗ...

សំឡេងស្រីឆ្លើយពីក្នុង ÷

- អ្នកណា មានការអី ចូលមកចុះ !

គន្លឹះទ្វារលាន់ឮឡើង ទ្វារក៏របើក លេចនាងឧប្បលនៅចំពោះមុខកេសរ ធ្វើឱ្យ


www.elibraryofcambodia.org

កេសរភ្ញាក់មាត់ ÷

- ចុម ! ឧប្បលទេតើ !...ឯណាបងរិទ្ធ !...មានរឿងអីមិនស្រួល ហើយបាន ជាមានទឹកមុខអាក្រក់ម្ល៉េះ ?

- ខ្ញុំបានប្រាប់ឱ្យគេមកទទួលឯងពេលល្ងាច (នាងឧប្បលតប) ព្រោះឯងនៅរៀនជាមួយគ្នាសិន...គ្មានរឿងអីទេ...គ្រាន់តែខ្ញុំបារម្ភ ព្រោះជិតប្រឡងណាស់ហើយ មេរៀននៅមិនទាន់ចេះអស់ !

- អីចឹងមានតែខំរៀនទៅមែនទេ ?

ឧប្បលមិនឆ្លើយនឹងសម្ដាញ់ នាងគ្រាន់តែងក់ក្បាលទទួលយល់ព្រមនឹងចម្លើយនោះ ។ រួចនាងនិយាយប្រាប់កេសរថា ÷

- ម៉ោងពីរ បងជីដូនមួយខ្ញុំនឹងមកបង្រៀនគណិតវិទ្យាខ្ញុំហើយ !

គ្រាន់តែឮឧប្បលនិយាយថា បងជីដូនមួយខ្ញុំ កេសរធ្លាក់ថ្លើមក្ដុក ។ នាងនឹកក្នុងចិត្ត “ គឺប្រុសនោះហើយដែលតាមសម្លឹងខ្ញុំឥតដាក់ភ្នែក ពេលគេបានជួបខ្ញុំលើកដំបូងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ” ។ ក្រសែភ្នែកបុរសនោះហើយដែលធ្វើឱ្យកេសរជ្រួលច្របល់វិលវល់ជាច្រើនថ្ងៃ ។ ឧប្បលសួរកេសរ ÷

- ម៉េចទៅល្ខោនឯងនោះលេងបានល្អទេ ?

កេសរឆ្លើយទាំងសម្លក់ថ្មែរទៅរកនាងឧប្បល ÷

- ពិបាកណាស់ឧប្បលអើយ...ភ័យស្ទើរស្លាប់ទៅហើយ !

- ប្រាប់ហើយៗថា ធ្វើតែធម្មតាទៅ វារួចគ្នាទៅហើយ !

- តែវាមិនស្រួលដូចមាត់និយាយអី... កាលណាមានគេគោះទ្វារ... ខ្ញុំតាំងបែកញើសស្រាក់ៗ ឯងៗ តែម្ដង ។

- របៀបនេះធ្វើឱ្យគេសង្ស័យទៅវិញទេ ( កេសរឆ្លើយតបទាំងម៉ិកម៉ក់ ) ÷

- ប្រាកដហើយ...មិនឱ្យភ័យយ៉ាងម៉េច បើមិនធ្លាប់សោះនោះ !


www.elibraryofcambodia.org

- ល្មមតែចាស់ៗលោកពោលថា : គោដំបៅខ្នង ក្អែកហើរវំលងរំសាយកន្ទុយ ។

ដើម្បីកុំឱ្យខាតពេល ឧប្បល និងកេសរ ក៏យកមេរៀនមករៀនរួមគ្នា ។

នាងកេសរទើបតែសុំផ្លាស់មកពីខេត្តបាត់ដំបង នាងមកតាមឪពុក ម្ដាយនាង គឺលោក កែវ ខាត់ និងអ្នកស្រី ឡូន ណារ៉ា ដែលផ្លាស់មកពីចៅហ្វាយស្រុកមោងឫស្សី មកជាចៅហ្វាយស្រុកស្អាង ។ លោកចៅហ្វាយស្រុកនេះមានបុត្រប្រុសមួយទៀតឈ្មោះ កែវ ខេមរិន្ទ អាយុម្ភៃប្រាំមួយឆ្នាំ រៀនចប់នៅសាលាច្បាប់ ។ នៅខែ សីហា ឆ្នាំ ១៩៧១ កែវ ខេមរិន្ទ និង សិរិវុឌ្ឍា ដែលត្រូវជាបងជីដូនមួយនឹងនាងឧប្បល ត្រូវបានរដ្ឋាភិបាលបារាំង ផ្ដល់អាហារូបករណ៍ឱ្យទៅបន្តវិជ្ជានៅប្រទេសបារាំងពីរឆ្នាំទៀត ។

ខេមរិន្ទបានមករស់នៅរៀនសូត្រឯទីក្រុងភ្នំពេញអស់រយៈពេលប្រាំឆ្នាំហើយមុនពេលដែលលោក កែវ ខាត់ ផ្លាស់ពីបាត់ដំបងមកនៅភ្នំពេញ ។ ខេមរិន្ទស្រឡាញ់ប្អូនស្រីណាស់ ស្រឡាញ់ចម្លែកប្លែកពីបងប្អូនទាំងឡាយ ។ បើអ្នកមិនស្គាល់ខេមរិន្ទ និង កេសរ នោះ គេតែងតែនឹកស្មានថា អ្នកទាំងពីរជាសង្សារនឹងគ្នា ព្រោះអ្នកទាំងពីរសមគ្នាណាស់សមដូចតួកុនដែលគេរើសយ៉ាងសម្រិតសម្រាំងអីចឹង ។

សំឡេងគោះទ្វារបន្ទប់ឧប្បល : តុក ១...តុក ១...

ឧប្បលស្រែកបញ្ជា ÷

- ចូលមក !

- មានទូរស័ព្ទពីផ្ទះលោកអ៊ំ ចាស ! (អ្នកបម្រើឆ្លើយប្រាប់) ។

ឧប្បលស្ទុះរឹងទៅទទួល ហើយក៏បានដំណឹងថា បងប្រុសជីដូនមួយនាង មិនបានមកតាមការណាត់នៅរសៀលម៉ោង ពីរ នេះទេ ។ ឧប្បលដើរចូលមកវិញទាំងរអ៊ូ ÷

- អីចឹងក៏ស្រួលដែរ...ទុកពេលទន្ទេញមេរៀនផង ។

ដឹងដំណឹងនេះហើយ នាងឧប្បលក៏បបួលនាងកេសរបន្តការរៀនសូត្រជាមួយគ្នាទៅទៀត ។



www.elibraryofcambodia.org

មីងយឿន ជាអ្នកបម្រើយ៉ាងស្មោះត្រង់ជាទីបំផុត គាត់មានអាយុ ហាសិបឆ្នាំហើយ គាត់រស់នៅក្នុងត្រកូលលោក វង្ស សម្បត្តិ តាំងពីយូរយារមកម្ល៉េះ ។ ថ្ងៃនេះ ពេលដែលមីងយឿនបានឃើញមិត្តរបស់នាងតូច (ឧប្បល) កាលណា មីងយឿន រសាប់រសល់ខ្វល់ខ្វាយ ចង់តែស្ទុះចូលមកបន្ទប់នាងឧប្បល ដើម្បីមកមើលឱ្យជាក់ច្បាស់នូវរូបរាងនាង កេសរដែលជាភ្ញៀវនោះឱ្យឆ្អែត ។ គាត់រអ៊ូតិចៗតែម្នាក់ឯង ៖

- អីក៏ដូចគ្នាម៉្លេះ !...ដូចជាទឹកពីរដំណក់...គ្រាន់តែម្នាក់មាន ឯម្នាក់ទៀតអត់ប្រជ្រុយ...

និយាយដល់ត្រឹមនេះ មីងយឿនបែរជាភិតភ័យ ហាក់ដូចជាមាននរណាម្នាក់ដេញចាប់ ។ គាត់ប្រញាប់យកដៃខ្ទប់មាត់ ដើម្បីជួយទប់កុំឱ្យធ្លាយរឿងសំខាន់អ្វីមួយ រួចបែរជាឆ្លើយរបៀបដោះខ្លួនតែម្នាក់ឯង ៖

- ទេ...គ្មានរឿងអ្វីទេ...គ្មានរឿងអ្វីទាំងអស់ !

និយាយហើយ គាត់ត្រឡប់ក្រោយចុះទៅជាន់ខាងក្រោម ត្បិតគាត់ឮសន្ធឹករថយន្តបរចូលមកក្នុងបរិវេណភូមិគ្រឹះ ។ រថយន្តម៉ែរសីដេស *(Mercedes)* ពណ៌ខ្មៅរលោងរលើប បរចូលមកឈប់នៅក្រោមដើមខ្នុរដ៏មានមែកសាខា ។ ចៅហ្វាយស្រីចៅហ្វាយប្រុសចុះពីរថយន្តមកឈរតម្រង់ខ្លួន ហើយពត់ពេនដោយអាការៈរោយស្រពន់ ។ រូបរាងលោកស្រីនៅក្មេង ស្រស់ថ្លាស្អាតមិនចាញ់ក្រមុំប៉ុន្មានឡើយ ។ លោកស្រីឈ្មោះសិរីវឌ្ឍសោភា មានអាយុសាមសិបប្រាំពីរឆ្នាំ ចំណែកលោកប្រុសវិញ មានមាឌធំដំបង និងមានអាយុ សែសិបប្រាំពីរឆ្នាំ ខុសគ្នាដប់ឆ្នាំ ប៉ុន្តែលោកទាំងពីរនៅមិនទាន់ចាស់ប៉ុន្មានទេ ។ លោកមានចម្ការរាប់សិបហិកតានៅខេត្តកំពត និង នៅខេត្តកំពង់ចាម មានកម្មកររាប់រយនាក់ ប៉ុន្តែអាកប្បកិរិយាលោកថ្លៃថ្នូរ សុភាពរាបសារ ចេះជួយទុក្ខធុរៈអ្នកក្រីក្រ ។ មីងយឿន ស្ទុះទៅក្រោមអម្បាញ់មិញ បានមួយសន្ទុះគាត់ក៏កាន់ថាសដាក់ទឹកក្រូចច្របាច់ពីរកែវ យកទៅជូនចៅហ្វាយស្រី ចៅហ្វាយប្រុស ដោយមិនចាំបាច់ឮពាក្យបង្គាប់


www.elibraryofcambodia.org

បញ្ហាទេ ។ មីងយឿន ហុចកែវជូនចៅហ្វាយប្រុស មិនរង់ចាំស្តាប់ពាក្យអរគុណដែលបន្ទឺចេញពីមាត់ចៅហ្វាយប្រុសតិចៗទេ រួចគាត់កាន់ថាសដដែលនេះយកទៅហុចជូនចៅហ្វាយស្រីព្រមទាំងបន្ទឺវាចា ÷

- លោកស្រី សុខសប្បាយទេឬ ?

- មិនអីទេ !

ថាហើយលោកស្រីក៏លើកកែវទឹកក្រូចរៀបតែពិសា ស្រាប់តែមានរថយន្តមួយមកឈប់នៅក្រៅរបង ។ បុរសម្នាក់មានរូបរាងស្អាតបាត ចុះពីលើរថយន្ត ហើយឈរវេរានៅក្រៅរបង ។ អ្នកបើកឡានស្ទុះទៅសួរនាំបុរសនោះរួចហើយ ទើបបើករបងឱ្យបុរសនេះចូលមក ។ អ្នកប្រុសនេះឈ្មោះ ខេមរិន្ទ គេមានទឹកមុខស្រស់ប៉ប្រៃ ធ្វើឱ្យលោកស្រី សោភា ពេញចិត្តនឹងរូបសម្បត្តិរបស់គេណាស់ ។ អ្នកកំលោះលើកដៃសំពះលោកស្រីម្ចាស់ផ្ទះពីចម្ងាយ ។ ជាទម្លាប់ ខេមរិន្ទ មានសុជីវធម៌ជាប់ក្នុងខ្លួនជានិច្ច ទោះជាស្គាល់ ឬមិនស្គាល់ក្តី ឱ្យតែអ្នកនោះចាស់ហើយមានអាយុច្រើនជាងខ្លួន ក៏គេលើកដៃសំពះគួរសមដែរ ។ លោកស្រីសម្លឹងអ្នកកំលោះជាប់រហូតទាល់តែគេមកប្រាកដនៅចំពោះមុខ ទើបលោកស្រីសួរនាំ ÷

- ក្មួយមានការអ្វីដែរ ?

- បាទ ខ្ញុំមកទទួលប្អូនស្រី...

ពេលអ្នកកំលោះនិយាយដល់ត្រឹមនេះ ក៏ងាកទៅផ្ទះធំដែលក្រមុំពីរនាក់កំពុងបណ្តើរគ្នាត្រសងមក ។ លោកស្រីសោភាងាកទៅសម្លឹងភាំងលើសម្ផស្សបុប្ផាទាំងពីរទងនោះ រួចលោកស្រីភ្ញាក់លាន់មាត់ដោយឥតដឹងខ្លួន ÷

- យីស...ណាមួយកូនខ្ញុំអីចេះ ?

លោកស្រីមើលកូនរបស់ខ្លួនមិនស្គាល់ ដោយសារតែនាងក្រមុំជាមិត្តនោះដូចឧប្បលបេះបិទ មើលទៅដូចកូនភ្លោះ ។ នាងក្រមុំបន្ទឺពាក្យពេចន៍ណែនាំខ្លួន ÷



www.elibraryofcambodia.org

- ជម្រាបសួរលោកមីង...ខ្ញុំឈ្មោះកេសរ...ខ្ញុំជាមិត្តឧប្បល ។

- មិត្តពីអង្កាល់ !...ដូចម្ដេចក៏មីងមិនដែលឃើញក្មួយមកលេង ?

- ចាស់ ! ខ្ញុំទើបតែផ្លាស់មកពីខេត្តបាត់ដំបង ។

- អូ ! អីចឹងបានជាមីងមិនដែលស្គាល់...មិនដែលឃើញក្មួយសោះ... យីអើ ! ក្មួយដូចឧប្បលណាស់ មើលតែកូនភ្លោះ ។

ចប់សំដីលោកស្រីសោភា ខេមរិន្ទក៏បន្ថែម ÷

- ខ្ញុំបាទក៏យល់ដូចលោកស្រីដែរ ។

- ក្មួយអើយ កុំហៅមីងលោកស្រីអី ! ហៅតែមីងៗទៅបានហើយ ឱ្យបានជិតស្និទ្ធគ្នាផង...មីងដូចជាមាននិស្ស័យនឹងប្អូនស្រីក្មួយ...សុំទុកដូចជាកូនចៅផង បានទេក្មួយ ?

- ខ្ញុំបាទត្រេកអរណាស់ បើដូច្នោះមែន ។

ចំណែកឯកេសរវិញ គ្រាន់តែលើកដៃសំពះទទួលដោយញញឹមអៀនប្រៀនប៉ុណ្ណោះ ។ ពេលនោះលោកសម្បត្តិ ដែលទើបនឹងអញ្ជើញមកពីមើលផ្កាអ័រគីដេនៅជ្រុងម្ខាងដោយដៃកាន់កែវទឹកត្រួចហៀបនឹងអកបង្ហើយទៅហើយ បែរជាតាំងហើយទម្លាក់ដៃមកវិញ ព្រោះឃើញនាងកេសរ និងឧប្បលនៅជិតគ្នា ។ លោកមានអារម្មណ៍ដូចជាភ្ញាក់ដូច ភរិយារបស់លោកដែរ លោកក៏បន្លឺថា ÷

- ឯណាឧប្បលរបស់ខ្ញុំ ?

ទាំងអស់គ្នាអស់សំណើច ។ ទាំងលោកប្រុស ទាំងលោកស្រីទៅជានឹកហួសចិត្តនឹងព្រឹត្តិការណ៍ចម្លែកនេះ ។

អ្នកកំលោះ ខេមរិន្ទ និងនាងក្រមុំ កេសរ លើកដៃឡើងប្រណមជម្រាបលាម្ចាស់ផ្ទះទាំងទ្វេ ដោយកិរិយាសុភាពរាបសាសមរម្យឥតខ្ចោះ ធ្វើឱ្យលោកប្រុស លោកស្រីលួចសរសើរនៅក្នុងចិត្ត : " តើកូនចៅអ្នកណាគេហ្ន៎ ! សមជាអ្នកមានពូជពង្សវង្សត្រកូលមែន ! ពិតជាកូនតាមបែបបទដំបូន្មានមាតាបិតាប្រាកដណាស់ " ។



www.elibraryofcambodia.org

លោកស្រីឈរមើលដំណើរបងប្អូនទាំងពីរដោយញញឹមពេញចិត្ត រហូតទាល់តែគេឡើងជិះរថយន្តបាត់ទៅ ។ លោកងាកមករកបុត្រី ហើយសួរនាំ ÷

- ឧប្បល...កូនដឹងទេ...ថាគេជាកូនចៅនរណាដែរ ?

- មិនដឹងច្រើនទេ អ្នកម៉ាក់...គ្រាន់តែដឹងថា លោកឪពុកគេជាចៅហ្វាយស្រុកស្អាង លោកទើបតែផ្លាស់មកពីខេត្តបាត់ដំបងបានប្រហែលជាមួយខែ.....ពេលដែលកេសរចូលមករៀនដំបូង... មិត្តនៅក្នុងថ្នាក់កូន ផ្អើលមើលខ្ញុំ និង កេសរ មានរូបរាងដូចគ្នា ... គេនាំគ្នាសួរខ្ញុំថា : ពីរនាក់ហ្នឹងត្រូវជាបងប្អូននឹងគ្នា...ជាកូនភ្លោះមែនឬទេ ? ។ លុះដល់ខ្ញុំឆ្លើយថាមិនមែនទេ យើងមិនដែលស្គាល់គ្នាសោះពីមុនមក...គេគ្រប់គ្នានៅតែមានមន្ទិលសង្ស័យ...ដល់អីចឹង អ្នកម៉ាក់សាកល្បងគិតមើលថាខ្ញុំឆ្លើយថាម៉េចទៅ ?

- អើ អីចឹងកូនឆ្លើយថាម៉េច ?

- ខ្ញុំឆ្លើយចាក់បណ្ដោយ ដើម្បីឱ្យរឿងរ៉ាវវាឆាប់ចប់ថា : យើងទាំងពីរនាក់ជាបងប្អូននឹងគ្នា ។

លោកស្រី និងលោកប្រុស ពេលនោះក៏អស់សំណើចនឹងសំដីកូនស្រី រួចលោកប្រុស និយាយចំអន់កូន ÷

- ឧប្បល ! កូនឯងឥឡូវលែងមានតែម្នាក់ឯងទៀតហើយ...គឺកូនមានបងប្អូនពីរនាក់ណា៎ !

ឧប្បលឆ្លើយស្របបន្ទរតាមពាក្យឪពុក ÷

- កូនក៏សប្បាយចិត្តដែរ ដែលឥឡូវមានបងប្អូននឹងគេ ។

និយាយដល់ត្រឹមនេះ ឧប្បលញញឹមតែម្នាក់ឯង ដែលធ្វើឱ្យមាតាបិតាយល់ច្រឡំនឹកស្មានថា នាងពេញចិត្តនឹងពាក្យលោកឪពុកចំអន់លេង ប៉ុន្តែផ្ទុយទៅវិញទេ នាងញញឹមពេលនេះ ព្រោះនាងបានឃើញភ័ក្ត្រខេមរិន្ទដែលលួចសម្លឹងនាងហាក់ដូចអង្វរករជាសម្ងាត់មករកនាងជាចុងក្រោយ ។ សេចក្ដីស្នេហា ដែលគ្រាន់តែជាស្រមោលរសាត់បាត់


www.elibraryofcambodia.org

ទៅហើយនោះ ធ្វើឱ្យសាម៉ុខ្លួនទាំងសងខាងនៅតែនឹកស្រណោះពុំមានភ្លេចតែប៉ុណ្ណោះ ។

ថ្ងៃនេះភូមិគ្រឹះលោក វង្ស សម្បត្តិ មានពន្លឺភ្លឺព្រោងព្រាតខុសប្លែកពីធម្មតា ។ នៅតាមរបងរៀងរាល់ថ្ងៃធម្មតា គេបើកអំពូលភ្លើងតែពីរទេ ប៉ុន្តែថ្ងៃនេះគេបើកភ្លើងទាំងអស់ ដែលដាក់ហែតាមរបង ដើម្បីអបអរសាទរបុណ្យចូលឆ្នាំខ្មែរដែលនៅតែពីរ-បីថ្ងៃទៀតប៉ុណ្ណោះ ។ លោកប្រុស លោកស្រីអញ្ជើញមកភ្នំពេញ ដើម្បីពិនិត្យពីហាងជំនួញ និងមកមើលសេចក្ដីសុខទុក្ខរបស់កូនចៅ និងអ្នកបម្រើ ។ ប៉ុន្តែទោះបីជាមានការប្រុងប្រយ័ត្នពីមាតា បិតាយ៉ាងណាក៏ដោយ ក៏មានបញ្ហាក្នុងគ្រួសារនេះខ្លះៗដែរ ។

លោកស្រី លោកប្រុស ក្រោយពីបរិភោគបាយពេលល្ងាចហើយ ក៏អញ្ជើញមកជួបជុំនៅបន្ទប់ទទួលភ្ញៀវ ។ លោកស្រីសួរទៅបុត្រីទោល ÷

- ឧប្បល ម៉េចទៅកិច្ចការរៀនសូត្ររបស់កូន ?

- មិនអីទេលោកម៉ាក់...ប៉ុន្តែជិតចូលឆ្នាំអ៊ីចឹងសម្បូណ៌ *(Surprise partie)* រាត្រីសមោសរណាស់ ។

- ប្រយ័ត្នប្រយែងណាំកូន !...ម្ដាយរំពឹងលើខ្លួនកូនផ្ទាល់ហើយ... ត្បិតម៉ាក់រវល់ពីរ-បីកន្លែងដូចកូនឃើញស្រាប់... មិនបាននៅជិតដិតនឹងកូនទេ... ម្យ៉ាងទៀតកូនមានចំណេះអាចនឹងចេះថ្លឹងថ្លែងរកសខ្មៅឃើញ ហើយអាចដឹងថាធ្វើអ្វីល្អ ធ្វើអ្វីអាក្រក់ ... កូនគិតមើល យើងកើតជាខ្មែរគឺមានប្រពៃណីទំនៀមទម្លាប់របស់ដូនតា ...ម៉ាក់និយាយបែបនេះមិនមែនម៉ាក់មានគំនិតចង្អៀតចង្អល់ពេកនោះទេ ព្រោះសម័យនេះវាខុសពីសម័យមុន អ្វីៗវាត្រូវតែប្ដូរផ្លាស់ខ្លះអ៊ីចឹងហើយ ប៉ុន្តែកូនកុំភ្លេចណា ! ថាសំដីប្រុសផ្អែមល្ហែមណាស់...វាអាចធ្វើឱ្យយើងលង់ខ្លួនបាន...។

លោកស្រីនិយាយដល់ត្រង់នេះ ឧប្បលភ្ញាក់ព្រើតនឹកថា ច្បាស់ជាមានអ្នកបម្រើណាមួយរាយការណ៍ប្រាប់ម្ដាយគេពីព្រឹត្តិការណ៍កាលពីយប់កន្លងទៅ ដែលគេបានឃុបឃិត យកកេសរមកដាក់បន្ទំហើយ ។ លោកស្រីបន្តសំដីប្រៀនប្រដៅតទៅទៀត ÷



www.elibraryofcambodia.org

- ម៉ាក់កើតមុនកូន ម៉ាក់ដឹងថា ប្រុសមានល្បិចកលច្រើនណាស់ បើគេស្រឡាញ់យើង គឺគេរកមធ្យោបាយគ្រប់យ៉ាងសម្រាប់បោកប្រាស់...ក្នុងលោកនេះសេចក្ដីស្មោះត្រង់មានតិចតួចណាស់កូនអើយ !...

សំដីចុងក្រោយនេះ ធ្វើឱ្យឧប្បលអាណិតម្ដាយខ្លោចចិត្ត ។ ខណៈពេលនោះអ្នកបម្រើប្រុសស្រីក៏ចូលមកបន្តបន្ទាប់ ធ្វើឱ្យលោកស្រីដែលកំពុងតែនិយាយប្រដៅប្រដៅកូន ស្រី ត្រូវផ្អាកទៅវិញ ។

ការពិតលោកស្រីមានទម្លាប់ប្រដៅប្រដៅកូនជាធម្មតា ប៉ុន្តែឧប្បលចេះតែរអៀសខ្លួនតែខ្លួនឯង ដូចសុភាសិតបុរាណលោកពោលថា " គោដំបៅខ្នង ក្អែកហើរវំលងរំសាយកន្ទុយ " ។

ថ្ងៃនេះលោកស្រីនៅជួបជុំជាមួយកូនស្រី និងអ្នកបម្រើ ចំណែកឯលោកប្រុសវិញ ពុំសូវនិយាយស្ដីអ្វីប៉ុន្មានទេ ។ កិច្ចការអ្វីៗនៅក្នុងផ្ទះ លោកប្រគល់ភារៈនេះឱ្យលោកស្រីចាត់ចែងទាំងអស់ ពីព្រោះលោកទុកចិត្តភរិយាទាំងស្រុង ថាអាចសម្រេចកិច្ចការអ្វីៗសមដូចចិត្តលោកប្រាថ្នាដែរ ។ លោកស្រីមានប្រសាសន៍ទៅកាន់អ្នកបម្រើ :

- មីងយឿន ! ខ្ញុំចង់រៀបចំសូត្រមន្តឱ្យបានមុនថ្ងៃចូលឆ្នាំ ហើយខ្ញុំនៅទីនេះលុះត្រាតែចូលឆ្នាំខ្មែររួច ទើបខ្ញុំត្រឡប់ទៅមើលចម្ការធូរេននៅទឹកឈូ(ខេត្តកំពត) វិញ។

និយាយហើយលោកស្រីលូកដៃទៅក្នុងកាបូប យកស្រោមសំបុត្រមួយដែលមានកាខ្ទង់សំបុត្រដាក់ឈ្មោះមីង យឿន រួចហុចឱ្យទៅគាត់ បន្ទាប់មកទៀតហុចឱ្យទៅអ្នកបើកឡានឈ្មោះ ឡាក់ អ្នកបោសសម្អាតឈ្មោះ យ៉ាត ដែលត្រូវជាសាច់ញាតិរបស់មីង យឿន ។ រួចហើយលោកស្រីងាកមកហុចឱ្យអ្នកដាំស្លឈ្មោះ រង់ និងកូនគាត់ ឈ្មោះរ៉ា ជាអ្នកថែសួន អាយុដប់ពីរឆ្នាំ ដែលលោកស្រីឧបត្ថម្ភឱ្យរៀនសូត្រ ព្បិតមីងរស់ជាស្ត្រីមេម៉ាយប្ដីជាទាហានស្លាប់នៅក្នុងសមរភូមិ ក្នុងសង្គ្រាមស៊ីវិលកាលពីឆ្នាំ ១៩៧០ ។

អ្នកបម្រើទាំងអស់គ្នា លើកដៃសំពះថ្លែងអំណរគុណចំពោះម្ចាស់ដែលមានទឹក


www.elibraryofcambodia.org

- សុំទោសលោកឈ្មោះអ្វី ?

- ខ្ញុំឈ្មោះ វីរៈជន ។

- ព្រះអើយ ! ឈ្មោះនេះពីរោះណាស់ ព្រមទាំងមានន័យខ្ពង់ខ្ពស់ទៀតផង ។

- អ្វីៗពុំប្រាកដដូចជានាងស្មាននោះទេ...ជួនកាលបែរជាកម្សត់ទុគ៌តក៏មិនដឹង ។

- អ្នកកម្សត់ទុគ៌តពុំមានលទ្ធភាពចូលរង្គសាលទេ មែនទេ ?

ជនងក់ក្បាលយល់ព្រម ប៉ុន្តែថ្ងៃនេះអ្នកមានវាសនាចូលរង្គសាល ប្រហែលជា " លោកស្រី " ឱ្យពរអ្នកថាជាថ្ងៃហេងហើយ ។ ឥឡូវហេងមែន ពីព្រោះរត់ស៊ីក្លូសុខៗ ស្រាប់តែបានមកនៃបនិត្យជិតស្រីស្រស់ក្មេង...ជន នឹកគិតថា : " មកពីខ្លួនឯងហ្នឹង វា កំសាកញីវាចាញ់ប្រៀបគេ គ្រាន់តែនិយាយឆ្លងឆ្លើយ ក៏មិនដឹងជាត្រូវផ្ដើមរបៀបណា ផង ព្រះអើយពិបាកម្ល៉េះអ្នកកំសាកខ្ញុំអើយ ! " ។ ភ្លេងប្រគំចប់ហើយ ហ្វេដេរ៉ូត្រឡប់ មកកាន់កន្លែងវិញដោយកៀកដៃគូយ៉ាងស្និទ្ធ ហាក់ដូចជាត្រូវដងត្រូវផ្ទៃគ្នាល្អណាស់ មិន ដូចជាជនទេ នៅខ្មាចញញើតញញើម ។ អ្នកដូចជានឹកឆ្ងល់ខ្លួនឯងថា " ហេតុអ្វីក៏ឱ្យអ្នក បម្រើហៅនាងពាក់អាវប៉ាក់ឱនមកធ្វើអ្វី ? បើនិយាយជាមួយគេក៏មិនហ៊ាន ធ្វើខ្លួន មើលតែទឹងមោងចាំចាបអីចឹង " ។ ជនសួរទៅហ្វេដេរ៉ូ ÷

- លោកសប្បាយទេ ?

- សប្បាយណាស់ ! ហើយហេតុអ្វីក៏ឯងមិនឡើងរាំជាមួយនាង ?

- ខ្ញុំមិនចេះ ។

នាងស្រីដែលនៅក្បែរកំលោះជននោះស្រាប់ ក៏និយាយទទួលជំនួស ÷

- ខ្ញុំធានាបង្រៀនលោកឱ្យចេះរាំក្នុងពេលឆាប់ៗ... ប៉ុន្តែដំបូងត្រូវរៀនបទ យឺតៗសិន គឺចង្វាក់ស្លូវ *( Slow )* ។

មិនពិបាកទេ ពីព្រោះនាងតូចស្ដើងនេះក៏ចេះនិយាយអង់គ្លេសដែរ...ដូច្នេះមិនចាំ បាច់ជនបកប្រែឡើយ ។ ហ្វេដេរ៉ូងក់ក្បាលយល់ស្របតាមសំដីនាង រួចគេសួរឈ្មោះនាង ÷



www.elibraryofcambodia.org

ចិត្តសប្បុរស ។ មីង យឿនរំភើបចិត្តពេក ស្ទុះទៅអង្គុយលុតជង្គង់ក្បែរលោកស្រី ហើយក្រសោបដៃលោកស្រីទាំងពីរយកមកដាក់នៅលើដើមទ្រូងរបស់គាត់ ព្រមទាំងនិយាយរៀបរាប់ ÷

- ក្នុងលោកនេះ ប្រហែលជាគ្មានចៅហ្វាយណាចិត្តល្អលើសលោកស្រីទេ ?

- អរគុណហើយមីង ...មីងកុំគិតអ៊ីចឹង...ថាក្នុងលោកនេះនៅមានគេជាច្រើនទៀតដែលពិសេសជាងខ្ញុំ !

មីង យឿន ប្រញាប់និយាយអះអាង ÷

- មានឯណាទៀត ខ្ញុំមិនដឹងទេ !...តែបើពិសេសសម្រាប់ខ្ញុំនោះ គឺលោកស្រីនេះឯងដែលខ្ញុំកម្របានជួបប្រទះរបៀបហ្នឹង...ឱ ! ព្រះអើយ មានទាំងសម្បត្តិ...មានទាំងចរិយា...មានទាំងករុណាធម៌មកជាមួយផង ។

អ្នកឯទៀតឆ្លើយព្រមគ្នា ÷

- ពិតហើយលោកស្រី !

មីងរស់ពោលឡើងដោយសំឡេងញ័រៗ ÷

- ខ្ញុំសូមជូនពរឆ្នាំថ្មី សូមលោកស្រីប្រកបដោយសុភមង្គលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

លោកស្រីលើកដៃប្រណម្យទទួល ÷

- សាធុ !...សាធុ !...សាធុ !... ខ្ញុំក៏សូមជូនពរដល់អ្នកទាំងអស់គ្នាដែរ ! សូមឱ្យបានសេចក្តីសុខ សេចក្តីចម្រើនដូចៗគ្នា ។

ចប់ពាក្យលោកស្រីហើយ គេក៏ឆ្លើយព្រមគ្នាដោយក្តីសោមនស្សរីករាយឥតឧបមា ។ បរិយាកាសនាពេលនោះពោរពេញដោយសុភមង្គលឥតសៅហ្មងឡើយ ។

*****


www.elibraryofcambodia.org

# ៤

# រាត្រីសមោសរ

អ្នករត់ការនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ[១] ដើរចូលមកក្នុងបន្ទប់រៀនមួយ ។ អ្នកគ្រូប្រវត្តិបានផ្អាកបង្រៀនបន្តិច ដើម្បីទុកឱកាសឱ្យអ្នករត់ការប្រមូលបញ្ជីវត្តមានអវត្តមានរបស់សិស្ស ។ រួចគេប្រគល់ឯកសារផ្សេងៗដែលទាក់ទងនឹងអ្នកគ្រូ ព្រមទាំងសំបុត្របួន-ប្រាំទៀតដាក់នៅលើតុអ្នកគ្រូ ដើម្បីឱ្យអ្នកគ្រូចាត់ចែងបន្តហើយ គេក៏ចេញទៅថ្នាក់ផ្សេងទៀត ។ អ្នកគ្រូបន្តការបង្រៀនប្រវត្តិប្រទេសកម្ពុជាតទៅទៀត ។ អ្នកគ្រូសួរទៅសិស្ស ÷

- តើអ្នកទាំងអស់គ្នាដឹងទេថា តើហេតុអ្វីបានជាក្រោយសតវត្សរ៍ទី ១៣ ប្រទេសកម្ពុជាយើងចុះអន់ខ្សោយ ?

សិស្សម្នាក់ឈ្មោះណារិនលើកដៃឡើងដើម្បីឆ្លើយនឹងសំនួររបស់អ្នកគ្រូ ។ អ្នកគ្រូហៅចំឈ្មោះណារិន ÷

- មើល៍ ! ណារិនមានយោបល់យ៉ាងណាដែរ ?

- បានជាក្រោយសតវត្សរ៍ទី១៣ប្រទេសកម្ពុជាយើងចុះអន់ខ្សោយ គឺដោយសារប្រទេសយើងមានសង្គ្រាមដណ្ដើមអំណាចគ្នាឯង ឈ្លោះតែគ្នាឯង ។ ដើម្បីឱ្យបានឈ្នះគូសត្រូវ ទាំងសង្ខាងក៏ទៅពឹងពាក់ប្រទេសជិតខាងឱ្យជួយខ្លួន ហើយសន្យាថានឹងសងគុណដល់អ្នកជួយខ្លួន ។ ហេតុដូច្នេះហើយ បានជាភាគីដែលឈ្នះអំណាចតែងតែប្រគល់ទឹកដី ឬសួយសារអាករផ្សេងៗដ៏មានតម្លៃឱ្យទៅអ្នកជួយនោះ ។ អំណាចដែលបានមក

១ - ពេលធ្វើរដ្ឋប្រហារឆ្នាំ១៩៧០ វិទ្យាល័យព្រះស៊ីសុវត្ថិ ប្រែទៅជាវិទ្យាល័យភ្នំពេញ



www.elibraryofcambodia.org

ពីលក្ខណៈបែបនេះ គឺជាអំណាចមិនឯករាជ្យសោះឡើយ នេះហើយដែលធ្វើឱ្យប្រទេសចុះខ្សោយនោះ !

អ្នកគ្រូសួរបន្តទៀត ÷

- ក្រៅពីអំណាច តើអ្នកណាអាចដឹងអំពីអ្វីទៀត ?

ឧប្បលឆ្លើយឈរឡើង ÷

- ចាស ! អ្នកគ្រូ ! ក្រៅពីសង្គ្រាមដណ្តើមអំណាច នៅមានកត្តាផ្សេងៗជាច្រើនទៀតដែលធ្វើឱ្យប្រទេសចុះអន់ខ្សោយនោះ គឺអ្នកចេះដឹងមានចំនួនតិចតួច ស្តួចស្តើង ។ កាលណាប្រទេសមួយសម្បូរទៅដោយមនុស្សល្ងង់ហើយ ប្រទេសនោះរកផ្លូវរីកចម្រើនពុំបានឆាប់រហ័សឡើយ ពីព្រោះមនុស្សល្ងង់ច្រើនតែអត្តនោម័តិ ពុំសូវស្តាប់យោបល់គេទេ ព្រមទាំងមានចិត្តមានះ មើលឃើញអ្វីតែនៅក្បែរខ្លួន ។ ដូចសម័យវង្វាយបន្ទាយលង្វែក ប្រជារាស្ត្រដែលគ្មានការយល់ដឹងពុំបានគិតគូរវែងឆ្ងាយ ពុំយល់ពីឧបាយកលរបស់សត្រូវ ដោយចង់បានប្រាក់ដួង ក៏នាំគ្នាកាប់បំផ្លាញកំពែងឫស្សី ដែលជាឱកាសមួយងាយស្រួលដល់ពួកសត្រូវចូលមកវាយលុកលុយយកបន្ទាយលង្វែកបានទាំងស្រុង ។ ម្យ៉ាងទៀតមហិច្ឆតាលោភលន់របស់មនុស្សនេះ មានពុំចេះស្កប់ស្កល់សោះ ធ្វើឱ្យងងឹតងងុលភ្លេចគិតអ្វីគ្រប់យ៉ាង រហូតដល់ហ៊ានកាប់សម្លាប់សាច់ញាតិឯង ជនរួមលោហិតរបស់ឯងទៀតផង ។

- ល្អហើយឧប្បល...អ៊ីចឹងយើងដែលជាកូនខ្មែរ ត្រូវធ្វើយ៉ាងណាដើម្បីឱ្យជាតិឋិតថេរគង់វង្សតទៅ ? (អ្នកគ្រូបន្តសំនួរ) ។

កេសរឆ្លើយឈរឡើងហើយមានយោបល់ថា ÷

- យើងជាយុវវ័យត្រូវតែប្រឹងប្រែងរៀនសូត្រ ពង្រីកពង្រឹងចំណេះដឹងឱ្យបានខ្ពង់ខ្ពស់ នេះហើយជាគោលដៅតែមួយដើម្បីឱ្យជាតិគង់វង្ស និងធ្វើឱ្យប្រទេសមួយខ្លាំងទៅបាន !


www.elibraryofcambodia.org

- ល្អហើយ កេសរ !

សំឡេងកណ្ដឹងអគ្គិសនីរោទិ៍ឡើង បញ្ជាក់ថាដល់ម៉ោងចេញលេងហើយ ។ អ្នកគ្រូប្រវត្តិហៅនាងឧប្បល និង នាងកេសរមកយកសំបុត្រ ។ អ្នកទាំងពីរបានសំបុត្រហើយក៏ប្រញាប់ដាក់សំបុត្រទៅក្នុងកាបូប ។ គេមិនហ៊ានបើកមើលនៅក្នុងថ្នាក់ទេ ។

---

ដោយបានការអនុញ្ញាតពីលោកស្រីសិរីវឌ្ឍសោភា នាងកេសរក៏មករស់នៅជាមួយឧប្បល ។ គោលបំណងលោកស្រី ចង់ឱ្យកូនស្រីមានគ្នា កុំឱ្យអផ្សុក ណាមួយពេលជិតប្រឡង ដូច្នេះឧប្បលត្រូវការមានគ្នារៀនសូត្រផង ។

មកដល់ផ្ទះ កេសរបើកសំបុត្រឡើង ទើបដឹងថាសំបុត្រនេះជាសំបុត្រអញ្ជើញរបស់បងប្រុសនាង និង សិរីវឌ្ឍរដ្ឋា មិនអាចអាក់ខានបានឡើយ ។ ចំណែកឯឧប្បល ក៏ទទួលបានសំបុត្រអញ្ជើញដូចគ្នាដែរ ។ អ្នកទាំងពីរអង្គុយសម្លឹងមុខគ្នាដោយចិត្តកន្ទះរាតែរៀង១ខ្លួន ។ រដ្ឋាជាបងជីដូនមួយរបស់នាងឧប្បល អ្នកទាំងពីរនេះ ចាស់ទុំទាំងសងខាងបានឃុបឃិតស្ងាត់ៗបំណងភ្ជាប់និស្ស័យជាគូអនាគតនឹងគ្នា ។ ចាស់ៗតែងតែឧស្សាហ៍ចំអែចំអន់អ្នកទាំងពីរនៅចំពោះមុខគ្នា ប៉ុន្តែរដ្ឋាបានចាត់ទុកឧប្បលដូចជាប្អូនស្រីរបស់ខ្លួនទៅហើយ ។ អ្នកស្រលាញ់ អាណិតនាងធម្មតា គ្មានចំណុចណាមួយដែលថាជាន័យស្នេហាឡើយ ។ ស្នេហាពុំមែនចេះតែចាប់ផ្ដួលតាមតែចិត្តទឹកឃើញឡើយ ទាល់តែសាមីខ្លួនទាំងសងខាងមានចិត្តជិតមេត្រីនឹងគ្នាផង ទើបស្នេហាបានទទួលសុភមង្គលពេញបរិបូណ៌ ។

ពេលនេះនាងកេសរផ្ដួលខ្លួនលើគ្រែដោយវង់ភក្ត្រក្រហមច្រាល ហាក់ដូចជាកំពុងចងកំហឹងនឹងនរណាម្នាក់ ។ ឧប្បលភ្ញាក់កន្ត្រាក់អារម្មណ៍ពីភាពស្ងប់ស្ងាត់ ហើយផ្ដើមសំនួរ ÷

- ឯងកើតអីកេសរ ?


www.elibraryofcambodia.org

- អត់កើតអីទេ ! (កេសរឆ្លើយទាំងរអាក់រអួល) ។

- អីចឹងម្ដេចក៏ឯងយំ ?

កេសរគ្រវីក្បាលលែងនិយាយស្ដី នាងកាន់តែខ្សឹកខ្សួលថែមទៀតនូវពាក្យសំដីរបស់ឧប្បលសួរខាងលើនេះ ។ នាងនឹកឃើញទិដ្ឋភាពថ្ងៃមួយនោះ ក្នុងឡានតូនុស *(Taunus)* ពណ៌ក្រហម នាងបានគ្រវែងសំបុត្រទៅកន្សៀតទូ ថែមទាំងមិនខ្ចីបើកមើលសេចក្ដីក្នុងសំបុត្រនោះទៀតផង ។ នាងមិនចង់ដឹងអ្វីទាំងអស់ ហើយប្រហែលជាមិនចង់ដឹងជារៀងរហូត ។ ប៉ុន្តែនេះជាលើកទីមួយហើយ ដែលនាងលូកដៃកាន់សំបុត្រប្រុសដែលផ្ញើមកនាងតាមរយៈឧប្បល ។ អក្សរនៅខ្នងសំបុត្រនេះសរសេរថា : ពី សិរិទ្ធ រដ្ឋា ចំពោះ កែវ កេសរ តាមរយៈ វង្ស ឧប្បល ។ ខ្លឹមសារក្នុងសំបុត្រនោះមានន័យថា : អញ្ជើញកេសរឱ្យទៅចូលរួមក្នុងឱកាសរាត្រីសមោសរភ្ជាក់ផ្អើលមួយ នារាត្រីថ្ងៃ សៅរ៍ ខាងមុខនេះ ។ សិរិទ្ធ រដ្ឋា និង កែវ ខេមរិន្ទ ជាអ្នករៀបចំកម្មវិធីនេះ ដែលប្រព្រឹត្តទៅនៅគេហដ្ឋាន សិរិទ្ធ រដ្ឋា ក្នុងគោលបំណងជប់លៀងមិត្តភក្ដិមុននឹងគេទាំងពីរនាក់ចេញទៅរៀនផ្នែកច្បាប់នៅបរទេស ។ ពិធីនេះពុំមានចាស់ទុំចូលរួមទេ ដែលជាឱកាសដ៏ល្អមួយសម្រាប់យុវជន-យុវនារី លួចគយគន់សម្លឹងសម្លក់គ្នាដូចបក្សីឡើងខ្លួនអួតដាក់គ្នាដូច្នេះដែរ ។

ពេលនោះកេសរកើតទុក្ខទោមនស្សតែម្នាក់ឯង ក្នុងទ្រូងអួលណែនសែនក្ដៅផ្សាដូចបួសដែលហ៊ុមខ្ទុះមិនទាន់ធ្លាយ ដោយសាររឿងនេះនាងដឹងតែម្នាក់ឯង ក្ដៅក្រហាយតែម្នាក់ឯង បើនាងនិយាយប្រាប់គេ ក៏និយាយមិនរួច ត្បិតខ្លួនជាស្រីក្រមុំនៅមានការអៀនខ្មាស ។ កេសរខំរកនឹកសាជាថ្មីនូវព្រឹត្តិការណ៍ថ្ងៃដែលខ្លួននាងមកគេងនៅផ្ទះឧប្បល ។ នៅពេលព្រឹកនោះនាងបានឃើញច្បាស់នឹងភ្នែក រដ្ឋាបណ្ដើរស្រី ហើយហេតុអ្វីក៏រដ្ឋា សំដែងអាកប្បកិរិយាថាពេញចិត្តនាងទៅវិញ ។ យុវកញ្ញាដ៏ក្មេងខ្ចីនេះ មិនទាំងដឹងការពិតដូចម្ដេចផងក៏ស្រោបតែបណ្ដោយឱ្យភ្លើងប្រច័ណ្ឌនេះរោលរាលទៅហើយ ។ ប៉ុន្តែ


www.elibraryofcambodia.org

ទោះបីជាភ្លើងនេះឆេះក្នុងទ្រូងនាងយ៉ាងណា ក៏គេសរក្សាភាពស្ងប់ស្ងាត់បាន គ្រាន់តែមានទឹកមុខស្លូតស្រពោនប៉ុណ្ណោះ ។

ចំណែកឯឧប្បលវិញ ក៏មានឆន្ទៈពុះកញ្ជ្រោលដោយក្តីស្នេហ៍ដំបូងដែរ គ្រាន់តែនាងខិតខំសើរើរឿងពីរឿងរ៉ាវដែលកន្លងផុតទៅថ្មីៗនេះ នាងចង់បង្វិលរឿងនោះឱ្យត្រឡប់ថយក្រោយវិញ ប៉ុន្តែនាងធ្វើទៅមិនបានដូចចិត្តប្រាថ្នាឡើយ ។ ឧប្បលនឹកគិតហើយខ្សឹបៗតែម្នាក់ឯងថា : " ឱ ! ក្តីស្នេហាអើយ ! ទើបតែបានជួប មិនបានប៉ុន្មានដង្ហើមផង ក៏ស្រាប់តែត្រូវ ឃ្លាតយ៉ាងតក់ក្រហល់ " ។

ចង្វាក់ផែនដីចេះតែវិលទៅមុខជានិច្ច ទោះជាអ្នកមានឥទ្ធិពលយ៉ាងណាក៏ឃាត់មិនបានឡើយ ។ ថ្ងៃសៅរ៍បានរំកិលខ្លួនមកដល់ ចាប់តាំងពីព្រឹកមកនៅគេហដ្ឋាន សិរិទ្ធ វឌ្ឍា លោកស្រី សិរិទ្ធ សោភា រៀបចំម្ហូបអាហារយ៉ាងញាប់ដៃ ញាប់ជើងជាមួយសាច់ ញាតិ និងអ្នកបម្រើ ។ ចំណែកឯលោក វង្ស សម្បត្តិវិញ គ្មានតួនាទីអ្វីសំខាន់ក្នុងពិធីនេះទេ គ្រាន់តែលោកយល់ព្រមឱ្យធ្វើពិធីនេះចាត់ថាពិសេសណាស់ទៅហើយសម្រាប់យុវវ័យ ។

ការរៀបចំពិធីនេះ ប្រព្រឹត្តទៅនៅលើដំបូលគេហដ្ឋាន ។ ក្រៅពីអ្នកផ្ទះ អ្នកជិតខាងពុំបានដឹងថាជាពិធីអ្វីឡើយ ។ ចាប់តាំងពីរសៀលម៉ោងដប់ប្រាំទៅ ឧបករណ៍តន្ត្រីសម័យជញ្ជូនមករៀបតាំងនៅលើថ្នាក់ធ្វើអំពីឈើ ។ នៅចំពីមុខតន្ត្រី គេវាតទីទុកសម្រាប់រាំរែកដែរ ដោយគេដាក់តុ និង កៅអីហ៊ុមព័ទ្ធជុំវិញទីរាំនោះ ។ ចំណែកឯម្ហូបអាហារ គឺគេរៀបនៅតុវែងមួយ សម្រាប់ភ្ញៀវទៅជូសញ្ញុំាតាមចិត្តចង់ រួចហើយទើបភ្ញៀវមកអង្គុយជុំគ្នានៅតាមតុរៀង១ខ្លួន ។ គេរៀបចំតុបតែងលំអទៅដោយអំពូលភ្លើង ចម្រុះពណ៌ និងរំយោលផ្កាភ្ញី អមទៅដោយប៉េងប៉ោងដែលគេចងបង្ហោះបណ្តែតខ្លួនទៅតាមខ្យល់បក់រវិចៗ ។

ម៉ោងដប់ប្រាំបី ក៏មកដល់ តាមកាលកំណត់ ភ្លេងចាប់ប្រគំឡើងព្រមជាមួយសំឡេងទះដៃកងរំពង ។ មិត្តភក្តិវឌ្ឍាម្នាក់ ដែលជាអ្នកចាត់ចែងកម្មវិធី បានឡើងថ្លែងបញ្ជាក់



www.elibraryofcambodia.org

ពីគោលបំណងនៃពិធីនេះថាជាពិធីភ្ញាក់ផ្អើល *(Surprise Partie)* មួយសម្រាប់ វឌ្ឍា និង ខេមរិន្ទ ដែលត្រូវត្រៀមខ្លួនទៅបន្តការសិក្សានៅប្រទេសបារាំងផ្នែកច្បាប់ ។ មិត្តភក្តិ វឌ្ឍា ថ្លែងជាឧឡារិកបន្តទៀត ÷

- យើងសូមសង្ឃឹមយ៉ាងមុតមាំថា តទៅអនាគតមិនយូរប៉ុន្មាន បញ្ញវ័ន្តរបស់យើងទាំងពីររូបនេះ នឹងពាំនាំយកច្បាប់ដ៏សុក្រឹតមកបម្រើផលប្រយោជន៍ប្រទេសជាតិ និង ប្រជាជនជាពុំខាន !... នៅទីបញ្ចប់នេះ សូមឱ្យអ្នកទាំងពីរជួបប្រទះតែជោគជ័យក្នុងការរៀនសូត្រ គ្រប់ពេលវេលា ។

សំឡេងទះដៃលាន់ឡើងជាថ្មីម្តងទៀត ធ្វើឱ្យអ្នករៀបចំកម្មវិធីរបស់យើង ឈរញញឹមញញែម ងាកឆ្វេង ងាកស្តាំ សំដែងស្វាគមន៍ដល់មិត្តទាំងអស់ដែលបានចូលរួម ។

សម័យនោះគេនិយមស្លៀកខោជើងធំ៌ ពាក់អាវីតរាង ចំណែកឯស្រី១វិញ អ្នកខ្លះក៏និយមស្លៀកខោជើងធំ ពាក់អាវីតរាងដូចបុរសដែរ ខ្លះទៀតស្លៀកសំពត់ហៀរកែង ឬក៏ស្លៀកសំពត់ខើចលើក្បាលជង្គង់ ស័ក្តិសមនឹងជើងដ៏សគ្រលួលរលូនខ្ចីដូចអន្ទក់ ។ ស្ងាត់សំឡេងទះដៃហើយ អ្នករៀបចំកម្មវិធីក៏ប្រកាសអញ្ជើញវឌ្ឍា និង ខេមរិន្ទឱ្យឡើងបើកឆាករាត្រីសមោសរដ៏សែនមនោរម្យនេះ ។

យុវជនទាំងពីររូប កាន់កម្រងផ្កាម្នាក់មួយទៅបំពាក់ឱ្យនារីណាម្នាក់ដែលគេស្ម័គ្រធ្វើជាគូរាំ ។ តន្ត្រីប្រគំយូរបន្តិចទៅហើយ អ្នកកំលោះទាំងពីរនៅតែស្ទាក់ស្ទើរ ហាក់ដូចជាពុំដាច់ស្រេចសោះ ថាខ្លួនត្រូវជ្រើសរើសនារីណាមួយ ពីព្រោះនារីដែលមកចូលរួម សុទ្ធតែស្អាត១ដូចទេពអប្សរ ដែលធ្វើឱ្យកំលោះយើងមានការរារែកក្នុងការជ្រើសរើសនោះ រួចគេក៏បំពាក់ឱ្យគ្នាទៅវិញទៅមក ធ្វើដូចកំប្លែងលេងទេវិញ ។

ស្រាប់តែរំពេចនោះ សំឡេងទះដៃកងរំពងជាថ្មី ទេពអប្សរពីរអង្គទើបតែច្យុតចុះមក ធ្វើដំណើរត្រសងដោយកាយវិការល្វតល្វន់ប្រពៃ គ្រងដោយអម្ពរពស្ត្រាជាប្រពៃណីខ្មែរដែលមានបន្ថែមក្រណាត់ស្តើងទន់ល្មើយគ្របលើដងខ្លួនល្អផូរផង់ឥតមន្ទិល ។


www.elibraryofcambodia.org

ទេពកញ្ញាទាំងពីរ ឧប្បល និង កេសរ ធ្វើដំណើរមកដល់ ក៏ស្រាប់តែភ្ញាក់ស្មារតីនឹងកម្រងផ្កាដែលបំពាក់ឱ្យនាងដោយមិនបានដឹងខ្លួនជាមុនបន្តិចសោះ ។ បន្ទាប់មក សំឡេងបុរសនិយាយលាយឡំនឹងស្នូរទះដៃ ÷

- សូមអញ្ជើញនាងឡើងរាំជាកិត្តិយសណា៎ នាងណា៎ !...សូមមេត្តាកុំបដិសេធនូវបំណងល្អរបស់ខ្ញុំ...ណា៎ ! ។

សំដីលួងលោមដ៏ទន់ភ្លន់និងប្រកបដោយសុជីវធម៌របៀបនេះ ធ្វើឱ្យយុវកញ្ញាទាំងទ្វេអៀនឡើងមុខក្រហមដូចរងើកភ្លើង ។ នាងពុំអាចប្រកែក ឬតវ៉ាដោយប្រការណាមួយបានឡើយ នៅចំពោះមុខបុរសដែលប្រកបដោយលក្ខណៈពិសេសទាំងចរិយាសម្បត្តិនិងទាំងវិជ្ជាសម្បត្តិ ព្រមទាំងសំឡេងកងរំពងស្វាគមន៍ដោយការទះដៃ ហាក់ដូចជាមានន័យថា : ការជ្រើសរើសរកគូរបស់វង្ឍា និង ខេមរិន្ទ ពិតជាស័ក្តិសមហើយ យើងជាមិត្តភក្តិចូលរួមអបអរសាទរផង ។

ភ្លេងតន្ត្រីប្រគំលាន់ឮរងំកាន់តែខ្លាំងជាងមុន ដែលម្ចាស់រៀបចំកម្មវិធីបានរៀបចំជាស្រេច ។ ពន្លឺភ្លើងដែលភ្លឺចិញ្ចាចពីមុន ប្រែជាស្រទន់រំលេចទៅដោយភ្លើងពណ៌តូចៗភ្លឺភ្លិបភ្លែតៗ ធ្វើឱ្យបរិយាសនេះកាន់តែលន្លង់លន្លោច ទៅតាមបទភ្លេង និងទំនុកច្រៀងរបស់យុវសិល្បករ ដែលកំពុងច្រៀងរ៉ាយរ៉ាប់ តួញត្អែរពីរឿងរ៉ាវ មនោសញ្ចេតនាពុះកញ្ជ្រោលក្នុងបេះដូង ។

នៅលើវេហាស៍ឯណោះវិញ ព្រះចន្ទ្រវះភ្លឺថ្លាត្រចះត្រចង់ បាចរស្មីមកលើភពផែនដី ទុកឱកាសថ្វាយព្រះចន្ទ្រ ទតមកកំលោះក្រមុំមួយចំនួនតូច ដែលកំពុងរាំយ៉ាងសប្បាយរីករាយ ប្រកៀកប្រកិតស្និទ្ធស្នាលគ្នា លើភូមិគ្រឹះលោកសិរិទ្ធ វង្ឍា ។ សំឡេងបេះដូងលោតរណ្តំក្នុងទ្រូងក្រមុំព្រហ្មចារីនៃយុវវ័យរបស់កេសរ ជាលើកដំបូងបំផុតហើយដែលត្រូវបានហត្ថារបស់វង្ឍា ឱបក្រសោបថ្នាក់ថ្នម ។ ទោះបីជានាងកេសរ ទទួលបាននូវការស្រៀវស្រើប រំភើបយ៉ាងណាក៏ដោយ ក៏នាងខំប្រមូលអារម្មណ៍ឱ្យនឹកផ្តោតលើភាព


www.elibraryofcambodia.org

មិនស្មោះត្រង់របស់រដ្ឋា ដែលនាងបានឃើញផ្ទាល់ភ្នែកកាលពីថ្ងៃមុន ។ នឹកឃើញដូច្នេះ កាពទន់ភ្លន់ សុខសាន្តអម្បាញ់មិញ ក៏រសាត់ទៅឆ្ងាយ នៅសេសសល់តែភាពក្តៅក្រហាយ ធ្វើឱ្យកេសរ ងាកមុខមកសម្លឹងសម្លក់ រដ្ឋា ដែលនៅជិតបង្អើយដោយក្រសែភ្នែកមុតស្រួច ។ ភាពក្រញូកក្រញូវ ងង៉ក់ សម្លឹងសម្លក់ ក្អិកក្អក់ បែបនេះ បែរជាបង្កើនសម្រស់វង់ភក្ត្រានាងកេសរឱ្យរឹតតែផូរផង់ឡើង ជាហេតុទាក់ទាញបេះដូង រដ្ឋា ឱ្យឈ្លក់វង្វេងកាន់តែខ្លាំងឡើងដោយក្តីស្នេហា ។ អ្នកកំលោះមិនយល់ពីការតុំគួនរបស់ក្រមុំកេសរទេ តែបែរជាបន្តឹងដៃរឹតរូបរាងកាយនាងកញ្ញាឱ្យកាន់តែកៀកកិតថែមទៀត រហូតទាល់តែកេសររើបម្រះពីដៃអ្នកកំលោះ ទើបគេភ្ញាក់ខ្លួន ហើយក៏បន្ធូរដៃវិញ ។

នៅក្នុងលោកសន្និវាសនេះគ្មានអ្វីធំជាងសេចក្តីស្នេហាឡើយ ។ ស្នេហាពោរពេញទៅដោយការឈឺចាប់គ្រាំគ្រាផង ការល្ងក់ល្ងើន ពីរោះផ្អែមល្ហែមផង ។ មនុស្សគ្រប់ រូប គ្រប់វ័យឱ្យតែលង់ក្នុងអន្លង់ស្នេហាហើយ គេទាំងឡាយនោះរមែងតែងតែឈ្លក់វង្វេងក្នុងសមុទ្រតណ្ហាដែលគ្មានកោះគ្មានត្រើយនេះពុំខានឡើយ ។ ប៉ុន្តែគេត្រូវឆ្លៀតយកផលនៃការឈឺចាប់នោះ ឱ្យប្រែក្លាយទៅជាគុណប្រយោជន៍សម្រាប់ជីវិតទៅអនាគត ហើយសូមកុំឱ្យ ប្រែក្លាយទៅជាការសងសឹកគ្នាទៅវិញ ។

ភ្លេងតន្ត្រីប្រគំចប់ ខេមរិន្ទ នឹកស្តាយដល់ក្លិនក្លែបស្រស់ស្រីឧប្បលដែលរវាតឃ្លាតចេញពីហត្ថារបស់អ្នក ។ បន្ទាប់មកអ្នករៀបចំកម្មវិធីក៏ប្រកាស ៖

- បន្ទាប់ពីការបើកឆាក មិត្តទាំងអស់ ! សូមឱ្យអញ្ជើញកញ្ញា វង្ស ឧប្បល ឡើងច្រៀងមួយបទ ដើម្បីជាកិត្តិយសដល់ សិរីទ្ធ រដ្ឋា និង កែវ ខេមរិន្ទ ។

សំឡេងទះដៃបន្លឺឡើង បញ្ជាក់ពីការយល់ព្រមរបស់មិត្តទាំងអស់ ។ បន្ទាប់មក ឧប្បល ក៏ធ្វើដំណើរទៅកាន់កន្លែងវេទិកា ។ ភ្លេងចាប់ប្រគំរង់ជាថ្មី សំឡេងដ៏ស្រួយឆ្មារស្រទន់ក៏បន្លឺឡើងទៅតាមចង្វាក់តន្ត្រីសម័យ បំពេរអារម្មណ៍មិត្តប្រុសស្រីដែលចូលរួមឱ្យលន្លង់លន្លោចទៅតាមន័យនៃបទចម្រៀង ដែលមានចំណងជើងថា ៖


www.elibraryofcambodia.org

" ស្រណោះ "

I. ដួងចិត្តស្រណោះ ស្រលាញ់អ្វីម្ល៉េះ កើតក្នុងជាតិនេះ រំពឹងវាសនា ។

II. រង់ចាំសំណាង ក្រែងលោកមេត្តា នឹងឱ្យឱកា ប្រែជាមានន័យ ។

R. ព្រះឥន្ទ្រព្រហ្មទេវតា សូមករុណាដល់រូបស្រី បើមានស្នេហ៍ សូមកុំឱ្យរីងរៃ

រំពឹងនិស្ស័យគូគ្រង ។

III. ឱ ! ព្រហ្មលិខិត អាណិតខ្ញុំផង សូមជួយចម្លង កងកម្មឱ្យផុត ។

គ្រាន់តែឧប្បលច្រៀងចប់ សំឡេងទះដៃហ៊ោកញ្ជ្រៀវ ព្រមទាំងស្រែកថាប៊ីស១ *(Bis)* លាន់ឡើង ។ ឧប្បលយល់ន័យ ក៏ច្រៀងសាម្តងទៀត ក្រោមបរិយាកាសសប្បាយរីករាយឥតឧបមា ។ មិត្តខ្លះដែលមានមាត់ដាច ក៏និយាយចំអន់លេងដោយឮដឹង ÷

- ឱ ! មើលមុខអ្នកអភ័ព្វ ហ្ន៎ះ !

ចប់ពាក្យឌឺដងហើយ សំណើចចំអកបន្តតាមក្រោយកួនសេដ្ឋី ។ ចំណែក ខេមរិន្ទ យកផ្កាកុលាបមួយទងទៅប្រគល់ឱ្យអ្នកចម្រៀងដ៏ស្រស់សោភា ដោយក្តីពេញ ចិត្ត ។

បន្ទាប់មកអ្នកប្រកាសកម្មវិធី ក៏និយាយថ្លែងអំណរគុណដល់អ្នកច្រៀង ព្រមទាំងថ្លែងអំណរគុណដល់អ្នកនិពន្ធទំនុកច្រៀង និង បទភ្លេងដែលតែងឡើងដោយ កញ្ញា អ៊ុំ សុផានី ដែលជាមិត្តនារីរបស់ឧប្បល ។

ពេលវេលាចេះតែរំកិលទៅមុខ ទោះបីជាក្រមុំ-កំលោះ ទាំងទ្វេមានចិត្តចង់ទប់ស្កាត់យ៉ាងណាក៏ដោយ ក៏ទប់មិនបាន ។ ពេលវេលាបែកគ្នាក៏មកដល់ ក្នុងទ្រូងកំលោះ ខេមរិន្ទ និង រដ្ឋា ស្ទើរប្រេះធ្លាយជាពីរដោយក្តីទោមនស្ស ។ សំឡេងខេមរិន្ទ និយាយខ្សឹបៗពីរ-បីម៉ាត់ ÷

- សូមនាងកុំបែកចិត្តពីបង ណា៎ !... មិនយូរទេ ពីរឆ្នាំទៀតយើងគង់នឹងបានជួបគ្នាវិញ ។

ចំណែកឯ រដ្ឋា វិញ ពុំមានពាក្យអ្វីច្រើនក្រៅពីសម្លឹងសម្លក់ភក្ត្រកេសរ ដោយទឹកមុខស្រណោះស្រណោក ។


www.elibraryofcambodia.org

- សុំទោសនាងឈ្មោះ អីដែរ ?

- ចាស ! នាងខ្ញុំឈ្មោះ វ៉ាវិន !

- ខ្ញុំ ! ហ្សេដៀរ៉ូ មកពីប្រទេសកាណាដា ហើយនេះឈ្មោះជនជាសហការីខ្ញុំ ។

- ពុទ្ធោ ! លោកហ្សេដៀរ៉ូ ហេតុអ្វីក៏ផ្ដល់កិត្តិយសខ្ពង់ខ្ពស់ដល់ខ្ញុំម្ល៉េះផង ?

- សមរម្យហើយចំពោះរូបឯងហ្នឹង ! ( ហ្សេដៀរ៉ូបន្ថែម ) ។

ភ្លេងចាប់ប្រគំចង្វាក់យឺតៗជាថ្មី ។ គេចាប់ផ្ដើមពន្លត់ភ្លើងបណ្ដើរៗ រហូតទាល់តែស្ទើរអស់គ្មានសល់ ។ នៅទីនេះមនុស្សទាំងអស់ហាក់ដូចជាចាត់ទុកខ្លួនជាបក្សីរាត្រីចរដែលមិនចូលចិត្តពន្លឺ ។ ភ្លើងក្រហមស្រទន់ចាំងមកលើភក្ត្រនាងវ៉ាវិនដែលបណ្ដាលឱ្យសម្រស់ល្អលើសភាពពិត បូន ដប់ដង សមអារម្មណ៍បុរស ដែលកំពុងតែផុតរោលដោយគ្រឿងស្រវឹងផងនោះ ក៏រាបនេះឡើងសន្ធោសន្ធៅនៅក្នុងឱរា ។ រួចជនអារកាត់តែម្នាក់ឯង : " កើតមកជាតួអង្គបុរស ត្រូវតែហ៊ានប្រឈមមុខនូវគ្រប់រឿង បើមិនដូច្នោះទេ មុខជាគេដាក់ឈ្មោះ គាំសាវគញ្ញី ហើយ " ។

វ៉ាវិនបបួលជន ÷

- លោក...អញ្ជើញឡើងរាំ...ខ្ញុំនឹងបង្រៀនលោកឱ្យចេះ ។

ជនមិនឆ្លើយ គ្រាន់តែក្រោកឈរដោយស្ម័គ្រចិត្ត ដើរតាមនាងវ៉ាវិនទៅកាន់ឆាក *(Piste)* រាំ ។ គ្រាន់តែអ្នកទាំងពីរប្រុងប្រៀបរាំ ស្រាប់តែដៃតួហ្សេដៀរ៉ូដើរទៅដល់ដែររួចខ្សិបខ្សៀបដាក់ត្រចៀកវ៉ាវិន ៗក៏ងាកមកសុំទោសជន ÷

- សុំទោសលោក....ខ្ញុំមានការបន្ទាន់និងចាំបាច់ណាស់...ហើយត្រូវទៅឥឡូវហ្នឹងតែម្ដង ។

ថាហើយ នាងក៏ដើរចេញពីឆាករាំនោះទៅ ទុកឱ្យជនដើរត្រឡប់មកកាន់កន្លែងវិញ ។ ហ្សេដៀរ៉ូសួរជន ÷

- ជន ! ហៅអ្នកបម្រើឱ្យយកស្រីម្នាក់មកជំនួសវ៉ាវិន មក៍ !


www.elibraryofcambodia.org

## ៥

# ជោគជ័យ

សាលាស្រុកស្អាងឋិតនៅខាងត្បូងផ្សារស្អាង តាមបណ្តោយមាត់ទន្លេបាសាក់ ។ ស្រុកនេះឋិតនៅចម្ងាយសាមសិបគីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ។ ប្រជាជនមានជីវភាពធូរធាគ្រាន់បើ ដោយគេប្រកបរបរធ្វើចម្ការផង ធ្វើស្រែប្រដេញទឹកផង ។ ប៉ុន្តែសេចក្តីលោភលន់នៅតែគ្របសង្កត់លើអារម្មណ៍មនុស្សលោក ឱ្យនៅតែចង់បានដោយមិនចេះឆ្អែតឆ្អន់សោះ ទោះបីជាគេបង្កើតច្បាប់សម្រាប់ជារង្វាស់ក្រឹត្យក្រមយ៉ាងណា ក៏មនុស្សនៅតែលួចបំពានទៀត ។

ថ្ងៃនេះលោកស្រី នួន ណារ៉ា ភរិយាលោកចៅហ្វាយស្រុកដែលទើបតែផ្លាស់មកពីស្រុកមោងក្នុងខេត្តបាត់ដំបង កំពុងត្រួតពិនិត្យអ្នកបម្រើធ្វើម្ហូបអាហារនៅក្នុងផ្ទះបាយ ។ លោកស្រីត្រូវរៀបចំទទួលលោកចៅហ្វាយខេត្ត ដែលនឹងអញ្ជើញមកសួរសុខទុក្ខលោក កែវ ខាត់ ចៅហ្វាយស្រុកថ្មី ។

មុនឆ្នាំ ១៩៧៥ ចៅហ្វាយខេត្ត ឬចៅហ្វាយស្រុក សុទ្ធតែមានគេហដ្ឋាននៅក្នុងសាលាខេត្ត ឬនៅក្នុងសាលាស្រុក ដូច្នេះហើយបានជាចៅហ្វាយខេត្ត ឬចៅហ្វាយស្រុកថ្មីផ្លាស់មក គឺមានលំនៅឋានស្រាប់ ដោយមិនចាំបាច់ដើររកជួលផ្ទះនៅទេ ។ នៅទីរួមខេត្តផ្ទះលោកចៅហ្វាយខេត្តសង់ដាច់ពីកន្លែងធ្វើការ ចំណែកឯនៅសាលាស្រុកស្អាងនេះវិញផ្ទះលោកចៅហ្វាយស្រុកនៅរួមគ្នានឹងកន្លែងធ្វើការ គ្រាន់តែកន្លែងធ្វើការនៅខាងមុខហើយមួយកំណាត់ក្រោយ ជាគេហដ្ឋានលោកចៅហ្វាយស្រុកស្នាក់នៅ ។ ឯផ្ទះបាយគេសង់ដាច់ពីផ្ទះធំ ការពារកុំឱ្យអគ្គិភ័យឆាបឆេះរហ័សដល់ផ្ទះធំពេក ដែលមានផ្ទុកសុទ្ធតែ


www.elibraryofcambodia.org

ឯកសាររបស់រដ្ឋ ។

លោក កែវ ខាត់ អង្គុយមិនសុខមិនសាប់នៅក្នុងការិយាល័យ ក៏ងើបដើរមកផ្ទះបាយ ដោយមានកាន់សំបុត្រមួយនៅដៃផង ។ លោកមានទឹកមុខញញឹមរីករាយ ។ លោកស្រីឃើញស្វាមីអញ្ជើញមកមុនម៉ោង ក៏នឹកឆ្ងល់រួចសួរ ÷

- លោកបង ថ្ងៃនេះរហ័សចុះម្ល៉េះ ?

- នៅមិនទាន់ដល់ម៉ោងបងចុះទេ ! ប៉ុន្តែនាងរៀបរយម្ហូបអាហារហើយឬនៅ ? លោកចៅហ្វាយខេត្តអញ្ជើញមកដល់ម៉ោង ដប់មួយសាមសិបនាទី ឥឡូវហ្នឹងហើយ !

- សូមលោកកុំព្រួយបារម្ភ...ខ្ញុំរៀបចំម្ហូបអាហាររួចរាល់អស់ហើយ !... ចាំតែដល់លោកអញ្ជើញមក ដាក់កម្តៅឱ្យក្តៅឡើងវិញ ។

អ្នកស្រីឃើញសំបុត្រនៅដៃស្វាមី ក៏នឹកឆ្ងល់ ហើយសួរនាំ ÷

- សំបុត្រអ្នកណាគេហ្នឹង លោកបង ?

- គឺសំបុត្រកូនប្រុសរបស់យើងណា៎ !

- អ្ហា៎ !...មើលទៅលោកបង...មើលទៅ...គេនិយាយពីអ្វីខ្លះ ?

- បងមើលហើយ...គឺគេនិយាយពីគេប្រឡងជាប់ចូលទៅឆ្នាំទីពីរទៀតហើយ ។

- ចុះសម្លាញ់គេ ឈ្មោះ រដ្ឋា នោះដូចម្តេចដែរ គេមានសរសេរប្រាប់យើងទេ ?

- ឱ ! រដ្ឋាឬ ?...ក៏ប្រឡងជាប់ដែរ ។

- ប្រសើរណាស់ ហ្ន៎ !

កំពុងតែនិយាយគ្នា ស្ត្រីបម្រើម្នាក់ដែលមកពីបេះជីរនៅសួនបន្លែខាងក្រោយដើរឱនលំទោន ហាក់មានបញ្ហាអ្វីចង់និយាយជម្រាបលោកស្រី... ប៉ុន្តែអាក់ខានដោយសារតែលោកស្រី និងលោកប្រុសកំពុងមានកិច្ចពិភាក្សា ។ លោកស្រីយល់អធ្យាស្រ័យអ្នកបម្រើក៏បែរមកសួរ ÷

- មីងមានការអ្វីដែរ ?


www.elibraryofcambodia.org

- ស្រីឆ្កួតនោះមកទៀតហើយ !

- ជូសបាយឱ្យគាត់ហូបផងទៅ !

អ្នកបម្រើរអ៊ូ ÷

- លោកស្រី ! ឧស្សាហ៍ឱ្យបាយទឹក នំចំណីអីចឹងបានជាគាត់ញ៉ាម...បន្តិច១មក ហើយ...ពីព្រោះមកទីនេះវាបានឆ្អែត ។

លោកស្រី ខ្ទួន ណារ៉ា មិននិយាយតប ទុកពេលឱ្យលោក កែវ ខាត់ ជាស្វាមី ឆ្លើយទៅអ្នកបម្រើវិញឱ្យអស់មន្ទិលសង្ស័យ ÷

- លោកស្រីមីង ជាគ្រូពេទ្យខាងចិត្តសាស្ត្រណា៎ !

លុះឮលោកចៅហ្វាយស្រុកថ្មីមានប្រសាសន៍ដូច្នេះ អ្នកបម្រើភ្ញាក់អារម្មណ៍ បើក ភ្នែកធំៗ សម្លឹងទៅមុខញញឹមដ៏ស្រទន់របស់លោកស្រីដែលកំពុងមើលទៅមុខស្វាមីហាក់ ដូចមានន័យថា : " ស្អប់បងណាស់ ! ពូកែនិយាយលើកទឹកចិត្ត នាងខ្ញុំតែងតែស្រលាញ់ លោកបងគ្មានពេលណារសាយឡើយ " ។ លោកចៅហ្វាយស្រុកនិយាយបន្តទៀតទៅ កាន់អ្នកបម្រើ ÷

- មីង ធ្វើតាមសទ្ធាលោកស្រីមីង ទៅមិនខុសទេ !

អ្នកបម្រើដែលមានវ័យចំណាស់ជាងលោកស្រីប្រហែលជា ដប់ប្រាំឆ្នាំ ក៏ថយទៅ បំពេញតួនាទីរបស់ខ្លួន ។ ចំណែកឯលោកស្រី ខ្ទួន ណារ៉ា វិញ ដើរតាមអ្នកបម្រើទៅមើល ស្ត្រីឆ្កួតនោះ ។ លោកស្រីឈរមើលអ្នកបម្រើផ្តល់ចំណីអាហារដោយយកចិត្តទុកដាក់ ។ អ្នកបម្រើនិយាយរអ៊ូតែម្នាក់ឯង ÷

- គ្រូពេទ្យ ឯងមានសំណាងហើយ !...បើចូលផ្ទះគេផ្សេង...គេដេញគប់ គេមិន ឱ្យចូលផ្ទះគេទេ...អើ ! បើគ្រូពេទ្យឯងមាត់អាក្រក់តាំងពីនៅជា ឥឡូវមិនគ្រប់ទឹក ហើយនៅតែឡូឡា ជេរបញ្ចោរ...ធ្វើមើលតែខ្លួនហ្នឹងជាម្ចាស់ទឹក ម្ចាស់ដីទៀតនោះ ! ឡាស់ជាពិបាកហើយ !


www.elibraryofcambodia.org

មីងលឿមចង់និយាយបន្តទៀត ប៉ុន្តែត្រូវលោកស្រីសួរ ៖

- មីង លឿម...អ្នកឆ្កួតហ្នឹង វាយ៉ាងម៉េច ?

- អ្នកឆ្កួតហ្នឹង !...ពិបាកនិយាយណាស់លោកស្រី...ម្តងដូចជាដឹងខុសដឹងត្រូវ ... ម្តងដូចជាមិនដឹងខុសមិនដឹងត្រូវ... គាត់វក់ម្តងៗ... តាំងពីចេញពីពេទ្យព្រែកធ្លាត មក ។ ប៉ុន្តែតាំងពីលោកស្រីឧស្សាហ៍ឱ្យបាយទឹកគាត់មក...មើលទៅដូចជាមនុស្ស ជានាអីចឹង !

មីងលឿម និយាយពិចារណាម្នាក់ឯង ហាក់ដូចជាមិនដាច់ស្រេចសោះពីរឿង មីងឆ្កួតនោះ ។ លោកស្រីឮដូច្នេះ ក៏មានយោបល់ ៖

- អ្នកឆ្កួតហ្នឹង ! ឆ្កួតយូរហើយ ឬ មីងលឿម ?

- ប្រាំមួយឆ្នាំហើយលោកស្រី !...គាត់ពីដើមធ្វើឆ្មប...ធ្វើពេទ្យដែរ ។

លោកស្រីភ្ញាក់ ភ្ញាត់មាត់ ៖

- យី ! មិនមែនមនុស្សល្ងង់ឯណា !...ជាអ្នកចេះដឹងដែរទេតើ !...ហើយជា ពេទ្យទៀត...អ្នកធ្វើពេទ្យជាមនុស្សជួយអាយុជីវិតគេផងណា !...មីងយល់ទេ ?

មិនឮមីងលឿមឆ្លើយយ៉ាងណាផង ស្រាប់តែអ្នកឆ្កួតឆ្លើយជំនួស ៖

- ភ្លើៗ !...ប៉ុណ្ណឹងក៏ធ្វើជាមិនយល់ដែរ !...និយាយដូចលោកស្រីធំបានត្រូវ ...អញចង់តែបញ្ចោរមីល្ងង់...អញខុសមែន...តែអញបានជួយជីវិតគេឱ្យរស់ តែ... ម៉េចក៏ ចោទថាអញឆ្កួត...គឺហងរាល់គ្នាទេដែលឆ្កួតនោះ !

មីងលឿម អង្គុយស្តាប់ដោយស្ងៀមស្ងាត់ មួយសន្ទុះទើបនិយាយថា ៖

- ហូបបាយទៅ...ឆ្អែតហើយឬនៅ ?...បើនៅទេយកទៀត !...បងឡី !

- អើ និយាយស្រួលៗអីចឹងអញយល់ !...កុំថាអញឆ្កួតណា !

គ្រាន់តែនិយាយមិនទាន់ផុតពីមាត់ផង អ្នកគ្រូពេទ្យដែលមីងលឿមហៅថា "បងឡី" អម្បាញ់មិញក៏ងើបក្រោះ ហើយស្រែកច្រៀង "សកវាទី" យ៉ាងពីរោះ


www.elibraryofcambodia.org

លន្ទង់លន្ទោច គួរឱ្យសង្វេគអនិច្ចា ។

លោកស្រីពិចារណា : " ឱ ! មនុស្សយើងអើយ ទោះបីជាខ្លួនឆ្កួត ក៏មិនចង់ឱ្យគេថាឆ្កួតដែរ !...បើម្នាក់ៗមិនទទួលខ្លួនដូច្នេះ...តើធ្វើដូចម្ដេចនឹងដឹងទៅ ? "

ស្ងូរសន្ធឹករថយន្តពីរ-បីគ្រឿងមកឈប់នៅមុខសាលាស្រុក ធ្វើឱ្យលោកស្រី ណារ៉ា ដឹងថា លោកចៅហ្វាយខេត្តកណ្ដាលអញ្ជើញមកដល់ហើយ ។ លោកស្រីចូលក្នុងបន្ទប់ ប្ដូរសម្លៀកបំពាក់បម្រុងទុកទទួលភ្ញៀវ ។ បន្ទាប់មក លោកស្រីក៏យកចិញ្ចៀនពេជ្រ មកស៊កចូលក្នុងម្រាមនាងដៃយ៉ាងស័ក្តិសម ។ លោកស្រីក៏ចេញទៅទទួលលោកចៅហ្វាយខេត្ត និងភរិយា ព្រមទាំងអ្នកមុខអ្នកការ និងបរិពារពីរ-បីនាក់ទៀត ។ រួចហើយលោកស្រី ណារ៉ា ចាប់ផ្ដើមលើកដៃសំពះភ្ញៀវទាំងអស់ ព្រមទាំងចោលភ្នែកក្រឡេកទៅភរិយាលោកចៅហ្វាយខេត្ត ដែលស្លៀកពាក់យ៉ាងស្រស់សោភា និងរំលេចទៅដោយគ្រឿងអលង្ការដ៏មានតម្លៃភ្លឺចាំងរន្ទាល ។

ក្រោយពេលសំណេះសំណាលគ្នាបានបន្តិចមក លោកចៅហ្វាយខេត្តក៏ពោលពាក្យពេចន៍ផ្ដាំផ្ញើខ្លះចំពោះលោកចៅហ្វាយស្រុកថ្មី ÷

- ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សន្ដានចិត្តរបស់លោក ដែលបានរៀបចំបាយទឹកចំពោះខ្ញុំ ជាពិសេសសូមសរសើរដល់ស្នាដៃលោកស្រីដែលចេះធ្វើម្ហូបយ៉ាងមានឱជារសឆ្ងាញ់ពិសា...លោកចៅហ្វាយស្រុកពិតជាមានសំណាងណាស់ !

លោកស្រី ណារ៉ា ញញឹមអៀនប្រៀននឹងពាក្យសរសើររបស់លោកចៅហ្វាយខេត្ត ។ លោកចៅហ្វាយស្រុកឆ្លៀតបន្ថែម ÷

- តេជគុណមានប្រសាសន៍ពិតជាត្រូវណាស់ ! នាងមិនត្រឹមតែពូកែធ្វើម្ហូបទេ អ្វីៗក៏ពូកែដែរ ! (គឺលោកចង់សំដៅទៅលើការប្រដៅកូនចៅក៏ពូកែដែរ) ។

លោកចៅហ្វាយខេត្ត និងលោកស្រីជាភរិយាដែលនៅក្បែរនោះ លុះឮពាក្យលោក កែវ ខាត់ ពោលដូច្នោះ ក៏ផ្ទុះសំណើចព្រមគ្នា នាំឱ្យបរិយាកាសមានភាពស្និទ្ធស្នាល


www.elibraryofcambodia.org

ក្រៃលែង ។

លោកចៅហ្វាយខេត្តមានយោបល់បន្ត ÷

- ស្រុកយើងទើបតែរំដោះពីរបបរាជានិយម...ប៉ុន្តែតាមខ្ញុំសង្កេតជាទូទៅឃើញថាក្មេងៗគេមានចិត្តសប្បាយរីករាយណាស់ ហាក់ដូចជាកំពុងតែស្រវឹងនឹងសេរីភាព... តែគេភ្លេចគិតថា តើសេរីភាពនោះវាជាសេរីភាពពិតប្រាកដដែរឬទេ ? ហើយយើងពិតជាមិននៅក្រោមអាណានិគមនៃប្រទេសណាមួយឡើយមែនឬ ?...រឿងនេះខ្ញុំបារម្ភខ្លាំងណាស់...ខ្ញុំសូមចិត្តលោកចៅហ្វាយស្រុកថា បេះដូងលោកនៅជាខ្មែរតែប៉ុណ្ណឹងបានហើយ !

ពាក្យផ្តាំផ្ញើយ៉ាងខ្លី ដែលប្រកបដោយសារៈសំខាន់យ៉ាងនេះ ធ្វើឱ្យលោកចៅហ្វាយស្រុក កែវ ខាត់ នឹកចាំមិនភ្លេចនូវពាក្យ " សូមឱ្យបេះដូងនៅជាខ្មែរ " នេះសបញ្ជាក់ថា លោកចៅហ្វាយខេត្តពិតជាអ្នកស្នេហាជាតិម្នាក់ដែរ ។

ក្រោយពីបរិភោគ និង សំណេះសំណាលរួចមក លោកចៅហ្វាយខេត្ត និងលោកចៅហ្វាយស្រុក ក៏អញ្ជើញចូលទៅក្នុងការិយាល័យ ពិភាក្សាពីកិច្ចការស្រុកទេសសំខាន់ៗបន្ថែមទៀតដោយមិនឱ្យភរិយាបានដឹងឡើយ ដោយសារជំនាន់ទសវត្សទី ៦០-៧០ ស្ត្រីភាគច្រើន ៗតែបានរៀនសូត្រជ្រៅជ្រះ និងរៀនវិជ្ជាមេផ្ទះ ឯការងាររដ្ឋសំខាន់ៗ ភាគច្រើនបុរសជាអ្នកកាន់កាប់ ។

ពេលជូនដំណើរភ្ញៀវហើយ លោកស្រី ណារ៉ា វិលមកជួយរៀបចំទុកដាក់ជាមួយអ្នកបម្រើ ដោយពុំមានប្រកាន់ខ្លួនឡើយ ។ អ្នកបម្រើប្រុសម្នាក់ បានយកសំបុត្រមកជូនលោកស្រី ៗហែកមើលភ្លាមដោយគ្មានបង្អង់ ។ លោកស្រីចាប់ផ្តើមមើលសេចក្តីនៅក្នុងសំបុត្រ ដែលពេលនោះមីងលឿម លួចតាមសង្កេតអាកប្បកិរិយារបស់លោកស្រីព្រមទាំងសំដែងទឹកមុខញញឹមតាមលោកស្រីដែរ ។ អានចប់លោកស្រីក៏ងាកមកសួរមីងលឿម ÷

- យ៉ាងដូចម្តេច បានជាមីងសប្បាយចិត្ត ?



www.elibraryofcambodia.org

- ចាស ! ឃើញលោកស្រីញញឹមពព្រាយ ។

- ចុះ មីងមានឆ្ងល់ទេ ថាហេតុអ្វីក៏ខ្ញុំរីករាយយ៉ាងនេះ ?

មីងលឿម គ្រវីក្បាល រួចឆ្លើយដោយគោរព ÷

- ចាស ! ដឹងតែត្រឹមថាមានដំណឹងល្អតែប៉ុណ្ណោះ ។

- ត្រូវហើយមីង...កូនស្រីខ្ញុំគេប្រឡងជាប់ហើយៗគេសុំច្បាប់ខ្ញុំ និងប្ដីខ្ញុំទៅលេងកែបជាមួយមិត្តភក្តិគេ ។

- ឱ ! ខ្ញុំសូមជួយត្រេកអរលោកស្រី លោកប្រុសផង ដែលមានកូនសុទ្ធតែរៀនពូកែដូច្នេះ !

- អរគុណហើយមីង ។

* * * * *


www.elibraryofcambodia.org

# ៦

# ជីវិតថ្មី នៃក្ដីសង្ឃឹម

ក្រុងកែប ជារមណីយដ្ឋានទេសចរណ៍មួយតាំងពីយូរយាមកហើយ ឋិតនៅជិតខេត្តកំពត មានចម្ងាយ ១៦៥ គ.ម ពីទីក្រុងភ្នំពេញ ។ ទីក្រុងនេះឋិតនៅតាមបណ្ដោយជើង ភ្នំ ក្បែរមាត់សមុទ្រ សម្បូណ៌ទៅដោយឆ្នេរខ្សាច់សម្រាប់មុជទឹកលេងកំសាន្ដ ។

ប្រជាជននៅទីនេះ ច្រើនតែប្រកបរបរលក់ដូរទទួលភ្ញៀវទេសចរណ៍ ជាកសិករ និង ជាអ្នកនេសាទសមុទ្រខ្លះ ។ ភ្ញៀវទេសចរណ៍ដែលទៅលេងទីក្រុងកែបភាគច្រើន ។ មានចំណូលចិត្តទិញក្ដាមសេះ មឹក បួបង្គា ។ ល ។ ដែលនៅស្រស់ថ្មីៗយកមកចម្អិនធ្វើជាម្ហូបអាហារ ។

ថ្ងៃនេះទីក្រុងកែបអ៊ូអរទៅដោយទេសចរណ៍ ដែលភាគច្រើនៗតែជាយុវវ័យមកលំហែកាយ បន្ទាប់ពីការប្រកាសលទ្ធផលប្រឡងមធ្យមសិក្សាប័ត្រភាគទី ២ មក ។ សិស្សមួយចំនួនដែលប្រឡងជាប់សប្បាយរីករាយក្នុងចិត្តឥតឧបមា គេរួមគំនិតគ្នាឆ្ឆៀតទៅលំហែកាយ សប្បាយនៅតាមរមណីយដ្ឋានផ្សេងៗ ។ ចំណែកឯឧប្បល និង កេសរ ក៏ត្រូវបានលោក សម្បត្តិ និង ភរិយា អនុញ្ញាតឱ្យមកលំហែកាយនៅភូមិគ្រឹះរបស់លោកឯចង្កេះភ្នំ នាក្រុងកែបនេះដែរ ។ លោក សម្បត្តិ បានចាត់ឱ្យមីងយឿនតាមមកមើលការខុសត្រូវកូនស្រីគាត់ ហើយលោកប្រគល់រថយន្ដវែសាយ *( Versaille )* ឱ្យអ្នកបើកបរឈ្មោះ ឡាក់ ជូនមកលេង និង នៅចាំបម្រើរហូតដល់ពេលត្រឡប់ទៅផ្ទះវិញ ។

រថយន្ដវែសាយ *(Versaille)* បានដឹកជញ្ជូនក្រុមគ្រួសារលោក សម្បត្តិ មកដល់ទីក្រុងកែបនៅពេលរសៀល ។ លុះព្រលឹមស្រាងៗនាងឧប្បល និង កេសរស្លៀកពាក់ខោ អាវ មុជទឹករីបរាង ធ្វើដំណើរមួយៗតាមឆ្នេរខ្សាច់ ភ្នែករវើរវៃពៃមើលសំបកខ្យងណា



www.elibraryofcambodia.org

ដែលមានពន្លឺ ហើយនាំគ្នារើសវាដាក់ក្នុងកូនកំប៉ុង ។ ជូនកាលនាងកញ្ញាទាំងពីរ ប្រទះកូនក្តាមសមុទ្ររត់យ៉ាងលឿន ធ្វើឱ្យនាងភ្ញាក់រត់ដេញតាមចាប់កូនក្តាមនោះ ម្តង១នាងភ្ញាត់ចំណាប់ដួលដេកលើឆ្នេរខ្សាច់ ធ្វើឱ្យក្តាមផ្អើលកាយរន្ធយ៉ាងលឿន ហើយចូលទៅសម្ងំក្នុងរន្ធបាត់អស់ទៅ ។ ឧប្បល និង កេសរ សប្បាយចិត្តណាស់ សប្បាយនឹងប្រឡងជាប់ថ្មី១ផង និងសប្បាយនឹងធម្មជាតិនៅមាត់សមុទ្រដែលនាងចូលចិត្តបំផុតផង ។ ជាពិសេសនាងសប្បាយដោយសារបានរត់ប្រឡែងលេងនឹងកូនក្តាម ហើយដួលច្រងាប់ច្រងិល ប្រឡាក់ខ្លួននឹងដីខ្សាច់ ។ ក្រុមកំលោះទាំងហ្វូងហ្វាយ ខ្លះអង្គុយជុំកង់គ្នាមានទាំងឧបករណ៍តន្ត្រីដូចជា ហ្គីតា ដេញកំដរ អ្នកខ្លះច្រៀង អ្នកខ្លះទះដៃ បង្កឱ្យបរិយាកាសកាន់តែរីករាយសប្បាយឡើង ។

ក្រោយពីរត់លេងតាមឆ្នេរខ្សាច់ នាងឧប្បល និង កេសរ នាំគ្នាជិះប៉េដាឡូ *" Pédalo "* ធាក់ទៅឆ្ងាយ តាមប៉េដាឡូ ពីរ-បី ទៀតដែលនៅដាច់ឆ្ងាយពីគេឯង ។ កូនកាណូតយន្តមួយគ្រឿង បើកឆ្វែលចុះឆ្វែលឡើងដែលនៅពីក្រោយ សណ្តោងមនុស្សម្នាក់ កំពុងសំដែងកាយវិការទៅតាមទេពកោសល្យដ៏ប៉ិនប្រសប់របស់គេនៅលើឈើស្គី *(Sky)* ដ៏ស្តើង ។ ស្រាប់តែពេលនោះឮសំឡេង ឧប្បល និង កេសរស្រែកឡើងដោយមានបក់ដៃធ្វើកាយវិការ ÷

- ជួយផង ១ !!!

កូនកាណូតយន្តបន្ថយល្បឿន បរមករែបជិតប៉េដាឡូ របស់កញ្ញាទាំងពីរ ១ក៏លើកដៃចង្អុលបញ្ជាឱ្យកាណូតនោះ បរសំដៅទៅប៉េដាឡូមួយទៀតដែលនៅឆ្ងាយពីនាងប្រហែលជាម្ភៃម៉ែត្រ ។ នៅក្បែរប៉េដាឡូនោះ មានមនុស្សលើកដៃខ្វែ១រកជំនួយសង្គ្រោះ ។ កូនកាណូតបើកសំដៅមកជិតជនរងគ្រោះ ហើយយុវជនម្នាក់ក៏លោតសំយុងទៅរកមនុស្សដែលលង់ទឹកនោះ លើកមកដាក់ក្នុងកាណូតយន្ត ហើយបរសំដៅមកខាង ។ ចំណែកឯឧប្បល និង កេសរក៏ធាក់ ប៉េដាឡូ មកតាមក្រោយដែរ ។


www.elibraryofcambodia.org

គេលើករលាក់អ្នករងគ្រោះដែលជាស្ត្រីភេទ រួចផ្ដេកនៅលើវាលខ្សាច់ ។ ហើយយុវជនអ្នកសង្គ្រោះ ក៏ចាប់ផ្ដើមឱ្យដង្ហើមនាងតាមមាត់...មួយសន្ទុះក្រោយមកទើបនារីរងគ្រោះបើកភ្នែកឡើងសន្សឹមៗ ឃើញវង់ភក្ត្រយុវជនម្នាក់នៅជិតនាង ឯវង់ភក្ត្រអ្នកផ្សេងទៀតនៅព័ទ្ធវង់ក្បែរៗគ្នា ។ ពេលដឹងស្មារតី នារីអភ័ព្វស្រវេស្រវាងើបឡើងទាំងអស់កម្លាំង ហើយស្រែកដោយសំឡេងល្វើយៗ បែបអស់សង្ឃឹម ÷

- ខ្ញុំមិនចង់រស់ទេ !...

នាងឧប្បល បន្លឺកាត់ ហាក់ដូចជាមិត្តតាំងពីយូរហើយ ÷

- មិត្តមិនត្រូវស្លាប់ទេ !...មិត្តជាយុវវ័យ ត្រូវតែតស៊ូរស់ ដើម្បីជាអនាគតជាតិខ្មែរណា !...

ពាក្យមួយឃ្លារបស់ ឧប្បល ធ្វើឱ្យនារីរងគ្រោះយំអណ្ដឺតអណ្ដកជាថ្មី ។ កេសរឃើញដូច្នោះក៏ស្ទុះទៅជិត លើកដៃនាងមកកាន់ រួចនិយាយលួងលោម ÷

- សូមមិត្តកុំអស់សង្ឃឹមអីណា ! ខ្ញុំក៏ជាមិត្តម្នាក់ដែរ !

កំពុងតែនិយាយគ្នា បុរសម្នាក់អាយុប្រហែលជាសែសិបឆ្នាំ មានមាឌស្គម សក់ស្កូវមួយៗ ដើរជ្រែកចូលមកជិតនារីរងគ្រោះ ។ សំឡេងអណ្ដឺតអណ្ដកក៏បន្លឺឡើង ÷

- បួផល !... ក្មួយ !... ហេតុអ្វីក៏ក្មួយធ្វើដូច្នោះអ៊ីចឹង ! ... មាឥតប្រកាន់ទោសពៃរ៍អ្វីទេ...ឆ្នាំនេះក្មួយប្រឡងមិនជាប់...តែឆ្នាំក្រោយ ក្មួយពិតជាជាប់ហើយ..មារន្ធត់ណាស់កាលបើឮដំណឹងដ៏អាក្រក់នេះ ។

លោកមារបស់កញ្ញា បួផល ងាកទៅរកអ្នកជួយសង្គ្រោះទាំងអស់ ហើយអញ្ជើញពួកគេឱ្យទៅគេហដ្ឋានរបស់លោក ដែលនៅក្បែរឆ្នេរសមុទ្រនេះដែរ ។ ឧប្បល និង កេសរ ដើរតាមពីក្រោយ ដោយនិយាយលួងលោម ព្រមទាំងផ្ដល់កម្លាំងចិត្ត ។

ក្រុមគ្រួសារនាងបួផល ទាំងក្មេង ទាំងចាស់ ចេញស្រមកទទួលនាងបួផលហើយ និងមនុស្សដែលហែហមអមដំណើរមកជាមួយផង ។ លោកមារបស់នាងបួផល


www.elibraryofcambodia.org

ជនគ្រវីក្បាលប្រកែក រួចឆ្លើយបដិសេធ ៖

- យកមកធ្វើអ្វី បើខ្ញុំមិនចេះវាផង !...មិនអីទេ ! ចាំថ្ងៃក្រោយខ្ញុំរៀនឱ្យចេះសិន....ចាំខ្ញុំយក ។

ពាក់កណ្តាលអធ្រាត្រទៅហើយ ភ្ញៀវក៏ចាប់ចាកចេញពីរង្គសាលបណ្តើរៗ ។ ចំណែកជនជូនហ្វេដេរ៉ូទៅកាន់សណ្ឋាគារកាំបូឌីយ៉ាណា រួចហើយ ក៏ជាក់ស៊ីក្លូត្រឡប់មកលំនៅដ្ឋានវិញ ។ គ្រាន់តែចេញដំណើរបានបន្តិច ស្រាប់តែមានជនមិនស្គាល់មុខពីរនាក់ជិះម៉ូតូហុងដាស្រីកញ្ចាស់មួយគ្រឿងមកអែបជន ដោយបញ្ចេញកាំភ្លើងខ្លី ហើយនិយាយគំរាមថា ៖

- មានប៉ុន្មានឱ្យអញទាំងអស់មក បើចង់សុខខ្លួន ?

ជនមិនតបតអ្វីទាំងអស់ ធ្វើអាកប្បកិរិយាស្ងាក់ស្ងើរ ហើយចុះពីលើស៊ីក្លូ។ រំពេចនោះចង្កៀងរថយន្តចាំងចំពីមុខកន្លែងកើតហេតុ ធ្វើឱ្យជនអន្ធពាលស្ទន់ស្ទា រួចសម្លុតបន្ថែម ៖

- លឿនឡើង !...បើចង់សុខខ្លួនឱ្យលុយមក ប្រយ័ត្នអញបាញ់ណាំ !

ឆ្លៀតឱកាសដ៏ប្រថុចប្រថុចនេះ ដើម្បីបង្ហាញសមត្ថភាពជាតួអង្គកូនប្រុសខ្លាំងប្រាំហត្ថ ជនតាំងស្មារតីប្រុងប្រយ័ត្នជានិច្ច ហើយគិតថា : “ បើយើងមិនមានប្រតិកម្មអ្វីនោះ ពួកអន្ធពាលនឹងបានចិត្ត ឡើងចាង ដើររាតត្បាតតាមអំពើចិត្តវាជាពុំខាន ” ។ រហ័សដូចផ្លេកបន្ទោរ ជនលើកជើងស្តាំទាត់ជាំងឡើង ធ្វើឱ្យកាំភ្លើងខ្ទាតចេញពីដៃជនអន្ធពាល ។ ពួកវាមិននឹកស្មានថាអ្នកជាក់ស៊ីក្លូ ដ៏សាមញ្ញរូបនេះមានវិជ្ជាគុណដ៏ចំណានបែបនេះសោះ ។ អាម្នាក់នៅលើម៉ូតូស្រែកថា : ប៉ូលីស !...គឺឡានប៉ូលីស !.... អាមួយដែលត្រូវជនដាក់មួយជើងរបូតកាំភ្លើងអំបាញ់មិញ ក៏ឡើងផែលទំលើកែបម៉ូតូពីក្រោយដែលមិត្តវាបញ្ឆេះម៉ាស៊ីនបញ្ចូលលេខចាំជាស្រេច ហើយបើកគេចខ្លួនពីសមត្ថកិច្ចបាត់ទៅ ។ រថយន្តប៉ូលីសក៏មកដល់ ។ ភ្នាក់ងារម្នាក់ស្រែកសួរថា ៖


www.elibraryofcambodia.org

ប្រញាប់ប្រញាល់ទៅអញ្ជើញគ្រូពេទ្យមកចាក់ថ្នាំលើកកម្លាំង ។ បន្ទាប់មកគាត់ងាកទៅកាន់ក្រុមុំ កំលោះទាំងអស់នោះដោយវាចាថា ÷

- មា សូមអរគុណក្មួយទាំងអស់ដែលចេះជួយឈឺឆ្អាល...មិនមើលបំណាំគ្នា ... (គាត់ងាកទៅរកនាងឧប្បល និងនាងកេសរ រួចនិយាយបន្ត) ថ្ងៃនេះសូមក្មួយជួយនៅកំដរប្អូនផលសិនទៅ !... ពីព្រោះនាងនៅពិបាកចិត្តខ្លាំងណាស់... ក្នុងផ្ទះនេះគ្មានអ្នកណាម្នាក់បន្ទោសសោះ...ប៉ុន្តែមិនដឹងជាដូចម្តេចបានជានាងគិតខ្លីយ៉ាងនេះ ?

លោក កើត សំភិន ត្រូវជាឪពុកមារបស់នាង បូផល ។ លោក រំភើប តក់ស្លុតណាស់នៅពេលដែលឃើញក្មួយស្រីលោតទឹកសម្លាប់ខ្លួនបែបនេះ ព្រោះកាលពីឆ្នាំកន្លងទៅភរិយាលោកមានគ្រោះថ្នាក់ដោយសារលង់ទឹកនេះរហូតដល់បាត់បង់ជីវិត ដូច្នេះហើយបានជាស្រមោលអពមង្គលនេះមកលងអារម្មណ៍លោក ឱ្យរន្ធត់ញាប់ញ័រឥតឧបមា ។ លោកងាកទៅសួរ អ្នកជួយសង្គ្រោះបូផល ដើម្បីបន្ទប់រឿងអតីតកាល ÷

- ក្មួយប្រុសខាងណោះឈ្មោះអីដែរ ? ធ្វើការ ឬក៏នៅរៀនទេ ?

- ខ្ញុំបាទឈ្មោះ សុផាន់ ខ្ញុំបាទរៀននៅឆ្នាំទី ៣ សាលាបច្ចេកទេសជាន់ខ្ពស់ ឯមិត្តខ្ញុំបាទនេះឈ្មោះ សារឿន គេជានិស្សិតសាលាពេទ្យ ឯមិត្តនេះឈ្មោះវិរុត ជានិស្សិតនាយទាហាន ។

- ចុះនាងខាងណោះ ! មេត្តាណែនាំឱ្យមាបានស្គាល់ផង !

- ចាស ! ខ្ញុំឈ្មោះឧប្បល មិត្តខ្ញុំនេះឈ្មោះកេសរ នាងខ្ញុំទើបតែប្រឡងជាប់មធ្យមសិក្សាប័ត្រភាគ ២ នេះ ។

ឮឧប្បល និយាយដូច្នេះ ទាំងលោក សំភិន ទាំងយុវជនទាំងបីងាកមើលមុខគ្នាចុះឡើង ហាក់មិនយល់នូវឃ្លាដែលឧប្បលនិយាយបង្ហាញអម្បាញ់មិញថា : “ មិត្តខ្ញុំនេះ ” ។ លោក សំភិន ក៏សួរនាងឧប្បលដោយងឿងឆ្ងល់ ÷

- នាងនិយាយថា នាងខាងណោះជាមិត្តឬ ? មា មិនយល់នាងនិយាយទេ...


www.elibraryofcambodia.org

មានមុខមាត់ប្រហាក់ប្រហែលគ្នា...មាស្មានតែកូន..

ឧប្បលនិយាយកាត់ ÷

- អ្នកណាៗក៏ស្មានខុសទាំងអស់...ការពិតមិនមែនសោះ...ខ្ញុំនិងកេសរជាមិត្តនឹងគ្នា... នាងខ្ញុំទាំងពីរនាក់ទើបតែជួបគ្នានៅឆ្នាំនេះហ្នឹងណា ! ... ដោយសារតែកេសរផ្លាស់ពីបាត់ដំបងមករៀននៅភ្នំពេញ ។

ក្នុងចំណោមអ្នកដែលស្គាល់នាងឧប្បល និង កេសរទាំងប៉ុន្មាន លែងហ៊ានស្មានថាអ្វីទៀតឡើយ ដោយសារសាមីខ្លួនគេពោលអះអាងដូច្នេះហើយ ។ លោក សំភិន និយាយលូងលោមថា ÷

- មា សូមឱ្យក្មួយទាំងអស់ រាប់អានបូផលផងណា !

អ្នកទាំងអស់ឆ្លើយព្រមគ្នា ÷

- ចាស ! លោកមាកុំព្រួយ !

- បាទ ! លោកមាកុំព្រួយ !

កេសរមានយោបល់ម្តង ÷

- លោកមា ! ល្ងាចនេះខ្ញុំសូមឱ្យ បូផល ទៅគេងជាមួយខ្ញុំ មួយយប់ ឬពីរយប់បានទេលោកមា ?

- ដើម្បីឱ្យបូផលសប្បាយចិត្ត មាយល់ព្រម...ប៉ុន្តែ...(លោកសំភិន ងាកទៅនិយាយជាមួយបូផលម្តងវិញ) ក្មួយគាប់ចិត្តទេ...បើនាងៗបបួលដូច្នេះ ?

បូផលឆ្លើយ ÷

- ចាស !...ក្រែងបានសប្បាយចិត្តដូចលោកមាមានប្រសាសន៍មែន ។

ឧប្បលប្រញាប់និយាយបន្ត ÷

- ខ្ញុំនៅតែពីរនាក់កេសរ...ដូច្នេះខ្ញុំក៏អផ្សុកដែរ ... ចង់បានគ្នាច្រើន ... លោកមាកុំបារម្ភអី ! ថ្វីត្បិតតែលោកឪពុក អ្នកម្តាយខ្ញុំមិនអញ្ជើញមកនៅជាមួយខ្ញុំ ... ក៏ប៉ុន្តែ


www.elibraryofcambodia.org

លោកបញ្ជូនចាស់ទុំឱ្យមកមើលការខុសត្រូវពួកយើងដែរ ។

- បើនាងនិយាយអ៊ីចឹង ! មារីតតែកក់ក្តៅណាស់ !

លោក សំភិន លាក្មួយៗទាំងអស់ចេញទៅក្រៅ ត្បិតគេទូរស័ព្ទមកអញ្ជើញលោកឱ្យទៅកំពត ។ ចំណែកបូផលវិញ នាងដូចជាបានធូរចិត្តដោយសារ ឧប្បល និង កេសរ មានប្អូនពាមិនឆ្មើងឆ្មៃ ថែមទាំងចេះនិយាយលួងលោមគួរឱ្យស្រឡាញ់ទៀតផង ។ ក្រោយពីនាងបូផលបានធូរស្បើយហើយ គេនាំគ្នាដើរត្រសងទៅភូមិគ្រឹះនាង ឧប្បល ដែលសង់នៅចង្កេះភ្នំ ។ ភូមិគ្រឹះតូចនេះសង់តែមួយជាន់ទេ មានបន្ទប់ដំណេកធំៗពីរ បន្ទប់ទទួលភ្ញៀវមួយ និងរានហាលបែរមុខមករកមាត់សមុទ្រដែលធំល្វឹងល្វើយ វែងឆ្ងាយដាច់កន្ទុយភ្នែក ។ រានហាលនេះលំអទៅដោយដើមផ្កាព័ទ្ធជុំវិញយ៉ាងល្អប្រណីត ។

រាត្រីនេះនាង ឧប្បល និងនាងកេសរ អញ្ជើញ សុផាន់ - សារឿន និង វិរុត ឱ្យមកនៅញុំាបាយជាមួយនាងដែរ ។ ក្នុងឱកាសនោះ កំលោះ ក្រមុំជជែកវែកញែក ឆ្លងឆ្លើយគ្នាយ៉ាងស្និទ្ធស្នាល ។ នាង បូផល ចាប់អារម្មណ៍នឹងសំដី សុផាន់ មួយឃ្លាទុកជាមេរៀននៅក្នុងជីវិត ។ សំដីនោះមានន័យថា ÷

- កើតមកជាមនុស្ស រមែងតែងតែជួបប្រទះជោគជ័យផង បរាជ័យផង... ពុំដែលមាននរណាម្នាក់លើលោកយើងនេះ ជួបតែជោគជ័យរហូតនោះទេ...ប៉ុន្តែបើគេជួបបរាជ័យហើយ...ក៏គេមិនត្រូវប្រកាន់យកការអស់សង្ឃឹមមកធ្វើជាគោលសំខាន់ឡើយ... ផ្ទុយទៅវិញគេត្រូវជំនះបរាជ័យ ដោយការតស៊ូឧស្សាហ៍ព្យាយាមជាប្រចាំ ។

បូផល លួចញញឹមសង្ឃឹមនៅក្នុងចិត្តតែម្នាក់ឯងថា : " តើសេចក្តីសង្ឃឹមនោះជាអ្វីទៅហ្ន៎ ! ឬក៏ពាក្យពេចន៍ដែលហូរចេញពីមាត់ប្រុសមានមន្តស្នេហ៍ ឬក៏ជាការជួបភក្រ្តគ្នាពេលនេះគ្រាន់តែធ្វើឱ្យកួចអារម្មណ៍ដូច្នេះឬ ? ។ ឱ ! វាមិនអ៊ីចឹងទេ ! ខ្ញុំគ្មានទៅរវើរវាយផ្តេសផ្តាសដូចដែលចិត្តឆ្កួតកួចគិតស្មាននោះឡើយ " ។

យប់ជ្រៅហើយ មិត្តភក្តិប្រុសៗក៏លាទៅផ្ទះសំណាក់របស់គេវិញ ។ ឧប្បល បាន


www.elibraryofcambodia.org

យកគ្រែបត់មកដាក់បន្ថែមនៅក្នុងបន្ទប់នាង ទុកសម្រាប់នាងបូផលគេងនៅទីនេះដែរ ។

មាន់រងាវកាន់តែញាប់រន្ថើនឡើង ជាសញ្ញាឱ្យយើងដឹងថាជិតភ្លឺហើយ ។ ឧប្បល ភ្ញាក់ហើយក៏ក្រឡេកភ្នែកដោយស្វ័យប្រវត្តិ មើលទៅឃើញបាត់ បូផល ពីលើគ្រែ ។ នាងភ័យណាស់ ខ្លាចមានហេតុការណ៍អាក្រក់ដោយថាហេតុអ្វីកើតឡើងម្តងទៀតលើរូប បូផល នាងស្ទុះងើបឡើង រួចស្រែកដាស់កេសរ ÷

- កេសរក្រោកឡើង !...បាត់បូផលទៅណាហើយ ?

ក្រមុំទាំងពីរ ដើរតម្រង់ទៅរានហាលដែលឋិតនៅខាងមុខបន្ទប់គេងរបស់ឧប្បល ក៏ប្រទះឃើញ បូផល កំពុងឈរសម្លឹងទៅជើងមេឃដែលបច្ចូសកាល បញ្ចេញពណ៌ក្រហម ច្រាលពេញផ្ទៃមេឃ ។ ខ្យល់សមុទ្របក់មកត្បូងរំរណ្តំគ្នា បង្កឱ្យក្រមុំទាំងបី អត់ទ្រាំស្រក់ទឹកភ្នែកមិនបាន ។ ឧប្បលបន្លឺឈ្មោះបូផល ដោយអំណរ ÷

- បូផល ឯងនៅទីនេះទេឬ ?...ខ្លាចតែភ័យ !

- មិត្តកុំព្រួយ...ខ្ញុំលែងគិតផ្តេសផ្តាសទៀតហើយ.....មាន...ការតាំងចិត្តខិតខំរៀនជាថ្មីឡើងវិញតែមួយមុខប៉ុណ្ណោះទេ ។

កេសរ ស្ទុះមកឱប បូផល ។ នាងទាំងបីនាក់រំភើប ញាប់ញ័រ យំខ្សឹកខ្សួលទាំងព្រឹកព្រហាម ។ ទឹកនេត្រាថ្លាឆ្វង់ដូចគ្រាប់ពេជ្រ ភ្លឺផ្លេក ហូរចុះមកកាត់ថ្ពាល់ស្រីក្រមុំទាំងបីដែលមានមូលហេតុខុសៗគ្នា ។ ឧប្បល យំព្រោះនឹកដល់អ្នកប្រុស ខេមរិន្ទ ឯនាង កេសរ យំខឹងព្រោះអារម្មណ៍នៅតែមើលឃើញការក្បត់ចិត្តរបស់វឌ្ឍនាឥតមានភ្លេចសោះ ចំណែកឯ បូផល យំពេលនេះដោយក្តីរំភើបនឹងបានរស់ជាថ្មី ដោយសារតែនាងក្រមុំទាំងពីរជួយពន្យល់ណែនាំ និងព្រមទាំងនឹកព្រឺព្រួចជាក្រោយ នូវការជួយសង្គ្រោះរបស់សុផាន់ ដោយឱ្យដង្ហើមតាមមាត់ដល់នាង ។ កេសរ បន្លឺដោយរអាក់រអួលជាចំៗទៅកាន់មិត្តថ្មី របស់នាងថា ÷

- ថ្ងៃថ្មី ជីវិតថ្មី ណាមិត្ត !


www.elibraryofcambodia.org

មិនមានឮសំឡេងអ្នកណាម្នាក់ឆ្លើយតប  ក្រៅពីឮតែខ្យល់បក់ថ្ងូរយ៉ាងគ្រលួច ជាជំនួសសំឡេងតបឆ្លើយនោះមកវិញ ។

* * * * *


www.elibraryofcambodia.org

# ៧

# ព្រេងវាសនា

រថយន្តម៉ាក ហ្ស៊ីប មួយគ្រឿងបានមកឈប់នៅជិតជើងភ្នំឧត្តុង្គ ។ ម្ចាស់រថយន្តពាក់មួកកាតិប ចុះពីរថយន្តមកអង្គុយពិនិត្យកង់រថយន្ត ក៏ឃើញកង់រថយន្តម្ខាងបែក ។ យុវជននោះគ្រវីក្បាលដកដង្ហើមធំ   ហាក់ដូចជាមិនដែលធ្លាប់ផ្លាស់ប្តូរកង់ឡានបានម្តងណាឡើយ ។ ស្រាប់តែរថយន្តមួយគ្រឿងផ្សេងទៀតមកឈប់ក្បែររថយន្តដែលបែកកង់នោះ ។ អ្នកបើកបរចុះមកសាកសួរម្ចាស់រថយន្តដែលបែកកង់នោះ ÷

- អានាង !...ចេះធ្វើខ្លួនឯងកើតទេ ?

ម្ចាស់រថយន្ត ហ្ស៊ីប ដែលត្រូវគេហៅអានាង ក៏ងាកមុខមកមើលម្ចាស់សំឡេង. ...ស្រាប់តែ...ភ្នៀវនោះភ្ញាក់ភ្នាត់មាត់ :

- ចុំយក្ស !....បូផល ទេតើ !...ពាក់មួកស្មៀកពាក់អ៊ីចឹង...ដូចក្មេងប្រុសបេះបិទ...ហើយទៅណាមកណាដែរ  បានជាបើកឡានម្នាក់ឯង  !...ចុះបើខ្ញុំមិនមកតាមផ្លូវនេះទេ...តើបានអ្នកណាជួយទៅហ្ន៎ ?

មុននឹងឆ្លើយតប បូផល ឆ្មៀតលួចសម្លក់អ្នកប្រុសដ៏សម្បូណ៌វោហារ ÷

- ប្រហែលជានៅតែងទីនេះរហូតហើយមើលទៅ !

នាងឆ្លើយរបៀបម៉ឺកុំង ។ អ្នកកំលោះខ្ជិលតតាំង ក៏សម្រួលប្រយោគ ÷

- ឯណាប្រដាប់គ្រឿប ?...គ្រាន់តែចង្អុលមក ខ្ញុំទៅយកខ្លួនឯង ។

- បើមិននៅក្នុងឡាននេះ លោកគិតថានៅឯណាទៅ ?

- ព្រះអើយ ! ឆ្លើយរបៀបនេះ ប្រហែលជានាងលួចតុំតាំងពីយូរមកហើយ !

- មានរឿងអីដែលខ្ញុំត្រូវតុំលោកនោះ ?


www.elibraryofcambodia.org

- បើមិនរឿងគុំទេ ហេតុអ្វីក៏នាងឆ្លើយយ៉ាងនេះ ?

- ខ្ញុំឆ្លើយទៅតាមសំនួរ លោកទេតើ !

អ្នកកំលោះនឹកថា :" នាងក្រមុំនេះជើងឆើតផង ! " ក៏ផ្ទុចសំនួរថ្មីមួយទៀត ដោយចង់ដេញដើងនាង បូផល ÷

- អឺចឹង ! បើខ្ញុំសួរនាងថា : នឹកខ្ញុំទេ ?

សំនួរនេះ ធ្វើឱ្យ បូផល ប្រែទឹកមុខទៅជាក្រហមងាំង ។ ជាតិជាប្រុស ធម្មជាតិបានបង្កើតឡើងឱ្យយល់នូវលក្ខណៈអៀនប្រៀនរបស់ស្ត្រីភេទ ។ សុផាន់ ក៏ឆ្មៀតសម្លឹងយ៉ាងយូរដោយកែវភ្នែកមុតស្រួច ធ្វើឱ្យខ្លាំងបាក់បបខ្លួបខ្លាច នៅចំពោះមុខដ៏ស្រស់ប៉ប្រែរបស់ខ្លួន ។ គេញញឹមនឹងជោគជ័យ ហើយនិយាយខ្សឹប១បន្តទៀត :

- ខ្ញុំផ្ញើសេចក្ដីនឹករឭកទៅនាង...ប៉ុន្តែបាត់សូន្យ...នាងមិនតបវិញសោះ ...ឯណាពាក្យថាយើងរាប់អានគ្នាជាមិត្តនោះ ទៅណាទៅ ?

- សុំទោស...ដោយសារខ្ញុំរវល់តែរៀន...ត្បិតខ្លាច..

- ឱ ! យល់ហើយ ១...

សុផាន់ស្រែកថ្ងូន១ រួចឆ្លើយឆ្លងតែម្នាក់ឯង ÷

- ... នាងខ្លាចខ្ញុំប្រព្រឹត្តពុំគប្បីលើរូបនាងទៀតឬ ?... ឥឡូវនាងប្រឡងជាប់ហើយមែនទេ ? យើងជួបគ្នានៅលើគោកវិញម្ដង...

សុផាន់ឈប់និយាយ ប៉ុន្តែគេនៅតែសម្លឹងមុខបូផល ស្ទើរតែនាងដកឃ្លាទៅណាមិនរួច ។ បូផល រអ៊ូតិច១តែម្នាក់ឯង : " ស្អប់ណាស់ប្រុសអីក៏មុខក្រាស់ម្ល៉េះ ! នៅព្រហើនមើលមុខគេ គ្មានចេះខ្មាសអ្នកណាអីចេះ ! " ។ ដោយអៀនទ្រាំពុំបាននាងបូផលក៏និយាយបន្ទប់ ÷

- បើមិនជួយផ្លាស់កង់ឡានខ្ញុំទេ អ៊ីចឹងគិតឱ្យខ្ញុំនៅគេងទីនេះហើយឬ ?

- បើនិយាយយ៉ាងនេះយូរហើយ ម្ល៉េះសមខ្ញុំផ្លាស់កង់ឱ្យនាងរួចបាត់ហើយ !...



www.elibraryofcambodia.org

ប៉ុន្តែនាងមិននិយាយអ្វីចឹងសោះ...នាងនៅតែពូកែរហូត ។

- ស្អប់ណាស់ !

- យល់ហើយ ! នាងមិនតបសំបុត្រមកខ្ញុំ មកពីនាងស្អប់ខ្ញុំ ។

បូផលដើរទៅយកប្រដាប់ត្រីបមកឱ្យសុផាន់ ។ នាងសម្គាល់ថា : " ពេលមានទុក្ខលេចមុខសុផាន់មកជួយភ្លាម នឹកទៅគួរឱ្យឆ្ងល់ណាស់ មានអ្វីទៅប្រាប់ហ្ន ? " ។

ប្រហែលជា ដប់ប្រាំ នាទី កន្លងផុតទៅ សុផាន់ក៏ផ្លាស់កង់ឡានហើយ ។ រីឯបូផល ប្រមូលប្រដាប់ប្រដាទុកដាក់រួចរាល់ ក៏បម្រុងនិយាយលាសុផាន់ ប៉ុន្តែត្រូវសុផាន់សួរនាង ÷

- នាងមកទីនេះជាមួយអ្នកណាដែរ ?

- ខ្ញុំមកជាមួយលោកមាខ្ញុំ

- វិស្សមកាលឆ្នាំនេះ បូផល ទៅលេងឯណាដែរ ?

- ប្រហែលជាទៅលេង ចម្ការចូរេនរបស់ឧប្បល ឯទឹកឈូ ។ ចុះលោកវិញ អញ្ជើញទៅទីណាដែរ ?

- ឱ្យខ្ញុំសុំទៅផងបានទេ ?

- លោកទៅសុំ ឧប្បលទៅ ពីព្រោះគេជាម្ចាស់ ។

- តែនាងអាចសុំជំនួសខ្ញុំផង...ខ្ញុំសង្ឃឹមទុកជាមុនហើយណា៎ !... សូមជម្រាបសួរសុខទុក្ខលោកមាជំនួសខ្ញុំផងណា៎ បូផល !

ថាហើយ គេក៏ងាកមកញញឹមដាក់បូផល រួចឡើងរថយន្តបរចេញទៅ ។ បូផលក៏បើករថយន្តបរវង់តាមជើងភ្នំក្រោមម្លប់ត្រឈឹងត្រឈៃនៃដើមគគីរ ដើមយាង ដើម ឈើទាល ។ នាងនឹកទៅព្រឹត្តិការណ៍នៃឆ្នាំកន្លងទៅដែលហាក់ដូចជានៅថ្មីៗ ។ អនុស្សាវរីយ៍នោះ វិលមកដាស់អារម្មណ៍បូផលឱ្យចេះតែស្រមៃនឹកដល់កំលោះសុផាន់ជាញឹកញយ ។



www.elibraryofcambodia.org

ឥឡូវនេះដោយសារតែក្មេងៗរាប់អានគ្នាយ៉ាងជិតស្និទ្ធ ធ្វើឱ្យលោកសំភិន ក៏ក្លាយជាញាតិផៅ លោក សម្បត្តិ និងលោក កែវ ខាត់ ដែរ ។ ជួនកាល បួផល មកលេងផ្ទះឧប្បលយូរថ្ងៃ ក៏លោក សំភិន ពុំបានបារម្ភដែរ ត្បិតនាងឧប្បលជានារីចូលចិត្តប្រមូលមិត្តណាស់ ។នាងជាកូនអ្នកមានសម្បត្តិស្តុកស្តម្ភមែន ប៉ុន្តែអាកប្បកិរិយា និង ឫកពារបស់នាងដូចលោក សម្បត្តិ ជាបិតានាង ធ្វើឱ្យគេចូលចិត្តគ្រប់ៗគ្នា ។ មនុស្សខ្លះគេលាក់តម្រិះពីការរកស៊ី ពីព្រោះគេគិតថា នេះជាឆ្នាំងបាយរបស់គេ ប៉ុន្តែផ្ទុយទៅវិញ លោក សម្បត្តិ មិនត្រឹមតែប្រាប់ពីអាថ៌កំបាំងរបស់មុខជំនួញទេ ថែមទាំងជួយផ្តុងផ្តើមទុនឱ្យគេរកស៊ីទៀតផង ។ ដូច្នេះហើយបានជាឧប្បល មានឱកាសនាំមិត្តភក្តិមករៀនសូត្រជាមួយនាងបានដោយគ្មានទើសទាស់ពីសំណាក់មាតា បិតា នាងឡើយ នាងតែងតែជម្រាបលោកជាចាស់ទុំនៅក្នុងផ្ទះជាដំណឹងបុំណ្ណោះ ។

---

នៅឯសាលាស្រុកស្អាងវិញ លោកប្រុសនិងភរិយា ព្រមទាំងអ្នកបម្រើប្រុស ស្រី រៀបចំទទួលកែវ ខេមរិន្ទ រដ្ឋា និង មិត្តភក្តិដែលបានវិលត្រឡប់មកពីប្រទេសបារាំងវិញ ។

ភ្ញៀវដែលត្រូវលោក កែវ ខាត់ អញ្ជើញមកក្នុងឱកាសនេះ មានលោកសម្បត្តិ និងលោកស្រី ព្រមទាំងបុត្រ លោកមាពោះម៉ាយ កើត សំភិន និងក្មួយស្រី បួផល លោក សិរិទ្ធ សក្តិ និងលោកស្រី ភួង បុប្ផា ដែលត្រូវជាបិតា មាតា របស់រដ្ឋា ។ ចំណែកឯ និស្សិត ទេព សុផាន់ សម សារឿន និង សាន វិរុត ក៏ចូលរួមតាមរយៈនាង ឧប្បល ដែរ។ អ្នកបម្រើនៅផ្ទះ ឧប្បល មួយចំនួនដូចជា មីង យឿន មីងរស់ ក៏ត្រូវបានលោកស្រីអនុញ្ញាតឱ្យមកដែរ ។ យុវជន យុវនារីទាំងអស់មកដល់ស្អាងភ្លាម ក៏បបួលគ្នាបង្ហួសទៅលេងវត្តស្អាងភ្នំសិន ។ នៅតែចាស់ៗបរិភោគបាយជុំគ្នា ។ កំពុងសំណេះសំណាលពីនេះពីនោះស្រាប់តែអ្នកឡីស្រីឆ្លូតចូលមក បំណងរកបាយហូបដូចរាល់ដង ។ លោកស្រីណារ៉ា ឃើញដូច្នេះក៏ងើបឡើង ហើយដើរទៅបង្គាប់មីង លឿម ឱ្យយកបាយទឹក នំចំណី


www.elibraryofcambodia.org

ឱ្យទៅអ្នកឡី ។ ពេលនោះអ្នកបម្រើទាំងអស់អង្គុយជុំគ្នាដែរ ។ មីងយឿន និមិត្តឃើញអ្នកឡី ក៏និយាយឡើង ÷

- អ្ហា ! អ្នកគ្រូពេទ្យ !

ពាក្យដែលមីងយឿនពោលអម្បាញ់មិញ ធ្វើឱ្យមីងលឿម និងលោកស្រី ណាវ៉ា ភ្ញាក់បន្តិច លោកស្រី ណាវ៉ា ក៏សម្លឹងទៅមីងយឿនដោយឆ្ងល់ រួចសួរ ÷

- មីងស្គាល់គ្រូពេទ្យឡីដែរ ឬ ?

មីងយឿន ខំសម្លឹងមុខលោកស្រី ណាវ៉ា ដោយមិនទាន់ឆ្លើយអ្វីទាំងអស់ រួចមើលទៅពេទ្យឡី ព្រមទាំងឆ្លើយមិនចំសំនួរទៅលោកស្រីវិញ ÷

- យូរឆ្នាំហើយ គ្រូពេទ្យ...មកនៅទីនេះសោះ..

មីងលឿមពោលកាត់ ÷

- អ្នកយឿន...មានទាក់ទងអីជាមួយគ្រូពេទ្យ ?

ពេលនោះអ្នកឡីដើរមកដល់ផ្ទះបាយ មីងយឿនឃើញដូច្នេះក៏និយាយមុនដោយមិនបានដឹងថា អ្នកគ្រូពេទ្យឡីក្លាយទៅជាមនុស្សវិកលចរិតដូច្នេះទេ ÷

- ពេទ្យ...ស្គាល់...ហើយចាំខ្ញុំទេ ?

ពេទ្យឡីខំសម្លឹងមុខមីងយឿនយ៉ាងយូរ រួចងក់ក្បាល ហើយនិយាយ ÷

- អញ និង ឯង រួមដៃគ្នាធ្វើ...

មីងយឿន រហ័សឆ្លើយ ÷

- ខ្ញុំមិនដែលនិយាយប្រាប់អ្នកណាទេ...ខ្ញុំលាក់រហូត...

ពេទ្យឡីបន្តប្រយោគ...ហាក់ដូចជាស៊ីចង្វាក់គ្នាល្អណាស់ នឹងមីងយឿន ÷

- ត្រូវមានទោសដូចគ្នា...

លោកស្រី ណាវ៉ា និងអ្នកបម្រើពីរនាក់ទៀត ហាក់ដូចជាស្រឡាំងកាំង ហើយមិនយល់ភាសាដែលអ្នកយឿន និងអ្នកឡីកំពុងជជែកគ្នា ។ បន្ទាប់មក មីងលឿម និយាយ



www.elibraryofcambodia.org

- ពូស៊ីកូ មានកើតហេតុអ្វីអំបាញ់មិញ ?

- គឺចោរវាសម្លុតគំរាមខ្ញុំបាទ ដោយកាំភ្លើងនុះ !

ថាហើយ ជនចង្អុលទៅកាំភ្លើងខ្លីតូចមួយដែលដេកស្ងៀមនៅលើស្មៅ ឋិត ឆ្ងាយពីជនប្រហែលបីទៅបួនម៉ែត្រ ។ ប៉ូលីសម្នាក់ហក់ភ្លែតពីលើរថយន្តដែលគ្មាន ដំបូលទៅរើសកាំភ្លើង រួចលាន់មាត់ថា ÷

- ជាកាំភ្លើងជ័រទេតើ !...ប្រញាប់ពួកយើងតាមអាជនកំហូច !

អ្នកបើកបររថយន្តប៉ូលីសរក្សាសណ្ដាប់ធ្នាប់ក្នុងទីក្រុង បានបើកចេញយ៉ាង លឿនដើម្បីដេញតាមឱ្យទាន់ពួកអន្ធពាល ។ ចំណែកឯជនក៏ឡើងស៊ីកូធាក់មកកាន់ គេហដ្ឋានរបស់ខ្លួនវិញនៅវេលាម៉ោងពីរអធ្រាត្រ ។ អ្នកនឹកគិតដល់ហេតុការណ៍ដែល កន្លងមកថ្មីៗ ដែលគ្រាន់តែប៉ុន្មានម៉ោងសោះរូបអ្នកផ្ទាល់ បានជួបប្រទះសំណាងផង ការ ភ័យរន្ធត់ផងលាយឡំគ្នា ។ អ្នកនឹកឃើញពេលចូលរង្គសាល ថាហេតុអ្វីបានជាអ្នកមិន សប្បាយឱ្យអស់ដៃទៅ ពីព្រោះជាឱកាសល្អហុចឱ្យហើយ ។ ប៉ុន្តែអ្នករកសប្បាយមិន កើត មកតែពីអ្នកប្រមើលមើលស្រមោលប្រាណរបស់ខ្លួនឯង ថារូបអ្នកជាទុគ៌តជន មិន គួរភ្លេចខ្លួនទេ ទោះបីជាឋិតនៅទីណាក៏ដោយ ។ មូលហេតុដូច្នេះហើយបានជាជនមាន ចរិតឫកពាមិនប្រែប្រួលសោះ ។ បន្ទាប់មកជននឹកព្រឺព្រួចក្នុងខ្លួនចំពោះកាំភ្លើងខ្លីរបស់ ពួកចោរ ។ ជនមិននឹកស្មានថាបានរស់រួចខ្លួនទេ បើសិនកាំភ្លើងនេះជាកាំភ្លើងពិតប្រាកដ ប្រហែលជាជនលួចភាវនាចមិស្រេចទៅហើយ រួចជនឧទ្ទិសខ្សឹបៗថា :" ឱ ! មាតុភូមិ ជាទីស្រឡាញ់របស់ខ្ញុំអើយ ! ខ្ញុំកើតមកមិនទាន់បានសងគុណលោកបន្តិចផង បើសិន ជាខ្ញុំស្លាប់ពេលនោះ ហាក់ដូចជាមិនគួរសោះ " ។ គ្រាន់តែនឹកដល់ត្រង់នេះ ស្រាប់តែ សភាវគតិចាំងភ្លែត ដូចជាពន្លាក់ស្មារតីឡើងឱ្យជនប្រកាន់ខ្ជាប់នូវពាក្យ : " ជីវិតជាការ តស៊ូទើបសម្រេចបានផ្លែផ្កាជាក្រោយ " ។ ជនញញឹមសប្បាយក្នុងចិត្តនឹងសេចក្ដីក្លាហាន ដែលសម្ដែងចេញមកដោយស្វ័យប្រវត្តិ ដើម្បីរំដោះខ្លួនផុតពីចង្កូមមច្ចុរាជ ។ នរណា



www.elibraryofcambodia.org

អារកាត់ឃ្លា ÷

- មកពេទ្យ ! លោកស្រីសន្តោសទៀតហើយ...មកហូបបាយទៅ...គ្មានមានទោសមានពៃរ៍អីទេ !

មីងយឿន មិនបានដឹងថាពេទ្យឡឺឆ្កួតឡើយ ពាក្យសំដីដែលពេទ្យឡឺនិយាយប៉ុន្មាន ធ្វើឱ្យគាត់ចាប់អារម្មណ៍ទាំងអស់ ។ គាត់នៅតែរអ៊ូ ÷

- ការពិតប្រហែលជាពេទ្យច្រឡំតែខ្លួនគាត់...ហើយមកសម្លុតខ្ញុំមិនឱ្យមាត់ ... ខ្ញុំមិនមាត់រហូតមក... អាលោក់នេះវាមានស្រួលឯណា ស្ទើរតែប្រេះទ្រូងស្លាប់ទៅហើយ ... តាំងពីថ្ងៃបានឃើញ " នាង " ដំបូងម្ល៉េះ ។

មីងលឿម និយាយទៅកាន់មីង យឿន ÷

- អ្នកលឿមរអ៊ូអីចឹង ! ខ្ញុំសង្ស័យតែមានរឿងអាថិកំបាំងអ្វីជាមួយនឹងគ្រូពេទ្យទេ បានចេញឃ្លាវែងហួរហែត្រប៉ែលតអីចឹង !

ពេទ្យឡឺនេះធ្លាប់ឆ្កួតម្តងរួចមកហើយ គេយកទៅដាក់ពេទ្យព្រែកត្នោត ដល់គាត់បានស្រាកមក គេនៅតែប្រកាន់ថាគាត់ឆ្កួតរហូត ដូច្នេះពេលខ្លះគាត់ក៏និយាយត្រូវពេលខ្លះក៏និយាយខុស ។ លុះដល់មកឥឡូវ អាយុគាត់កាន់តែចាស់ ស្មារតីចងចាំគាត់ ក៏កាន់តែភ្លេចភ្លាំងឡើង ។ ទោះជាគេស្អប់នឹងសំដីគាត់អាក្រក់យ៉ាងណាក្តី ក៏លោកស្រីណារ៉ា តែងតែសន្តោសគាត់ជានិច្ច ទើបបណ្តាលឱ្យពេទ្យឡឺឧស្សាហ៍មករកលោកស្រីភរិយាចៅហ្វាយស្រុកថ្មីណាស់ ។ ចំណែកមីងយឿនជាមនុស្សត្រង់ គាត់រអិលមាត់មួយគ្រួសអម្បាញ់មិញនោះ ដោយសារតែគាត់ពុំបានដឹងសភាពការណ៍អ្វីទាំងអស់ ជាពិសេសពីរឿងពេទ្យឡឺដែលក្លាយជាមនុស្សវិកលចរិតនេះតែម្តង ។

លោកស្រី ណារ៉ា សង្ស័យដូចមីងលឿមដែរ ។ លោកស្រីក៏និយាយលួងលោមដោយចង់ដឹងការពិត ÷

- មីងយឿន...មានអាថិកំបាំងអីឬ ជាមួយពេទ្យ ?


www.elibraryofcambodia.org

មីងយឿន ពេលនោះដូចជាភ័យរអាក់រអួលបន្តិច គាត់និយាយចេញសំដីទាំងអួលអាក់ ÷

- រឿងនេះ... កើតឡើងតាំងពីយូរណាស់មកហើយ... គឺគ្រូពេទ្យនេះបានបន្ទំយកកូនលោកស្រី សោភា...ដែលកើតមកភ្លោះ...ទៅដាក់ឱ្យស្រីម្នាក់ទៀត... ដែលមានកូន... កើតមករៀបនឹងស្លាប់... ហើយខ្ញុំបានដឹង... បានឃើញគាត់ធ្វើអំពើនេះ... ពេទ្យក៏គំរាមខ្ញុំមិនឱ្យខ្ញុំនិយាយរឿងនេះប្រាប់អ្នកណាឡើយ !...

មីងយឿន ឈប់និយាយបន្តិច រួចបន្តសំដីដោយអះអាងយ៉ាងម៉ឺងម៉ាត់ថា ÷

- ...ខ្ញុំមិនដែលនិយាយទេ !... ទើបតែថ្ងៃដែលនាងកេសរទៅផ្ទះនាងឧប្បលដំបូង...ខ្ញុំឃើញស្លាមនៅកញ្ចឹងកខាងក្រោយ ទើបធ្វើឱ្យខ្ញុំនឹកដល់រឿងកាលពី ១៧ ១៨ឆ្នាំ កន្លងមក...ហើយដឹងអីថារឿងនោះវាទាក់ទងនឹងលោកស្រីដែរ (លោកស្រីពេលនេះគឺ មីងយឿនសំដៅលើរូបលោកស្រី ណារ៉ានេះតែម្តង) ។

*ការសម្ងាត់ដែលគេខំលាក់យ៉ាងណាក៏ដោយ ក៏គង់មានថ្ងៃមួយត្រូវដល់កំណត់បើកកកាយមកដោយឯកឯង ដូចដែលមីងយឿន រង្កៀសខ្លួនដោយខ្លួនឯង ។ ឯគ្រូពេទ្យបានធ្វើអំពើខុសច្បាប់ ក៏នៅតែមានវិប្បដិសារី ហើយវិប្បសារីនេះតាមមកលងអារម្មណ៍គាត់រាល់ពេល ធ្វើឱ្យគាត់ក្លាយទៅជាមនុស្សឡប់សតិរហូតមក ។*

យុវកំលោះក្រមុំ ត្រឡប់មកពីដើរលេងវត្តស្លាងភ្នំវិញ ប្រកបដោយអារម្មណ៍សប្បាយរីករាយយ៉ាងក្រៃលែង ជាពិសេសខេមរិន្ទ និង នាងឧប្បល ដែលកាន់តែយល់ចិត្តយល់ថ្លើមគ្នាខ្លាំងឡើង ។ កែវភ្នែកដែលគេសម្លឹងសម្លក់គ្នា សុទ្ធតែមានន័យស្នេហាយ៉ាងប្តូរផ្តាច់ទាំងអស់ ។

លោកស្រីណារ៉ា នៅពេលដែលបានដឹងរឿងរ៉ាវអាថិកំបាំងពីមីងយឿនហើយហាក់ដូចជាមានពពកខ្មៅស្រអាប់ មកបិទបាំងដួងចិត្តគាត់ដែលកំពុងតែមានរស្មីភ្លឺថ្លាត្រចះត្រចង់ ឱ្យទៅជាងងឹតអួអាប់ទៅវិញ ។ ភាពល្អក់កករនេះស្តែងចេញតាមរយៈ


www.elibraryofcambodia.org

ទឹកមុខស្រពាប់ស្រពោនរបស់លោកស្រី ណារ៉ា ។ ពេលមកពីដើរកំសាន្ត និមិត្តឃើញតែ ទឹកមុខម្តាយដូច្នេះ កេសរ ក៏និយាយខ្សឹប១ដាក់ត្រចៀកម្តាយ ÷

- ម៉ាក់ អើយ ! ម៉ាក់មានរឿងអ្វី បានជាធ្វើមុខអាក្រក់ម្ល៉េះ ?

លោកស្រីមិននិយាយ បែរជាក្រសោបកូនស្រីក្នុងរង្វង់ដៃដោយមានទឹកភ្នែក រលីងរលោង រួចមានវាចាររអាក់រអួល ទំនងដូចជាមានអ្វីមកខ្ទាស់បំពង់ក ÷

- កូនអើយ !...ក្នុងលោកនេះ !...គ្មាននរណាមួយក្តាប់សុភមង្គលបានជារៀង រហូតទេ !...

និមិត្តតែឮម្តាយនិយាយបែបនេះ... កេសរដែលកំពុងឱបម្តាយណែនពេញដៃ ក៏ រលាខ្សាក រួចបែរមើលមុខម្តាយទាំងមានចម្ងល់ថា : " តើមានអ្វីកើតឡើងយ៉ាងនេះ ? ឬមួយលោកឪពុក វាយដំម៉ាក់ ? ទេ ដូចជាមិនសម !...លោកទាំងពីរមិនដែលខ្វែងគំនិត គ្នាសោះ !...តើមកពីអ្វីទៅហ្ន៎ ?" ។ ទ្រាំមិនបានកេសរក៏សួរម្តាយតទៅទៀត ÷

- ម៉ាក់មានបញ្ហាអ្វីទៅ...អាចប្រាប់កូនផងបានទេ ?

លោកស្រីមិនឆ្លើយនឹងសំនួរកូន បែរជានិយាយដោយបារម្ភ ÷

- មិនត្រឹមតែប្រាប់កូនទេ គឺត្រូវប្រាប់ទាំងអស់គ្នា...

លោកស្រីដូចជារឹតតែខ្សឹកខ្សួលខ្លាំងឡើង ហើយលែងនិយាយអ្វីតទៅទៀត ដោយលោកស្រីចង់រក្សាអាថិកំបាំងនោះទុករហូត ។ លោកចៅហ្វាយស្រុកសួររកប្រពន្ធ ÷

- នាង... នាង... ទៅណាហ្នឹង ?...

លោកភ្ញាក់ព្រើត ដើរសំដៅទៅភរិយា ÷

- ហ្ន៎ ! នាងនៅទីនេះសោះ !...ហើយចុះមានរឿងអីហ្នឹង ទាំងម្តាយ ទាំងកូន ម៉េចក៏មិនចេញទៅញ៉ាំបាយ...ហេតុអីក៏នាងយំអីចឹង ! អ្នកណាធ្វើអីនាង ?

លោកស្រី ណារ៉ា ទាញដៃប្តីទៅឆ្ងាយពីកូនស្រី រួចខ្សឹប១ ÷

- ថា...ខ្ញុំមិនចង់និយាយទេ...ប៉ុន្តែបើមិននិយាយដូចជាតឹងចិត្តណាស់... ពេទ្យ


www.elibraryofcambodia.org

ឡើនិយាយជាមួយមីងយឿនថា :“ ពេទ្យបានយកកូនរបស់អ្នកស្រីម្នាក់ដែលកើតកូនភ្លោះយកទៅដាក់ឱ្យអ្នកស្រីម្នាក់ទៀតដែលកើតកូនមកបម្រុងនឹងស្លាប់ ”... រឿងនេះជារឿងខ្ញុំទេដឹងលោកបង ?...ហើយបើដូច្នេះមែន... គេសរ...

លោកស្រី ណារ៉ា និយាយតទៅទៀតមិនរួច... ហាក់ដូចជាពាក្យដែលលោកស្រីមិនបញ្ចេញមកនោះ វាជាពាក្យសំខាន់អ្វីមួយដែលធ្វើឱ្យលោកស្រីសោយសោកា ។ លោក ខាត់ លួងលោមភរិយា ÷

- កុំយំអីនាង... បើទោះជានាងសោកស្តាយយ៉ាងណាក៏រឿងពិតនោះវានៅតែជារឿងពិតដដែល ឥតប្រែប្រួលឡើយ !

លោកខាត់និយាយទាំងកម្សា ឯចិត្តលោកក៏រន្ធត់ចម្លែកដែរ លោកបន្តលួងលោម ÷

- ទៅនាង !... ចេញទៅកំដរភ្ញៀវ... ហើយរឿងរ៉ាវនោះមិនមែនជាកំហុសរបស់នាងឯណា !...

លោក ខាត់ ងក់ក្បាលយឺតៗ ដូចជាខំរកពាក្យអ្វីឱ្យសមនឹងសភាពការណ៍ពិត... លើកមកនិយាយបន្ថែមទៀត ÷

- យើងចិញ្ចឹមគេពីតូចរហូតដល់ធំ... ប៉ុណ្ណឹងក៏អស់ចិត្តដែរ... ហើយថ្ងៃណាមួយគេរៀបការ... គេគង់នឹងបែកពីយើង... មែនទេនាង ?

ពាក្យមួយឃ្លាចុងក្រោយរបស់ស្វាមីនេះ ធ្វើឱ្យលោកស្រី ណារ៉ា កាត់ការសោកសៅបានខ្លះ ។ នៅខាងក្រៅ ភ្ញៀវជជែកគ្នាអ៊ូអែ លោកស្រី ណារ៉ា សំដែងទឹកមុខឱ្យដូចធម្មតា រួចក៏ចេញទៅទទួលភ្ញៀវ ។ លោកស្រីឮលោក សម្បត្តិ និយាយ ÷

- ពុម្ពអីក៏ដូចគ្នាម្ល៉េះ !...មានអីចឹងដែរហ្ន៎ ! ក្នុងលោកយើងនេះ ។

ភ្ញៀវសម្លឹងលោកស្រី ណារ៉ា ម្តង រួចងាកទៅសម្លឹងលោកស្រី សោភា ម្តងវិញហើយមានអារម្មណ៍ថា : អ្នកទាំងពីរមានសម្រស់មួយបែបម្នាក់ ហេតុអីក៏មានកូនដូចគ្នាបេះបិទអីចឹងហ្ន៎ ?


www.elibraryofcambodia.org

កេសរ ដើរសំដៅទៅផ្ទះបាយ ឃើញពេទ្យឡីកំពុងហូបបាយ នាងមិនរវល់នឹងពេទ្យឡីទេ នាងបែរជាសួរទៅមីង លឿម វិញ ÷

- មីង លឿម !...ម៉ាក់មានរឿងអី បានជាលោកយំ ?

មីងលឿម កាលបើឮសំនួរនេះ ហាក់ដូចជាភ្ញាក់ សួរត្រឡប់មកនាងកេសរវិញ :

- ហ្អា ! លោកស្រីយំរឿងអី ? មុននេះបន្តិចខ្ញុំឮសួរពេទ្យឡី និង អ្នកយឿនជជែកគ្នា ។

- មីងមានដឹងទេ ថាមីងឆ្គួតនោះមានរឿងអីជជែកជាមួយមីងយឿន ?

មីងលឿម រ៉ាយរ៉ាប់រឿងអតីតកាលឡើងវិញ ស្រាប់តែកេសរបន្លឺចេញសំឡេងមកថា :

- កូនភ្លោះ !...អ៊ីចឹងមានតែខ្ញុំនិងឧប្បលជាកូនភ្លោះ ?

មីងយឿនលូកមាត់តតាំង ដើម្បីចង់សំដែងការស្មោះត្រង់ឱ្យបានមុនពេទ្យឡី ÷

- ត្រូវហើយនាង !

- បើមីងដឹងអ៊ីចឹង... យូរណាស់ ម្ដេចក៏មីងមិននិយាយជម្រាបម៉ាក់ ?

មីងយឿន គ្រវីក្បាល រួចនិយាយចេញមកស្ទើរតែមិនដឹងខ្លួន ÷

- ទុកឱ្យរឿងវាបែកសាយាមោអ៊ីចឹងទៅចុះ ល្អជាង !

នាងកេសរចង់ដឹងណាស់ នាងក៏បង្ខំមីងយឿនឱ្យនិយាយសាឡើងវិញនូវដំណើររឿងដែលបានផុតរលត់ជាយូរមកហើយ ។ មីងយឿននឹកថា : " បើរឿងរ៉ាវវាធ្លាយបានប៉ុណ្ណោះហើយ ទោះបីជាខំលាក់តទៅទៀត ក៏លាក់មិនជិតដែរ នេះចាត់ទុកថាជាចំណារនៃព្រហ្មលិខិតទៅចុះ ! " ។ មីងយឿនចាប់ផ្ដើមនិទាន ÷

- កាលពីឆ្នាំ ១៩៤៩ លោកស្រី សោភា សម្រាលបានបុត្រីភ្លោះពីរ មួយមានស្នាមដៅនៅត្រង់កញ្ចឹងក រឿងនេះមិនដឹងជាលោកស្រីដឹង ឬមិនដឹងឡើយ ប៉ុន្តែមីងដឹង ពីព្រោះមីងបានចូលទៅបន្ទប់អ្នកសម្រាលកូនដែរ ។ ពេលអ្នកគ្រូពេទ្យមុជទឹក


www.elibraryofcambodia.org

ស្រាប់តែមានការភ័ន្តច្រឡំកូន ពេលនោះមីងតវ៉ាស្ងាត់ៗប្រាប់អ្នកគ្រូពេទ្យ តែគាត់ចង ចិត្តថាគាត់មិនច្រឡំទេ ម្យ៉ាងទៀតកូនម៉ានោះដូចៗតែគ្នា ពិបាកចំណាំណាស់ ដល់ពេទ្យ គេអះអាងថាគេប្រាកដប្រជាជាងដូច្នេះ មីងបែរជាមិនហ៊ានតតាំងជាមួយគេដែលជា ពេទ្យ ។ ចំណែកឯមីងគ្រាន់តែជាអ្នកបម្រើគេ ហើយកាលនោះខ្លួនក៏នៅក្មេងដែរ នៅធំ ក្អិនស្រែនៅឡើយ... នៅខ្លាច រួចមិនបានប៉ុន្មានម៉ោងផង ក្នុងចំណោមកូនពីរនោះមានកូន មួយក៏ស្លាប់ទៅ...។

មីងយឿននៅតែឆ្ងល់ លើករឿងនោះមកពិចារណាតែម្នាក់ឯង : "...ឬមួយ អ្នកគ្រូពេទ្យដឹងមុន គេក៏ដូរទៅកុំឱ្យម្ដាយសោកសៅខ្លាំងពេក កាលណាដឹងថាកូនមុខ ជាស្លាប់ ឯម្ដាយដែលមានកូនពីរនាក់(កូនភ្លោះ)នោះមិនជាបញ្ហាប៉ុន្មានទេ បើស្លាប់មួយ ក៏គង់នៅមួយដែរ ម្យ៉ាងវាងាយស្រួលចិញ្ចឹមផង ។ បើសិនជាចិញ្ចឹមម្ដងពីរ គឺវាមានការ លំបាកណាស់ ..." ។

មីងលឿមឮដូច្នេះ ក៏តវ៉ាធ្វើខ្លួនមើលតែចៅក្រម ÷

- ទេ ! កូនគេ ម៉ែគេ លំបាកស្រណុកបែបណា ស្រេចតែគេ...រឿងអីឯងមក ចេះដូរអី...បើគិតតាមច្បាប់ អ្នកគ្រូពេទ្យនោះត្រូវមានទោស... ខ្វះការប្រុងប្រយ័ត្ន ... ធ្វើឱ្យច្រឡំច្រឡាយបាន...ឬមួយក៏គ្រូពេទ្យមានចេតនាដូច្នេះមែន ?.. ហ៊ឺរឿង នេះពិបាក យល់ណាស់... ឥឡូវសំដីអ្នកគ្រូពេទ្យក៏យកជាការមិនបាន ដោយសារតែគាត់ឡប់សតិ...

មីងយឿននិយាយកាត់ ÷

- ឥឡូវគាត់យ៉ាងម៉េច ?

មីងលឿមឆ្លើយ ÷

- មានយ៉ាងម៉េច... គឺឡប់សតិ... គឺឆ្កួតនោះណា !

មីងយឿនពោលដោយហួសចិត្ត ÷

- ពុទ្ធោអើយ... គ្រូពេទ្យឆ្កួតហើយ... មានចាំបាច់មនុស្សដាក់ទោសឯណា គឺ


www.elibraryofcambodia.org

ទេវតាដាក់ទោសគាត់... ដែលគេហៅថាកម្មតាមផ្ដន្ទា ។

មីងលឿមពិចារណា ÷

- ចុះបើលោក១ទាំងអស់ដឹង លោកគិតដូចម្ដេចទៅរឿងហ្នឹង ?

មីងយឿនឆ្លើយ ÷

- គិតយ៉ាងម៉េចក៏មិនកើតដែរ... បើរឿងវាកន្លងមកជាយូរឆ្នាំហើយ... វាមានតែសម្រួលគ្នាទៅវិញ ។

មីងលឿមនៅតែឆ្ងល់ ÷

- សម្រួលដូចម្ដេច !... បើតាមខ្ញុំ មានតែទុកដូចសព្វថ្ងៃអីចឹងទៅ... គឺថានាងណាកូនលោកស្រីណា ទុកឱ្យនៅដដែលចុះ... មិនចាំបាច់រើរុះទេ ។

មីងយឿនសើចក្អឹក១ ÷

- យី ! អ្នកលឿម និយាយពាក្យរើរុះ ធ្វើមើលតែស្រួលដូចរុះខោអាវ ឬក៏រុះផ្ទះឯណា !... នេះគឺជាមនុស្សណា៎ ! មិនមែនខោអាវ ឬផ្ទះទេ ?

អ្នកទាំងពីរជជែកគ្នាចុះឡើង១ ក៏នៅតែកំហុសនោះធ្លាក់ទៅលើគ្រូពេទ្យដដែល ...ប៉ុន្តែរឿងវាចប់ត្រឹមគ្រាន់តែបានដឹងប៉ុណ្ណោះ ។

- ឥឡូវរឿងនេះវាមានខាត មានចំណេញឯណា ! គឺវា... (មីងយឿនឱនទៅខ្សឹបដាក់ត្រចៀកមីងលឿម មួយសន្ទុះ ស្រាប់តែមីងទាំងពីរភ្ញាក់ព្រមគ្នាដូចគេណាត់ទុកជាមុន)... គឺគ្រាន់តែដូរឈ្មោះតែប៉ុណ្ណឹងឯង !

ថាហើយស្ត្រីចំណាស់ទាំងពីរអស់បារម្ភ បែរជានាំគ្នាអស់សំណើចទៅវិញ ដែលគេហៅថា អស់បើគិត ទោះជាគាត់ខំគិត ក៏គិតមិនលេចដែររឿងនេះ ។

កេសរដែលសម្ងំចាំស្ដាប់ស្ងាត់ស្ងៀមយូរហើយ ក៏បន្លឺឡើង ÷

- ណ្ហើយចុះ !...ខ្ញុំគិតថា ពុំមែនជាកំហុសរបស់អ្នកណាម្នាក់ឡើយ...

កេសរមិនទាន់ទាំងបញ្ចប់ពាក្យស្រួលបួលផង ស្រាប់តែនាងងាកទៅឃើញ


www.elibraryofcambodia.org

ឧប្បលឈរនៅក្បែរមាត់ទ្វារចូល ក៏ប្រញាប់និយាយ ÷

- ....ឧប្បល មកយូរហើយឬ ?

ឧប្បល ញញឹមងក់ក្បាល រួចបែរជាឆ្លើយ ÷

- នេះគឺព្យុះព្រេងសំណាងរបស់យើងណា៎ កេសរ !

កេសរឆ្លើយតបទៅឧប្បល យ៉ាងគួរឱ្យហួសចិត្តទៅវិញ ÷

- ចាស ! ត្រូវហើយអ្នកបងថ្លៃ ។

មីងយឿន និងមីងលឿម និមិត្តតែឮពាក្យកេសរឆ្លើយ គាត់បើកភ្នែកធំៗមើលមុខគ្នា ហើយនិយាយខ្សឹបៗល្មមតែឮពីរនាក់ថា ÷

- ប្តូរពីពាក្យថាកូន មកកូនប្រសាវិញ ប្តូរពីឈ្មោះកេសរ មកឧប្បលវិញ ចំណែករូបមនុស្សនៅតែរូបដដែល មានទៅខុសគ្នាត្រង់ណាហ្ន៎ !... ដូចគំនិតយើងទាំងពីរមិនខុសមែន ... លោកស្រី ណារ៉ា នៅតែចំណេញដដែលហ្នឹង !

បន្ទាប់មក ឧប្បលក៏លើកយោបល់របស់ខ្លួនប្រកាសប្រាប់ដល់អ្នកដែលនៅក្នុងផ្ទះបាយទាំងអស់ឱ្យបានដឹងថា ÷

- ទោះបីជារឿងរ៉ាវទាំងអស់នោះ ដូចមីងយឿនបានលើកឡើងក្តីថា គ្រូពេទ្យឡី មានចេតនា ឬគ្មានចេតនា ក៏នៅទីបំផុត ខ្ញុំ និងកេសរបានវិលមកជួបជុំគ្នា... គ្មានរឿងអ្វីអាក្រក់កើតឡើងឡើយ... ដូច្នេះតាមយោបល់ផ្ទាល់របស់ខ្ញុំ សូមឱ្យរឿងចប់តែត្រឹមហ្នឹងចុះ !... ចំណែកឯគ្រូពេទ្យ ទោះបីជាយើងប្តឹងផ្តល់ ហើយចាប់គាត់ដាក់គុក ក៏គាត់គ្មានប្រកែកតវ៉ាឡើយ ពីព្រោះថា គាត់ឆ្កួតទៅហើយ ឯម៉ាក់របស់ខ្ញុំ... ល្មើយកុំឱ្យលោកដឹងក្រែងលោលោកពិបាកចិត្ត...

នៅពេលដែល ឧប្បល កំពុងតែលើកពីយោបល់របស់ខ្លួនដូច្នេះ អ្នកស្រី ណារ៉ា ក៏ដើរចូលមក នាងកេសររត់ទៅឱបម្តាយជាថ្មីម្តងទៀតដោយអះអាងពីចិត្តគំនិតរបស់ខ្លួន ÷

- ទោះយ៉ាងណាក្តី ក៏ចិត្តកូនឥតប្រែប្រួលឡើយ គឺបានសេចក្តីថា កូននៅតែជា



www.elibraryofcambodia.org

កូនរបស់ម៉ាក់ នៅតែស្រឡាញ់ម៉ាក់ នៅតែស្តាប់បង្គាប់ម៉ាក់ជារៀងរហូត ។

នាង ឧប្បល ឈរក្បែរនោះ ក៏លើកដៃសំពះ ហើយពោលយ៉ាងគោរពថា ÷

- ខ្ញុំក៏ដូច្នេះដែរ គឺពុំមានប្តូរចិត្តអ្វីឡើយ ។

លោកស្រី ណារ៉ា ទាញនាងឧប្បលយកមកឱបនៅដៃម្ខាងទៀត ដោយបន្លឺវាចារបៀបរភើបឥតឧបមា ÷

- កេសរ... ឧប្បល... កូនម៉ាក់...ម៉ាក់ត្រេកអរណាស់នឹងសំដីរបស់កូនទាំងពីរ ។

បរិយាកាសកាលពីមុននេះបន្តិច មានសភាពអ៊ូអាប់ តែពេលនេះប្រែក្លាយជាថ្លាស្រឡះ ត្រចះត្រចង់ លែងមានក្តីមន្ទិលសៅហ្មងអ្វីទៀតឡើយ ។

ពេលវេលាចេះតែកន្លងទៅ នៅចុងឆ្នាំ ១៩៧៣ ក្នុងខែ វិច្ឆិកា ពិធីរៀបអាពាហ៍ពិពាហ៍ រវាង កែវ ខេមរិន្ទ និងកញ្ញា វង្ស ឧប្បល ក៏បានប្រព្រឹត្តឡើងយ៉ាងគគ្រឹកគគ្រេង ទៅតាមឋានៈអភិជនរបស់ត្រកូលលោក វង្ស សម្បត្តិ ។

ឧប្បល មិនត្រឹមតែមានរូបឆោមលោមពណ៌ល្អផូរផង់តែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានចរិយាសម្បត្តិដែលប្រកបដោយសីលធម៌ឥតខ្ចោះ និងមានសម្បត្តិហូរហៀសម្រាប់កំដរជីវិតឱ្យរីងរឹតតែរុងរឿងបន្ថែមទៀត ។ តាំងពីពេលកើតឡើងរហូតមកដល់ថ្ងៃនាងរៀបអាពាហ៍ពិពាហ៍ ឧប្បលមិនទាន់ស្គាល់ដូចម្តេចហៅថា អត់ឃ្លាន... ហៅថា លំបាក... ហៅថាកម្សត់... ផ្ទុយទៅវិញឱ្យតែនាងចង់បានអ្វី គឺបានទាំងអស់ហាក់ដូចរូបនាងជាទេពអប្សរបវរកញ្ញាកើតឡើងនៅឋានសួគ៌ ។ ឧប្បលជាឈ្មោះផ្កាមួយប្រភេទ " ឱ ផ្កាឧប្បលអើយ ! អ្នកជាបុទុមជាតិមួយដែលដុះនៅតាមស្រះ ត្រពាំងនានា មានជាអាទិ៍ដូចជាព្រលិត លំចង់ជាដើម... អ្នកមានសំណាងអ្វីម្ល៉េះទេ សំណាងនេះជាសំណាងដ៏ខ្ពស់ត្រដែតដែលកម្រមានដូច្នេះណាស់ កាលពីជាតិមុននាងបានសាងអំពើអ្វីទៅហ្ន៎ ? " ។

នៅក្នុងបន្ទប់ដែលវិចិត្រទៅដោយក្រណាត់វាំងននពណ៌កុលាបខ្ចី ស្តើងទន់លំអ


www.elibraryofcambodia.org

ទៅដោយជរផងនោះ កំពុងតែរសាត់ផាត់ផាយនឹងព្រះពាយបក់ផាត់ថ្មម១ រំពើត ហាក់ដូចជារបស់ទាំងអស់នោះមានវិញ្ញាណរស់រវើក ។ បន្ទប់នេះធំទូលាយមានរំលេចដោយផ្កាកុលាប ផ្កាកេសរកូល (ដែលគេនិយមហៅថាផ្កាអ័រគីដេ) និងផ្ទាំងគំនូររបស់វិចិត្រករញីកនឹមដែលលោក ស៊ិន ស៊ីសាមុត បានបកស្រាយក្នុងចម្រៀងមានឈ្មោះថា " កុលាបមួយទង " ដាក់ព្យួរនៅជញ្ជាំង និងផ្ទាំងគំនូរមួយទៀតនិយាយពីរឿងព្រះសុធន និងនាង កែវ មនោហរា ត្រង់ចំណុចបង១កំពុងភិតភ័យយកស្លាបមកពាក់ ឯ នាង កែវ មនោហរា វិញរកស្លាបមិនឃើញ ។ ចំណុចនេះវិចិត្រករគូរឱ្យអ្នកមើលឃើញអាកប្បកិរិយារបស់នាងដូចជាឆ្មេឆ្មា ស្មន់ស្មោ កំពុងរកស្លាបរបស់ខ្លួនដែរ ។

កម្រងផ្កាម្លិះរបស់កូនកំលោះ កូនក្រមុំដែលដោះដាក់លើកូនតុក្បែរគ្រែជះក្លិនក្រអូបសាយភាយ ។ នាងឧប្បលមានអារម្មណ៍ជ្រួលច្របល់ នៅពេលដែលពិធីផ្សំដំណេកនឹងមកដល់នៅពេលខាងមុខនេះ ។ ចាស់១នាំគ្នាចេញទៅក្រៅអស់ ដោយទុកឱ្យកំលោះ ក្រមុំ នៅស្ងាត់១តែពីរនាក់ដំពេញសិទ្ធិបរិបូណ៌ ។ សេចក្ដីព្រួយបារម្ភ ឬមន្ទិលសៅហ្មងទាំងឡាយរលាយបាត់អស់ពីទ្រូងឧប្បល ជំនួសមកវិញនូវក្ដីរំភើបញាប់ញ័រដោយស្រួលស្រើបនៃតណ្ហា ដែលបាញ់ព្រួញស្នេហាជ្រលក់ដោយទឹកឃ្មុំនៃព្រះនាងសរកាមទេពតែប៉ុណ្ណោះ ។ នាងដើរទៅឈរក្បែរបង្អួច យកម្រាមដៃដ៏ស្រឡូនទៅផាត់វាំងននឱ្យញែកចេញពីគ្នា រួចនាងសម្លឹងចុះទៅក្រោម មើលទេសភាពដែលទទួលរស្មីដ៏ស្រទន់ពីព្រះចន្ទ្រា ។ បន្ទាប់មក នាងមើលទៅព្រះចន្ទ្រដែលកំពុងបណ្ដែតខ្លួនកណ្ដាលលំហអាកាស ហ៊ុមព័ទ្ធដោយដួងតារាចាំងពន្លឺផ្លេក១ដូចគ្រាប់ពេជ្រ ។ សម្រស់ធម្មជាតិពាក់តែងមកតែឯកឯង គេគ្មានពាក្យអ្វីពោលរិះគន់ថាយ៉ាងណា ១នោះបានទេ ...

- អូន... កំពុងគិតអីហ្នឹង ?

ឧប្បលងាកមករកម្ចាស់សំឡេង ដែលឋិតមកក្បែរកិតជិតប្រាណនាងរួចទៅហើយ ។ នាងញញឹមគ្រវីក្បាល រួចបញ្ជាក់ប្រាប់ថា : " អូនគ្មានគិតពីអ្វីទេ " ។ គេពុំឮ


www.elibraryofcambodia.org

អើយ ! មិនស្មុគរន្ធត់នៅពេលដែលសេចក្ដីស្លាប់មកដល់ ! ជនគិតចុះ គិតឡើងរហូតនិទ្រាលក់ស្កប់ស្កល់ ។

* * * * *


www.elibraryofcambodia.org

សំឡេងឆ្លងឆ្លើយអ្វីទៀតឡើយក្រៅពីគេឃើញអ្នកប្រុសខេមរិន្ទ លើកត្រកង បីបមថ្នាក់ថ្នម នូវរាងកាយដ៏តូចច្រឡឹងរបស់កញ្ញា ឧប្បល ពេញក្នុងរង្វង់ហត្ថាទាំងទ្វេដោយក្តីប្រតិព័ទ្ធអស់ពីដួងហឫទ័យ ។ នៅក្នុងលោកនេះសម្រាប់ជីវិតយុវវ័យគ្មានអ្វីសប្បាយលើសពីនេះទេ ។ ព្រលឹងគូស្នេហ៍ទាំងទ្វេហោះអណ្តែតត្រសែតទៅរកឋានមួយដ៏ខ្ពស់ផុតភពផែនដី ដែលភាសាស្នេហាគេហៅថា "ក្រេបចន្ទ្រទឹកឃ្មុំ" ... នោះ ។

របត់មួយរបស់ជីវិត ដើរមកដល់ពាក់កណ្តាលផ្លូវហើយ គូអង្គទាំងពីរក្រាបក្បាលដល់កន្ទេលឱនសំពះចាស់ទុំទាំងខាងឪពុក ទាំងខាងម្តាយ នៅក្នុងពិធីអាពាហ៍ពិពាហ៍នេះ ដែលផ្នត់គំនិតរបស់ជនជាតិខ្មែរយើង ច្រើនឱ្យតម្លៃដល់កូនស្រីថាបានសងគុណឪពុកម្តាយរួចហើយ ។ ប៉ុន្តែក្នុងដំណើររឿងនេះ កំពុងស្ថិតនៅក្នុងប្រទេសមានសង្គ្រាម យើងពុំអាចដឹងថា តើជីវិតរបស់គូអង្គ និង ប្រជាជនទូទៅមានលក្ខណៈប្រែប្រួលយ៉ាងដូចម្តេចទេ ? ដូច្នេះសូមអស់លោកអ្នកអានជួយតាមដានទៀតចុះ !...

ទំព័រប្រវត្តិសាស្ត្របានផ្លាស់ប្តូរប្រទេសកម្ពុជាជាច្រើនរបប ពីរបបរាជានិយមមកជារបបសាធារណរដ្ឋ ពីរបបសាធារណរដ្ឋ មកជារបបកម្ពុជាប្រជាធិបតេយ្យ ហើយពីរបបកម្ពុជាប្រជាធិបតេយ្យ មកជារបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បន្ទាប់មកក្លាយទៅជារដ្ឋកម្ពុជា ។ ហើយនៅឆ្នាំ ១៩៩៣ ប្រទេសដ៏អភ័ព្វដែលខិតខំប្តូររបបជាច្រើនសានេះ ក៏បានទទួលរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ របបនេះយកតាមលំនាំឆ្នាំ ១៩៤៧ កាលនោះ សម្តេចព្រះបាទនរោត្តម សីហនុ មានឋានៈជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា ។

ប្រជាជនណាដែលកើតនៅឆ្នាំ ១៩៧០មក គេចាត់ទុកថាប្រជាជននោះទទួលឥទ្ធិពលសង្គ្រាមតាំងពីនៅក្នុងគភ៌មាតាម្ល៉េះ ដូច្នេះសម្ពាធនៃការភ័យខ្លាចបានដក់ជាប់នៅក្នុងផ្នត់គំនិតរបស់ជននោះរួចជាស្រេចទៅហើយ ។ ចំណែកនាងឧប្បល កើតនៅឆ្នាំ ១៩៤៩ នាងរៀបមង្គលការនៅឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ នាងរៀនចប់ថ្នាក់មហាវិទ្យា


www.elibraryofcambodia.org

ល័យបុរាណវិទ្យា នាងបានយល់ច្បាស់អំពីប្រវត្តិសាស្ត្រ ពីវប្បធម៌ ដែលប្រទេសនិមួយៗលើសកលលោក ខំថែរក្សាទុកយ៉ាងយកចិត្តទុកដាក់បំផុត ។ រីឯប្រទេសកម្ពុជាវិញសម្បូណ៌ទៅដោយសម្បត្តិវប្បធម៌នៅរាយប៉ាយពាសពេញផ្ទៃប្រទេស... ប៉ុន្តែប្រជាជនភាគច្រើនមិនសូវយកចិត្តទុកដាក់ទេ គេបានយកកាំបិតទៅសំលៀងលើថ្មដែលមានក្បាច់ចម្លាក់ ... នៅពេលមានសង្គ្រាម គេយកប្រាសាទធ្វើជាកន្លែងជ្រកពួន ... បើពុំនោះទេ គេលួចយករូបចម្លាក់ទៅលក់ឱ្យឈ្មួញទុច្ចរិតដែលរកស៊ីខុសនឹងច្បាប់រដ្ឋ ។

យល់ដល់ស្ថានការណ៍បែបនេះ ឧប្បល ដកដង្ហើមធំ ខេមរិន្ទឃើញអាការៈប្រពន្ធដូច្នេះ ក៏សួរទៅនាង ÷

- អូន... គិតអ្វីច្រើនម្ល៉េះ ?

- ខ្ញុំព្រួយដល់អនាគតប្រទេសយើងណា៎ !

ខេមរិន្ទ ហាក់ដូចនឹកឆ្ងល់នឹងសំដីភរិយា ក៏បន្តការសួរទៅទៀត ÷

- តើអូនបារម្ភពីអនាគតប្រទេសយើងយ៉ាងដូចម្តេច ?

ឧប្បលមិនឆ្លើយចំសំនួរទេ បែរជានាងឆ្លើយថា ÷

- យើងត្រូវទទួលស្គាល់យ៉ាងច្បាស់ថា ប្រជាជនយើងភាគច្រើន ៗតែមានគំនិតបំផ្លិចបំផ្លាញជាតិឯង ឯការស្រឡាញ់ជាតិមានដែរ តែមានតិចតួចស្តួចស្តើងណាស់ ដូចភ្លើងចំបើងអីចឹង កាលណាគេដុតក៏ឆេះមួយវ៉ាវរួចក៏រលត់ទៅវិញ ...

ខេមរិន្ទនឹកឃើញដល់ភរិយាមានគភ៌ ក៏និយាយកាត់ឡើង ÷

- អូនកុំគិតអ្វីដែលនាំឱ្យតានតឹងក្នុងចិត្ត... នឹងបណ្តាលឱ្យប៉ះពាល់ដល់សុខភាពកូនយើងណា៎ !...

ថាហើយ ខេមរិន្ទ ក៏ធ្វើមុខធ្វើមាត់ បណ្តាលឱ្យភរិយាជាទីស្រឡាញ់អស់សំណើចរួចនិយាយបន្ត ÷

- បើមានកូនប្រុស អូនដាក់ឈ្មោះថាយ៉ាងណាដែរ ?



www.elibraryofcambodia.org

- គឺថា ខេមរា ឱ្យជូននឹងឈ្មោះបង ។

- ចុះបើមានកូនស្រីវិញ !

- បងជាអ្នកដាក់ឈ្មោះចុះ... អូនសូមប្រគល់ជូនបងហើយ !

ខេមរិន្ទ ឮដូច្នោះ ក៏យកដៃអេះក្បាលទំនងដូចជាគិត រួចនឹកស្ញើចប្រាជ្ញាឧប្បល ដែលឆ្លើយបានភ្លាម ។ បន្ទាប់មក គេឆ្លើយយករួចខ្លួន ÷

- រ៉ារិន !

- លោកអើយ ! គ្មានជូនអីនឹងខ្ញុំជាម្ដាយបន្តិចណាសោះ ដូចជាគ្មានន័យអ្វីឡើយ មែនណាបងសម្លាញ់ ?

ខេមរិន្ទ ឆ្លើយយ៉ាងព្រងើយ ÷

- តែបងពេញចិត្តឈ្មោះនេះណាស់... ឱ ! បងភ្លេច... អូនទាយទៅមើល ថាបងនឹងបង្ហាញអ្វីដល់អូន ?

ឧប្បលនឹកមួយស្របក់ ក៏ឆ្លើយថា ÷

- ប្រហែលមានស្វាយជ្រក់ផ្ញើខ្ញុំទៀតហើយមើលទៅ ?

និយាយរួចខេមរិន្ទក៏ដើរទៅបើកកាបូប យកសំបុត្រការពីរមកប្រគល់ឱ្យ ឧប្បល ។ សំបុត្រទីមួយ ជាសំបុត្រការរវាង វឌ្ឍា និងនាង កេសរ ឯសំបុត្រការមួយទៀត ជាសំបុត្រការរវាង សុផាន់ និងនាង បូផល ។

នាយឆ្លើយរបៀបកំប្លែង ÷

- នេះហើយប្រភពដែលនាំឱ្យចង់ញ៉ាំស្វាយជ្រក់នោះអី !

ឧប្បលអស់សំណើច នឹងពាក្យស្វាមីដ៏សមហេតុសមផល ÷

- បងពូកែរកទំនុក ឆ្លើយមែន !

គ្រួសារ កែវ ខេមរិន្ទ និង វង្ស ឧប្បល រស់នៅប្រកបដោយសុភមង្គលល្អគ្រចះ គ្រចង់ ។ អ្នកទាំងពីរមិនដែលឈ្លោះប្រកែកគ្នាដល់ម្ដងណាឡើយ ។ អ្នកខ្លះឃើញគេ


www.elibraryofcambodia.org

ដូច្នេះ ចេះតែនឹកស្ញើចភ័ព្វវាសនារបស់គេ ថាតើពីជាតិមុនគេបានសាងអ្វីខ្លះ បានជាជួបប្រទះតែសេចក្ដីសុខយ៉ាងដូច្នេះ ? តើសុភមង្គលដែលភាសាសាមញ្ញហៅថា សេចក្ដីសុខនោះ វាជារឿងចៃដន្យ ឬមកពីម្ចាស់នៃសេចក្ដីសុខនោះសាងពីអតីតជាតិ ដូចគេទាំងឡាយបាននឹកស្មាន ដោយលើកពីកម្មផលតាមធម៌របស់ព្រះពុទ្ធប្រាកដមែនឬ ? រឿងនេះ បើគេធ្វើការពិចារណា និងតាមដានទៅឃើញថា គ្រួសារនេះខំតស៊ូក្នុងឆាកជីវិតយ៉ាងស្វិតស្វាញ ក្រាញននៀលធ្វើស្រែចម្ការ ដើម្បីឱ្យខ្លួនលោកក្លាយទៅជាអ្នកមានសម្បត្តិស្ដុកស្ដម្ភ ។ ពេលបានប្រាក់ចំណេញពីផលដំណាំ លោកពង្រីកដីធ្លីហើយបង្កើនផលិតផលរបស់លោកឱ្យមានទំហំធំធេងបន្ថែមទៀត ។ ម្យ៉ាងទៀតលោកជម្រុញកូនឱ្យខិតខំរៀនសូត្រ ។ ការរៀនសូត្រនេះហើយ ដែលធ្វើឱ្យឧប្បល ចេះត្រិះរិះពិចារណា ថ្លឹងថ្លែងរកហេតុ រកផល ស្គាល់ល្អអាក្រក់ ស្គាល់អ្វីដែលលូតលាស់ និងស្គាល់អ្វីដែលធ្វើឱ្យអន់ថយ ។ កាលណាគេរកឃើញអ្វីអស់ទាំងនេះហើយ នោះគេក៏រកឃើញសុភមង្គលដែរ សុភមង្គលទាំងនេះឋិតនៅតែក្បែរៗខ្លួនរបស់យើង ។ ប៉ុន្តែមនុស្សខ្លះស្ទើរតែមួយជីវិតរកសុភមង្គលមិនឃើញឡើយ ដោយសារតែសុភមង្គលមកដល់ដៃហើយ គេមិនចេះក្ដាប់យក ។ ព្រះពុទ្ធជាម្ចាស់ លោកបានរកសេចក្ដីសុខឃើញ ហើយលោកបានខិតខំចងក្រងជាអត្ថបទច្រើនសន្ធឹកទុកឱ្យយើងរៀនសូត្រតាម ដើម្បីឱ្យយើងដែលមានវាសនាកើតមកជាមនុស្សហើយ បានស្គាល់សេចក្ដីសុខដូចព្រះអង្គផងដែរ ។ ប៉ុន្តែមនុស្សភាគច្រើនរកមិនឃើញ គេនៅតែឈ្លក់វង្វេង វីវក់ វិលវល់តែនឹងតណ្ហាដែលមានជាអាទិ៍គឺលោភលន់អំណាច ទ្រព្យសម្បត្តិនេះ ។ បើគេតាំងចិត្តឱ្យបានស្ងប់ នឹងននោះ គេអាចរំដោះខ្លួនចេញផុតពីតណ្ហាបាន ។

ស្ថានការណ៍វិវត្តទៅមុខជាលំដាប់ នៅឆ្នាំ ១៩៧៤ នាង ឧប្បលប្រសូត្របានកូនប្រុសមួយឈ្មោះ “ វង្ស ខេមរា ” ។ នៅឆ្នាំ ១៩៧៥ នាខែ មេសា ចាប់តាំងពីថ្ងៃទី ១៧ ទៅ ប្រទេសកម្ពុជាបានប្ដូររបបពីសាធារណរដ្ឋខ្មែរ ទៅជារបបកម្ពុជាប្រជាធិបតេយ្យ ។


www.elibraryofcambodia.org

រដ្ឋអំណាចថ្មី ក៏បានរុះរើរដ្ឋអំណាចចាស់ ធ្វើឱ្យប្រជាជនជក់ក្នុងអារម្មណ៍នូវចម្ងល់ពុំចេះចប់ថា " ហេតុអ្វីទៅបានជាគេដេញឱ្យយើងចុះចេញពីផ្ទះសម្បែង ? " ។

នាងឧប្បល និងស្វាមី ព្រមទាំងអ្នកបម្រើមួយចំនួន បានចាកចេញពីផ្ទះ តាមបញ្ជារបស់អង្គការដែលថា ឱ្យចេញពីភ្នំពេញតែមួយរយៈប៉ុណ្ណោះ ។ គ្រួសារនាងបានយករថយន្តតូចមួយគ្រឿងផ្ទុកទៅដោយអង្ករ និងសម្ភារៈបន្តិចបន្តួចទៅជាមួយដែរ ។ លុះធ្វើដំណើរបានតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ស្បៀងអាហារក៏ត្រូវអស់ ។ អ្នកបម្រើមើលមុខគ្នាឡឹងឡង់ រង់ចាំការសម្រេចពីចៅហ្វាយស្រី ។

យល់សភាពការណ៍កាន់តែតឹងតែងឡើងៗ នាងឧប្បល ក៏និយាយទៅកាន់អ្នកបម្រើទាំងក្ដីបារម្ភ ÷

- អ្នកទាំងអស់គ្នា បើមានផ្ទះសម្បែងនៅស្រុកណា អង្គការអនុញ្ញាតឱ្យទៅរកស្រុកភូមិវិញ... ពីព្រោះគេបានរំដោះហើយ !

ខេមរិន្ទ និងនាង ឧប្បល កើតក្ដីកង្វល់យ៉ាងខ្លាំង គេទាំងពីរមិនអាចយល់ពីសភាពការណ៍ខាងមុខទៅជាយ៉ាងណាៗនោះឡើយ ។ មីងយឿន ដែលជាមេដោះនាងឧប្បល និយាយទាំងទឹកភ្នែករលីងរលោងដោយក្ដីអស់សង្ឃឹម រកកោះត្រើយមិនឃើញ ÷

- នាងកើតមកមិនធ្លាប់លំបាកសោះ ហើយបើដល់ពេលលំបាកដូច្នេះ ! ខ្ញុំចាកចោលនាងទៀតនោះ ព្រះអើយ !... មីងមិនអាចធ្វើដូច្នេះកើតទេ !

មីងយឿន និយាយបានតែត្រឹមនេះ ហាក់ដូចជាតាំងនិយាយលែងចេញដោយសារការធានាអះអាងរបស់គាត់គ្មានអ្វីជាសំអាងឡើយ... បើទោះបីជាមានលុយហើយក៏គេមិនចាយដែរ ។

អ្នកដាំស្លឈ្មោះ រស់ និយាយប្រាប់ទៅចៅហ្វាយស្រី ចៅហ្វាយប្រុស ÷

- លោកប្រុស និងនាងកុំបារម្ភពីពួកយើងអី ! កាលណាយើងចង់ឃ្លាតពីនាងយើងនឹងជម្រាបនាងហើយ ប៉ុន្តែពេលនេះយើងចង់ទៅតាមនាងឱ្យដល់កំពង់ចាមសិន


www.elibraryofcambodia.org

សឹមពួកយើងខ្ញុំបន្តទៀត ។ ចំណែកឯឡាននេះ មិនអាចយកទៅតាមខ្លួនបានរហូតទេ ពីព្រោះបន្តិចទៀតនឹងត្រូវអស់សាំងហើយ ។ពួកយើងនឹងជួយរកពុនឥវ៉ាន់ ណាមួយនាងមានកូនខ្ចីពនៅនឹងដៃទៀត... ពួកយើងនៅតែនឹកគុណលោកស្រី លោកប្រុសដែលលោកមានមេត្តាជានិច្ចដល់ពួកយើង... លោក និងនាងកុំគិតច្រើនពេក... រឿងនេះមិនមែនមានតែយើងឯណា ។

ឧប្បល ពុំមានយោបល់អ្វីបន្តទៀត ក៏សុខចិត្តនៅស្ងៀម ។ ទៅដល់ព្រៃកក្កាម ស្រឡាងក៏បានដឹកគ្រួសារនាង និងអ្នកជម្លៀសឆ្លងទន្លេទៅត្រើយខាងកើត ។ គ្រួសារនាងឧប្បល និងអ្នកបម្រើ បន្តដំណើរមកដល់ស្គន់ អង្គការបង្វែរឱ្យអ្នកជម្លៀសទាំងអស់ទៅតាមផ្លូវកំពង់ធំវិញ ដោយមានឡានកងទ័ពដឹករហូតដល់ទៅខេត្តព្រះវិហារ ។ ឯគ្រួសារនាងឧប្បល គេយកទៅដាក់នៅស្រុករវៀង ។ នាងឧប្បល ត្រូវមិនបានជួបមាតាបិតាឡើយ ។

ចូលដល់ខែ មិថុនា ឆ្នាំ ១៩៧៥ អង្គការរៀបចំបញ្ចូលប្រជាជនថ្មីទៅក្នុងកង ហើយអ្នកបម្រើទាំងអស់ដែលទៅតាមឧប្បល ។បានឆ្លើយរាយការណ៍ថា ជាសាច់ញាតិ មិនហ៊ានថាជាអ្នកបម្រើទេ ។ ទាំងចៅហ្វាយ ទាំងអ្នកបម្រើ ពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែអាណិតស្រឡាញ់គ្នាខ្លាំងឡើង ។ នាងលួចដូរអ្វីបាន នាងតែងតែចែករំលែកទុកឱ្យអ្នកទាំងអស់គ្នាបរិភោគដែរ ។ លក្ខណៈនេះហើយដែលជាកត្តាធ្វើឱ្យអ្នកនៅជុំវិញខ្លួនឧប្បលរឹងរឹតតែមើលឃើញគុណសម្បត្តិរបស់ឧប្បលកាន់តែខ្ពស់ ។ ចំណែកឯអ្នកដទៃទៀត ពេលទៅធ្វើពលកម្ម រមែងតែងតែរកបន្លែបង្កាយកមកផ្ញើរផ្សំធ្វើជាម្ហូប គ្រាន់ជាជំនួយបង្អន់នូវការស្រេកឃ្លាន ហើយចែករំលែកឱ្យគ្នាទៅវិញទៅមកជាហូរហែ ។

ស្រុករវៀងឋិតនៅទិសឦសានខេត្តកំពង់ធំ បើគេធ្វើដំណើរមកដល់ខេត្តកំពង់ធំហើយ ។បន្តដំណើរតាមផ្លូវមួយតម្រង់ទៅទិសខាងជើង បានចម្ងាយប៉ែតសិបគីឡូម៉ែត្រ គេនឹងបានមកដល់ស្រុករវៀង ប៉ុន្តែគ្រួសារខេមរិន្ទ គេបញ្ជូនឱ្យទៅនៅភូមិបោះពៃ ដែល


www.elibraryofcambodia.org

ឋិតនៅក្នុងឃុំ រវៀងខាងត្បូង ។ អ្នកស្រុកក្នុងសម័យប៉ុល ពត ដែលគេហៅថាអ្នកមូលដ្ឋាន បាននិយាយរៀបរាប់ពីប្រវត្តិភូមិបោះពៃឱ្យខេមរិន្ទស្ដាប់ដូចតទៅ ÷

- កាលពីដើមឡើយ មានស្ត្រីម្នាក់បបួលកូនទៅជីកទំពាំង នៅក្បែរមាត់ត្រពាំងមួយ ។ កំពុងតែជីក ស្រាប់តែឮសូរសំឡេងអ្វីចម្លែក ស្ត្រីនោះក៏ងាកទៅរកប្រភពសំឡេងនោះ ស្រាប់តែគាត់ឃើញទូកមួយផ្ទុកទៅដោយ កែវកង ពិទូរ្យសូរ្យកាន្ត ផុសឡើង ស្ត្រីនោះឃើញដូច្នេះក៏ស្រែកហៅកូនឱ្យបោះកញ្ជើ ។ ភាពឆោឡោរបស់ស្ត្រីនោះ ធ្វើឱ្យទូកដែលផ្ទុកទៅដោយទ្រព្យសម្បត្តិស្ដុកស្ដម្ភអស្ចារ្យ ក៏លិចទៅក្នុងត្រពាំងនោះវិញទៅហើយ ទីនោះក៏ជាប់ឈ្មោះថា បោះកញ្ជើ រួចតៗមកក្លាយជាបោះពៃ ឯអ្នកខ្លះទៀតហៅថា បុសពៃៗ រហូតមកដល់សព្វថ្ងៃនេះ ។

ខេមរិន្ទស្ដាប់ហើយ ក៏សួរទៅអ្នកមូលដ្ឋានដែលខេមរិន្ទរាប់អានយ៉ាងជិតស្និទ្ធ ÷

- បង ! ឃុំរុងរឿង ហើយនិងឃុំ របៀប ជាឈ្មោះតាំងពីយូរយាណាស់មកហើយ មែនទេ?

ពូលុយគ្រវីក្បាល រួចបន្ថយសំឡេង ហាក់ខ្លាចឮទៅដល់ត្រចៀកអ្នកដទៃ ÷

- ប្អូនដឹងទេថា អ្នកស្រុកនេះមិនសប្បាយចិត្តទេ នឹងអង្គការផ្លាស់ឈ្មោះ !... កាលពីមុន មិនមែនឈ្មោះរុងរឿងអីចឹងទេ គឺឈ្មោះឃុំស្រែធំ ចំណែកឃុំរបៀប ពីមុនឈ្មោះឃុំបាក់ក្ដោង ហើយភូមិខ្ទាំង គឺមកពីពាក្យ ករវាំង យូរៗក្រោយមកក៏ក្លាយជាពាក្យខ្ទាំងនេះឯង ។

ស្ងាត់ពាក្យអ្នកមូលដ្ឋានឈ្មោះលុយ ខេមរិន្ទក៏និយាយខ្សឹបៗវិញ ÷

- អ្នកស្រុករវៀង ឬក៏និយាយថាពួកអ្នកខេត្តព្រះវិហារនេះ មានសន្ដានចិត្តល្អណាស់ ដូចបងលុយជាដើម តែងតែជួយផ្ដល់សាច់សត្វព្រៃដែលបងបរបាញ់បាន ខ្ញុំនិងគ្រួសារ សូមថ្លែងអំណរគុណបងណាស់ !

ពូលុយនិយាយរដឹនរបៀបអ្នកស្រុករវៀង ឆ្លើយមកកាន់ខេមរិន្ទ ÷


www.elibraryofcambodia.org

- មិនអីទេ ...

ដោយសារសន្តានចិត្តអ្នកស្រុកភាគច្រើនជាមនុស្សល្អ ដូច្នេះហើយបានជាគ្រួសារខេមរិន្ទមានភ័ព្វសំណាងបានរស់ឆ្លងរបបប៉ុល ពតបាន ។

កង់ប្រវត្តិសាស្ត្របានវិលទៅមុខជាលំដាប់ របបចាស់បានត្រូវផ្លាស់ប្តូរដោយរបបថ្មីវិញ ។ របបកម្ពុជាប្រជាធិបតេយ្យបានត្រូវរលត់រលាយអស់ទៅនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ ជំនួសមកវិញនូវរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គ្រួសារខេមរិន្ទ ពុំបានវិលមកភ្នំពេញទេ ដោយសារខេមរិន្ទត្រូវបានគេតែងតាំងឱ្យធ្វើជាប្រធានភូមិបោះពៃចាប់ពីថ្ងៃនោះមក ។ នៅឆ្នាំ ១៩៨០ នាងឧប្បល ក៏ប្រសូត្របានបុត្រីមួយ ។ នាងបានដាក់ឈ្មោះថា កែវ វិរិន ដើម្បីរំឭកពីអនុស្សាវរីយ៍កាលពីយុវវ័យ នៅពេលដែលនាងនិយាយគ្នាជាមួយស្វាមី ។

ឆ្នាំ ១៩៨៤ ខេមរិន្ទ លាភរិយាចុះទៅធ្វើសកម្មភាពយុទ្ធនាការ " ក៥ " ជាមួយប្រជាជនមួយចំនួន ។ ពេលត្រឡប់មកវិញ ខេមរិន្ទបានផ្ទុកជំងឺគ្រុនសន្និបាតមកជាមួយផង ។ នាងឧប្បល បានយកចិត្តទុកដាក់ព្យាបាលជំងឺ ខេមរិន្ទ អស់រយៈពេលជាច្រើនខែ-ឆ្នាំ ធ្វើឱ្យទ្រព្យសម្បត្តិដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវអស់រលីង ។ ទីបំផុតជីវិតខេមរិន្ទ ក៏នាង ឧប្បល ពុំអាចស្រោចស្រង់ឱ្យមានជីវិតបាន ស្វាមីក៏ស្លាប់ចោលទៅទាំងនៅក្មេងវ័យ ឯទ្រព្យសម្បត្តិក៏គ្មានសេសសល់អ្វីឡើយ ។ ខេមរាជាកូនឃើញម្តាយធ្លាក់ខ្លួនក្រ ព្រមទាំងជំពាក់គេរីណ្ណកទៀត អ្នកមិនដឹងជាគិតយ៉ាងណា ក៏ចាកចេញពីម្តាយដើម្បីស្វែងរកទ្រព្យមកដោះបំណុល ។ គោលបំណងរបស់ ខេមរា ចង់ឈានទៅប្រទេសទី បី ប៉ុន្តែអ្នកទៅពុំរួចឡើយ បានត្រឹមនៅវិលវល់តាមទល់ដែនប៉ុណ្ណោះ ។

* * * * *


www.elibraryofcambodia.org

# ៥

# ទីប្បជិសារ

ខេមរា រលំគ្រេងទាំងជំហរ លើកម្រាលព្រិចពណិខ្សៀវខ្ចីនៃរជូវប្រាំងទាំងកាន់កាំភ្លើអាកា *(AK)* នៅនឹងដៃ ។ នៅលើខ្លួនគេមានស្ពាយគ្រាប់កាំភ្លើងមួយខ្សែពាក់ឆៀង និងមានគ្រាប់បែកពីរគ្រាប់ទៀតសៀតនៅនឹងចង្កេះ ។ ខ្លួនគេឋិតនៅក្រោមស្នូរកាំភ្លើងដៃ និងកាំភ្លើងធំ ផ្ទុះលាយឡំគ្នាក្នុងសមរភូមិប្រយុទ្ធប្ដូរស្លាប់ប្ដូររស់នៅតំបន់អន្លង់ វែងក្បែរព្រំដែនខ្មែរ សៀម ក្នុងខេត្តឧត្ដរមានជ័យ ។ យុទ្ធជនទាំងសងខាងដួលត្នោលៗ លើ*សមរភូមិ ។ នេះគឺជាការប្រយុទ្ធរវាងកងទ័ពជាតិ និងកងទ័ពរំដោះជាតិ ។ ទ័ពទាំង*សងខាងដណ្ដើមឈ្មោះ " ស្នេហាជាតិ " ដូចគ្នា មានឈាមដូចគ្នា និងមានជាតិសាសន៍តែមួយគឺ " ខ្មែរ " ដូចគ្នា ។

ខេមរា ធ្លាយសំឡេង " អួយ ! " ដោយស្វ័យប្រវត្តិ រួចគេក៏បញ្ចេញនូវពាក្យពីរបីម៉ាត់បន្តទៀត ដើម្បីបញ្ជាក់បន្ថែមនូវការឈឺចុកចាប់ហួសនិស្ស័យនឹងប្រមាណ ÷

- អួយ !... ម៉ែអើយ !... ជួយកូនផង !!!...

អ្នកកំលោះឧទាននូវពាក្យពីរ-បីម៉ាត់ខាងលើនេះ ដោយសារតែគេកើតចេញពីអ្នកមេ ហើយត្រូវអ្នកមេចិញ្ចឹមបីបាច់ថែរក្សា ថ្នាក់ថ្នម និងផ្ដល់នូវភាពកក់ក្ដៅតាំងពីក្មេងវ័យម្ល៉េះ ដូច្នេះហើយបានជាខេមរាស្រែកដង្ហោយហៅមុនគេទាំងអស់ រកអ្នកមេមានគុណយ៉ាងនេះ ។

- កូនត្រូវរបួសហើយ !

នៅពេលដែលយុវយុទ្ធជនយើងដកដៃពីមុខរបួស លោហិតក្រហមច្រាលហូរ



www.elibraryofcambodia.org

ចេញពីមុខរបួសខ្លោល១ ធ្វើឱ្យខ្លួនអ្នកកំលោះសើមទទឹកជោក ។ នាយខំគ្រងរអូសខ្លួនទាំងក្តីវេទនាឥតឧបមាបានចម្ងាយប្រហែលជា បី បួនម៉ែត្រទៀត ក៏ទុព្វលភាព ។ នាយដឹងខ្លួនថាពុំអាចបន្តទៀតបានឡើយ ហើយហាក់ដឹងថាអ្វី១សព្វបែបយ៉ាងត្រូវបានបញ្ចប់នាពេលដ៏ខ្លីបន្តិចទៀតខាងមុខនេះ ។ អ្នកខ្សឹកខ្សួល អួលអាក់ នឹងការឈឺចុកចាប់ពើតផុរាពីមុខរបួសផង និងឈឺចុកចាប់ខាងផ្លូវចិត្តផង ។ ខេមរា មានការសោកស្តាយយ៉ាងខ្លាំង ធ្វើឱ្យវិប្បដិសារី មកកម្រើករំពើក ញាំញីពេញអារម្មណ៍របស់គេ ។ រូបគេពុំទទួលបាននូវក្តីស្ងប់ឡើយ នៅនាទីចុងបញ្ចប់នេះ ។ ទឹកភ្នែករបស់ ខេមរា ហូរមកដោយឯកឯងកាន់តែខ្លាំងឡើង១ ជំនួសពាក្យថាស្តាយណាស់ ។

បន្ទាប់មកសតិសម្បជញ្ញៈរបស់គេយល់ព្រមសារភាពថា : ស្តាយណាស់ព្រះអើយ ខ្លួនខ្ញុំខុសហើយ១មិនគួរណាឡើយមកប្រព្រឹត្តអំពើគ្មានសីលធមិសោះ នាំឱ្យមានវិប្បដិសារីយ៉ាងនេះ ! ។

កាលពីមុនមិនទាន់ត្រូវរបួស គេប្រមើលមើលឃើញខ្លួនគេប្រៀបបីដូចជាអធិរាជមួយអង្គដ៏មានមហិទ្ធិឫទ្ធិអស្ចារ្យ ។ ពេលគេដើរទៅណាមកណា អ្នកផងតែងតែគោរពកោតខ្លាច ក្រែងរអា ។ អ្នកសួរខ្លួនឯងថា : តើមូលហេតុអ្វីបានជាមានគេខ្លាចរូបអ្នក ? ឬដោយសារតែគេឃើញឯកសណ្ឋានជាកងទ័ព បំពាក់ដោយគ្រឿងសាស្ត្រាវុធ ឬ ក៏ចរិតអ្នកកាចឃោរឃៅដូចពួកចោរព្រៃ កាប់សម្លាប់ឥតញញើតដៃឥតវិចារណញ្ញាណ ឬ ? ទើបបណ្តាលឱ្យគេខ្លាចរូបអ្នក ។ លុះដល់ពេលអ្នកត្រូវគ្រាប់អស់លក្ខណ៍ដូចពេលនេះ ទើបអ្នកមើលឃើញយ៉ាងច្បាស់ថា : សេចក្តីស្លាប់ គឺពិតជាកំណប់ទ្រព្យរបស់មនុស្សគ្រប់រូប ជាបំណុលដែលមនុស្សលោកគ្រប់គ្នាចាំបាច់ត្រូវតែសងដល់ផែនដី ដោយអាក់ខានពុំបាន ដែលមានសាច់ ឈាម និងឆ្អឹង ។ ប៉ុន្តែគ្រាន់តែមនុស្សម្នាក់១សម្រេចចិត្តថា តើនៅពេលគេនៅរស់ គេគ្រប់គ្នានោះត្រូវមានកតព្វកិច្ចយ៉ាងណាខ្លះ ដើម្បីមុនពេលស្លាប់ទៅឱ្យបានសេចក្តីស្ងប់ កុំឱ្យមានវិប្បដិសារីទៅថ្ងៃមុខ ។


www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ចៅ យ៉ាតណៃ, ខ្ចៅ សុផល, ខ្ចៅ វិសាល, ខ្ចៅ រ៉ាមុន, ខ្ចៅ ភារាជា, ខ្ចៅ ចំរើន និង ខ្ចៅ ភារី
បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ អ៊ិត ចន្ទស៊ីណា
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគាដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគាទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ករុណាខ្មែរ
ធ្វើទាន ដោះទុក្ខ កសាង

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

www.elibraryofcambodia.org